# ផ្លូវភេទ ការរំលោភបំពាន និង កុមារភាព

ការសិក្សាស្រាវជ្រាវអំពីចំណេះដឹង ឥរិយាបទ និងទង្វើផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការបំពានផ្លូវភេទកុមារ ក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ នៅប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ប្រទេសថៃ និង ប្រទេសវៀតណាម



Australian Aid

World Vision

# ភេទ ការរំលោភបំពានផ្លូវភេទ និងកុមារភាព

ISBN: 978-0-9925215-6-1
រក្សាសិទ្ធិ © ឆ្នាំ ២០១៣ ដោយអង្គការទស្សនៈពិភពលោក

*ផ្នែកណាមួយនៃឯកសារនេះអាចត្រូវបានផលិតឡើងវិញដោយសេរីតែត្រូវបញ្ជាក់ប្រភពឯកសារត្រឹមត្រូវ។*

www.childsafetourism.org
childsafetourism@wvi.org

របាយការណ៍នេះផ្អែកតាមពង្រាងរបាយការណ៍សំយោគរបស់លោក John Vijghen និងរបាយការណ៍ជាតិរបស់លោក Ok Amry បណ្ឌិត Ngo Thi Ngan Binh បណ្ឌិត Aree Prohmmo និងអ្នកស្រី Rananan Boonyopakorn។ របាយការណ៍នេះ ត្រូវបានរៀបរៀងដោយបណ្ឌិត Sophorntavy Vorng និងកែសម្រួលដោយអ្នកស្រី Aarti Kapoor និង Afrooz Kaviani Johnson គម្រោងផ្អែកបង្កា របស់អង្គការ World Vision។

រចនាដោយ ក្រុមហ៊ុន រចនាឌីហ្សាញ

រូបថត ៖ អង្គការ World Vision/Lanie Carillo, Nila Douanesouvanh, Jerry Galea, Khaing Min Htoo, Sopheak Kong, Vanhlee Lattana, Xuan Thiem Le, Seyha Lychheang, Jay Mijares, Athit Rerawongmetha, Thongxay Phavixay, Vichheka Sok, Khamphot Somphanthabansouk, Phouvangmano Vongthounkham, Jon Warren, និង Albert Yu។

រូបភាពកុមារដែលប្រើប្រាស់នៅក្នុងឯកសារអប់រំនេះ គឺសម្រាប់ការបង្ហាញប៉ុណ្ណោះ ហើយសម្រាប់ចំណេះដឹងស្តីពីគម្រោងកុមារភាពទាំងនេះ មិនមែនជារូបភាពពិតប្រាកដរបស់ជនរងគ្រោះ ដោយសារការរំលោភបំពាននោះឡើយ។ អង្គការ World Vision បានអនុវត្តតាមស្តង់ដាការពារកុមារក្នុងការថតរូបកុមារទាំងនេះ។

គម្រោងផ្អែកបង្កា គឺជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី។ រាល់ទស្សនៈដែលលើកមកបង្ហាញក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីឡើយ។

# ផ្លូវភេទ ការរំលោភបំពាន និង កុមារភាព

ការសិក្សាស្រាវជ្រាវអំពីចំណេះដឹង ឥរិយាបទ និងទង្វើផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការបំពានផ្លូវភេទកុមារ ក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ នៅប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ប្រទេសថៃ និង ប្រទេសវៀតណាម










# តារាងមាតិកា




អក្សរកាត់ និងពាក្យបំព្រួញ .......... 2

សន្ទានុក្រម និង និយមន័យនៃពាក្យ .......... 4

ខ្លឹមសារសង្ខេប .......... 6

លក្ខណៈទូទៅ .......... 6

សាវតា .......... 7

កម្មវត្ថុស្រាវជ្រាវ .......... 7

វិធីសាស្ត្រ .......... 7

ការរកឃើញសំខាន់ៗ .......... 9

កាយល់ដឹងអំពីការំពានផ្លូវភេទកុមារ .......... 9

ឥរិយាបទ និងទង្វើផ្សេងៗ .......... 9

ឧបសគ្គ និងឱកាសទទួលបាន អន្តរាគមន៍ .......... 11

អនុសាសន៍ផ្សេងៗ .......... 12


## ជំពូកទី១


សេចក្ដីផ្ដើម .......... 16

សាវតា .......... 16

គម្រោងកុមារភាព .......... 16

ការបំពានផ្លូវភេទកុមារនៅក្នុងការធ្វើដំណើរ និងវិស័យទេសចរណ៍ .......... 17

ការប្រែប្រួលនៅក្នុងមហាអនុតំបន់មេគង្គ (GMS) 18

វិធីសាស្ត្រ .......... 22

បុព្វហេតុនៃការស្រាវជ្រាវ .......... 22

កម្មវត្ថុស្រាវជ្រាវ .......... 22

អ្នកឆ្លើយតប .......... 23

ការពិចារណាលើវិជ្ជាជីវៈ .......... 23

ការកំហិត .......... 24

ទីកន្លែងស្រាវជ្រាវ .......... 26

ប្រទេសកម្ពុជា .......... 27

ក្រុងសៀមរាប និង ឃុំពួក .......... 27

ខេត្តមណ្ឌលគិរី និងទីរួមស្រុកសែនមនោរម្យ .......... 28

សាធារណរដ្ឋប្រជាមានិតឡាវ .......... 28

ក្រុងវៀងចាន់ .......... 29

ហ្លួងប្រាបាង .......... 29

ប្រទេសថៃ .......... 30

ក្រុងប៉ាត់តាយ៉ា .......... 30

ក្រុងឈាងម៉ៃ .......... 31

ប្រទេសវៀតណាម .......... 31

ក្រុងហូជីមិញ ៖ ស្រុកទី៤ និងទី៨ .......... 32

រមណីយដ្ឋានដូសុន និង ស្រុកធុយង៉ៀន .......... 32

# ជំពូកទី២


ការយល់ដឹងអំពីការបំពានផ្លូវភេទកុមារ .. 34

**ទស្សនាទានស្តីពីសិទ្ធិកុមារ និងការបំពានផ្លូវភេទ 34**

លក្ខណ:នៃការយល់ឃើញរបស់កុមារ ទៅលើការបំពានផ្លូវភេទកុមារ ..................... 34

លក្ខណ:នៃការយល់ឃើញរបស់មនុស្សពេញវ័យ ទៅលើការបំពានផ្លូវភេទកុមារ ..................... 36

**ការអប់រំ និងព័ត៌មានស្តីពីបញ្ហាផ្លូវភេទ ........... 37**

សាលារៀន ..................................... 37

ឪពុកម្តាយ ..................................... 37

បទពិសោធន៍/ការសង្កេត ......................... 39

ប្រព័ន្ធផ្សព្វផ្សាយ បច្ចេកវិទ្យាឌីជីថល និងអ៊ីនធឺណិត ..................................... 39

យុទ្ធនាការសាធារណ:............................ 40

**ចំណេះដឹងអំពីច្បាប់ និង សិទ្ធិ ................. 40**

កុមារភាព និង សិទ្ធិ.............................. 40

អាយុគ្រប់ការស្របច្បាប់ .......................... 41


# ជំពូកទី៣


ឥរិយាបទ និងទង្វើនានា .................. 44

**គុណតម្លៃ និង ទំនៀមទម្លាប់ .................... 44**

ព្រហ្មចារីភាព និងអាកប្បកិរិយាផ្លូវភេទ............ 44

ការលក់ដូរផ្លូវភេទ និងការដោះដូរសម្ភារ .......... 46

ទំនាក់ទំនងផ្លូវភេទជាមួយភេទដូចគ្នា ............ 49

ទំនាក់ទំនងនៃអំណាច ៖ គ្រួសារ ................. 50

ការភ័យខ្លាចបាត់បង់កិត្តិយស ..................... 57

ឥទ្ធិពលពីមនុស្សវ័យស្របាលគ្នា ................. 52

ប្រព័ន្ធផ្សព្វផ្សាយ បច្ចេកវិទ្យាឌីជីថល ............. 52

**ការឆ្លើយតបចំពោះការរំលោភបំពាន ............ 54**

គ្រួសារ ........................................... 54

អ្នកកាន់ភារកិច្ច ................................... 55


# ជំពូកទី៤


ភាពងាយរងគ្រោះ និង ឱកាសនានា..... 58

គ្រួសារ និង ស្ថានភាពនៅក្នុងផ្ទះ ................. 58

ការធ្វើដំណើរ និង ទេសចរណ៍ ................... 59

ការធ្វើចំណាកស្រុក ............................. 53

បរិស្ថានរស់នៅ ................................. 62

ពិការភាព ....................................... 65

សេចក្តីទុកចិត្ត និង អំពើពុករលួយ ............... 65


# ជំពូកទី៥


សេចក្តីសន្និដ្ឋាន ............................. 70

ការយល់ដឹងអំពីការបំពានផ្លូវភេទកុមារ ........... 70

ឥរិយាបទ និងទង្វើនានា .......................... 71

ឧបសគ្គ និងឱកាសទទួលបានអន្តរាគមន៍ ........ 73

ឯកសារយោងផ្សេងៗ....................... 76

ឧបសម្ព័ន្ធ ១ ៖
ឧបករណ៍ស្រាវជ្រាវ .......................... 78

គោលការណ៍ណែនាំសម្រាប់ការពិភាក្សារបស់ក្រុមមនុស្សវាយតម្លៃ ............................. 78

គោលការណ៍ធ្វើបទសម្រាសន៍សម្រាប់កុមារ ...... 79

គោលការណ៍ធ្វើបទសម្រាសន៍សម្រាប់ឪពុកម្តាយ ឬអាណាព្យាបាល ............................. 81

គោលការណ៍ធ្វើបទសម្រាសន៍សម្រាប់ អ្នកកាន់ភារកិច្ច ................................ 83

គោលការណ៍ធ្វើបទសម្រាសន៍សម្រាប់ អ្នករកស៊ីផ្លូវភេទ ................................ 84

ឧបសម្ព័ន្ធ ២ ៖
ការវិភាគស្ថិតិអ្នកចូលរួម ................. 86

ប្រទេសកម្ពុជា ................................ 86

ប្រទេសថៃ .................................... 87

សាធារណរដ្ឋប្រជាមានិតឡាវ ................... 88

ប្រទេសវៀតណាម ............................. 89






# អក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| AIDS | ជំងឺអេដស៍: ប្រជុំចង្កោមរោគសញ្ញាដោយសារប្រពន្ធ័ភាពស៊ាំនៃរាងកាយចុះខ្សោយ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BCC | ការទំនាក់ទំនងដើម្បីផ្លាស់ប្តូរអាកប្បកិរិយា |
| CBO | អង្គការផ្អែកលើសហគមន៍ |
| CPN | បណ្តាញការពារកុមារ |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| CSO | អង្គការសង្គមស៊ីវិល |
| FGI/D | បទសម្ភាសន៍/ការពិភាក្សាជាមួយក្រុមមនុស្ស |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GMS | មហាតំបន់អនុទន្លេមេគង្គ |
| HIV | មេរោគអេដស៍ |
| IEC | ព័ត៌មាន ការអប់រំ និង ការទំនាក់ទំនង |
| II | ការសម្ភាសមនុស្សម្នាក់ៗ |
| IO | អង្គការអន្តរជាតិ |
| INTERPOL | ប៉ូលីសឧក្រិដ្ឋកម្មអន្តរជាតិ |
| MDG | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ |
| MOLISA | ក្រសួងការងារ ជនពិការ និង កិច្ចការសង្គម (ប្រទេសវៀតណាម) |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| STD/I | ជំងឺ/ការឆ្លងជំងឺដោយសារការរួមភេទ |
| UN | អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិកុមារនៃអង្គការសហប្រជាជាតិ |
| UNODC | ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម |
| UNWTO | អង្គការទេសចរណ៍ពិភពលោកនៃអង្គការសហប្រជាជាតិ |



# សន្ទានុក្រម និង និយមន័យនៃពាក្យ



**ការរំលោភបំពាន** » *សំដៅលើសកម្មភាពណាមួយ (ឬទោះមិនមែនជាសកម្មភាពណាមួយក៏ដោយ) ដែលមិនបានកើតឡើងដោយចៃដន្យ ហើយដែលបង្កការឈឺចាប់ ឬធ្វើឲ្យមនុស្សណាម្នាក់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ ។*

**មនុស្សជំទង់** » *វ័យជំទង់រាប់គិតពីពេលមនុស្សចាប់ផ្តើមគ្រប់ការ ហើយបញ្ចប់ទៅវិញនៅពេលអត្តសញ្ញាណ និងអាកប្បកិរិយារបស់មនុស្សម្នាក់នោះ ត្រូវគេទទួលស្គាល់ថាបានក្លាយជាមនុស្សពេញវ័យរួចហើយ ។ ជាទូទៅ អំឡុងពេលចម្រើនធំធាត់នេះ គឺនៅពេលកុមារមានអាយុចាប់ពី ១០ឆ្នាំ រហូតដល់១៩ឆ្នាំ ។*

**អាយុគ្រប់ការ** » *គឺជាវ័យមួយស្របច្បាប់ ដែលមនុស្សម្នាក់អាចនឹងយល់ព្រមប្រព្រឹត្តសកម្មភាពផ្លូវភេទជាមួយមនុស្សម្នាក់ទៀតដោយស្ម័គ្រចិត្ត។*

**កុមារ** » *សំដៅលើមនុស្សគ្រប់រូបដែលមានអាយុក្រោម១៨ឆ្នាំ ប៉ុន្តែលុះត្រាណាតែច្បាប់នៃប្រទេសនោះកំណត់ ថាជាកុមារគួរមានអាយុតិចជាងនេះ។*

**ការរំលោភបំពានលើកុមារ** » *សំដៅលើសកម្មភាពទាំងឡាយណា (ឬ មិនមែនជាសកម្មភាពណាមួយ) ដែលមិនមែនកើតឡើងដោយចៃដន្យ ហើយបង្កការឈឺចាប់ ឬធ្វើឲ្យមនុស្សណាម្នាក់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ ។ ការរំលោភបំពានលើកុមារចែកចេញជាបួនប្រភេទធំៗគឺ ការមិនអើពើ ការរំលោភបំពានផ្លូវកាយ ការរំលោភបំពាន ផ្លូវចិត្ត និងការរំលោភបំពានផ្លូវភេទ។*

**ពលកម្មកុមារ** » *សំដៅលើការងារទាំងឡាយណា ដែលកេងប្រវ័ញ្ចលើកុមារ ។ កុមារបានចូលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល នៅក្នុងការងារធ្ងន់ៗ ប្រថុយប្រថាន និង ប្រកបដោយគ្រោះថ្នាក់ ដែលការងារទាំងនោះ ទំនងជាបង្កឲ្យមានគ្រោះមហន្តរាយដល់ការអភិវឌ្ឍន៍ផ្នែករូបរាងកាយ ប្រាជ្ញា ស្មារតី សីលធម៌ និង សង្គមរបស់កុមារ ឬ ជាការតម្រូវឲ្យធ្វើការងារពេលកំពុងមានវ័យមួយពុំទាន់អាចធ្វើការបាន (វ័យ១៥ឆ្នាំ) ដែលលក្ខណៈបែបនេះ ធ្វើឲ្យកុមារបាត់បង់កុមារភាព ឱកាស និងពេលវេលាចាំបាច់សម្រាប់រៀនសូត្រ ការលំហែកាយ និងការកំសាន្តជាដើម (អង្គការពលកម្មអន្តរ ជាតិ) ។*

**ការរំលោភបំពានផ្លូវភេទកុមារ** » *កើតឡើងនៅពេលមនុស្សម្នាក់បានដាក់ឲ្យកុមារចូលពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទ តាមរយៈការប្រើប្រាស់អំណាចរបស់ខ្លួនទៅលើកុមារទាំងនោះ ឬការទាញប្រយោជន៍ពីសេចក្តីទុកចិត្តរបស់កុមារ ។ ការរំលោភបំពានផ្លូវភេទកុមារ បានលេចឡើងគ្រប់រូបភាពនៃអាកប្បកិរិយាផ្លូវភេទដែលគេមិនបានប្រាថ្នា ។ ទង្វើបែបនេះអាចពាក់ព័ន្ធនឹងការប៉ះពាល់ ឬការមិនប៉ះពាល់ទាល់តែសោះក៏បាន ។*

**ការកេងប្រវ័ញ្ចផ្លូវភេទកុមារ** » *គឺជាទូទៅអាចនិយាយបានថា ជាការរំលោភបំពានផ្លូវភេទលើកុមារដោយ ការដោះដូររបស់អ្វីមួយ ជាថ្នូរទៅនឹងសកម្មភាពផ្លូវភេទ ។ ទង្វើបែបនេះ អាចមិនមែនសុទ្ធតែធ្វើឡើងក្នុងគោលដៅរកប្រាក់ចំណេញឡើយ ព្រោះសម្ភារៈមួយចំនួនត្រូវផ្តល់ជូន រួមមានទីជម្រក អាហារ ថ្នាំសង្កូវ ។ល។ រូបភាពនៃការកេងប្រវ័ញ្ចបែបនេះ អាចកើតឡើងលើរាងកាយតែម្តង និងតាមរយៈបច្ចេកវិទ្យា ដូចជាអ៊ីនធឺណិត ឬទូរសព្ទជាដើម ។*

**ការរំលោភបំពានផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ការរំលោភបំពានផ្លូវភេទ** » *កុមារពីសំណាក់ភ្ញៀវទេសចរ អ្នកធ្វើដំណើរ ឬជនបរទេស ដែលប្រព្រឹត្ត ការរំលោភបំពានផ្លូវភេទ កុមារនៅក្នុងប្រទេសដែលខ្លួនកំពុងរស់នៅ ឬ ប្រទេសនានាដែលខ្លួនកំពុងធ្វើដំណើរ កំសាន្ត ។*

**ការជួញដូរកុមារ** » *ការជ្រើសរើសឲ្យធ្វើការ ការដឹកជញ្ជូន ការផ្តល់ជម្រកឃុំខ្លួន ឬ ការទទួលយកកុមារក្នុងគោលបំណងកេងប្រវ័ញ្ច ។*

**អ្នកមានកាតព្វកិច្ច** » *មនុស្សដែលមានមុខងារជាអ្នកកាន់អំណាច ដឹកនាំ និងមានឥទ្ធិពល ជាពិសេស ពាក់ព័ន្ធទៅនឹងបញ្ហារបស់កុមារ ។*

**ក្រុមជនជាតិភាគតិច** » *គឺជាមនុស្សមួយក្រុមនៅក្នុងសង្គម ដែលមានប្រពៃណីជាតិ ឬវប្បធម៌មួយរួមគ្នា (រីឯក្រុមជនជាតិភាគតិច មានន័យថា ជាមនុស្សមួយក្រុមតូច នៅក្នុងសហគមន៍មួយ ឬប្រទេសមួយ ដែលខុសពីប្រជាជនទូទៅ ផ្នែកជាតិសាសន៍ សាសនា ភាសា ឬនយោបាយ (វចនានុក្រម Oxford) ។*

**ការកេងប្រវ័ញ្ច** » *ការប្រើប្រាស់ស្ថានភាពណាមួយ ដើម្បីទាញយកប្រយោជន៍ដោយអយុត្តិធម៌សម្រាប់ខ្លួនឯង ។*

**ល្បិចលួងលោម** » *គឺជាដំណើរការបង្កើតទំនាក់ទំនងមួយដ៏គួរឲ្យទុកចិត្តជាមួយកុមារ និងអ្នកថែទាំកុមាររូបនោះ ក្នុងគោលបំណងរំលោភបំពាន ។ ជាដំបូង ជនល្មើសធ្វើការសង្កេត និងតម្រង់គោលដៅឆ្ពោះទៅរកកុមារ ហើយបន្ទាប់មកក៏បង្កើតទំនាក់ទំនងធ្វើឲ្យកុមារទុកចិត្ត ដោយការបង្ហាញនូវចំណាប់អារម្មណ៍របស់ខ្លួន យកចិត្តទុកដាក់ចំពោះគាត់ ឲ្យអំណោយដល់គាត់ និងធ្វើជាមិត្តរបស់គាត់។ នៅពេលជនល្មើសបង្កើតទំនាក់ទំនងនេះ ជនល្មើសក៏ចាប់បង្កើតរឿងសម្ងាត់ផ្សេងៗជាមួយកុមារ ដើម្បីធ្វើយ៉ាងណាកុំឲ្យកុមាររាយការណ៍ពីទង្វើរំលោភបំពាននេះប្រាប់អ្នកដទៃ។ រយៈពេលនៃការប្រព្រឹត្តអាចនឹងខុសគ្នា ប៉ុន្តែនៅទីបំផុត ជនល្មើសនឹងពន្លឿនទំនាក់ទំនងផ្លូវភេទនេះតែម្តង ។ ទង្វើទាំងនេះរួមមានការបង្ហាញរូបទាក់ទាញអារម្មណ៍ផ្លូវភេទ ដើម្បីឲ្យកុមារមានអារម្មណ៍រំជើបរំជួលខ្លាំងជាដើម។ ជនល្មើសចេះតែបន្តប៉ះពាល់ផ្លូវភេទ និងមានអាកប្បកិរិយាផ្សេងៗទៀតដែលជាការរំលោភបំពានផ្លូវភេទ។*



**មនុស្សវ័យស្រេបាលគ្នា** » *គឺសំដៅលើមនុស្សមួយក្រុម ដែលជាធម្មតាមានលក្ខណៈ ប្រហាក់ប្រហែលគ្នាទាំងអាយុ គ្រួសារ និងឋានៈក្នុងសង្គម ទៅនឹងបុគ្គលម្នាក់ទៀត ដែលមនុស្សមួយក្រុម នោះសេពគប់ជាមួយ ហើយដែលទំនងជាមានឥទ្ធិពលទៅលើជំនឿរបស់របស់បុគ្គលម្នាក់នោះផងដែរ។*

**កុមារតាមចិញ្ចើមថ្នល់ និងកុមារប្រកបការងារ** » *កុមារតាមចិញ្ចើមថ្នល់ គឺជាក្មេងម្នាក់ ដែល (ក) កំពុងរស់នៅតាមចិញ្ចើមថ្នល់ (អាចនៅជាមួយគ្រួសារ) (ខ) កំពុងរស់នៅតាមគេហដ្ឋានក្នុងតំបន់ក្រីក្រអាណាធិបតេយ្យ និង/ឬ (គ) ត្រូវបានអ្នកផ្ទះបោះបង់ចោល ឬបានរត់ចេញពីផ្ទះ[១]។ កុមាររកស៊ីតាមចិញ្ចើមថ្នល់ក៏ជា (ក) ក្មេងម្នាក់ ដែលចំណាយពេលច្រើនបំផុតរបស់ខ្លួននៅតាមចិញ្ចើមថ្នល់ ប៉ុន្តែដល់ពេលវេលា ក៏ត្រឡប់មកផ្ទះវិញជាប្រចាំ ឬ (ខ) កុមារនៅតាមចិញ្ចើមថ្នល់ ដែលពាក់ព័ន្ធសកម្មភាពសេដ្ឋកិច្ចមួយចំនួន (តែកុមារភាគច្រើនត្រឡប់ទៅផ្ទះវិញនៅពេលល្ងាច ហើយកុមារទាំងនេះអាចនឹងបានចូលសាលារៀន ហើយក៏សមាជិករបស់គ្រួសារមួយដែរ) (អង្គការ UNICEF) ។ កុមារប្រកបការងារ គឺជាកុមារម្នាក់ដែលមានសកម្មភាពរកប្រាក់ចំណូល ជាការងារពេញម៉ោង ឬក្រៅម៉ោង ឬធ្វើជាកូនជាង។*

[១] អង្គការ UNICEF ប្រទេសបង់ក្លាដែស ២០០៩ ៖ ការការពារកុមារ ដែលរស់នៅតាមចិញ្ចើមថ្នល់ ទំព័រទី១

**អ្នកធ្វើដំណើរបំពានផ្លូវភេទ** » *គឺជាភ្ញៀវទេសចរ អ្នកធ្វើដំណើរ ឬអ្នកមកតាំងទីលំនៅជាជនបរទេស ដែលប្រព្រឹត្តការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងប្រទេសមួយដែលខ្លួនកំពុងរស់នៅ ឬប្រទេសនានាដែលខ្លួនកំពុងធ្វើដំណើរកំសាន្ត ។*

**ងាយរងគ្រោះ** » *មនុស្សម្នាក់ ឬមនុស្សមួយក្រុម ត្រូវបានចាត់ទុកថា ងាយរងគ្រោះ ប្រសិនបើមនុស្ស ឬក្រុមនោះស្ថិតនៅក្នុងស្ថានភាពមួយដែលអាចនឹងទទួលរងនូវការវាយប្រហារ ឬបង្កគ្រោះថ្នាក់ ដែលអាចជាផ្លូវកាយ ឬស្មារតីអារម្មណ៍ ។*

**មនុស្សវ័យក្មេង ឬយុវជន** » *ពាក្យទាំងនេះ សម្គាល់លើអំឡុងពេលមួយ ដែលឆ្លងកាត់ពីកុមារភាព ទៅមនុស្សពេញវ័យ ហើយជាទូទៅ គឺសម្រាប់មនុស្សមានវ័យចាប់ពី១៥ឆ្នាំ ទៅ២៤ឆ្នាំ[២]។*

[២] ផ្អែកលើវិធីប្រើប្រាស់ពាក្យក្នុង ផ្នែកស្ថិតិ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា របស់លេខាធិការដ្ឋានអង្គការសហប្រជាជាតិ ដោយទទួលស្គាល់ថា អត្ថន័យនៃពាក្យ “យុវជន” នេះមានលក្ខណៈខុសគ្នា ទៅតាមបរិបទសេដ្ឋកិច្ច សង្គម និងវប្បធម៌ នៅក្នុងប្រទេសខុសៗគ្នា នៅក្នុងពិភពលោក ។

# ខ្លឹមសារសង្ខេប

## លក្ខណៈទូទៅ

របាយការណ៍សង្ខេបនេះ បង្ហាញពីលក្ខណៈទូទៅនៃការកឃើញនានា នៅក្នុងការសិក្សាស្រាវជ្រាវចំនួនបួនដាច់ដោយឡែកពីគ្នា ដែលគេបានធ្វើឡើង នៅក្នុងសហគមន៍ ងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាម ស្តីអំពីចំណេះដឹង ឥរិយាបទ និងទង្វើផ្សេងៗ ដែលទាក់ទងទៅនឹងការបំពានផ្លូវភេទកុមារ ក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ។ ការសិក្សាទាំងនេះ ត្រូវបានធ្វើឡើង ដើម្បីរួមចំណែកនៅក្នុងការរៀបចំ និងទម្រង់គំនិតនៃគម្រោងកុមារភាពផ្អែកបង្ការ ។ ការស្រាវជ្រាវនេះបង្កើតការយល់ឃើញជាទូទៅមួយ ទៅលើការយល់ដឹងភាពយោគយល់ និងអាកប្បកិរិយានៅក្នុងសហគមន៍នានាជុំវិញ បញ្ហារំលោភបំពានផ្លូវភេទកុមារ ។



**នៅក្នុងជំពូកដំបូងនេះ** មានផ្តល់ព័ត៌មានសំខាន់ៗស្តីពីគម្រោងកុមារភាពផ្អែកបង្ការ ការរំលោភបំពានផ្លូវភេទកុមារ ក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ការប្រែប្រួលដែលគេបានដឹងរួចមកហើយអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ នៅក្នុង មហាអនុតំបន់ទន្លេមេគង្គ ដែលគេបានគូរនៅលើទំព័រព័ត៌មានដែលមានស្រាប់ ។ ជំពូកនេះក៏បង្ហាញត្រួសៗ អំពីបុព្វហេតុ កម្មវត្ថុ វិធីសាស្រ្ត កត្តាក្រម សីលធម៌ និងការកំហិតទៅលើរបាយការណ៍ ។ រូបថតដែលគេបានថតភ្លាមៗដោយឥតមានការព្រៀងទុកមានដាក់បង្ហាញនៅតាមការ ដ្ឋានស្រាវជ្រាវនីមួយៗ ចំនួន៨កន្លែងដែលគេបានជ្រើសរើសទុកជាស្រេច ។

**នៅក្នុងជំពូកទីពីរ** មានពិពណ៌នាអំពីរបៀបយល់ដឹងរបស់កុមារ និងមនុស្សពេញវ័យ ទៅលើគំនិតនានាដែលទាក់ទងនឹងកុមារភាព សិទ្ធិកុមារ ចំណង់ផ្លូវភេទ ការរំលោភបំពាន និង ប្រធានបទនានាដែលពាក់ព័ន្ធ។ ជំពូកនេះក៏ពិភាក្សាអំពីចំណេះដឹងរបស់កុមារទៅលើបញ្ហាផ្លូវភេទ រាប់បញ្ចូលទាំងការអប់រំផ្លូវភេទ និង ទំនាក់ទំនងផ្សេងៗ ដែលកុមារទទួលបាន និងការជ្រួតជ្រាបអំពីការរំលោភបំពានផ្លូវភេទ។

**នៅក្នុងជំពូកទីបីនៃរបាយការណ៍នេះ** មានបង្ហាញថា តើការយល់ឃើញ និងយល់ដឹងរបស់ មនុស្សពេញវ័យ និងកុមារ ទៅលើការរំលោភបំពានលើកុមារ ជាពិសេស ការរំលោភបំពានផ្លូវភេទកុមារ មានសភាពប្រែប្រួលដូចម្តេច នៅពេលជួបប្រទះទង្វើ និងអាកប្បកិរិយា ជាក់ស្តែង។ ជំពូកនេះបង្ហាញទៀតថា តើអាកប្បកិរិយានេះមានទំនាក់ទំនងដូចម្តេចខ្លះជាមួយនឹងឥទ្ធិពលពីមជ្ឈដ្ឋានជុំវិញខ្លួន របស់កុមារ ហើយថា តើមនុស្សម្នាក់ៗ និងសង្គមទាំងមូល មានទស្សនៈ និងឆ្លើយតបដូចម្តេចខ្លះ ចំពោះទង្វើ និងរឿងហេតុរំលោភបំពានទាំងនេះ។

**ជំពូកទីបួន រំឭកអំពីគ្រោះថ្នាក់បន្ថែមទៀត** ចំពោះកុមារ ដែលទទួលរងដោយការបំពានផ្លូវភេទ រាប់បញ្ចូលទាំងរងគ្រោះដោយសារភ្ញៀវទេសចរ និង អ្នកធ្វើដំណើរនានា ដែលពាក់ព័ន្ធទៅនឹងស្ថានភាពមជ្ឈដ្ឋានជុំវិញនយោបាយ និងស្ថានភាពដ៏ច្រើនស្មុគស្មាញ។ ជំពូកនេះក៏ពិនិត្យមើលថា តើកាលៈទេសៈ និង លក្ខខណ្ឌនានាទាំងក្នុងទាំងក្រៅអ្វីខ្លះ ដែលបង្កើន ឬបន្ថយភាពងាយរងគ្រោះរបស់កុមារ ចំពោះការរំលោភបំពាននេះ ។ លើសពីនេះក៏មានបង្ហាញអំពីឧបសគ្គនានា ដែលបង្កការរាំងស្ទះដល់ដំណើរការអន្តរាគមន៍សមស្របនានា ហើយដែលរារាំងមិនឲ្យកុមារមានឱកាសទទួលបានព័ត៌មាន និងការគាំទ្រ ។

**ជំពូកទីប្រាំ និងជំពូកចុងក្រោយ** មានគោលដៅធ្វើការសន្និដ្ឋានរួមទៅលើការស្រាវជ្រាវនេះ ដើម្បីច្បិចយកអង្គប្រកបសំខាន់ៗនៅក្នុងការសិក្សានេះដូចជា ចំណេះដឹង ឥរិយាបទនិងទង្វើ និងភាពងាយរងគ្រោះ និងជម្រើសធ្វើអន្តរាគមន៍របស់កម្មវិធីនេះ។ ក្រៅពីនេះ ក៏មានបង្ហាញយុទ្ធសាស្រ្តផ្តាំផ្ញើ សម្រាប់យកទៅធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពផងដែរ។ នៅចុងបញ្ចប់នៃរបាយការណ៍នេះ មានបង្ហាញឯកសារយោង និងឧបសម្ព័ន្ធចំនួនពីរ។

# សារតា

គម្រោងកុមារភាព គឺជាគំនិតផ្តួចផ្តើមមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដែលបានចំណាយទឹកប្រាក់ចំនួន ៧,៥លានដុល្លារអូស្ត្រាលី ដើម្បីប្រយុទ្ធប្រឆាំងការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៍ ក្នុងមហាអនុតំបន់ទន្លេមេគង្គ ជាពិសេសនៅក្នុងប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ប្រទេសថៃ និង ប្រទេសវៀតណាម រួមគ្នា។ កម្មវិធីដែលមានរយៈពេលបីឆ្នាំកន្លះ (២០១១-២០១៤) បានបង្កើតឲ្យមានកិច្ចសហការគ្នាមួយ រវាងការិយាល័យអង្គការសហប្រជាជាតិ ទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) និងអង្គការទស្សនៈពិភពលោក ដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរមួយ គឺការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៍។ គម្រោងនេះមានពីរផ្នែកគឺ ផ្នែកបង្ការ និងការពារ។

នៅក្នុងផ្នែកការពារ អង្គការ UNODC បានសហការជាមួយទីភ្នាក់ងារអនុវត្តន៍ច្បាប់នានាដើម្បីការពារកុមារដោយត្រូវពង្រឹងការឆ្លើយតបនានាចំពោះការអនុវត្តច្បាប់។ នៅក្នុងផ្នែកបង្ការ អង្គការទស្សនៈពិភពលោក បានសហការជាមួយអាជ្ញាធរនានា វិស័យឯកជន និងសហគមន៍ផ្សេងៗដើម្បីការពារកុមារមិនឲ្យក្លាយជា ជនរងគ្រោះនៅក្នុងការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍។



# កម្មវត្ថុស្រាវជ្រាវ

យុទ្ធសាស្ត្រជាចម្បងរបស់គម្រោងកុមារភាពផ្នែកបង្ការ នៅក្នុងការការពារមិនឲ្យមានការរំលោភបំពានផ្លូវភេទលើកុមារកើតឡើង នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ គឺត្រូវលើកកម្ពស់ការផ្លាស់ប្តូរអាកប្បកិរិយាជាវិជ្ជមាន និងត្រូវបង្កើតបរិស្ថានមួយដែលអាចបង្កើនភាពរឹងមាំរបស់កុមារា និងកុមារី ដើម្បីរួចផុតពីការប៉ះទង្គិចជាមួយអ្នក កេងប្រវ័ញ្ចផ្លូវភេទ និងដើម្បីធ្វើយ៉ាងណាឲ្យឪពុកម្តាយនិងគ្រួសារ អ្នកកាន់ភារកិច្ច និងសមាជិកសហគមន៍ អាចការពារកុមារបាន។ យុទ្ធសាស្ត្រនេះត្រូវបានអនុវត្តតាមរយៈអន្តរាគមន៍ទំនាក់ទំនងនានា ដែលពាក់ព័ន្ធនឹងបរិបទវប្បធម៌ និងសង្គមរបស់សហគមន៍គោលដៅ។ ដើម្បីទំនាក់ទំនងសារនានាប្រកបដោយប្រសិទ្ធភាពតាមរយៈឧបករណ៍ និងអន្តរាគមន៍នានាដែលពាក់ព័ន្ធ។ កម្មវិធីនេះទាមទារឲ្យមានគម្រោងគំនិតរឹងមាំ រួមមានការយល់ឃើញជារួម ទៅលើទស្សនៈសំខាន់ៗ ឥរិយាបទ និងអាកប្បកិរិយា ដែលធ្វើឲ្យកុមារា និងកុមារី ងាយរងគ្រោះដោយការរំលោភបំពានផ្លូវភេទ។ កម្មវិធីនេះ ក៏តម្រូវឲ្យមានការយល់ដឹងឲ្យបានច្បាស់ថា តើកុមារងាយរងគ្រោះ គ្រួសារ និងសហគមន៍ទាំងមូល ទទួលបានការប្រើប្រាស់ និង រងឥទ្ធិពលពីប្រព័ន្ធផ្សព្វផ្សាយនៅក្នុងទម្រង់ខុសៗគ្នា។ បើគ្មានព័ត៌មានទាំងនេះទេ ឱកាសទទួលបានសារប្រកបដោយប្រសិទ្ធភាពតាមបណ្តាញផ្សព្វផ្សាយដែលពាក់ព័ន្ធ នឹងត្រូវពឹងផ្អែកលើការសន្មត់ផ្សេងៗ ដែលជាហេតុបង្កឲ្យមានគ្រោះថ្នាក់ គឺថាសារទាំងនេះអាចនឹងត្រូវបាត់បង់ ឬអាចនឹងមិនបានទៅដល់ក្រុមគោលដៅ។ ការយល់ដឹងនេះក៏មានលក្ខណៈចាំបាច់នៅក្នុងការរៀបចំឧបករណ៍ សម្រាប់ជួយអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពដែរ ដែលឧបករណ៍ទាំងនោះពាក់ព័ន្ធទៅនឹងសហគមន៍មូលដ្ឋាន ហើយត្រូវបញ្ចូលគ្នាជាលក្ខណៈវប្បធម៌ និងលក្ខណៈ ប្រព័ន្ធបានដោយងាយ និងប្រកបដោយនិរន្តរភាព។

# វិធីសាស្ត្រ

ការស្រាវជ្រាវនេះមានគោលដៅធ្វើឲ្យគម្រោងកុមារភាពផ្នែកបង្ការ បានជ្រាបអំពីចំណេះដឹង ឥរិយាបទ និងទង្វើរបស់សមាជិកនៅក្នុងសហគមន៍ (រាប់បញ្ចូលទាំងកុមារា និងកុមារី ញាតិសន្តានរបស់កុមារ និងអ្នកកាន់ភារកិច្ច) ពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទកុមារ ទាំងអ្នកធ្វើដំណើរ ទាំងភ្ញៀវទេសចរ។ ខាងក្រោមនេះគឺជាសំណួរដ៏ជាក់លាក់សម្រាប់ដឹកនាំការស្រាវជ្រាវ។ នេះគឺរាប់បញ្ចូលទាំងបរិបទធ្វើដំណើរ និងទេសចរណ៍ផង ៖

**១. តើចំណេះដឹង ឥរិយាបទ និងទង្វើនានានៅក្នុងសហគមន៍ មានទំនាក់ទំនងអ្វីខ្លះ ជាមួយនឹងការរំលោភបំពានលើកុមារ និងការការពារកុមារ?**

**២. តើមានទស្សនៈសំខាន់ៗ ឥរិយាបទ អាកប្បកិរិយា និងទង្វើនានាអ្វីខ្លះ ដែលបង្កឲ្យមានគ្រោះថ្នាក់ និង ភាពងាយរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទកុមារ?**

៣. តើមានឧបសគ្គ និងឱកាសសំខាន់ៗអ្វីខ្លះ នៅក្នុងការការពារពីការ រំលោភបំពានផ្លូវភេទកុមារ ?

៤. តើធនធានដែលមានស្រាប់យន្តការ និងបណ្តាញសំខាន់ៗ មានអ្វីខ្លះ ដើម្បីទំនាក់ទំនង ជូនដំណឹង ព្រមទាំងអប់រំកុមារ គ្រួសារ និងសហគមន៍ស្តីពីការរំលោភបំពានផ្លូវភេទកុមារ ?

ការស្រាវជ្រាវនៅសាធារណរដ្ឋប្រជាមានិតឡាវ ដែលគេបានធ្វើឡើងយឺតយ៉ាវជាងការស្រាវជ្រាវថ្នាក់ជាតិ ដទៃទៀតនោះ ក៏បានពិចារណាអំពីសំណួរបន្ថែមនេះដែរ៖

៥. តើប្រាក់ទិញទឹកចិត្ត រួមចំណែកអ្វីខ្លះនៅក្នុងការកេងប្រវ័ញ្ចលើកុមារ ? ហើយ តើមានឧបសគ្គ និងឱកាសអ្វីខ្លះ សម្រាប់ឲ្យផ្នែកបង្ការ ឆ្លើយតបទៅនឹងកត្តាបែបនេះ ?

ការសិក្សានេះបានប្រើប្រាស់វិធីស្រាវជ្រាវបែបគុណភាព ដូចជា បទសម្ភាសន៍ ការពិភាក្សាជាមួយក្រុមមនុស្សវាយតម្លៃ ការសង្កេត និងការពិនិត្យរឿងរ៉ាវឡើងវិញ ។ ក្រុមស្រាវជ្រាវស្នូល បានរៀបចំឲ្យមានវិធីសាស្ត្រស្រាវជ្រាវ នៅក្នុងសិក្ខាសាលាត្រៀម ដែលមានរយៈពេល៥ថ្ងៃ។ ការចុះស្រាវជ្រាវដល់ទីកន្លែងត្រូវបានធ្វើឡើងចំនួនពីរសប្តាហ៍ រាប់បញ្ចូលទាំងពេលវេលាធ្វើដំណើរ ដោយមានរយៈពេលកំណត់សម្រាប់ស្រាវជ្រាវចំនួនមួយសប្តាហ៍ នៅតាមទីកន្លែងសំខាន់ៗក្នុងប្រទេសនីមួយៗ។

កុមារត្រូវបានជ្រើសរើស ជាប្រភពព័ត៌មានយ៉ាងសំខាន់ ហើយក៏មានការខិតខំប្រឹងប្រែង ទំនាក់ទំនងទៅកាន់កុមារ នៅក្នុងកាលៈទេសៈខុសៗគ្នា។ ពេលមានកន្លែងណាមួយដែលអាចធ្វើទៅបាន យើងបានសម្ភាសឪពុកម្តាយ និង អ្នកកាន់ភារកិច្ចរបស់កុមារដែលយើងទំនាក់ទំនងនោះ ដើម្បីបានប្រើប្រាស់ វិធីបែងចែកទីកន្លែងជាបីដើម្បីអង្កេត ។ មនុស្សដែលពាក់ព័ន្ធផ្សេងទៀត ដូចជា មន្ត្រីប៉ូលីស និងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀត ក៏ត្រូវសម្ភាសដែរ ដោយប្រើប្រាស់បញ្ជីសំណួរសម្ភាសន៍ មិនរៀបរយ ឬតារាងប្រជានបទនានា។ យើងក៏បានប្រមូលករណីសិក្សានានា ជាពិសេសនោះ គឺបានមកពីបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ករណីសិក្សាទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីកំណត់ សេណារីយ៉ូ ខុសៗគ្នាសម្រាប់ការរំលោភបំពានផ្លូវភេទ ។ នៅទីបំផុត អ្នកឆ្លើយតបជាកុមារ នៅក្នុងការសិក្សាស្រាវជ្រាវនេះក៏មានចំនួនច្រើនបំផុត ។ លក្ខណៈបែបនេះ ហាក់ដូចជាបានមកពីវិធីសាស្ត្ររបស់អ្នកស្រាវជ្រាវដែរ ព្រោះនៅត្រង់ចំណុចនេះ កុមារបានចូលរួមនៅក្នុងការស្រាវជ្រាវ តាមរយៈបទសម្ភាសន៍ជាលក្ខណៈក្រុមមនុស្សវាយតម្លៃ រីឯមនុស្សពេញវ័យវិញ ភាគច្រើនត្រូវបានគេសម្ភាសម្នាក់ៗ។ ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងរវាងឆ្នាំ២០១១ និង២០១២។
អ្នកស្រាវជ្រាវមានការប្រុងប្រយ័ត្នខ្ពស់ទៅតាមបទដ្ឋានត្រឹមត្រូវ ដើម្បីការពារសុវត្ថិភាព និងការសម្ងាត់របស់អ្នកឆ្លើយតប ដោយរាប់ទាំងត្រូវសុំការអនុញ្ញាតដើម្បីជួប និងសម្ភាសកុមារផង។ អ្នកស្រាវជ្រាវក៏បានប្រើប្រាស់វិធានការច្បាស់លាស់ ដើម្បីចៀសវាងមិនឲ្យមានរបួស ទោះក្នុងវិធីណាក៏ដោយចំពោះកុមារដែលអាចនឹងទទួលរងផលប៉ះពាល់គ្រោះថ្នាក់ ដែលបណ្តាលមកពីការសិក្សាស្រាវជ្រាវនេះ។ ការកំហិតទៅលើការស្រាវជ្រាវ គឺការកំណត់ពេលវេលាជាក់លាក់ ហើយការកំណត់ពេលវេលានេះ បានដាក់កម្រិតទៅលើវិធីសាស្ត្រស្រាវជ្រាវដែលគេអាចប្រើប្រាស់ និងថែមទាំង បានការពារបញ្ហាមួយចំនួនដោយមិនឲ្យជជីករកនូវអ្វីដែលមានលក្ខណៈលម្អិតលើសពីនេះឡើយ។ ការកំណត់ពេលវេលាជាក់លាក់ ក៏បាននាំឲ្យនូវការជ្រើសរើសសំណាកសម្រាប់ស្រាវជ្រាវ ជាពិសេសកុមារប្រកបការងារ និង កុមារតាមចិញ្ចើមថ្នល់ដែលពិបាកនឹងធ្វើសម្ភាស៍ជាងកុមារជាសិស្ស។ ទោះបីការដាក់កម្រិតទៅលើទំហំនៃការស្រាវជ្រាវបានការពារមិនឲ្យមានភាពទូទៅហួសពីកន្លែង សិក្សាស្រាវជ្រាវនីមួយៗនោះក៏ដោយការសិក្សានេះ បានបង្កើតឲ្យមានធនធានព័ត៌មាន និង បានធ្វើឲ្យយើងស្គាល់ពីចំនួននៃការប្រែប្រួលដែលគួរឲ្យកត់សម្គាល់បំផុត។

# ការរកឃើញសំខាន់ៗ

## ការយល់ដឹងអំពីការរំលោភរំពានផ្លូវភេទកុមារ



ចំពោះអ្នកឆ្លើយតបភាគច្រើន ការយល់ដឹងជាមូលដ្ឋានរបស់គាត់ទៅលើការ រំលោភបំពានផ្លូវភេទកុមារ និងសិទ្ធិកុមារ គឺនៅមានកម្រិតនៅឡើយ។ មនុស្សពេញវ័យ និង កុមារមានការយល់ដឹងមិនបានវែងឆ្ងាយ ឡើយ ទៅលើការរំលោភបំពានផ្លូវភេទកុមារ ដោយគិតថាជាការចាប់រំលោភសេពសន្ថវៈ ទៅលើកុមារី។ ពេលសម្ភាសន៍កុមារ និងមនុស្សពេញវ័យ ពួកគាត់ភាគច្រើនមានការភាន់ច្រឡំ រវាងពាក្យថា អាយុគ្រប់ការស្របច្បាប់ និងអាយុអាចរៀបការបានស្របច្បាប់ ហើយយល់ថារឿងនេះគឺជាទម្រង់នៃ ការគ្រប់គ្រងទៅលើកុមារច្រើនជាង ជាផ្នែកការពារកុមារ។ ជារឿយៗការវិនិច្ឆ័យទៅលើ ការរំលោភបំពានផ្លូវភេទ ពឹងផ្អែកលើកាលៈទេសៈជាក់លាក់ រាប់បញ្ចូលទាំងអាយុរបស់ដៃគូរួមភេទទំនាក់ទំនងរបស់មនុស្សម្នាក់នោះជាមួយកុមារ និងរឿងដែលថា តើកុមារីដែលជាប់សង្ស័យនោះ គឺជាស្រីក្រមុំឬមិនមែន។ សិស្សរៀនជំនាញវិជ្ជាជីវៈ កុមារប្រកបមុខរបរ កុមារតាមចិញ្ចើមថ្នល់ និងសិស្សសាលាឯកជន ហាក់ដូចជាមានការយល់ដឹងយ៉ាងច្រើនទៅលើបញ្ហានេះ ជាងសិស្សនៅសាលារដ្ឋ។ ជាទូទៅគេឃើញថា សិស្សស្រីងាយរងគ្រោះដោយការរំលោភបំពាន ជាងសិស្សប្រុស។ តាមពិតការរំលោភបំពានផ្លូវភេទ មិនត្រូវបានគេស្គាល់ឲ្យបានទូលំទូលាយថា ជាអ្វីដែលអាចកើតឡើងចំពោះកុមារានោះឡើយ ហើយលក្ខណៈបែបនេះបានធ្វើឲ្យលេចចេញនូវលទ្ធផលនានា ដែលអាចឲ្យយើងស្គាល់អំពីការរំលោភបំពានផ្លូវភេទលើកុមារា ហើយក៏ឆ្លើយតបទៅនឹងការរំលោភបំពាននេះ។

សរុបសេចក្តីមក មានមនុស្សពេញវ័យ និង កុមារជាច្រើនដែលហាក់ដូចជាខ្វះខាតចំណេះឲ្យបាន គ្រប់គ្រាន់ទៅលើការរំលោភបំពានផ្លូវភេទកុមារ និង វិធីអនុវត្តជាក់ស្តែងដើម្បីស្គាល់ ការពារ ឬ ឆ្លើយតបទៅនឹងការរំលោភបំពាននេះ។ ចំពោះឪពុកម្តាយវិញ ការយល់ដឹងរបស់គាត់ ទៅលើបញ្ហា រំលោភបំពានផ្លូវភេទកុមារ គឺមានកម្រិតទាបបំផុត រីឯកុមារវិញមានចំនួនតិចតួចណាស់ ដែលបានស្គាល់ថា ការរួមភេទតាមរន្ធគូទការរួមភេទ ដោយប្រើមាត់ ការចូលរួម/ឃើញរូបអាសអាភាស ឬការធ្វើឲ្យស្រើប គឺជាសកម្មភាពបំពានផ្លូវភេទ។ ជាទូទៅ គេហាក់ដូចជាយល់ថា ការរំលោភបំពានផ្លូវភេទ គឺជាអ្វីដែលកើតឡើងដោយសារប្រភពពីខាងក្រៅគ្រួសារ ឬសហគមន៍ ជាពិសេស ការរំលោភបំពានផ្លូវភេទ កុមារាគឺជាការបារម្ភផងដែរ។ ប៉ុន្តែក្នុងពេលជាមួយគ្នានេះ វិធីល្បួងលោម ដែលជនល្មើសជាជនបរទេស ឬអ្នកនៅមូលដ្ឋានបានប្រើប្រាស់នោះ កម្រនឹងត្រូវបានចាត់ទុកថា ជាវិធីធ្វើ ឬជាទម្រង់នៃការរំលោភបំពានណាស់។

អ្នកស្រាវជ្រាវបានរកឃើញថា មានប្រភពសំខាន់ៗចំនួនប្រាំ សម្រាប់អប់រំស្តីពីផ្លូវភេទ និងបញ្ហាពាក់ព័ន្ធនឹងផ្លូវភេទកុមារគឺ៖ ប្រព័ន្ធផ្សព្វផ្សាយ/បច្ចេកវិទ្យាឌីជីថល មិត្តភក្តិ/មនុស្សវ័យស្របាលគ្នា សាលារៀន យុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ និងបទពិសោធន៍ផ្ទាល់ខ្លួន/ការសង្កេត។ ទោះបីជាកុមារ ដែលបានកំណត់ថា ឪពុកម្តាយគឺជាគឺជាមនុស្សដែលមានឥទ្ធិពលបំផុតនៅក្នុងជីវិតរបស់ខ្លួនក៏ដោយ គេរកឃើញថា ឪពុកម្តាយមិនមែនជាប្រភពផ្តល់ព័ត៌មានមួយដ៏សំខាន់ឡើយ ហើយមានកុមារច្រើនបាន សម្តែងការភ័យខ្លាចមិនហ៊ានប្រាប់ឪពុកម្តាយរបស់ខ្លួន អំពីបញ្ហាផ្ទាល់ខ្លួន រាប់បញ្ចូលទាំងបញ្ហាផ្លូវភេទផងដែរ។ លើសពីនេះ ក្មេងសិស្សសាលាក៏បានទទួលព័ត៌មានស្តីពី កាយវិភាគសាស្ត្រ និងសុខភាពបន្តពូជនៅតាមសាលា និង ពីអង្គការក្រៅរដ្ឋាភិបាលនានាដែរ ប៉ុន្តែកម្រនឹងទទួលបានព័ត៌មានលម្អិតជាងនេះ ដែលផ្តោតជាពិសេសទៅលើយុទ្ធសាស្ត្រការពារការរំលោភបំពានផ្លូវភេទកុមារ។

គំរូដ៏លេចធ្លោរមួយដែលគេបានរកឃើញនៅក្នុងការស្រាវជ្រាវនេះ គឺការរារាំងពីឪពុកម្តាយ មិនឲ្យកុមារទទួលបានការអប់រំផ្លូវភេទ ដោយភ័យខ្លាចថា ការអប់រំនេះនឹងជំរុញឲ្យកុមារសាកល្បងក្នុងទង្វើផ្លូវភេទ និងមានអាកប្បកិរិយាមិនសមរម្យ។ ទោះបីជាយ៉ាងនេះក៏ដោយ មានកុមារជាច្រើននៅតាមទីតាំងសិក្សាស្រាវជ្រាវក្នុងប្រទេសថៃ និងប្រទេសវៀតណាម គឺបានចូលពាក់ព័ន្ធនឹងទំនាក់ទំនងផ្លូវភេទរួចទៅហើយ។ កុមារទទួលបានព័ត៌មានជាច្រើនអំពីផ្លូវភេទតាមរយៈបណ្តាញក្រៅផ្លូវការ ដូចជាមនុស្សវ័យស្របាលគ្នា ទូរទស្សន៍ ប្រព័ន្ធផ្សព្វផ្សាយ និង អ៊ីនធឺណិត តែព័ត៌មាននេះក៏អាចមិនពិតដែរ។

## ឥរិយាបទ និងទង្វើផ្សេងៗ

គេឃើញមានឥរិយាបទ ជំនឿ និងទង្វើមួយចំនួននៅតាមទីតាំងស្រាវជ្រាវនីមួយៗ ដែលអ្វីទាំងនេះអាចរួមចំណែកធ្វើឲ្យកុមារងាយរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ។ ក្នុងចំណោមនេះ មានខ្លះជាបម្រាមនានាប្រឆាំងនឹងការពិភាក្សា ដោយចំហរស្តីពីបញ្ហាផ្លូវភេទ ដែលជាការរារាំងមិនឲ្យ មានការផ្សព្វផ្សាយព័ត៌មាននិងការអប់រំ ស្តីពីការរំលោភបំពានផ្លូវភេទ និងរបៀបការពារពីការរំលោភបំពាននេះ វិសមភាពយេនឌ័រ និងទំនាក់ទំនងទៅតាមឋានុក្រមពីឪពុកម្តាយទៅកូន ដែលនាំឲ្យខ្វះការអនុញ្ញាតដើម្បីទទួលបានឱកាសអប់រំ និងខ្វះការទទួលស្គាល់សិទ្ធិកុមារ ជាពិសេសកុមារី។ ក្រៅពីនេះ ក៏មានការសង្កត់ធ្ងន់ទៅលើកិត្តិយសនៃភាពក្រមុំព្រហ្មចារី កិត្តិយសគ្រួសារ និងមុខមាត់សហគមន៍ ហើយជាទូទៅ បែរជាទៅស្តីបន្ទោសនារី ទៅវិញ ក្នុងករណីមានការរំលោភសេពសន្ថវៈ ឬទង្វើមិនសមរម្យបែបណាមួយពាក់ព័ន្ធនឹងផ្លូវភេទ ព្រមទាំងបានរារាំងមិនឲ្យមានការឆ្លើយតបឲ្យបានសមស្របទៅលើការរំលោភបំពានផ្លូវភេទកុមារ ព្រោះបានបង្កើត នូវវប្បធម៌ស្ងាត់ស្ងៀម និងបដិសេធមិនព្រមទទួល។



តាមការស្រាវជ្រាវបានបញ្ជាក់ថា ទម្ងន់វប្បធម៌ដ៏ធ្ងន់នេះ បានធ្លាក់ទៅលើនារីនៅគ្រប់ទិសតំបន់ ដើម្បីរក្សានូវភាពក្រមុំបរិសុទ្ធមុនពេលរៀបការ ទោះបីជានៅក្នុងការអនុវត្តជាក់ស្តែង មានកុមារជាច្រើន បានប្រាប់ឲ្យដឹងថា មានទំនាក់ទំនងមនោសញ្ចេតនា ឬទំនាក់ទំនងផ្លូវភេទក៏ដោយ។ ជារឿយៗ នារីត្រូវបានស្តីបន្ទោស បន្ទុះបង្អាប់ និងមិនសូវឲ្យតម្លៃ ដោយសារតែឥរិយាបទផ្លូវភេទមុនពេលរៀបការ សូម្បីតែនៅពេលពួកគាត់បានក្លាយជាជនរងគ្រោះដោយការរំលោភបំពានក៏ដោយ។ លើសពីនេះទៅទៀត គេផ្តោតសារៈសំខាន់ទៅលើការថែរក្សាកិត្តិយសស្ត្រី មានន័យថា ចាំបាច់ត្រូវធ្វើជាទទួលស្គាល់ថា សកម្មភាពផ្លូវភេទដែលកើតឡើងនោះ គឺជារឿងដោយអចេតនា ឬកើតឡើងដោយពុំមានការយល់ព្រម ហើយការបង្ខិតបង្ខំបែបនេះ អាចនឹងនាំឲ្យប្រឈមមុខចំពោះទង្វើផ្លូវភេទប្រកបដោយគ្រោះថ្នាក់ ហើយក៏បណ្តាលឲ្យមានការរំលោភបំពានជាបន្តបន្ទាប់។

ភាពក្រីក្រ តម្រូវការប្រាក់ដើម្បីផ្គត់ផ្គង់ការអប់រំ និងបញ្ហាសុខភាព គឺជាមូលហេតុសំខាន់ៗមួយចំនួនដែលនាំឲ្យកុមារជាប់ពាក់ព័ន្ធនៅក្នុងអាជីវកម្មផ្លូវភេទ។ ក្រៅពីនេះ នៅគ្រប់ទីកន្លែងស្រាវជ្រាវទាំងអស់ កុមារត្រូវស្តាប់តាម និងគោរពឪពុកម្តាយរបស់ខ្លួន។ កាតព្វកិច្ចចំពោះបងប្អូន និងការដែលត្រូវផ្គត់ផ្គង់គ្រួសាររបស់ខ្លួន ត្រូវបានពោលឡើងជាញឹកញាប់ សម្រាប់ជាមូលហេតុ ដែលនារីត្រូវប្រឡូក នៅក្នុងវិស័យអាជីវកម្មផ្លូវភេទ។

គេបានឃើញថា ឥទ្ធិពលពីមនុស្សវ័យស្រាបលគ្នា ក៏ជាកត្តារួមចំណែកមួយដែរ ជាពិសេសនៅត្រង់ចំណុចដែលកុមារជំរុញមិត្តរបស់ខ្លួនឲ្យចូលរួមនៅក្នុងការដោះដូរអាជីវកម្មផ្លូវភេទ ។ គេក៏បានរកឃើញដែរថា ចំពោះមនុស្សវ័យក្មេងមួយចំនួន ការលក់ភេទដើម្បីបានប្រាក់ក៏ជាវិធីព្រមទទួលយកនូវទង្វើរបស់អតិថិជន។ នេះអាចមានលក្ខណៈជាទម្លាប់នៃការលក់ដូរទំនិញផ្លូវភេទ ឬមានទម្រង់ជា “ការដោះដូរសម្ភារ" ដែលល្អជាងនេះ ពាក់ព័ន្ធនឹងអំណោយនៃទំនិញអតិថិជន ។ ករណីនានាអំពីការ ល្បិចលួងលោម ដែលជារឿយៗទាក់ទងនឹងការផ្គត់ផ្គង់ប្រាក់ និងអំណោយជាសម្ភារ ក៏ត្រូវបានកត់ត្រាទុកជាឯកសារនៅគ្រប់កន្លែងស្រាវជ្រាវទាំងអស់។

ទំនាក់ទំនងផ្លូវភេទជាមួយភេទដូចគ្នា ត្រូវបានគេបន្ទុះបង្អាប់ ហើយត្រូវបានចាត់ទុកជាការមិនអាចទទួលយកបាននៅក្នុងសង្គមនៅគ្រប់កន្លែងស្រាវជ្រាវទាំងអស់ លើកលែងតែ សាធារណរដ្ឋប្រជាមានិតឡាវ និងទីក្រុងប៉ាតាយ៉ា ប្រទេសថៃប៉ុណ្ណោះ ហើយការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារា មិនបានចាត់ទុកជាការគំរាមកំហែង ឬជាបញ្ហាពិតប្រាកដឡើយ។ កង្វះខាតការយល់ដឹង និងការទទួលស្គាល់នេះ បង្ហាញពីគ្រោះថ្នាក់ដ៏ធំចំពោះកុមារា ដែលស្ថិតនៅក្នុងគ្រោះថ្នាក់ ឬកំពុងរងគ្រោះដោយការរំលោភបំពាន។

នៅគ្រប់ទីកន្លែងស្រាវជ្រាវ ឥទ្ធិពលនៃប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកវិទ្យា ឌីជីថលទៅលើ ឥរិយាបទនិងអាកប្បកិរិយាផ្លូវភេទរបស់កុមារ ពិតជាកើតមានប្រាកដមែន។ ការជួយកុមារឲ្យ ចេះប្រើប្រាស់បច្ចេកវិទ្យាឌីជីថលគឺមិនមានឡើយ នៅក្នុងការអនុវត្តជាក់ស្តែង។ក្តីបារម្ភជាចម្បងរបស់ឪពុកម្តាយ និងអ្នកកាន់ភារកិច្ច គឺថាកុមារអាចនឹងងប់ងល់ទៅនឹងវីដេអូហ្គេម ឬតែងប្រទះ ឃើញរូបអាសអាភាសជានិច្ច។ មានឪពុកម្តាយ ឬកុមារតិចតួចណាស់ ដែលបង្ហាញពីការយល់ដឹងអំពី ល្បិចលួងលោម ក្នុងបណ្តាញអ៊ីនធឺណិត តាមរយៈជនល្មើសផ្លូវភេទ និងគ្រោះថ្នាក់ដែលស្តែងឡើង តាមរយៈ ទង្វើផ្លូវភេទនេះ។ ពាក្យថា "លេខទូរស័ព្ទសុំជំនួយ" ដែលជាបណ្តាញសម្រាប់ឲ្យកុមារទទួលបានព័ត៌មានសម្ងាត់ និងយោបល់ផ្សេងៗដើម្បីដោះស្រាយបញ្ហារបស់ខ្លួននោះភាគច្រើន គឺគ្មានអ្នកណាដឹងឡើយ ។

ការឆ្លើយតបនានាចំពោះការរំលោភបំពាន មានលក្ខណៈខុសគ្នាទៅតាមកន្លែងស្រាវជ្រាវនីមួយៗ។ នៅទី

ណាដែលគេផ្តល់សារៈសំខាន់ខ្លាំងបំផុត ទៅលើកេរ្តិ៍ឈ្មោះ ជារឿយៗនៅទីនោះ កុមារមិនបានប្រាប់ពីការរំលោភបំពានដល់មនុស្សពេញវ័យឡើយ ព្រោះដោយសារតែការខុសឆ្គង និងភាពអាម៉ាស់ រីឯឪពុកម្តាយក៏សម្រេចចិត្តមិនប្រាប់ដល់អាជ្ញាធរ ហើយអាជ្ញាធរក៏ទំនងជាមិនទទួលស្គាល់អត្ថិភាព នៃការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងសហគមន៍នានាឡើយ។ តាមរបាយការណ៍បានបង្ហាញថា ឧបសគ្គដែលរារាំងដល់ការឆ្លើយតបឲ្យបានសមស្រប ចំពោះតួនាទីរបស់អ្នកកាន់ភារកិច្ចរួមមាន ការខ្វះខាតធនធាន កង្វះខាតការសម្របសម្រួលរវាងនាយកដ្ឋាន និងអង្គភាព ការគ្មានចំណេះដឹងគ្រប់គ្រាន់ ផ្នែកច្បាប់ និងនីតិវិធី កង្វះខាតកិច្ចសហការពីក្រុមគ្រួសារ ឧបសគ្គដ៏ពិបាកៗ លើបញ្ហាព័ស្តុភារ និងទំនោរចាត់ទុកការរំលោភបំពានផ្លូវភេទកុមារជាបញ្ហាគ្រួសារ ឬជាបញ្ហាស៊ីវិល ។

## ឧបសគ្គ និងឱកាសទទួលបានអន្តរាគមន៍

គេកំណត់ថា មានកត្តាមួយចំនួនបានរួមចំណែកនៅក្នុងភាពងាយរងគ្រោះ ដោយសារការបំពានផ្លូវភេទកុមារ។ កត្តាទាំងនេះមានដូចជាបញ្ហាហិរញ្ញវត្ថុ ការធ្វើចំណាកស្រុក បរិស្ថានរស់នៅអវត្តមានឪពុកម្តាយ ស្ថានភាពរំលោភ បំពាននៅក្នុងគ្រួសារផ្នែករាងកាយ ឬសតិអារម្មណ៍ ព្រមទាំងការប្រើប្រាស់សារជាតុញៀន នៅក្នុងគ្រួសារ។ ទោះបីជាមានកុមារតាមចិញ្ចើមថ្នល់មួយចំនួនទទួល ទីជម្រកនៅពេលថ្ងៃនិងអាហារហូបចុកក៏ដោយ ទីជម្រកទាំងនោះក៏អាចជាទីកន្លែងសម្រាប់ឲ្យក្មេងតាមចិញ្ចើមថ្នល់ ឬមនុស្សពេញវ័យដទៃទៀតជ្រើសរើសកុមារឲ្យប្រព្រឹត្តទង្វើកេងប្រវ័ញ្ចផ្សេងៗ។

នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរក៏មានកត្តាគ្រោះថ្នាក់មួយទៀត ដែលរួមចំណែកនៅក្នុងភាពងាយរងគ្រោះ។ ជាពិសេសនៅទីណា ដែលកុមារប្រកបការងារផ្សេងៗ ឧទាហរណ៍ ការលក់ដូរតាមចិញ្ចើមថ្នល់ ដូចជាមគ្គុទេសន៍ទេសចរណ៍ ឬ នៅក្នុងឧស្សាហកម្មផ្តល់សេវា ការជិតដិតនឹងអ្នកធ្វើដំណើរអាចធ្វើឲ្យកុមារងាយរងគ្រោះបំផុត ដោយសារល្បិចលួងលោម និងការកេងប្រវ័ញ្ចផ្លូវភេទ។ ប៉ុន្តែ គេបានរកឃើញថា ជាទូទៅកុមារនិងមនុស្សពេញវ័យនៅក្នុង ការសិក្សានេះមិនបានដឹងថា ភ្ញៀវទេសចរ និង អ្នកធ្វើដំណើរគឺជាការគំរាមកំហែងឡើយ។

ទោះបីជាបញ្ហាការពារកុមារហាក់ដូចជាកំពុងកើនឡើងយ៉ាងជាក់ស្តែង នៅក្នុងកម្មវិធីនយោបាយជាតិក៏ដោយ មានករណីជាច្រើន ដែលប្រភពផ្តល់មូលនិធិមួយចំនួនធំក្នុងការខិតខំទប់ស្កាត់ និងការពារកុមារ គឺបានមកពីម្ចាស់ជំនួយបរទេស និងអង្គការសង្គមស៊ីវិលជាជាងអាជ្ញាធរជាតិ។ ហេតុនេះនៅពេលអ្នកស្រាវជ្រាវរកឃើញថាមានប្រព័ន្ធការពារកុមាររួចជាស្រេចនៅគ្រប់កន្លែងស្រាវជ្រាវហើយនោះ អ្នកឆ្លើយតប អាចសម្តែងថា កម្រិតប្រសិទ្ធភាពនៃរចនាសម្ព័ន្ធនានា នឹងត្រូវថមថយដោយសារបញ្ហាផ្សេងៗ ដូចជាកង្វះខាតការបណ្តុះបណ្តាលរបស់អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលិកសង្គមកិច្ចមិនទទួលស្គាល់ថាមានការរំលោភបំពានលើកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទកុមារពីសំណាក់អាជ្ញាធរ សេវាកម្មដែលអាចរកបាន នៅមានកម្រិតនៅឡើយនៅតាមទីជនបទឆ្ងាយៗ ទំនោរឆ្ពោះទៅរកដំណោះស្រាយក្រៅផ្លូវច្បាប់ និង ការចាត់ទុកការរំលោភបំពានផ្លូវភេទកុមារថាជាបញ្ហាស៊ីវិល ប៉ូលីសដែលរងការចោទប្រកាន់ និងអំពើពុករលួយនៅថ្នាក់មូលដ្ឋាន កង្វះធនធានប៉ូលីស ខ្វះការសម្របសម្រួលរវាងនាយកដ្ឋាន និងអង្គភាពខ្វះចំណេះដឹងផ្នែកច្បាប់និងនីតិវិធី បញ្ហាព័ស្តុភារសម្រាប់ឆ្លើយតបទៅនឹងករណីរំលោភបំពាន (ដូចជាចម្ងាយ ការដឹកជញ្ជូន និងធនធានមនុស្ស) ការមិនបានចាត់ទុកការរំលោភបំពានផ្លូវភេទលើកុមារជារឿងធ្ងន់ធ្ងរ និងទំនៀមទម្លាប់ និងជំនឿនៅក្នុងមូលដ្ឋាន។

ទោះជាយ៉ាងណាក៏ដោយ តាមការស្រាវជ្រាវបានបង្ហាញមានឱកាសច្រើនណាស់ដែលអាចឲ្យ ធ្វើអន្តរាគមន៍បាន។ ទោះបីជាមានគ្រូបង្រៀន និងឪពុកម្តាយជាច្រើនបានបដិសេធមិនព្រមនិយាយលម្អិតអំពីបញ្ហាផ្លូវភេទក៏ដោយ សាលារៀននានាត្រូវបានគេចាត់ទុកថា យានដ៏សំខាន់ក្នុងការទទួលនិងផ្សព្វផ្សាយបន្ត នូវព័ត៌មានស្តីពីការរំលោភបំពានផ្លូវភេទ។ អង្គការក្រៅរដ្ឋាភិបាលនានាដែលមាន និងអង្គការផ្អែកលើសហគមន៍ ក៏អាចត្រូវបានប្រើប្រាស់សម្រាប់បង្ហាញសារ ព័តមាន ការអប់រំ និងការទំនាក់ទំនង (IEC) ស្តីពីការការពារកុមារទៅដល់ទស្សនិកជនកាន់តែច្រើន។ យុទ្ធនាការដែលមានគោលដៅឆ្ពោះទៅរកឪពុកម្តាយដោយផ្ទាល់ អាចបញ្ជាក់ពីជោគជ័យដ៏ធំ នៅក្នុងការលើកកម្ពស់ទំនាក់ទំនង រវាងឪពុកម្តាយនិងកុមារ កាត់បន្ថយបំរាមនានាអំពីបញ្ហាផ្លូវភេទ និងជូនដំណឹងដល់ឪពុកម្តាយអំពីគ្រោះថ្នាក់នានាដែលបង្ហាញឡើងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកវិទ្យាឌីជីថល។ បណ្តាញទូរស័ព្ទ រាយការណ៍ទាន់ហេតុការណ៍ និងទូរស័ព្ទសុំជំនួយ ហាក់បី ដូចជាកំពុងត្រូវបានប្រើប្រាស់ ហើយអាចក្លាយ ជាឧបករណ៍ដ៏មានអានុភាព សម្រាប់ទំនាក់ទំនង និងលើកកកម្ពស់ការយល់ដឹង។ ដូចគ្នានេះដែរ ការដែលកុមារមានអ៊ីនធឺណិតប្រើប្រាស់ បានទូលំទូលាយ ក៏អាចយកមកធ្វើជាមធ្យោបាយផ្តល់សារដ៏មានប្រសិទ្ធភាពទៅឪពុកម្តាយ និងធ្វើជាយុទ្ធសាស្ត្រការពារកុមារពីការរំលោភបំពានផ្លូវភេទដែរ ។

# អនុសាសន៍ផ្សេងៗ

១. អន្តរាគមន៍ការពារគួរតែប្រើប្រាស់វិធីគ្រប់បែបយ៉ាង ដោយផ្តល់ទៅឲ្យកុមារ ឪពុកម្តាយរបស់កុមារ និងសហគមន៍ នូវព័ត៌មាន ជំនាញ និងយុទ្ធសាស្រ្តការពារកុមារពីការរំលោភបំពានផ្លូវភេទគ្រប់ប្រភេទ ទោះបីត្រូវមនុស្សប្លែកមុខ ជនបរទេស មនុស្សនៅមូលដ្ឋាន មិត្តភក្តិ ឬ សមាជិកគ្រួសារ គឺជាអ្នកប្រព្រឹត្តក៏ដោយ។

២. អន្តរាគមន៍ការពារផ្តោតទៅលើការរំលោភបំពានផ្លូវភេទកុមារដែលជាទង្វើរបស់អ្នកធ្វើដំណើរ/ភ្ញៀវទេសចរនៅក្នុងមជ្ឈមណ្ឌលទេសចរណ៍ផង និងជាទង្វើរបស់មនុស្សនៅមូលដ្ឋាននិងជនបរទេសនៅតាមតំបន់ជនបទដាច់ស្រយាល និងកន្លែងជនជាតិដើមនានា ដែលនៅទីនោះអាជ្ញាធរមានសមត្ថកិច្ចមិនងាយនឹងទៅដល់សហគមន៍ឡើយ ហើយបើតាមរបាយការណ៍អ្នករំលោភបំពានផ្លូវភេទកុមារចេះតែបន្តឆ្ពោះទៅរកកុមារកាន់តែច្រើនឡើង។

៣. គ្រោះថ្នាក់ និងភាពងាយរងគ្រោះរបស់កុមារចំពោះការរំលោភបំពានផ្លូវភេទ មិនអាចសរុបទៅជាស្ថានភាពមួយជាក់លាក់បានឡើយ ដូចជា ភាពក្រីក្រ វត្តមាននៃវិស័យទេសចរណ៍។ល។ មានកត្តាមួយចំនួន រួមមានបរិស្ថានរស់នៅ និងបរិបទសេដ្ឋកិច្ច បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើអាកប្បកិរិយា គឺមានន័យថា ឥរិយាបទ និងទង្វើនានា ចាំបាច់ត្រូវមានការសង្កេតតាមរយៈការយល់ឃើញជារួម និងដោយឆាប់រហ័ស។ ការវិភាគជាប្រចាំទៅលើស្ថានភាព នឹងត្រូវមានជាចាំបាច់ ដើម្បីឲ្យស្គាល់ពីការប្រែប្រួលអាកប្បកិរិយា។ ចំពោះវិធី និងឧបករណ៍ទប់ស្កាត់ចំបាច់ត្រូវពិនិត្យ និងពិចារណាឡើងវិញជាប្រចាំ ទាក់ទងទៅនឹងការយល់ឃើញ និងចំណាប់អារម្មណ៍ដោយឆាប់រហ័សនេះ ជាជាងដោយលម្អិត។

៤. គួរយកចិត្តទុកដាក់ទៅលើការរំលោភបំពានផ្លូវភេទលើកុមារា ដែលពុំសូវមានអ្នកដឹង ហើយដែលទទួលបានការស្រាវជ្រាវតិចតួច ជាពិសេសកុមារា ដែលងាយរងគ្រោះច្រើនជាងគេដោយសារការចេះតែបន្ទុះបង្អាប់ពួកគាត់ នៅជុំវិញបញ្ហាផ្លូវភេទជាមួយភេទដូចគ្នា។ ចាំបាច់ត្រូវធ្វើការស្រាវជ្រាវបន្ថែមទៀតទៅលើបម្រែបម្រួលនៃវិធីនានារបស់អ្នករំលោភបំពានផ្លូវភេទកុមារដូចជាការប្រើប្រាស់មេអណ្តើកជាដើម និងទៅលើការចូលទៅរកកុមារតាមរយៈការងារក្លែងក្លាយ។

៥. កុមារគួរតែជាគោលដៅ នៅក្នុងអន្តរាគមន៍ការពារ ហើយត្រូវទទួលនូវការអប់រំ ដើម្បីជួយឲ្យពួកគាត់ស្គាល់ពីសញ្ញានៃការរំលោភបំពាន (រួមទាំងល្បិចលួងលោមផងដែរ) ហើយដើម្បីលើកទឹកចិត្តពួកគាត់ឲ្យផ្សព្វផ្សាយព័ត៌មានដល់មនុស្សពេញវ័យណាម្នាក់ដែលគួរឲ្យទុកចិត្ត ប្រសិនបើខ្លួនកំពុងទទួលរងការរំលោភបំពាន។

៦. អន្តរាគមន៍ការពារគួរតែអនុវត្តទៅដល់កុមារដែលជាសិស្សសាលា និងកុមារដែលងាយរងគ្រោះ (ក្មេងតាម ចិញ្ចើមថ្នល់ និងក្មេងប្រកបការងារ និងក្មេងពិការ) ដែលមិនអាចទទួលការអប់រំក្នុងប្រព័ន្ធ ឬ មិនទទួលបានសារស្តីពីសិទ្ធិកុមារ និងសេវាការពារនោះ។

៧. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកវិទ្យា មានតួនាទីកាន់តែសំខាន់ចំពោះជីវិតរស់នៅរបស់កុមារ ពោលគឺជាប្រភពនៃការកំសាន្តផង និងជាប្រភពព័ត៌មានផង។ គួរតែបង្ហាញព័ត៌មាន និងសារផ្សេងៗ ដល់កុមារ តាមរយៈទម្រង់ទំនាក់ទំនងនានា ដែលខ្លួនពេញចិត្ត។ វិធីផ្តល់ព័ត៌មានតាមបែបផ្លូវការជាងនេះ ដូចជាខិតប័ណ្ណ កូនសៀវភៅខិតប័ណ្ណ និងផ្ទាំងផ្សព្វផ្សាយ អាចសមនឹងប្រើប្រាស់ជាងនេះ ចំពោះក្មេងតាមចិញ្ចើមថ្នល់ និងក្មេងប្រកបការងារ ដែលមានអ៊ីនធឺណិត និងទូរស័ព្ទប្រើប្រាស់តិចជាងនេះ។ គួរលើកកម្ពស់បណ្តាញទូរស័ព្ទជំនួយកុមារដែលមានស្រាប់ ជាពិសេសនៅតាមតំបន់ដាច់ស្រយាល។

៨. ឪពុកម្តាយគួរតែជាគោលដៅនៅក្នុងអន្តរាគមន៍ទប់ស្កាត់ និងត្រូវទទួលបានព័ត៌មាន និងជំនាញ ដើម្បីអាចការពារ និងទំនាក់ទំនងប្រកបដោយសុវត្ថិភាពជាមួយកុមារា និងកុមារី ។ ឧបករណ៍សម្រាប់អ្នកថែទាំ គួរតែរាប់បញ្ចូលទាំងការយល់ និងទទួលស្គាល់ទៅលើសញ្ញានានា ដែលបង្ហាញឲ្យឃើញពីការរំលោភបំពានផ្លូវភេទ។

៩. ឪពុកម្តាយ និងអ្នកកាន់ភារកិច្ច កំពុងប្រើបច្ចេកវិទ្យាថ្មីៗមិនបានញឹកញាប់ទេ ហើយក៏មិនស្ទាត់ជំនាញដូចកុមារដែរ ហេតុនេះហើយ ជួនកាល បានធ្វើឲ្យពួកគាត់មិនដឹងអំពី ចំណាប់អារម្មណ៍ និងទង្វើរបស់កុមារឡើយ។ ឪពុកម្តាយ និងអ្នកកាន់ភារកិច្ចត្រូវអភិវឌ្ឍខ្លួនឯងជានិច្ចអំពីឧបករណ៍ និងបណ្តាញទំនាក់ទំនងនានាដែលពួកគាត់ប្រើប្រាស់ ព្រោះថា អ្វីទាំងអស់នេះអាចធ្វើឲ្យអាកប្បកិរិយារបស់កុមារមានការប្រែប្រួលខ្លាំងណាស់ ឬអាចធ្វើឲ្យគ្រោះថ្នាក់ដល់ជីវិតរបស់ពួកគាត់។.

១០. ត្រូវមានយុទ្ធនាការផ្សេងៗ នៅក្នុងមជ្ឈដ្ឋានអ្នកដំណើរកំសាន្ត និងភ្ញៀវទេសចរ ដើម្បីកាត់បន្ថយសកម្មភាពដែលធ្វើឲ្យកុមារចេះតែបន្តនៅតាមចិញ្ចើមថ្នល់ជានិច្ច និងជាពិសេស គឺកុមារដែលងាយរងគ្រោះដោយសារការជួញដូរ ដូចជាកាត់បន្ថយការឲ្យទានដល់ ក្មេងសុំទាន ឬការទិញរបស់របរពីកុមារអ្នកលក់ជាដើម។

១១. អន្តរាគមន៍នៅថ្នាក់សហគមន៍ គួរតែរួមគ្នាប្រើប្រាស់ និងគាំទ្រយន្តការដែលមានស្រាប់ដើម្បីការពារកុមារនៅមូលដ្ឋាន ។ យន្តការទាំងនេះ ត្រូវបានធ្វើសមាហរណកម្មរួចហើយនៅក្នុងសហគមន៍នានា ហើយកិច្ចសហការទាំងអស់ក៏គួរតែផ្តល់ជាទម្រង់កសាងសមត្ថភាពនៅមូលដ្ឋាន និងរួមចំណែកធ្វើឲ្យកម្មវិធីនេះមាននិរន្តរភាព។

១២. ក្រៅពីផ្តល់ព័ត៌មាន និងការអប់រំ អន្តរាគមន៍ទាំងឡាយ ក៏គួរតែមានការតស៊ូមតិជាមួយអង្គភាពមានសមត្ថកិច្ចជាន់ខ្ពស់ដែលពាក់ព័ន្ធ ដើម្បីកែសម្រួល និងអនុវត្តការឆ្លើយតបដោយយុត្តិធម៌ក្នុងបទឧក្រិដ្ឋ ចំពោះការរំលោភបំពានផ្លូវភេទ ជាជាងប្រើប្រាស់ដំណោះស្រាយដោយប្រើប្រាស់រដ្ឋប្បវេណី ដូចជាការបង់ប្រាក់សំណង ឬសំណើរៀបការជាដើម និងដើម្បីជានាររៀបចំឲ្យបានល្អនូវធនធាននានា និងការបណ្តុះបណ្តាលផ្សេងៗ សម្រាប់អាជ្ញាធរមូលដ្ឋានដែលគួរឲ្យទុកចិត្តដោយមានការឆ្លើយតបទៅនឹងករណីរំលោភបំពានផ្លូវភេទផ្សេងៗលើកុមារ ។

អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពី

# សិទ្ធិកុមារ

## មាត្រា ៣៤

ភាគីរដ្ឋទាំងអស់ត្រូវអនុវត្តដើម្បីការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ គ្រប់រូបភាពទាំងអស់។ ដើម្បីសម្រេចគោលដៅនេះ ភាគីរដ្ឋទាំងអស់ ត្រូវចាត់វិធានការគ្រប់បែបយ៉ាងឲ្យបានសមស្រប និងជាក់លាក់ នៅក្នុងថ្នាក់ជាតិ ថ្នាក់ទ្វេរភាគី និងពហុភាគី ក្នុងគោលបំណងទប់ស្កាត់ ៖

ក. គ្រឿងទាក់ទាញទឹកចិត្ត ឬការបង្ខិតបង្ខំកុមារណាម្នាក់ឲ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទណាមួយខុសច្បាប់។

ខ. ប្រើប្រាស់កុមារដោយការកេងប្រវ័ញ្ចនៅក្នុងពេស្យាកម្ម ឬទង្វើផ្លូវភេទខុសច្បាប់ផ្សេងៗទៀត។

គ. ប្រើប្រាស់កុមារដោយការកេងប្រវ័ញ្ចនៅក្នុងសកម្មភាពបែបអាសអាភាស និងសម្ភារអាសអាភាស។

# សេចក្តីផ្តើម



# ទី១ ៖ សេចក្តីផ្តើម

## សារតា

របាយការណ៍នេះ បង្ហាញពីការរកឃើញនៃការសិក្សាចំនួនបួនដាច់ដោយឡែកគ្នា ដែលបានធ្វើឡើងនៅក្នុងសហគមន៍ងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាម ស្តីអំពីចំណេះដឹង អាកប្បកិរិយា និងទង្វើផ្សេងៗ ដែលទាក់ទងទៅនឹង ការរំលោភបំពានផ្លូវភេទ រាប់ទាំងវិស័យទេសចរណ៍ និងការធ្វើដំណើរផង។ ការសិក្សាទាំងនេះ ត្រូវបានធ្វើឡើងដើម្បីជាការរួមចំណែកនៅក្នុងការរៀបចំនិងទម្រង់គំនិតនៃគម្រោងកុមារភាពផ្នែកបង្ការ ។

## គម្រោងកុមារភាព



គម្រោងកុមារភាព គឺជាគំនិតផ្តួចផ្តើមមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដែលបានចំណាយទឹកប្រាក់ចំនួន ៧,៥លានដុល្លារអូស្ត្រាលីដើម្បីប្រយុទ្ធប្រឆាំងការរំលោភបំពាន ផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៍ ក្នុងមហាអនុតំបន់ទន្លេមេគង្គ ជាពិសេសនៅក្នុងប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាម។ កម្មវិធីដែលមានរយៈពេលបីឆ្នាំកន្លះ (២០១១-២០១៤) បានបង្កើតឲ្យមានកិច្ចសហការគ្នាមួយ រវាងការិយាល័យអង្គការសហប្រជាជាតិ ទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) និងអង្គការទស្សនៈពិភពលោក ដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរមួយ គឺការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៍។ គម្រោងនេះមានពីរផ្នែកគឺ ការពារ និងបង្ការ។

នៅក្នុងផ្នែកការពារ អង្គការ UNODC បានសហការជាមួយទីភ្នាក់ងារអនុវត្តន៍ច្បាប់នានា ដើម្បីការពារកុមារ ដោយត្រូវពង្រឹងការឆ្លើយតបនានាចំពោះការអនុវត្តច្បាប់។ នៅផ្នែកបង្ការ អង្គកាទស្សនៈពិភពលោក បានសហការជាមួយអាជ្ញាធរនានា វិស័យឯកជន និងសហគមន៍ផ្សេងៗ ដើម្បីការពារកុមារមិនឲ្យ ក្លាយជាជនរងគ្រោះនៅក្នុងការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍។




ផ្នែកបង្ការ មានគោលដៅឆ្ពោះទៅរកអ្នកសម្តែងសំខាន់ៗ ដោយមានការទទួលខុសត្រូវជាពិសេសក្នុងការថែរក្សាសុវត្ថិភាពកុមារ ឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ។ ជារួម ផ្នែកបង្ការនេះ គឺចាប់ផ្តើមពីកុមារខ្លួនឯង ឪពុកម្តាយរបស់កុមារនិងអ្នកថែទាំ សមាជិកសហគមន៍ (ឬអ្នកកាន់ភារកិច្ច) ដោយមានការទទួលខុសត្រូវការពារកុមារ (សមាសសភាពទី១)។ ក្នុងកិច្ចអន្តរាគមន៍នៅថ្នាក់បន្ទាប់ គេបានពង្រឹងលេខទូរស័ព្ទជំនួយកុមារ ដើម្បីលើកកម្ពស់យន្តការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងថ្នាក់ជាតិសម្រាប់កុមារា និង កុមារីដែលងាយរងគ្រោះ (សមាសសភាពទី២)។ អ្នកធ្វើដំណើរទូទៅ និង ឧស្សាហកម្ម

ទេសចរណ៍ ត្រូវមានភារកិច្ចជួយ តាមរយៈយុទ្ធនាការទេសចរណ៍ ដើម្បីសុវត្ថិភាពកុមារ និង ការបណ្តុះបណ្តាល កែសម្រួលវិស័យទេសចរណ៍ ប្រកបដោយការទទួលខុសត្រូវកាន់តែខ្ពស់ដើម្បីរួមចំណែក នៅក្នុងបរិស្ថានថែរក្សាសុវត្ថិភាព និងការពារកុមារ (សមាសភាពទី៣)។ ជាចុងក្រោយ អាជ្ញាធរដែលពាក់ព័ន្ធ ត្រូវបានគាំទ្រឲ្យលើកកម្ពស់ការឆ្លើយតបទៅនឹងកិច្ចការពារមិនឲ្យមាន ការរំលោភបំពានផ្លូវភេទលើកុមារា និង កុមារីនៅក្នុងវិស័យវិស័យទេសចរណ៍ និងការធ្វើដំណើរ (សមាសសភាពទី៤)។ អន្តរាគមន៍ផ្សេងៗទៅតាមកម្រិតខុសៗគ្នានេះ បានផ្សារភ្ជាប់គ្នាតាមរយៈការ ទាញយកលទ្ធផល ពីលើចុះក្រោម និងពីក្រោមឡើងលើ ការរៀនសូត្រ ទិន្នន័យ និងសកម្មភាព (សមាសសភាពទី៥)។ ការសិក្សាដែលគេបាន សង្ខេបនៅក្នុងរបាយការណ៍នេះ ដែលទាក់ទងនឹងកុមារ ឪពុកម្តាយ និងអ្នកថែទាំ អ្នកកាន់ភារកិច្ច និងសមាជិកសហគមន៍ បានផ្តល់នូវទម្រង់គំនិតជ្រាលជ្រៅ សម្រាប់អន្តរាគមន៍កម្មវិធី។ ការផ្សព្វផ្សាយលទ្ធផលទាំងនេះគឺជាការ សម្តែងនូវគោលបំណងជាស្នូលរបស់ ផ្នែកការពារ ដើម្បីលើកកម្ពស់ ការបន្តកិច្ចខិតខំក្នុងការពារកុមារ ពីការបំពានផ្លូវភេទ នៅក្នុងវិស័យទេសចរណ៍ ប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព។ គេសង្ឃឹមថា ការរកឃើញនេះ នឹងបន្តទៅមុខទៀត នូវកម្មវិធីការស្រាវជ្រាវ និងការខំប្រឹងជាបន្តដើម្បីទប់ស្កាត់ការរំលោភបំពានផ្លូវភេទកុមារដ៏គួរឲ្យរន្ធត់នេះ។

## ការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៍ និង ការធ្វើដំណើរ

ចំពោះគម្រោងកុមារភាព ផ្នែកបង្ការ និងរបាយការណ៍នេះ ឃ្លាថា *ការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ* គឺគេនិយមប្រើជាងឃ្លាផ្សេងៗទៀត ដូចជា *ទេសចរណ៍ផ្លូវភេទកុមារ* ព្រោះថា ៖

- **ពាក្យ "*ទេសចរណ៍ផ្លូវភេទកុមារ*" មានខ្លឹមសារមិនគ្រប់គ្រាន់សម្រាប់ផ្តោតលើផលប៉ះពាល់នៃបទឧក្រិដ្ឋ ការកេងប្រវ័ញ្ច និងគ្រោះថ្នាក់មួយដ៏ធំ ដែលបណ្តាលមកពី ទម្រង់រំលោភបំពានដ៏ធ្ងន់ធ្ងរនេះឡើយ ហើយក៏មិនសមស្របទៅនឹងវិធីសាស្ត្រផ្អែកលើសិទ្ធិកុមារដែរ។**
- **នៅប្រទេសភាគច្រើន បទឧក្រិដ្ឋនៃការរំលោភបំពានផ្លូវភេទកុមារបានកើត ពាក់ព័ន្ធនឹងមនុស្សគ្រប់គ្នា ដោយមិនប្រកាន់សញ្ជាតិឡើយ។ ការរំលោភបំពានផ្លូវភេទកុមារអាចកើតមាននៅតាមទីកន្លែងផ្សេងៗ រួមទាំងនៅក្នុងវិស័យវិស័យទេសចរណ៍ និងការធ្វើដំណើរ។**
- **ភ្ញៀវទេសចរមានប្រភេទខុសៗគ្នា ភាគច្រើនភ្ញៀវទាំងនោះ គឺជាអ្នកគោរពច្បាប់សង្គម និងជាអ្នកធ្វើដំណើរដែលរំលោភបំពានផ្លូវភេទលើកុមារ ។ អ្នករំលោភបំពានផ្លូវភេទ ឬហៅថាជនឧក្រិដ្ឋ អាចជាអ្នកទេសចរ ឬជាជនបរទេសមកធ្វើការ ឬជាជនបរទេស មករស់នៅដែលប្រើប្រាស់បរិយាកាសធ្វើដំណើរ និងទេសចរណ៍ដើម្បីរំលោភបំពានលើកុមារ។**

វាជាចាំបាច់ត្រូវកត់សម្គាល់ថា ប្រភេទខុសគ្នាទាំងនេះ អាចហាក់ដូចជាជាក់លាក់ និងស្ថិតនៅដាច់ដោយឡែកពីគ្នា នៅពេលមើលពីចម្ងាយ។ ប៉ុន្តែ ភាពខុសគ្នាបែបនេះនៅក្នុងការប្រើប្រាស់ភាសា អាចមានលក្ខណៈដាច់ឆ្ងាយពីគ្នាខ្លាំង នៅពេលផ្សព្វផ្សាយ និងយល់ដឹងអំពីការពិតស្តីពីការរំលោភបំពានផ្លូវភេទកុមារ និងអាកប្បកិរិយារបស់ជនល្មើស តាមរយៈភាសា និងវប្បធម៌ ជាមួយមនុស្សដែលទទួលខុសត្រូវដោយផ្ទាល់ក្នុងការការពារកុមារ។ ឧទាហរណ៍ ដើម្បីឲ្យច្បាស់ខ្លាំងជាងនេះ ត្រូវសំដៅលើពាក្យដែលទាក់ទងនឹងច្បាប់ជាធរមាន និងយន្តការទប់ស្កាត់ ដែលគ្រប់គ្នាត្រូវអនុវត្តតាមដោយឥតលំអៀង។ ហេតុនេះ ឥទ្ធិពលនៃភាសា និងបច្ចេកវិទ្យា បានជះឥទ្ធិពលទៅលើកុមារពិត ហើយឥទ្ធិពលនេះ បានដឹកនាំគម្រោងកុមារភាព ផ្នែកបង្ការដំបូងបំផុត។

ពីរទសវស្សត៍កន្លងទៅនេះដោយសារការយល់ដឹងអំពីការរំលោភបំពានផ្លូវភេទ កុមារ បានកើនឡើងនៅក្នុង ប្រទេសនានា ដូចជា ប្រទេសអូស្ត្រាលី អង់គ្លេស និងសហរដ្ឋអាមេរិក គេបានពង្រឹងច្បាប់ និងនីតិវិធីជាប្រព័ន្ធ ដើម្បីការពារ និងឆ្លើយតប[៣]។ អាស្រ័យហេតុនេះ ជនដែលអាចជាអ្នករំលោភបំពានផ្លូវ ភេទកុមារ គឺកំពុងសម្លឹងរកវិធីងាយស្រួល ដើម្បីចូលទៅរកកុមារនៅក្នុងប្រទេសដទៃទៀត។ ព័ត៌មាននិងសេចក្តីរាយការណ៍ អំពីប្រជាជាតិរបស់ខ្លួន ដែលធ្វើដំណើរទៅរំលោភបំពានលើកុមារនៅក្នុងប្រទេសដទៃទៀត រួមជាមួយការយល់ដឹងស្តីពីឥទ្ធិពលដ៏គួរឲ្យរន្ធត់នៃបញ្ហានេះទៅលើកុមារ និងសហគមន៍ បញ្ជាក់ថា

[៣] ប្រទេសនានាដូចជា UK សហរដ្ឋអាមេរិក និង អូស្ត្រាលី បានអនុម័តច្បាប់យ៉ាងតឹងរឹងទៅលើ ទម្រង់ផ្សេងៗនៃការបំពានផ្លូវភេទកុមារ រួមទាំងការបំពានដោយការបណ្តុះអារម្មណ៍ផ្លូវភេទ និងដាក់បញ្ញត្តិតឹងរ៉ឹងអំពីការគ្រប់គ្រងក្រោយពេល មានអនុសញ្ញាទៅលើជនល្មើស។ គេបានអនុវត្តដំណើរការពិនិត្យពិច័យយ៉ាងតឹងរ៉ឹង ចំពោះមនុស្សណាម្នាក់ដែលកំពុងបំពេញភារកិច្ចជិតស្និទ្ធ ជាមួយកុមារ ឬមនុស្សដទៃទៀតដែលងាយរងគ្រោះ។ សហគមន៍នានា និងសាធារណជន កំពុងមានការយល់ដឹង និងទទួលបានការអប់រំស្តីពីគ្រោះថ្នាក់ នៃការបំពានផ្លូវភេទកុមារតាមរយៈការលើកកម្ពស់សមត្ថភាពនៃប្រព័ន្ធ ារពារកុមារ ផ្នែកវិជ្ជាជីវៈ និងស្ថាប័ន ព្រមទាំងបង្កើនការយល់ដឹងនៅក្នុងសហគមន៍តាមរយៈការពិភាក្សាជាសាធារណៈ។

ការយល់ដឹងស្ដីពីឥទ្ធិពលដ៏គួរឲ្យរន្ធត់នៃបញ្ហានេះទៅលើកុមារ និងសហគមន៍ បញ្ជាក់ថាប្រទេសនានាដូចជាប្រទេសអូស្ត្រាលី អង់គ្លេស និងសហរដ្ឋអាមេរិក ត្រូវទទួលខុសត្រូវ និងមានភារកិច្ចអនុវត្តវិធានការ។

ពុំមានអ្នកណាដឹងពីទំនាក់ទំនងដោយផ្ទាល់ រវាងប្រភពដើម និងបំណងរបស់ជនល្មើស ក្នុងការចូលពាក់ព័ន្ធសកម្មភាពផ្លូវភេទជាមួយកុមារតូចៗឡើយ។[៤] ការស្រាវជ្រាវខ្លះបានបង្ហាញថា អ្នកធ្វើដំណើរបំពានផ្លូវភេទលើកុមារដ៏ច្រើននៅក្នុងមហាអនុតំបន់ទន្លេមេគង្គ គឺមានប្រភពនៅអាស៊ី[៥] ទោះបីជាមិនបានបង្ហាញនៅក្នុងស្ថិតិជាផ្លូវការនៃការចាប់ខ្លួន និងការចោទប្រកាន់នានាក៏ដោយ ។ មានមូលហេតុមួយចំនួនត្រូវបានលើកឡើង ដើម្បីពន្យល់អំពីភាពមិនស្របគ្នានេះ។ គេបានបង្ហាញថា ការចាប់ខ្លួនបុរសស្បែកសមកពីបច្ចឹមប្រទេស ក្នុងចំនួនកាន់តែច្រើន ផ្ទុយពីជនល្មើសនៅអាស៊ី អាចមានទំនាក់ទំនងទៅនឹងរឿងដែលជនល្មើស ជាអ្នកបច្ចឹមប្រទេសមានចិត្តចង់ស្វែងរកកុមារតាមចិញ្ចើមថ្នល់ រីឯអ្នកជនល្មើសជាជនជាតិអាស៊ីប្រព្រឹត្តចំពោះកុមារ តាមរយៈបណ្ដាញដែលមានលក្ខណៈបិតបាំង[៦]។ លើសពីនេះ នៅតាមទីក្រុងនៅអាស៊ីជាទូទៅ អ្នកបច្ចឹមប្រទេសគួរឲ្យចាប់អារម្មណ៍ជាងគេ ហេតុនេះជនល្មើសង ាយនឹងត្រូវគេចាប់ខ្លួនណាស់ ហើយរឿងនេះ បានទាក់ទាញចំណាប់អារម្មណ៍ប្រព័ន្ធផ្សព្វផ្សាយ និងការខិតខំគាំទ្រពីអង្គការនានាដែលមានទីតាំងនៅបច្ចឹមប្រទេស។ ជនល្មើសបច្ចឹមប្រទេស ដែលមកពីអូស្ត្រាលី សហរដ្ឋអាមេរិក អង់គ្លេស និង ប្រទេសដទៃទៀត ក៏ទំនងប្រឈមមុខនឹងការចាប់ខ្លួនជាងគេ ដោយសារវិធានការការពារជាមុនរបស់រដ្ឋាភិបាលប្រទេសនោះ ដើម្បីកាត់ទោសពលរដ្ឋរបស់ខ្លួន ដែលប្រព្រឹត្តការរំលោភបំពានផ្លូវភេទកុមារនៅបរទេស។ យូរៗទៅ កម្មវិធីជាច្រើនដែលប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ បានទទួលមូលនិធិពីរដ្ឋាភិបាលនៃប្រទេសដដែលនេះ ដែលធ្វើឲ្យផ្ដោតលើពលរដ្ឋរបស់ខ្លួន[៧]។ តាមការស្រាវជ្រាវក៏បានបង្ហាញដែរថា អ្នកធ្វើដំណើររំលោភបំពានផ្លូវភេទកុមារ ភាគច្រើនគឺជាមនុស្សប្រុស បើតាមអត្រាប៉ាន់ស្មាននៃអ្នកបំពានផ្លូវភេទជាស្ត្រី ធៀបទៅនឹងមនុស្សប្រុសនោះ គឺ ១:១០[៨]។ ជាទូទៅ គេកំណត់ជនល្មើសជាមនុស្សស្រីថា ជាអ្នកសមគំនិត ដោយមាននាទីស្វែងរកកុមារមកឲ្យជនល្មើសដែលខ្លួនបានទាក់ទង។ គេបានបង្ហាញថា ជារឿយៗ កិច្ចការស្វែងរកនេះ គឺជានាទីរបស់មនុស្សស្រី ព្រោះងាយស្រួលទាញយកសេចក្ដីទុកចិត្តពីកុមារជាងមនុស្សប្រុស[៩]។

នៅក្នុងគោលបំណងនៃការស្រាវជ្រាវនេះ បញ្ហាទេសចរណ៍នៅក្នុងស្រុក និងអ្នករំលោភបំពានផ្លូវភេទដែលធ្វើដំណើរ និងប្រព្រឹត្តបទល្មើសនានាដែលស្ថិតក្នុងយុត្តាធិការ នៃប្រទេសរបស់ជនល្មើសត្រូវបាន ដកចេញ។ ជនជាតិមួយ ដែលប្រព្រឹត្តការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងប្រទេសរបស់ខ្លួនគួរតែត្រូវ ជាប់ចោទពីបទរំលោភបំពានផ្លូវភេទកុមារ។ គោលបំណងនាំយកអំពើរំលោភបំពាននេះមកដាក់នៅក្រោមការធ្វើដំណើរ ពីរំលោភបំពានផ្លូវភេទកុមារ បានរារាំងដល់កិច្ចខិតខំកាត់ទោស ហើយមិនបានធ្វើឲ្យរាំងស្ទះដល់ធាតុនៃបទល្មើសរំលោភបំពានគ្រប់គ្រាន់ឡើយ ។ តាមលំនាំនេះ កិច្ចសហការក្នុងការការពារ និងកាត់បន្ថយ ក៏គួរតែបានឆ្លុះបញ្ចាំងពិតប្រាកដអំពីក្របខ័ណ្ឌច្បាប់ទាំងនេះ ដើម្បីជាឧត្តមប្រយោជន៍ចំពោះកុមារ។

ទោះជាយ៉ាងណាក៏ដោយ ឧស្សាហកម្មទេសចរណ៍ដែលបម្រើឲ្យភ្ញៀវទេសចរ អាចនឹងពាក់ព័ន្ធដោយផ្ទាល់ និងមិនផ្ទាល់ នៅក្នុង*ការធ្វើឲ្យមាន*ការកេងប្រវ័ញ្ចផ្លូវភេទកុមារ ។ ហេតុនេះ គេត្រូវពិនិត្យមើលទៅលើគោលដៅ ទេសចរណ៍ក្នុងស្រុក នៅក្នុងបរិបទធំទូលាយជាងនេះ នៃគម្រោងកុមារភាព ផ្នែកបង្ការដើម្បីបង្កើត *បរិស្ថានទេសចរណ៍* សម្រាប់ការពារសុវត្ថិភាពជូនកុមារ ។

## ការប្រែប្រួលនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS)

តំបន់អាស៊ីអាគ្នេយ៍ បានទទួលស្វាគមន៍ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិចំនួនជាង៩២,៧ លាននាក់ នៅក្នុងឆ្នាំ២០១៣។ ចំនួននេះបានកើនឡើង១០% គិតចាប់ពីឆ្នាំ២០១២មក ដែលធ្វើឲ្យតំបន់នេះក្លាយជាតំបន់ដែលមានកំណើនភ្ញៀវទេសចរលឿនបំផុត នៅលើពិភពលោក[១០]។ ទីផ្សារដែលជាប្រភពមួយដ៏សំខាន់សម្រាប់ប្រទេសទាំងអស់ កើតឡើងមកពីក្នុងសមាគមនៃតំបន់ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ដែលមានចំណែកចំនួន៤៥% នៅឆ្នាំ២០១២[១១]។ នៅតំបន់អាស៊ីភាគអាគ្នេយ៍ គេរំពឹងថា លំហូរពីតំបន់មួយទៅតំបន់មួយនឹងកើនឡើងបន្ថែមទៀត ព្រោះប្រទេសទាំងអស់បានត្រៀមខ្លួនសម្រាប់ទីផ្សារតែមួយរបស់អាស៊ាន ឬសហគមន៍សេដ្ឋកិច្ចអាស៊ាន (ABC) ដែលនឹងត្រូវអនុវត្តយ៉ាងពេញលេញ នៅឆ្នាំ២០១៥[១២]។

[៤] ឯកសារ Putman-Cramer (2005) ស្ដីពីទេសចរណ៍ផ្លូវភេទកុមារ ៖ ការសិក្សាស្រាវជ្រាវស្ដីពីទំហំនៃបញ្ហា និងការវាយតម្លៃ របស់គំនិតផ្ដួចផ្ដើមទេសចរណ៍ប្រឆាំងផ្លូវភេទកុមារ, COSECAM

[៥] ឯកសារ Niron et al (2001) ស្ដីពីការងាររបស់កុមារ, ឥទ្ធិពលនៃមនុស្សពេញវ័យ៖ ទេសចរណ៍ផ្លូវភេទកុមារ -បញ្ហានៅក្នុងប្រទេសកម្ពុជា; អង្គការទស្សនៈពិភពលោក និងអង្គការសង្គ្រោះកុមារ (ខែកុម្ភៈ ឆ្នាំ២០០៩) អ្នកបំពានផ្លូវភេទគ្មានព្រំដែន៖ ការស៊ើបអង្កេតស្ដីអំពីការបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចលើកុមារ នៅប្រទេសថៃ កម្ពុជា និងភូមា ទាក់ទងនឹងការធ្វើដំណើរ និងទេសចរណ៍។

[៦] គម្រោងការពារ សាកលវិទ្យាល័យ Johns Hopkins (2007) ស្ដីពីទេសចរណ៍ផ្លូវភេទកុមារ អន្តរជាតិ ៖ ទំហំនេះបញ្ហា និងករណីសិក្សាបែបប្រៀបធៀប។

[៧] ឯកសារ Putman-Cramer (2005), ទេសចរណ៍ផ្លូវភេទកុមារ ៖ ការសិក្សាស្រាវជ្រាវស្ដីពីទំហំនៃបញ្ហា និងការវាយតម្លៃ របស់គំនិតផ្ដួចផ្ដើមទេសចរណ៍ប្រឆាំងផ្លូវភេទកុមារ, COSECAM

[៨] ការបកស្រាយមួយដែលអាចយកជាការបានគឺនិន្នាការសង្គម ចំពោះការបោះបង់ចោលនូវឥទ្ធិពលនៃទំនាក់ទំនងផ្លូវភេទរវាងក្មេងប្រុស និងនារីពេញវ័យ ។ អ្នកដែលនឹងបានប្រាប់ឲ្យដឹងអំពីទំនាក់ទំនងផ្លូវភេទរវាងបុរសពេញវ័យ និងក្មេងប្រុស ឬក្មេងស្រី ប្រហែលជាមិនអាចប្រាប់ឲ្យដឹងអំពីទំនាក់ទំនងផ្លូវភេទ រវាងនារីពេញវ័យ និងក្មេងប្រុសឡើយ ។ អង្គការ អង្គការសកម្មភាពដើម្បីកុមារ (ខែកុម្ភៈ ឆ្នាំ២០១៤), ការស៊ើបអង្កេតអំពីអ្នកដំណើរបំពានផ្លូវភេទកុមារ ៖ ការវិភាគស្ដីពីនិន្នាការ និងការប្រឈមនៅក្នុងផ្នែកការបំពានផ្លូវភេទកុមារ និងការកេងប្រវ័ញ្ច នៅក្នុងប្រទេសកម្ពុជា។

[៩] ឯកសារអង្គការសកម្មភាព ដើម្បីកុមារ (ខែកុម្ភៈ ឆ្នាំ២០១៤) ស្ដីពីការស៊ើបអង្កេតអំពីអ្នកដំណើរបំពានផ្លូវភេទកុមារ ៖ ការវិភាគស្ដីពីនិន្នាការ និងការប្រឈមនៅក្នុងផ្នែកការបំពានផ្លូវភេទកុមារ និងការកេងប្រវ័ញ្ច នៅក្នុងប្រទេសកម្ពុជា ។

[១០] ឯកសារអង្គការ UNWTO ស្ដីពី សុចនាករបង្ហាញពីបម្រែបម្រួលនៃទេសចរណ៍ក្នុង ពិភពលោក វែបសាយ http://www.innovasjonnorgeno/Documents/old/Documents/UNWTO ចូលមើលចុងក្រោយនៅថ្ងៃទី១០ មេសា ២០១៤។

[១១] ឯកសាររបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ថ្ងៃទី៣១ មករា ២០១៤ ក្នុងវែបសាយ http://www.asean.org/ images/resources/2014/Jan/StatisticUpdate28Jan/Tourism%20 Update/Table%2030.pdf ចូលមើលចុងក្រោយ នៅថ្ងៃទី១២ មេសា ២០១៤។

[១២] ឯកសារអង្គការ UNWTO ស្ដីពីសូចនាករបង្ហាញពីបម្រែបម្រួលនៃទេសចរណ៍ក្នុងពិភពលោក វែបសាយ http://www.innovasjonnorgeno/Documents/old/Documents/UNWTO ចូលមើលចុងក្រោយនៅថ្ងៃទី១០ មេសា ២០១៤។

ទម្រង់សំខាន់ៗទាំងបីនៃវិស័យទេសចរណ៍នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ គឺជាទេសចរណ៍កាន់តែធំទូលាយ ទេសចរណ៍ក្នុងតំបន់ និងទេសចរណ៍ក្នុងស្រុក។ ការកំសាន្តគឺជាមូល ហេតុដ៏ធំបំផុតមួយសម្រាប់ការធ្វើដំណើរទៅកាន់តំបន់នេះ មានទាំងអាជីវកម្ម និងគ្រួសារដែលទៅកំសាន្ត។ បុព្វហេតុសាសនា ការសិក្សា និងការស្ម័គ្រចិត្ត គឺជាមូលហេតុផ្សេងទៀត សម្រាប់ដំណើរកំសាន្ត។

អង្គការទេសចរណ៍ពិភពលោកនៃអង្គការសហប្រជាជាតិ ( UNWTO) បានព្យាករថា តំបន់អាស៊ីអាគ្នេយ៍គឺជាតំបន់មួយដែលគេចូលចិត្តទៅកំសាន្តបំផុត ដែលមានភ្ញៀវទេសចរចំនួន១៨៧លាននាក់ ដូចបានព្យាករសម្រាប់ឆ្នាំ២០៣០[១៣]។ នៅពេលវិស័យទេសចរណ៍បន្តកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងតំបន់ ចំនួនអ្នកធ្វើដំណើរដែលអាចទៅស្គាល់កុមារងាយរងគ្រោះ ក៏នឹងកើនឡើងផងដែរ។ អ្នកធ្វើដំណើរទៅ បរទេសក្នុងគោលដៅពាណិជ្ជកម្មដែលកើនឡើងនោះ កំពុងនាំគ្នាទៅកំសាន្តនៅតំបន់អាស៊ីអាគ្នេយ៍ ហើយជនបរទេសដែលមកធ្វើការ រស់នៅ និងចូលនិវត្ត ក៏កើនឡើងច្រើននៅក្នុងតំបន់។ ជារឿយៗ អ្នកដែលនៅឆ្ងាយពីផ្ទះ នឹងស្វែងរកអាជីវកម្មផ្លូវភេទកាន់តែងាយ។ លក្ខណៈបែបនេះបាន បង្កការលំបាក និងគ្រោះថ្នាក់ដ៏ជាក់លាក់ សម្រាប់ការរំលោភបំពានផ្លូវភេទកុមារនៅក្នុងប្រទេសគោលដៅ ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍ[១៤]។ មានការស្រាវជ្រាវថ្មីៗជាងនេះបានបង្ហាញថា អ្នកធ្វើដំណើរបំពានផ្លូវភេទ កុមារនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលមកពីប្រទេសដទៃទៀតនោះបានកើនឡើង[១៥]។ ជាទូទៅ ទោះបីជាការរំលោភបំពានផ្លូវភេទកុមារនៅក្នុងវិស័យទេសចរណ៍ត្រូវបានគេរាយការណ៍ថា កើតឡើងនៅក្នុងទីក្រុងធំៗក៏ដោយ បញ្ហានេះក៏កំពុងកើតឡើងនៅទីតាំងថ្មីៗ ដូចជាតំបន់ដាច់ស្រយាល និងតំបន់ដែលគេបោះបង់ចោល[១៦]។

ការផ្លាស់ទីនៅក្នុងតំបន់ របស់ជនអន្តោប្រវេសន៍ដែលងាយរងគ្រោះ ក៏ទាក់ទាញកុមារឲ្យទៅកាន់កន្លែងគោលដៅទេសចរណ៍ ដោយកុមារទាំងនោះសង្ឃឹមចង់បានប្រាក់ ទោះពួក គាត់នៅម្នាក់ឯង ឬនៅជាមួយគ្រួសាររបស់ខ្លួនក៏ដោយ។ កាលៈទេសៈទាំងអស់នេះ រួមទាំងស្ថានភាព សង្គម-សេដ្ឋកិច្ច និងស្ថានភាពចំនួនប្រជាជននៅក្នុងមូលដ្ឋាន មានកម្រិតទាបផងនោះ បានបង្កើតនូវទំនោរខ្លាំង ឆ្ពោះទៅរកការកេងប្រវ័ញ្ចកុមារ។ គេបានបង្ហាញថា កន្លែងគោលដៅទេសចរណ៍នៅក្នុងតំបន់កំពុងបង្កើនការងាររបស់ខ្លួន ដើម្បីទាក់ទាញអ្នកធ្វើដំណើរកំសាន្តនៅក្នុងតំបន់ ជាពិសេសបុរសៗតាមរយៈសេវានានា ដូចជា កន្លែងកំសាន្ត ពេលយប់ ឬកន្លែងអាជីវកម្មផ្លូវភេទជាដើម[១៧]។ ការស្រាវជ្រាវបានបង្ហាញថា ជារឿយៗ អ្នកធ្វើដំណើរកំសាន្តទាំងនេះ មានចំណូលចិត្ត ទៅលើនារីក្មេងស្អាត និងទាក់ទាញ ហើយពាក់ព័ន្ធនឹងទង្វើមួយចំនួន ដូចជាការស្វែងរកភាពក្រមុំព្រហ្មចារីជាដើម[១៨]។ លើសពីនេះ តាមការវិភាគស្ថិតិបែបបរិមាណ នៃការស្រាវជ្រាវដែលមានស្រាប់ បានបង្ហាញពីការប្រែប្រួលដ៏គួរឲ្យព្រួយបារម្ភ គឺថាកុមារនៅក្នុងតំបន់កំពុងធ្លាក់ចូលទៅក្នុងឧស្សាហកម្មផ្លូវភេទ ឬកំពុងត្រូវបានជួញដូរពេលមានវ័យក្មេងៗ[១៩]។

*ជនល្មើស*ផ្សេងៗបាន*ប្រើប្រាស់វិធីខុសៗគ្នា* ដើម្បីធ្វើការរំលោភបំពានទៅលើកុមារ ហើយជាញឹកញាប់ អ្នកធ្វើដំណើរបំពានផ្លូវភេទកុមារ ត្រូវបានបែងចែកជាពីរប្រភេទផ្សេងៗគ្នា ប្រភេទស្ថានភាព និងប្រភេទរើសមុខ។ ក្នុងប្រភេទស្ថានភាព ជនល្មើសមិនមានចំណូលចិត្តផ្លូវភេទទាំងស្រុងចំពោះកុមារឡើយ ប៉ុន្តែការរំលោភបំពានធ្វើឡើងដោយការពិសោធន៍ ឬតាមរយៈអនាមិកភាព និងសិទ្ធិពិសេសរបស់អ្នកធ្វើដំណើរ ឬទេសចរ[២០]។ ក្នុងប្រភេទរើសមុខជនល្មើសបង្ហាញពីចំណូលចិត្តផ្លូវភេទដែលកំពុងមានចំពោះកុមារ ហើយនឹង ស្វែងរកកុមារដើម្បីរំលោភបំពាន[២១]។

*អ្នកប្រព្រឹត្តអំពើផ្លូវភេទលើកុមារ* អាចត្រូវបានចាត់ទុកជាឧទាហរណ៍បញ្ជាក់ ឬជាប្រភេទនៃជនល្មើសដោយរើសមុខ ព្រោះមានចំណូលចិត្តផ្លូវភេទជាក់លាក់ចំពោះកុមារដែលមានវ័យមុនពេលគ្រប់ការ។ លោក Lanning បានស្នើឲ្យមានការរៀបចំដាក់ឲ្យនៅដាច់ដោយឡែកឡើងវិញ ដោយបានដាក់ឲ្យជនល្មើសទាំងអស់ស្ថិតនៅក្នុងលំដាប់គ្នាទៅតាមចំណង់ ( ពីលក្ខណៈស្ថានភាព ទៅលក្ខណៈរើសមុខ ) ជាជាងចាត់ឲ្យចូលក្នុងប្រភេទណាមួយ ក្នុងចំណោមប្រភេទទាំងពីរនេះ តាមរយៈ គំរូមួយដែល ជាធម្មតាលុបលើគំរូមួយទៀត។ គាត់ក៏បានពន្យល់ថា ជារឿយៗ ការពង្រឹងច្បាប់ បានទទួលយកជនល្មើសទាំងពីរប្រភេទនេះ និងលក្ខណៈនៃជនល្មើស ដែលបានបង្កើតឡើងដោយចិត្តវិទូ និងឧក្រិដ្ឋវិទូ។ ជារឿយៗ ប្រភេទ និងលក្ខណៈទាំងនេះ ត្រូវបានបង្កើតឡើង បន្ទាប់ពីប្រមូលបានទិន្នន័យ ពីជនល្មើស បន្ទាប់ពីការចាប់ខ្លួន ឬចោទប្រកាន់ ហើយជារឿយៗ ឆ្លុះបញ្ចាំងពីព័ត៌មានដែលគ្មានភស្តុតាងបញ្ជាក់ ស្តីពីអាកប្បកិរិយាមុនពេលចាប់ខ្លួន។ អាកប្បកិរិយាមុនពេលចាប់ខ្លួន ឬមុនពេលគេស្គាល់ របស់ជនល្មើសលើកុមារ គឺមានតម្លៃណាស់ចំពោះការអនុវត្តច្បាប់[២២]។

[១៣]ឯកសារអង្គការ UNWTO (2013) ស្តីពីទេសចរណ៍ឆ្ពោះទៅឆ្នាំ២០១៣។

[១៤] ឯកសារ O'Connell Davidson, J (2014) ស្តីពីទេសចរណ៍ផ្លូវភេទកុមារ ៖ ទម្រង់ពិសេសនៃចលនា? សារព័ត៌មានស្តីពីការការសិក្សាស្រាវជ្រាវបែបទំនើបនៅអឺរ៉ុប វ៉ុលទី ១២ (១) ទំព័រ ៣៦-៤៦, និងទំព័រទី៣៧។

[១៥] ឯកសារអង្គការសង្គ្រោះកុមារ (ខែកុម្ភៈ ២០០៩) ស្តីពីអ្នកបំពានផ្លូវភេទគ្មានព្រំដែន ៖ ការស៊ើបអង្កេតស្តីអំពីការបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចលើកុមារ នៅប្រទេសថៃ កម្ពុជា និងភូមា ទាក់ទងនឹងការធ្វើដំណើរ និងទេសចរណ៍។

[១៦] ឯកសាររបស់អង្គការ UNICEF (2011) ស្តីពីការវិភាគទៅលើការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ ក្នុងខេត្ត និងទីក្រុងមួយចំនួនដែលបានជ្រើសរើស នៅប្រទេសវៀតណាម។ សូមមើលឯកសាររបស់អង្គការសកម្មភាពដើម្បីកុមារ (ខែកុម្ភៈ ឆ្នាំ២០១៤)ស្តីពី ការស៊ើបអង្កេតអំពីអ្នកដំណើរបំពានផ្លូវភេទកុមារ ៖ ការវិភាគស្តីពីនិន្នាការ និងការប្រឈមនៅក្នុងផ្នែកការបំពានផ្លូវភេទកុមារ និងការកេងប្រវ័ញ្ចនៅក្នុងប្រទេសកម្ពុជា។

[១៧] ឯកសារ Peters, H (2007) ផ្លូវភេទកំដៅព្រះអាទិត្យ និង បីតិភណ្ឌ ៖ ការគំរាមកំហែង និងឱកាសក្នុងវិស័យទេសចរណ៍នៅតំបន់អាស៊ីអាគ្នេយ៍ អង្គការ UNIAP និងអង្គការទស្សនៈពិភពលោក។

[១៨] ១៨ ឯកសារ Peters, H (2007) ផ្លូវភេទកំដៅព្រះអាទិត្យ និង បីតិភណ្ឌ ៖ ការគំរាមកំហែង និងឱកាសក្នុងវិស័យទេសចរណ៍នៅតំបន់អាស៊ីអាគ្នេយ៍ អង្គការ UNIAP និងអង្គការទស្សនៈពិភពលោក។

[១៩] ឯកសារអង្គការ UNICEF-EAPRO (2012) ការធ្វើបាបដល់កុមារ ៖ ប្រេវ៉ាឡង់ ឧប្បត្តិហេតុ និងផលវិបាក នៅតំបន់អាស៊ីបូព៌ា និងតំបន់ប៉ាស៊ីហ្វិក ៖ ការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធទៅលើការស្រាវជ្រាវ ។ សូមមើល ឯកសាររបស់អង្គការ UNICEF (2011) ស្តីពីការវិភាគទៅលើការកេងប្រវ័ញ្ចកុមារសម្រាប់ អាជីវកម្មផ្លូវភេទ ក្នុងខេត្ត និងទីក្រុងមួយចំនួនដែលបាន ជ្រើសរើស នៅប្រទេសវៀតណាម។

[២០] នៅប្រទេសកម្ពុជា គេបានសង្កេតឃើញថា ជនល្មើសបច្ចឹមប្រទេស ច្រើនតែធ្វើការកេងប្រវ័ញ្ចនៅតាមចិញ្ចើមថ្នល់ ឬឆ្លៀតឱកាសកេងប្រវ័ញ្ច រីឯជនល្មើសកម្ពុជា និងជនជាតិអាស៊ីដទៃទៀតច្រើនតែធ្វើការកេងប្រវ័ញ្ចនៅតាមកន្លែងកំសាន្តនានា។ ជនល្មើសឆ្លៀតឱកាសសំដៅទៅជនរងគ្រោះដោយផ្ទាល់ រីឯជនល្មើសនៅអាស៊ី (រួមមានចិន ជប៉ុន និង តៃវ៉ាន់ជាដើម) ទំនងជាខំនៅឲ្យឆ្ងាយពីទីសាធារណៈ ហើយចាត់ឲ្យមេខ្យល់ជួយ និង/ឬទៅជួបកុមារនៅកន្លែងដែលបានកំណត់ទុកជាមុន ដូចជាសណ្ឋាគារ និងកន្លែងពេស្យា។ ឯកសារ Grilot (2005) ឯកសារ Putman-Cramer, C.(2005) ។

[២១] ឯកសារ ECPAT International (2008) ស្តីពី ការប្រយុទ្ធប្រឆាំងនឹងទេសចរណ៍បំពានផ្លូវភេទកុមារ ៖ សំណួរ ចម្លើយ ទំព័រទី ១២ ។

[២២] ឯកសាររបស់ Lanning, KV (2010) ស្តីពី អ្នកបៀតបៀនផ្លូវភេទកុមារ៖ ការវិភាគលើអាកប្បកិរិយា ៖ ចំពោះអ្នកមានវិជ្ជាជីវៈដែលស្រាវជ្រាវអំពីការកេងប្រវ័ញ្ចផ្លូវភេទ កុមារ កែសម្រួលលើកទី៥ ។ មជ្ឈមណ្ឌលជាតិ ដើម្បីកុមារបាត់ខ្លួន និងកុមាររងការបំពានផ្លូវភេទ ទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ក្នុងវែបសាយ http://www.missingkids.com/en_US/publications/NC70.pdf ចូលមើលចុងក្រោយ នៅថ្ងៃទី២៦ កក្កដា ២០១១ ទំព័រទី៣១ ។

ភាពដាច់ដោយឡែកមួយផ្សេងទៀតរបស់អ្នករំលោភបំពានផ្លូវភេទ ដែលត្រូវបានបង្ហាញនៅក្នុងការសិក្សាមួយរបស់ CEOP (មជ្ឈមណ្ឌលកេងប្រវ័ញ្ចលើកុមារ និងការការពារតាមបណ្តាញអ៊ីនធឺណិត[២៣]) បានផ្តល់វិធី កាន់តែដាច់ដោយឡែកពីគ្នា ដូចជា *ការឆ្លៀតឱកាស* (ឆក់យកឱកាសពីបរិស្ថានវិស្សមកាលដើម្បីរំលោភបំពានលើកុមារ) *ការរំលោភបំពានដោយខ្លួនឯង* (ធ្វើដំណើរទៅក្រៅប្រទេសជាមួយក្រុមជនរងគ្រោះជាកុមារ ដែលខ្លួនត្រូវការ) *ការស្វែងរកដោយរំពឹងទុក* (ធ្វើដំណើរទៅក្រៅប្រទេសនៅកន្លែងដែលគេប្រាប់ថា មានកុមារសម្រាប់រួមភេទ) *បណ្តាញជូនដំណឹង* (រៀបចំទុកជាមុនដើម្បីរំលោភបំពានលើកុមារនៅទីតាំងមួយជាក់លាក់) *ការរំលោភបំពានពីជនបរទេសដែលមកនៅ* (ការរំលោភបំពាន ពីជនបរទេសដែលមករស់នៅ ក្នុងប្រទេសកំពុងអភិវឌ្ឍ) *ការងារបន្ទំជាថៃទាំ* (អ្នកមាន វិជ្ជាជីវៈ និងបុគ្គលិកស្ម័គ្រចិត្ត ដែលរំលោភបំពានលើកុមារ ដែលខ្លួនធ្វើការជាមួយ) *ការរំលោភបំពានពីក្រៅប្រទេស តាមបណ្តាញអ៊ីនធឺណិត* (ប្រើប្រាស់បណ្តាញអ៊ីនធឺណិតដើម្បីបំពានផ្លូវភេទលើកុមារនៅក្រៅប្រទេស)[២៤]។ ទោះយ៉ាងណាក៏ដោយ ចាំបាច់ត្រូវចាំថា នៅក្នុងការដាក់ឲ្យនៅដាច់ដោយឡែកទាំងអស់ មនុស្សម្នាក់ៗ តែងតែមិនសមល្មមទៅនឹងប្រភេទណាមួយ ឬប្រភេទផ្សេងទៀតជានិច្ចឡើយ ហើយត្រូវចាំទៀតថា ការកេងប្រវ័ញ្ចដែលកើតឡើង អាចនឹងមានលក្ខណៈខុសៗគ្នាជាច្រើន។

គេបានបង្ហាញថា ការកេងប្រវ័ញ្ចផ្លូវភេទកុមារ អាចឲ្យគេមើលឃើញតិចជាងមុន នៅក្នុងប្រទេសថៃ និងប្រទេសកម្ពុជា។ ប៉ុន្តែ លក្ខណៈបែបនេះអាចជាការបង្ហាញថា ជោគជ័យនៃយុទ្ធនាការបង្កើនការយល់ដឹង បានជំរុញឲ្យការរំលោភបំពានផ្លូវភេទកុមារធ្លាក់ចូលទៅក្នុងសភាពលួចលាក់ បណ្តាលឲ្យមានការចូលរួមកាន់តែច្រើនពីអ្នកកេងប្រវ័ញ្ចដែលជាភាគីទីបី ដែលដើរតួជាអ្នកកណ្តាល រវាងជនរងគ្រោះ និងជនល្មើស។ លក្ខណៈបែបនេះ ក៏អាចជាផលវិបាកមួយដែរ ដែលបណ្តាលមកពីជនល្មើសបានប្រើប្រាស់បច្ចេកវិទ្យាថ្មីកាន់តែច្រើនឡើង (ទូរស័ព្ទចល័ត អ៊ីនធឺណិត ។ល។) ដើម្បីសម្រួលដល់ការទំនាក់ទំនងជាមួយជនរងគ្រោះរបស់ខ្លួន និងភាគីអ្នកស្វែងរក ជាភាគីទីបីរបស់ខ្លួន[២៥]។

មានមូលហេតុមួយចំនួនដែលអ្នកបំពានផ្លូវភេទកុមារ មានការចាប់អារម្មណ៍ចំពោះតំបន់អាស៊ីអាគ្នេយ៍ ដូចជាឱកាសនិយម បុព្វហេតុប្រើប្រាស់អាកប្បកិរិយាជា "ជំនួយ" ដល់កុមារ" ឬគ្រួសារ ក្នុងបញ្ហាសេដ្ឋកិច្ច និង ស្ថានភាពដែលខ្លួនបានដឹង ឬដែលពិតប្រាកដអំពីបញ្ហាការរួចទោស។ នៅក្នុងតំបន់ទាំងមូល កុមារា និងកុមារី គឺងាយរងគ្រោះចំពោះការកេងប្រវ័ញ្ចផ្លូវភេទដោយសារកត្តាផ្សេងៗគ្នា។ ការស្រាវជ្រាវ ដែលផ្តល់ឱកាសឲ្យចូលរួមនេះ ដែលត្រូវបានធ្វើឡើងដោយមានការចូលរួមពីកុមារី និងកុមារាចំនួន៤០០នាក់នៅឆ្នាំ២០០៧ និង២០០៨ បានធ្វើឲ្យយើងស្គាល់នូវកត្តាពិសេសៗមួយចំនួនដូចជា ភាពក្រីក្រ និងការមិនឲ្យតម្លៃ ព្រមទាំងកង្វះខាតការគាំទ្រពីគ្រួសារ អប់រំ ឱកាស និងការការពារ។ កត្តានីមួយៗរួមមានការរំលោភសេពសន្ថវៈ អំពើហឹង្សាក្នុងគ្រួសារ និង/ឬការប្រើប្រាស់គ្រឿងញៀនជាដើម[២៦]។

នៅទូទាំងពិភពលោក មានស្ត្រីជិត១នាក់ក្នុងចំណោមប្រាំនាក់ រីឯបុរសវិញគឺម្នាក់ក្នុងចំណោមដប់មួយនាក់ ដែលត្រូវទទួលរងការបំពានផ្លូវភេទកាលវ័យកុមារ[២៧]។ មានភស្តុតាងកាន់តែច្រើន អំពីការរំលោភបំពានផ្លូវភេទនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកនេះ ដែលបង្ហាញថា ចំពោះមនុស្សវ័យក្មេងជាច្រើននាក់មានបទពិសោធន៍ដំបូងដែលខ្លួនបានជួបប្រទះអំពីការរំលោភបំពានផ្លូវភេទ គឺការបង្ខំឲ្យរួមភេទ រីឯទិន្នន័យដែលបានប្រមូលផ្តុំនៅក្នុងតំបន់ទាំងមូល ជាទូទៅបង្ហាញថា កុមារា និងកុមារី គឺងាយរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ[២៨]។

នៅប្រទេសកម្ពុជា ការស្រាវជ្រាវបានបង្ហាញថា កុមារីដល់ទៅ៥១,២% និង កុមារាចំនួន ១,៩% បានប្រាប់ឲ្យដឹងថា ធ្លាប់ត្រូវបានគេបង្ខំឲ្យរួមភេទ[២៩]។ ការសិក្សាផ្សេងទៀតបានបង្ហាញថា កុមារចំនួន ១៦,១% បានប្រាប់ឲ្យដឹងអំពីបទពិសោធន៍ដោយផ្ទាល់ អំពីការប៉ះលើប្រដាប់ភេទរបស់ខ្លួនពីសំណាក់មនុស្សពេញវ័យ បន្ទាប់ពីខ្លួនមានអាយុ៩ឆ្នាំ ហើយកុមារ១,២% បានរាយការណ៍អំពីបទពិសោធន៍ដោយផ្ទាល់ចំពោះការរំលោភសេពសន្ថវៈលើកុមារ ពីសំណាក់មនុស្សពេញវ័យ[៣០]។

នៅប្រទេសថៃ មានកុមារ១១,៩% នៅក្នុងការស្រាវជ្រាវមួយ រាយការណ៍ថាបានជួបប្រទះ ការរំលោភបំពានផ្លូវភេទ[៣១] រីឯការសិក្សាមួយទៀតបង្ហាញថា អ្នកឆ្លើយតបចំនួន៥,៨% (៤,៩% ជានារីវ័យក្មេង និង៦,៥% ជាបុរសវ័យក្មេង) ដែលបានរាយការណ៍អំពីការជួបប្រទះនឹងការរំលោភបំពានផ្លូវភេទមុនពេលមានអាយុ១៦ឆ្នាំ[៣២]។ ជាទូទៅ ប្រេវ៉ាឡង់អាយុកាលនៃការរំលោភបំពានផ្លូវភេទ ទោះដោយការប៉ះក្តី ឬមិនប៉ះក្តី ដែលបានមកពីការជ្រើសរើសសំណាកប្រូបាប៊ីលីតេ ត្រូវបានរកឃើញថា មានកម្រិតពី៥,០%

[២៣] ប្រពន្ធ័ការពារការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមរយៈបណ្តាញអ៊ីនធឺណិត គឺជាផ្នែកមួយ នៃទីភ្នាក់ងារជាតិប្រឆាំងឧក្រិដ្ឋកម្មរបស់រដ្ឋាភិបាល UK។

[២៤] ឯកសារ Maalla M' jid, N.របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីការលក់ដូររបស់កុមារ ពេស្យាកម្មកុមារ និងរូបអាសអាភាសកុមារ ក្រុមប្រឹក្សាសិទ្ធិមនុស្ស មេរៀនទី២២ របៀបវីរៈបី A/HRC/22/54 (ថ្ងៃទី២៤ ធ្នូ ២០១២) ចេញជូនសារជាថ្មីដោយសារបញ្ហាបច្ចេកទេស នៅថ្ងៃទី២៣ មករា ២០១៣)។

[២៥] ឯកសារអង្គការសង្គ្រោះកុមារ (ខែកុម្ភៈ ២០០៩) ស្តីពីអ្នកបំពានផ្លូវភេទ គ្មានព្រំដែន ៖ ការស៊ើបអង្កេតស្តីអំពីការបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចលើកុមារ នៅប្រទេសថៃ កម្ពុជា និងភូមា ទាក់ទងនឹងការធ្វើដំណើរ និងទេសចរណ៍។

[២៦] អង្គការទស្សនៈពិភពលោកអន្តរជាតិ (គ្មានកាលបរិច្ឆេទ) ស្តីពីកុមារដឹងថាតើកុមារដទៃធ្វើបាបខ្លួនដូចម្តេច៖ កុមារ និងមនុស្សវ័យជំទង់ឡើងសម្តែងមតិអំពីការកេងប្រវ័ញ្ចផ្លូវភេទ។

[២៧] ឯកសារអង្គការ UNICEF-EAPRO (2012) ការធ្វើបាបដល់កុមារ ៖ ប្រេវ៉ាឡង់ ឧប្បត្តិហេតុ និងផលវិបាក នៅតំបន់អាស៊ីបូព៌ា និងតំបន់ប៉ាស៊ីហ្វិក ៖ ការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធទៅលើការស្រាវជ្រាវ។

[២៨] ឯកសារអង្គការ UNICEF-EAPRO (2012) ការធ្វើបាបដល់កុមារ ៖ ប្រេវ៉ាឡង់ ឧប្បត្តិហេតុ និងផលវិបាក នៅតំបន់អាស៊ីបូព៌ា និងតំបន់ប៉ាស៊ីហ្វិក ៖ ការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធទៅលើការស្រាវជ្រាវ។

[២៩] ឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡា អង្គការ UNICEF និងអង្គការ UNESCO (២០០៤) ស្តីពី ការអង្កេតជាតិស្តីពីអាកប្បកិរិយាគ្រោះថ្នាក់របស់ជំទង់នៅកម្ពុជា។ រាជធានីភ្នំពេញ ៖ ព្រះរាជាណាចក្រកម្ពុជា។ ការស្រាវជ្រាវប្រើប្រាស់សំណាកប្រូបាប៊ីលីតេ ដែលបានយោងនៅក្នុង UNICEF-EAPRO (2012) ស្តីពីការធ្វើបាបដល់ កុមារ៖ ប្រេវ៉ាឡង់ឧប្បត្តិហេតុ និងផលវិបាក នៅតំបន់អាស៊ីបូព៌ា និង តំបន់ប៉ាស៊ីហ្វិក ៖ ការ ពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធទៅលើការស្រាវជ្រាវ។

[៣០] ឯកសារ Miles, G. & Thomas, N. (2007) មានចំណងជើងថា "កុំយកពងមាន់ទៅជល់នឹងថ្ម" -សិទ្ធិកុមារ និងការប្រើប្រាស់អំពើហឹង្សានៅក្នុងប្រវត្តិសាស្ត្រ និងវប្បធម៌កម្ពុជា ។ ការពិនិត្យឡើងវិញស្តីពីការបំពានលើកុមារ លេខ ១៦ ទំព័រ៣៨៣-៤០០ និង ឯកសារ Tearfund (គ្មានកាលបរិច្ឆេទ) ស្តីពី សូមបញ្ឈប់ការប្រើអំពើហិង្សាមកលើយើងខ្ញុំ ៖ របាយការណ៍សង្ខេប។ ការសិក្សាស្រាវជ្រាវដំបូងបំផុតថ្នាក់ជាតិនៅក្នុងប្រេវ៉ាឡង់ និងការយល់ឃើញរបស់កុមារកម្ពុជា ចំពោះការប្រើអំពើហិង្សាលើកុមារ ក្នុងប្រទេសកម្ពុជា។ ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។ ឯកសាររបស់ Miles, G. & Varin.S. ការសិក្សាស្រាវជ្រាវប្រើប្រាស់សំណាកងាយ ដែលយោងនៅក្នុង UNICEF-EAPRO (2012) ស្តីពីការធ្វើបាបដល់កុមារ៖ ប្រេវ៉ាឡង់ឧប្បត្តិហេតុ និងផលវិបាក នៅតំបន់អាស៊ីបូព៌ា និងតំបន់ប៉ាស៊ីហ្វិក ៖ ការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធទៅលើការស្រាវជ្រាវ។

[៣១] ឯកសារ Chaopricha and Jirapramukpitak (2009) ស្តីពី "ការបំពានលើកុមារ និងអាកប្បកិរិយាប្រថុយ នឹងគ្រោះថ្នាក់ក្នុងមជ្ឈដ្ឋានយុវជន"។ សារព័ត៌មានរបស់មាគមន៍វេជ្ជសាស្ត្រនៅប្រទេសថៃលេខ 93(S7): S160-165។ ការស្រាវជ្រាវប្រើប្រាស់សំណាកប្រូបាប៊ីលីតេ ដែលបានយោងនៅក្នុង UNICEF-EAPRO (2012) ស្តីពីការធ្វើបាបដល់កុមារ៖ ប្រេវ៉ាឡង់ឧប្បត្តិហេតុ និងផលវិបាក នៅតំបន់អាស៊ីបូព៌ា និងតំបន់ប៉ាស៊ីហ្វិក ៖ ការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធទៅលើការស្រាវជ្រាវ។

[៣២] ឯកសារ Jirapramukpitak, Prince និង Harpham (2010) ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងបណ្តុំនៃផលប៉ះពាល់មិនល្អ ៖ សហគមន៍ នៃអំពើហឹង្សាក្នុងគ្រួសារ និង ផលប៉ះពាល់មិនល្អដល់សតិបញ្ញារបស់មនុស្សវ័យក្មេង។" វេជ្ជវិទ្យាផ្នែកវិកលចារិតសង្គម និងការសិក្សាពីរោគរាតត្បាតផ្នែកវិកលចារិត ។ ការស្រាវ ជ្រាវប្រើប្រាស់សំណាកប្រូបាប៊ីលីតេ ដែលបានយោងនៅក្នុង UNICEF-EAPRO (2012) ស្តីពីការធ្វើបាបដល់កុមារ៖ ប្រេវ៉ាឡង់ឧប្បត្តិហេតុ និងផលវិបាក នៅតំបន់អាស៊ីបូព៌ា និងតំបន់ប៉ាស៊ីហ្វិក ៖ ការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធទៅលើការស្រាវជ្រាវ ។

ទៅ៣២,៨% រីឯ ប្រេវ៉ាឡង់អាយុកាលនៃការរំលោភបំពានផ្លូវភេទទោះដោយការប៉ះក្ដី ឬមិនប៉ះក្ដី ដែលបានមកពីការជ្រើសរើសសំណាកប្រូបាប៊ីលីតេ ត្រូវបានរកឃើញថា មានកម្រិតពី១៧,១%ក្នុងមជ្ឈដ្ឋានមនុស្សជំទង់ ទៅ ៤៧% ក្នុងចំណោមស្ត្រី និងកុមារ ដែលត្រូវបានគេនាំទៅធ្វើជាស្រីពេស្យា[៣៣]។

ការស្រាវជ្រាវ ដែលផ្អែកលើសំណាកប្រហែល ដែលត្រូវបានធ្វើឡើងនៅក្នុងមជ្ឈដ្ឋានយុវជនចំនួន២៣៩៤នាក់ នៅជាយក្រុងហាណូយ ប្រទេសវៀតណាម បានបង្ហាញថា មានយុវជន ១,១% បានរាយការណ៍អំពីការដែលធ្លាប់ត្រូវបានគេរំលោភបំពានផ្លូវភេទ[៣៤]។ ចំនួននេះបានកើនឡើងដល់១៩,៧ភាគរយ នៃប្រេវ៉ាឡង់អាយុកាលនៃការបំពានផ្លូវភេទក្នុងមជ្ឈដ្ឋានសិស្សនៅមធ្យមសិក្សា ដែលត្រូវបានអង្កេតនៅក្នុងការស្រាវជ្រាវ ដែលផ្អែកលើសំណាកប្រូបាប៊ីលីតេ នៅជាយក្រុងហាណូយ និងជាយខេត្តហាយដុង ប្រទេសវៀតណាម[៣៥]។

ទោះបីជាការសិក្សាមួយចំនួនបានស្រាវជ្រាវ អំពីបញ្ហាធ្វើចំណាកស្រុករបស់កុមារ និងការជួញដូរកុមារក៏ដោយ[៣៦] មានកង្វះខាតទិន្នន័យមូលដ្ឋាននិងជាក់លាក់របស់ប្រទេស ស្ដីអំពីការរំលោភបំពានផ្លូវភេទកុមារ ( និងការធ្វើបាបចំពោះកុមារទូទៅ ) នៅសាធារណរដ្ឋប្រជាមានិតឡាវ។

ទស្សនៈ និងបទដ្ឋានវប្បធម៌មួយចំនួន ក៏អាចរួមចំណែកនៅក្នុងការរំលោភបំពានដែរ ។ ឧទាហរណ៍ បញ្ហាទំនាក់ទំនងរបស់ជនល្មើសនៅតាមមូលដ្ឋាន និងការខកខានមិនបានទទួលស្គាល់កុមារថាជាមនុស្សដែលមានសិទ្ធិ[៣៧]។ នៅក្នុងបរិស្ថាន ដែលតម្រូវឲ្យមានសេវាកម្មផ្លូវភេទ សម្រាប់មនុស្សពេញវ័យនៅតាមមូលដ្ឋាន និងមានការអត់ឱនចំពោះការរំលោភបំពានលើកុមារី និងកុមារាពីសំណាក់ជាតិរបស់ខ្លួន ដោយប្រើប្រាស់មនុស្សវ័យក្មេង ជាដៃគូរួមភេទ គឺជារឿងមួយខុសពីធម្មតានៅ ក្នុងក្រសែភ្នែកសាធារណជនទូទៅ ព្រោះថានេះគឺជាបទឧក្រិដ្ឋប្រឆាំងនឹងកុមារ ឬជាការបំពានលើសិទ្ធិកុមារ[៣៨]។

ដូចក្រុង Montgomery បានសង្កេតឃើញថា ៖

> *"ការទំលាក់ការស្ដីបន្ទោសឲ្យធ្ងន់ ទៅលើបុរសជនបរទេសណា ដែលប្រព្រឹត្ត អំពើផ្លូវភេទខុសច្បាប់ ដោយរំលោភបំពានលើកុមារបរិសុទ្ធ គឺមានលក្ខណៈងាយស្រួលច្រើនជាងការដែលត្រូវសម្លឹង មើលទៅស្ថានភាពមួយ នៅពេលការរំលោភបំពានផ្លូវភេទកុមារចេះតែកើតមានយូរមកហើយ ជានិច្ច និងបានក្លាយជារឿងធម្មតា និងមិនតែប៉ុណ្ណោះ ត្រូវធ្វើឲ្យក្លាយទៅជាទម្លាប់ទៀតនោះ[៣៩]។*

បើនិយាយទៅ ការរំលោភបំពានផ្លូវភេទកុមារបានកើតឡើងនៅក្នុងសង្គមណា ដែលយន្តការការពារកុមារមានសភាពទន់ខ្សោយ ឬមិនមានលក្ខណៈទូលំទូលាយ ។ ប្រព័ន្ធការពារកុមារគឺជាផ្នែកមួយនៃបរិស្ថានដែលនៅទីនេះ កុមារទទួលបានយ៉ាងពេញលេញ និងជាទីគាប់ចិត្ត នូវសិទ្ធិទទួលបានការថែទាំសុខភាព ការអប់រំ ជីវិតគ្រួសារ និងចំណុចអតិវឌ្ឍន៍ដទៃទៀតរបស់ខ្លួន ដើម្បីឈានទៅរកសក្ដានុពលភាពខ្ពស់បំផុត។ បំណងនេះ ត្រូវសម្រេចបាន តាមរយៈ ការពារកុមារកុំឲ្យមានគ្រោះថ្នាក់ ដោយត្រូវកាត់បន្ថយភាពងាយរងគ្រោះនិងគ្រោះថ្នាក់ ដូចជាកង្វះខាតនៃការជួយគ្រប់គ្រងកុមារ និងត្រូវពិនិត្យមើលមនុស្សពេញវ័យដែលធ្វើការជាមួយកុមារ ។ បំណងនេះអាចសម្រេចទៅបាន ដោយត្រូវធានាថា ប្រព័ន្ធការពារមានភាពរឹងមាំគ្រប់គ្រាន់ ដែលអាចធ្វើឲ្យយើងស្គាល់បានឆាប់រហ័ស នូវករណីដែលកុមារកំពុងឆ្ពោះទៅរកគ្រោះថ្នាក់ ហើយអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាព ចំពោះគ្រោះថ្នាក់នោះ មុនពេលវាធ្លាក់ចូលក្នុងសភាពមួយកាន់តែធ្ងន់ធ្ងរ។ នៅទីនោះ ប្រព័ន្ធបែបនេះមានលក្ខណៈខ្វះខាត ឬហួសពីការប្រើទៅហើយ ហើយក៏ពុំមានការយកចិត្តទុកដាក់ទៅលើអត្ថប្រយោជន៍ច្រើនបំផុតរបស់កុមារដែរ ដែលធ្វើឲ្យឱកាស និងភាពងាយរងគ្រោះ ចំពោះការរំលោភបំពានផ្លូវភេទកុមារ កើនឡើងកាន់តែច្រើន ។

ការស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើការយល់ឃើញដែលបានគ្រោងខាងលើ ស្ដីពីវិធីប្រើប្រាស់អាកប្បកិរិយារបស់ជនល្មើស ដែលគេធ្លាប់បានស្គាល់ ។ ការស្រាវជ្រាវនេះ ក៏ត្រូវបានធ្វើឡើងតាមរយៈការយល់ដឹងបានច្បាស់លាស់ទៅលើយន្តការល្អៗដើម្បីការពារកុមារ ហើយយន្តការទាំងនេះអាចធ្វើឲ្យយើងស្គាល់ពីករណីរំលោភបំពានផ្លូវភេទកុមារ និងអន្តរាគមន៍បានមុន ឬបានឆាប់រហ័ស បន្ទាប់ពីស្ថានភាពរំលោភបំពានបានកើតឡើង។ គំនិតផ្ដួចផ្ដើមធ្វើអន្តរាគមន៍ ត្រូវបានរៀបចំឡើងដោយយកចិត្តទុកដាក់ តាមរយៈការយល់ដឹងអំពីទិដ្ឋភាពថ្មីនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ នៃគម្លាតនៃការយល់ដឹង និងអាកប្បកិរិយាការពារជុំវិញការរំលោភបំពានផ្លូវភេទកុមារ ។



[៣៣] ឯកសារអង្គការ UNICEF-EAPRO (2012) ការធ្វើបាបដល់កុមារ ៖ ប្រេវ៉ាឡង់ ឧប្បទ្ទវហេតុ និងផលវិបាក នៅតំបន់អាស៊ីបូព៌ា និងតំបន់ប៉ាស៊ីហ្វិក ៖ ការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធទៅលើការស្រាវជ្រាវ ។

[៣៤] ឯកសារ Le and Blum (2009) ស្ដីពីផ្លូវភេទ មុនពេលរៀបការ និងការប្រើប្រាស់ស្រោមអនាម័យ ក្នុងមជ្ឈដ្ឋានយុវវ័យមិនទាន់រៀបការ ក្នុងប្រទេសវៀតណាម។ សារព័ត៌មានអន្តរជាតិស្ដីពីសុខភាពវេជ្ជសាស្ត្រ លេខ ២១(៣),ទំព័រ ១-១៤។ ការស្រាវជ្រាវប្រើប្រាស់ សំណាកប្រូបាប៊ីលីតេ ដែលបានយោងនៅក្នុង UNICEF-EAPRO (2012) ស្ដីពីការធ្វើបាបដល់កុមារ៖ ប្រេវ៉ាឡង់ឧប្បទ្ទវហេតុ និងផលវិបាក នៅតំបន់អាស៊ីបូព៌ា និងតំបន់ប៉ាស៊ីហ្វិក ៖ ការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធទៅលើការស្រាវជ្រាវ ។

[៣៥] ឯកសារ Nguyen, Dunne & Le (2010) ស្ដីពី "ពហុប្រភេទ នៃការធ្វើទុក្ខបុកម្នេញដល់សុខភាពបញ្ញាស្មារតីកុមារ និងក្មេងជំទង់ នៅប្រទេសវៀតណាម" ។ ព្រឹត្តិប័ត្ររបស់អង្គការសុខភាពពិភពលោកលេខ៨៧ ទំព័រ ២២-៣០ យោងនៅក្នុង UNICEF-EAPRO (2012) ស្ដីពីការធ្វើបាបដល់កុមារ៖ ប្រេវ៉ាឡង់ឧប្បទ្ទវហេតុ និងផលវិបាក នៅតំបន់អាស៊ីបូព៌ា និងតំបន់ប៉ាស៊ីហ្វិក ៖ ការពិនិត្យឡើងវិញ ជាលក្ខណៈប្រព័ន្ធទៅលើការស្រាវជ្រាវ។

[៣៦] ឯកសារ E.g. Phetsiriseng, I. (2003) ស្ដីពីការវាយតម្លៃដំបូង ទៅលើការជួញដូរកុមារ និងស្ត្រី ចំពោះការកេងប្រវ័ញ្ចកម្លាំងពលកម្ម នៅសាធារណរដ្ឋប្រជាមានិតឡាវ។ អង្គការ ILO-IPEC របស់សាធារណរដ្ឋប្រជាមានិតឡាវ ឬក្រសួងការងារ និងសុខុមាលភាពសង្គម នៃសាធារណរដ្ឋប្រជាមានិតឡាវ និង អង្គការ UNICEF (2004)។ ការបំពានពាក្យសន្យា ការបំផ្លាញក្ដីសុបិន ៖ ព័ត៌មានត្រួសៗការជួញដូរកុមារនៅសាធារណរដ្ឋប្រជាមានិតឡាវ ។

[៣៧] ឯកសារ O'Brian, M, Grillo, M and Barbosa, H (2008) ការកេងប្រវ័ញ្ចផ្លូវភេទកុមារ និងក្មេងជំទង់នៅក្នុងវិស័យទេសចរណ៍ ៖ ការរួមចំណែករបស់អង្គការ ECPAT អន្តរជាតិ ជាមួយនឹងសន្និបាតពិភពលោកលើកទី៣ ប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារ និងក្មេងជំទង់អង្គការ ECPAT អន្តរជាតិ ទំព័រទី១០។

[៣៨] ឯកសារ O'Brian, Grillo and Barbosa (2008) ការកេងប្រវ័ញ្ចផ្លូវភេទកុមារ និងក្មេងជំទង់ នៅក្នុងវិស័យទេសចរណ៍ ៖ ការរួមចំណែករបស់អង្គការ ECPAT អន្តរជាតិ ជាមួយនឹងសន្និបាតពិភពលោកលើកទី៣ ប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារ និងក្មេងជំទង់អង្គការ ECPAT អន្តរជាតិ ទំព័រទី១០។

[៣៩] ឯកសារ Montgomery, H (2001), Modern Babylon? កុមារដែលធ្វើជាពេស្យាចារនៅ ប្រទេសថៃ ឯកសារ Berghahn Books ទីក្រុងញូវយ៉ក ទំព័រទី៣២។

# បុព្វហេតុនៃការស្រាវជ្រាវ

យុទ្ធសាស្ត្រសំខាន់នៅក្នុងគម្រោងកុមារភាពផ្អែកបង្ការ នៅក្នុងការការពារ ការរំលោភបំពានផ្លូវភេទកុមារនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ គឺត្រូវលើកកម្ពស់ការផ្លាស់ប្តូរអាកប្បកិរិយាវិជ្ជមាន និងត្រូវបង្កើតបរិស្ថានជុំវិញមួយ ដែលបង្កើនលទ្ធភាពធ្វើឲ្យកុមារា និងកុមារីគេចផុត ពីជនល្មើសផ្លូវភេទ និងធានាឲ្យបានថា ឪពុកម្តាយ និងគ្រួសារ អ្នកកាន់ភារកិច្ច និងសមាជិកសហគមន៍អាចការពារកុមារបាន។ យុទ្ធសាស្ត្រនេះ ត្រូវបានអនុវត្តតាមរយៈអន្តរាគមន៍ទំនាក់ទំនង ដែលពាក់ព័ន្ធនឹងបរិបទវប្បធម៌ និងសង្គម របស់សហគមន៍គោលដៅ។ ដើម្បីទំនាក់ទំនងសារ ប្រកបដោយប្រសិទ្ធភាព តាមរយៈឧបករណ៍ និងអន្តរាគមន៍ដែលពាក់ព័ន្ធ កម្មវិធីនេះទាមទារឲ្យមានទម្រង់គំនិតជ្រាលជ្រៅ រួមទាំងការយល់ដឹងទៅលើគំនិតសំខាន់ៗ ឥរិយាបទ និងអាកប្បកិរិយា ដែលធ្វើឲ្យកុមារា និងកុមារីងាយរងគ្រោះ ដោយការរំលោភបំពានផ្លូវភេទ។ វាក៏តម្រូវឲ្យយើងយល់ឲ្យបានច្បាស់ថា តើកុមារងាយរងគ្រោះ គ្រួសារ និងសហគមន៍នានាអាចចូលទៅកាន់ប្រព័ន្ធផ្សព្វផ្សាយបានទូលំទូលាយ និងទទួលរងឥទ្ធិពលពីប្រព័ន្ធផ្សព្វផ្សាយក្នុងទម្រង់ខុសៗគ្នា ដូចម្តេចខ្លះ។ បើគ្មានព័ត៌មានទាំងនេះទេ ឪកាសចែកផ្សាយសារប្រកបដោយប្រសិទ្ធភាពតាមរយៈមណ្ដាញដែលពាក់ព័ន្ធ នឹងត្រូវពឹងផ្អែកលើការសន្មត់ផ្សេងៗ ដែលជាហេតុ បង្កឲ្យមានគ្រោះថ្នាក់គឺថាសារទាំងនេះ អាចនឹងត្រូវបាត់បង់ ឬអាចនឹងមិនបានទៅដល់ក្រុមគោលដៅ។ ការយល់ដឹងនេះក៏មានលក្ខណៈចាំបាច់នៅក្នុងការរៀបចំឧបករណ៍ សម្រាប់ជួយអន្តរាគមន៍ប្រកបដោយ ប្រសិទ្ធភាពដែរ ដែលឧបករណ៍ទាំងនោះពាក់ព័ន្ធទៅនឹងសហគមន៍មូលដ្ឋាន ហើយត្រូវបញ្ចូលគ្នា ជាលក្ខណៈវប្បធម៌ និងលក្ខណៈប្រព័ន្ធបានដោយងាយ និងប្រកបដោយនិរន្តរភាព។

# កម្មវត្ថុស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានគោលដៅបញ្ជ្រាបដល់គម្រោងកុមារភាពផ្អែកបង្ការ ស្តីពីចំណេះដឹង ឥរិយាបទ និងទង្វើរបស់សមាជិកសហគមន៍ (រាប់បញ្ចូលទាំងកុមារា កុមារី ញាតិសន្តានរបស់កុមារ និងអ្នកកាន់ភារកិច្ច) ដែលទាក់ទងនឹងការរំលោភបំពានផ្លូវភេទកុមារ រួមមានអ្នកធ្វើដំណើរ និងភ្ញៀវទេសចរ។ សំណួរស្រាវជ្រាវដ៏ជាក់លាក់ខាងក្រោមនេះ បានដឹកនាំការស្រាវជ្រាវ ។ នេះរាប់បញ្ចូលនៅក្នុងបរិបទនៃទេសចរណ៍ និងការធ្វើដំណើរ ៖

**១. តើចំណេះដឹង ឥរិយាបទ និងទង្វើនានានៅក្នុងសហគមន៍ មានទំនាក់ទំនងអ្វីខ្លះ ជាមួយនឹងការរំលោភបំពានលើកុមារ និង ការការពារកុមារ ?**

**២. តើមានទស្សនៈសំខាន់ៗ ឥរិយាបទ អាកប្បកិរិយា និងទង្វើនានាអ្វីខ្លះ ដែលបង្កឲ្យមានគ្រោះថ្នាក់ និង ភាពងាយរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ កុមារ ?**

**៣. តើមានឧបសគ្គ និងឱកាសសំខាន់ៗអ្វីខ្លះ នៅក្នុងការការពារពីការរំលោភបំពានផ្លូវភេទកុមារ ?**

**៤. តើធនធានដែលមានស្រាប់ យន្តការ និងបណ្តាញសំខាន់ៗ មានអ្វីខ្លះ ដើម្បីទំនាក់ទំនង ជូនដំណឹង ព្រមទាំងអប់រំកុមារ គ្រួសារ និងសហគមន៍ស្តីពីការបំពានផ្លូវភេទកុមារ ?**

ការស្រាវជ្រាវនៅសាធារណរដ្ឋប្រជាមានិតឡាវ ដែលគេបានធ្វើឡើងយឺតយ៉ាវជាងការស្រាវជ្រាវថ្នាក់ជាតិដទៃទៀតនោះ ក៏បានពិចារណាអំពីសំណួរបន្ថែមនេះដែរ ៖

**៥. តើប្រាក់ទិញទឹកចិត្ត រួមចំណែកអ្វីខ្លះនៅក្នុងការកេងប្រវ័ញ្ចលើកុមារ ? ហើយតើមាន ឧបសគ្គ និងឱកាសអ្វីខ្លះ សម្រាប់ឲ្យផ្អែកការពារ ឆ្លើយតបទៅនឹងកត្តាបែបនេះ ?**

## អ្នកឆ្លើយតប

យោងតាមទំហំនៃចម្ងល់នៅក្នុងការស្រាវជ្រាវ អ្នកឆ្លើយតបត្រូវបានសម្រាំងចេញជាបួនប្រភេទសំខាន់ៗគឺ៖

១. **កុមារី និងកុមារា ៖ អ្នកដែលកំពុងសិក្សា អ្នកដែលកំពុងប្រកបរបរ អ្នកដែលកំពុងរស់នៅតាមចិញ្ចើមថ្នល់ និងអ្នកដែលជាជនរងគ្រោះ នៃការរំលោភបំពានផ្លូវភេទ ដែលមានអាយុពី៨ដល់១៨ឆ្នាំ[៤០]។**

២. **អ្នកថែទាំ និងអ្នកជិតខាង ៖ ឪពុកម្តាយ ញាតិសន្តាន មិត្តភក្តិ និងមនុស្សវ័យស្របាលគ្នារបស់កុមារ ព្រមទាំងអ្នកលក់ដូរនៅតាមចិញ្ចើមថ្នល់។ ម្ចាស់ហាង ឬមនុស្សដទៃទៀត ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយ ឬស្គាល់កុមារដែលត្រូវបានសម្ភាស។**

៣. **អ្នកកាន់ភារកិច្ច ៖ គ្រូបង្រៀន មន្ត្រីប៉ូលីស អ្នកផ្តល់សេវាសុខភាព បុគ្គលិកសង្គមកិច្ច និងបុគ្គលិកមណ្ឌល ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយកុមារ ក្នុងលក្ខណៈជាការងាររបស់ខ្លួន។**

៤. **មន្ត្រី ៖ ជាបុគ្គលិកមកពីទីភ្នាក់ងាររដ្ឋាភិបាល អង្គការសង្គមស៊ីវិល ឬអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា។**

កុមារត្រូវបានជ្រើសរើស ជាប្រភពព័ត៌មានយ៉ាងសំខាន់ ហើយក៏មានការខិតខំប្រឹងប្រែងទំនាក់ទំនងទៅកាន់កុមារនៅក្នុងកាលៈទេសៈខុសៗគ្នា។ ពេលមានកន្លែងណាមួយ ដែលអាចធ្វើទៅបាន យើងបានសម្ភាសឪពុកម្តាយ និងអ្នកកាន់ភារកិច្ចរបស់កុមារដែលយើងទំនាក់ទំនងនោះ ដើម្បីបានប្រើប្រាស់វិធីបែងចែកទីកន្លែងជាបីដើម្បីអង្កេត។ មនុស្សដែលពាក់ព័ន្ធផ្សេងទៀត ដូចជាមន្ត្រីប៉ូលីស និងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀត ក៏ត្រូវសម្ភាសដែរ ដោយប្រើប្រាស់បញ្ជីសំណួរសម្ភាសន៍មិនរៀបរយ ឬតារាងប្រធានបទនានា។ យើងក៏បានប្រមូលករណីសិក្សានានា ជាពិសេសនោះ គឺបានមកពីបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ករណីសិក្សាទាំងនេះ ត្រូវបានប្រើប្រាស់ ដើម្បីកំណត់សេណារីយ៉ូខុសៗគ្នា សម្រាប់ការរំលោភបំពានផ្លូវភេទ។ នៅទីបំផុត អ្នកឆ្លើយតបជាកុមារ នៅក្នុងការសិក្សាស្រាវជ្រាវនេះ ក៏មានចំនួនច្រើនបំផុត។ លក្ខណៈបែបនេះ ហាក់ដូចជាបានមកពីវិធីសាស្ត្ររបស់អ្នកស្រាវជ្រាវដែរ ព្រោះនៅត្រង់ចំណុចនេះ កុមារបានចូលរួមនៅក្នុងការស្រាវជ្រាវតាមរយៈបទសម្ភាសន៍ជាលក្ខណៈក្រុមមនុស្សវាយតម្លៃ រីឯមនុស្សពេញវ័យវិញ ភាគច្រើន ត្រូវបានគេសម្ភាសម្នាក់ៗ។ ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងរវាងឆ្នាំ២០១១ និង២០១២។

## ការពិចារណាលើក្រមសីលធម៌

អ្នកស្រាវជ្រាវមានការប្រុងប្រយ័ត្នខ្ពស់ទៅតាមបទដ្ឋានត្រឹមត្រូវ ដើម្បីការពារសុវត្ថិភាព និងការសម្ងាត់របស់អ្នកឆ្លើយតប ដោយរាប់ទាំងត្រូវសុំការអនុញ្ញាតដើម្បីជួប និងសម្ភាសកុមារផង។ អ្នកស្រាវជ្រាវក៏បានប្រើប្រាស់ វិធានការច្បាស់លាស់ ដើម្បីចៀសវាងមិនឲ្យមានរបួស ទោះក្នុងវិធីណាក៏ដោយ ចំពោះកុមារដែលអាចនឹងទទួលរងផលប៉ះពាល់គ្រោះថ្នាក់ ដែលបណ្តាលមកពីការសិក្សាស្រាវជ្រាវនេះ។ ឧទាហរណ៍ អ្នកស្រាវជ្រាវទាំងអស់ បានសង្កេតទៅលើគោលនយោបាយការពារកុមាររបស់អង្គការទស្សនៈពិភពលោក និងរដ្ឋាភិបាលអូស្ត្រាលី។ មុនពេលចូលរួម គម្រោងកុមារភាព ផ្អែកបង្ការទទួលបានការសំអាងយ៉ាង ហោចណាស់ចំនួនពីរ សម្រាប់អ្នកស្រាវជ្រាវនីមួយៗ ព្រមទាំងលិខិតបញ្ជាក់កិរិយាមាយាទ ពីប៉ូលីស ដើម្បីធានានូវការការពារកុមារ។ អ្នកសម្របសម្រួលនៅក្នុងការស្រាវជ្រាវ ដែលបាន រស់នៅក្រៅប្រទេសដែលរស់នៅបច្ចុប្បន្នអស់រយៈពេលជាយូរ ក៏បានផ្តល់នូវសេចក្តីសំអាងដើម្បីបញ្ជាក់ ពីកិរិយាមាយាទល្អ ពីប៉ូលីសនៅក្នុងប្រទេសកំណើតរបស់ខ្លួនដែរ ព្រមទាំងប្រធានអង្គការក្រៅរដ្ឋាភិបាល ដែលខ្លួនបានធ្វើការជាមួយកន្លងមក។ នៅក្នុងសិក្ខាសាលាត្រៀម មានការយកចិត្តទុកដាក់ច្រើនទៅលើរបៀបសង្កេតគោលនយោបាយ ក្នុងអំឡុងពេលចុះធ្វើការ ដល់ទីកន្លែង និងទៅលើកិច្ចការដែលត្រូវធ្វើ ប្រសិនបើជួបប្រទះករណីរំលោភបំពានជាក់ស្តែង។ នៅក្នុងស្ថានភាពបែបនេះ អ្នកស្រាវជ្រាវត្រូវ ទំនាក់ទំនងការិយាល័យរបស់អង្គការទស្សនៈពិភពលោកនៅមូលដ្ឋាន ( ដែលនឹងអនុវត្តពិធីការការពារកុមារ នៅពេលបន្ទាប់ ) ឬទីភ្នាក់ងារការពារកុមារដទៃទៀត។

[៤០] ឯកសារបែងចែកកុមារទៅតាមក្រុមអាយុ និងសំណួរដែលត្រូវសួរមានលក្ខណៈខុសគ្នាទៅតាមទីកន្លែងសិក្សាស្រាវជ្រាវនីមួយៗ។

ដោយផ្អែកលើ (១) ភាពធ្ងន់ធ្ងរនៃករណីរំលោភបំពាន (២) តើការរំលោភបំពានកំពុងបន្តឬទេ? និង (៣) ទស្សនៈរបស់កុមារ នោះគេនឹងត្រូវចាត់វិធានការជាក់លាក់ ។ លក្ខណៈនេះ បង្កើតជាវិធីមួយដ៏សមស្រប ព្រោះថា ក្នុងពេលកំពុងស្រាវជ្រាវ គេបានរកឃើញថាមានករណីរំលោភបំពានជាច្រើនដែលគេសង្ស័យ និងករណីរំលោភបំពានជាក់ស្តែង ហើយករណីទាំងនេះ ក៏ត្រូវបានគេជូនដំណឹងដល់ទីភ្នាក់ងារនានា ដែលទទួលខុសត្រូវ ។

#### កិច្ចព្រមព្រៀងស្តីពីទង្វើនៃក្រមសីលធម៌ ជាមួយអ្នកស្រាវជ្រាវ

**អ្នកស្រាវជ្រាវទាំងអស់ បានចុះហត្ថលេខ និងមានការតាំងចិត្តក្នុងការសង្កេតពិធីការការពារកុមាររបស់អង្គការទស្សនពិភពលោកប្រទេសអូស្ត្រាលី និងទីភ្នាក់ងារពាក់ព័ន្ធរបស់ខ្លួន។ គេបានព្រមព្រៀងគ្រប់ពេលវេលាថា ចំពោះករណីនានា ដែលកុមារមានយុក្រោម១៦ឆ្នាំ ត្រូវមានការអនុញ្ញាតច្បាស់លាស់ពីឪពុកម្តាយ អ្នកថែទាំ (គ្រូបង្រៀន បុគ្គលិកសង្គមកិច្ចជាដើម) ដើម្បីទៅជួបអ្នកស្រាវជ្រាវ។ ចំពោះច្បាប់នេះ អាចនឹងមានករណីលើកលែង ក្នុងករណីពុំអាចមានឪពុកម្តាយ ឬអ្នកថែទាំសម្រាប់ទំនាក់ទំនង (ឧទាហរណ៍ ក្នុងករណីកុមារតាមចិញ្ចើមថ្នល់)។ កុមារដែលមានអាយុ១៦ឆ្នាំ ឬចាស់ជាងនេះ ត្រូវសម្តែងការព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដើម្បីជួបជាមួយអ្នកស្រាវជ្រាវ។ ការជួបជាមួយកុមារម្នាក់ៗ ត្រូវនឹងត្រូវធ្វើឡើងតែនៅតាមទីសាធារណៈប៉ុណ្ណោះ។ នៅកន្លែងណាដែលត្រូវជួបនៅក្នុងបន្ទប់ ត្រូវចំហទ្វារ។ នៅទីណាដែលអាចធ្វើទៅបាន អ្នកថែទាំ ឬអាជ្ញាធរមូលដ្ឋានមិនគួរមានវត្តមាននៅក្នុងការសម្ភាសនានាឡើយ ប៉ុន្តែប្រសិនបើពួកគេទទូចសុំឲ្យមាននោះ អ្នកស្រាវជ្រាវមិនគួរជជីកសួរនាំអំពីបញ្ហាផ្ទាល់ខ្លួន ឬកិច្ចការសម្ងាត់ដែលអាចមាននោះ ដើម្បីរៀបចំកុមារសម្រាប់ការពិភាក្សា ។**

# ដែនកំណត់

គេរកឃើញថា រយៈពេលមួយសប្តាហ៍ ដើម្បីធ្វើការស៊ើបអង្កេតទៅលើបញ្ហានានា នៅកន្លែងស្រាវជ្រាវនីមួយៗ គឺខ្លីពេក ជាពិសេសបើគិតទៅលើពេលធ្វើដំណើរ និងដំណើរការនៃការរៀបចំគម្រោងបរិច្ឆេទណាត់ជួបជាមួយមនុស្សដែលពាក់ព័ន្ធ។ ពេលវេលាដែលមានសម្រាប់ ឆ្ពោះទៅកាន់ក្រុមគោលដៅ និងវិធីដែលអាច ប្រើប្រាស់បាន ជាពិសេសការអង្កេត និងវិធីត្រៀម ត្រូវមានកម្រិត គឺដូចគ្នាទៅនឹងសមត្ថភាពតាមដានលទ្ធផល និងការបែងចែកទីកន្លែងជាបីដើម្បីអង្កេតដូច្នេះដែរ។

ការអំឡុងពេល នាំឲ្យមានការជ្រើសរើសគំរូសម្រាប់ស្រាវជ្រាវ។ អ្នកស្រាវជ្រាវមិនអាចនឹងសម្រិតសម្រាំងជម្រើសរបស់ខ្លួនបានឡើយ អំពីមនុស្សដែលត្រូវសម្ភាសជាមួយក្រុមគោលដៅ។ លើសពីនេះ គេពិបាកនឹងទំនាក់ទំនង និងសម្ភាសជាមួយក្មេងប្រុសបរបរណាស់ នៅពេលម៉ោងធ្វើការ ភាគច្រើនជាពេលយប់។ កុមារដែលរស់នៅតាមចិញ្ចើមថ្នល់ ក៏ពិបាកស្វែងរក និងសម្ភាសដូចគ្នាដែរ។ ផ្ទុយទៅវិញ ការសម្ភាសសិស្សផ្តល់នូវភាពងាយស្រួលច្រើន។ ហេតុនេះហើយ ការសិក្សាស្រាវជ្រាវអាចមានភាពលំអៀង ទៅខាងចំណេះដឹង ឥរិយាបទ និងទង្វើសិស្សសាលា។ គ្រូបង្រៀននៅតាមសាលាទទួលខុសត្រូវនៅក្នុងការដាក់អ្នកចូលរួមជាកុមារ ទៅក្នុងក្រុមមនុស្សវាយតម្លៃ ហើយលក្ខណៈបែបនេះក៏អាចជះឥទ្ធិពលលើទិន្នន័យផងដែរ។ ឧទាហរណ៍ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម មានតែសិស្សពូកែបំផុតប៉ុណ្ណោះ (និងឪពុកម្តាយរបស់គាត់) ត្រូវបានជ្រើសរើសមកធ្វើសម្ភាសន៍ តាមរយៈគ្រូបន្ទុកថ្នាក់ដែលគេបានកំណត់។ សិស្សទាំងឡាយសុទ្ធតែបានដឹង អំពីតួនាទីរបស់ខ្លួនដែលតំណាងឲ្យសាលា និងអាចផ្តល់ព័ត៌មានបានតិចជាងសិស្សដែលសិស្សរៀនវិជ្ជាជីវៈ និងអ្នកលក់/ក្មេងតាមចិញ្ចើមថ្នល់។ លើសពីនេះទៅទៀត នៅរដូវដែលមានភ្ញៀវទេសចរមកលេងតិច នៅក្នុងតំបន់ មានន័យថាសមត្ថភាពទំនាក់ទំនងជាមួយ និងសង្កេតក្មេងប្រុសបរការងារ អាចនឹងបានរងនូវផលប៉ះពាល់។

អ្នកស្រាវជ្រាវពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីបង្កើតទំនុកចិត្តជាមួយអ្នកឆ្លើយតបឡើយ នេះមានន័យថាបញ្ហានានាមិនត្រូវបានរកឃើញដោយលក្ខណៈស៊ីជម្រៅច្រើន ជាងការដែលប្រសិនគេបានបង្កើត

ទំនាក់ទំនងជិតស្និទ្ធដ៏រឹងមាំជាងនេះឡើយ។ នេះគឺជាករណីជាក់លាក់ ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងថៃ ព្រោះអ្នកស្រាវជ្រាវនៅទីនោះគឺទើបតែបានស្គាល់កន្លែងស្រាវជ្រាវជាលើកដំបូងទេ។ កត្តាលើកកម្ពស់មួយ អាចនឹងក្លាយជារឿងមួយដែលក្រុមប្រទេសនានា បានបញ្ចូលអ្នកស្រាវជ្រាវជានារីដែលមានបទពិសោធន៍ ដែលប្រហែលជាបានបង្កលក្ខណៈងាយស្រួល ក្នុងការបង្កើតទំនាក់ទំនងជាមួយកុមារ។ ការសម្ភាសកុមារដែលបានក្លាយជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទហើយនោះ គឺមិនអាចធ្វើបានឡើយនៅគ្រប់ទីកន្លែងទាំងអស់ ព្រោះថា ជារឿយៗ កុមារទាំងនេះ នៅតែស្ថិតក្នុងដំណើរការសង្គ្រោះ ហើយវានឹងបានក្លាយទៅជាការប្រឆាំងទៅនឹងបទដ្ឋានការពារកុមារទៅវិញ។

ជារឿយៗ គេមានការលំបាកច្រើន នៅក្នុងការទទួលបានការឆ្លើយតបដោយលម្អិតពីមនុស្ស ពេញវ័យជាងកុមារ។ ឧទាហរណ៍ នៅកន្លែងសិក្សាស្រាវជ្រាវក្នុងប្រទេសកម្ពុជា ជួនកាល សំណួរដោយផ្ទាល់ដែលពាក់ព័ន្ធ នឹងចំណេះដឹងរបស់អ្នកកាន់ភារកិច្ចស្តីពីការរំលោភបំពានផ្លូវភេទកុមារ ត្រូវបានគេស្គាល់ជាស្រេចថា ជាការប្រឈមមុខចំពោះអំណាចរបស់ខ្លួន ហើយរួមជាមួយគ្នានេះ ក៏មានគ្រោះថ្នាក់នៃការ "បាក់មុខ" ដែរ ប្រសិនបើគេមិនដឹងចម្លើយត្រឹមត្រូវ។ ឪពុកម្តាយជាច្រើនមានភាពមមារញឹកពេកហើយជាមួយនឹងជីវភាពរស់នៅរបស់ខ្លួន គឺមិនអាចចូលរួមការសម្ភាសបានទេ។ ចំពោះមនុស្សដែលចូលរួមមានច្រើននាក់ណាស់ ដែលមិនបានទទួលស្គាល់ អំពីការយល់ដឹងទៅ លើរឿងហេតុរំលោភបំពាននៅក្នុងមូលដ្ឋានខ្លួន។ នេះគឺប្រហែលបណ្តាលមកពីការមិនចង់ពិភាក្សា ពីបញ្ហាបុគ្គលផ្ទាល់ខ្លួន ព្រោះខ្លាចអ្នកជិតខាងសើចចំអក។ អ្នកស្រាវជ្រាវក៏បានជួបប្រទះការលំបាកក្នុងការប្រមូលព័ត៌មានផងដែរ លើបញ្ហាទ្រឹស្តី ឬនិក្ខេបបទផ្សេងៗ ( ដូចជាគំនិតជាដើម ) ជាពិសេស ជាមួយក្រុមជនជាតិដើម ។ ព័ត៌មាននេះ មានលក្ខណៈលម្អិតច្រើនជាង ទាក់ទងទៅនឹងព្រឹត្តិការណ៍ពិតៗ។



នៅទីក្រុងប៉ាតាយ៉ា និងឈាងម៉ៃ ប្រទេសថៃ និងទីក្រុងហូជីមិញ ប្រទេសវៀតណាម មន្ត្រីរដ្ឋាភិបាលខ្លះ និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលចំនួន ក៏ពិបាកដូចគ្នាដែរ ក្នុងការបង្ហាញអំពីព័ត៌មាន ដែលគេដឹងថាត្រូវដោះស្រាយជាចាំបាច់នោះ ។ អ្នកនៅក្នុងហៃ ផុង ប្រទេសវៀតណាម មានភាពស្មោះត្រង់ច្រើនជាងគេនៅក្នុងការឆ្លើយតបរបស់ខ្លួន ។ លើសពីនេះទៅទៀត ក្នុងភូមិមួយ នៅសាធារណរដ្ឋប្រជាមានិតឡាវ សមាជិកជាន់ខ្ពស់ម្នាក់ របស់ក្រុមដឹកនាំបដិវត្តន៍ឡាវ ត្រូវបានមន្ត្រីសាលាស្រុកចាត់តាំងឲ្យជួយក្រុមស្រាវជ្រាវ ។

ទោះបីជាទំហំមានកំណត់ នៃការស្រាវជ្រាវនេះ ការពារមិនឲ្យមានភាពទូទៅ ដែលហួសពីកន្លែងស្រាវជ្រាវនោះក៏ដោយ ការសិក្សានេះ បានបង្កើតឲ្យមានធនធានព័ត៌មាន និងបានធ្វើឲ្យយើងស្គាល់ពីចំនួន នៃការប្រែប្រួលដែលគួរឲ្យកត់សម្គាល់បំផុត។

# ទីកន្លែងស្រាវជ្រាវ

កត្តានានាដែលបានប្រើប្រាស់សម្រាប់ជ្រើសរើសទីកន្លែងស្រាវជ្រាវ មានដូចតទៅ៖(ក) ទីនោះគឺជាគោលដៅភ្ញៀវទេសចរ និង (ខ) ជាកន្លែងដែលអាចទៅដល់បាន។ ទាំងនេះក៏ជាទីកន្លែង ដែលត្រូវបានជ្រើសរើសសាកល្បងធ្វើជាគោលដៅ សម្រាប់គម្រោងកុមារភាពផ្អែកបង្ការ ដើម្បីចាប់ផ្តើមសកម្មភាពសហគមន៍។ ទីកន្លែងខ្លះ ត្រូវបានជ្រើសរើសតាមសំណើររបស់អាជ្ញាធរដៃគូ ឧទាហរណ៍ ខេត្តមណ្ឌលគីរី ប្រទេសកម្ពុជា ត្រូវបានជ្រើសរើសដោយក្រសួងទេសចរណ៍របស់ប្រទេសកម្ពុជា។ ការិយាយល័យរបស់ អង្គការទស្សនៈពិភពលោកដែលមានទីតាំងនៅក្នុងប្រទេសនីមួយៗបានរាយការណ៍អំពីទិដ្ឋភាពនៃ ព័ស្តុភារស្រាវជ្រាវ និងការចូលទៅកាន់ទស្សនិកជនគោលដៅនៅទីណាដែលអាចធ្វើទៅបាន។ ក្នុងចំណោមកន្លែងស្រាវជ្រាវចំនួនប្រាំបី មានបីកន្លែង ដែលស្ថិតនៅកៀកនឹងគម្រោងផ្អែកលើសហគមន៍ របស់អង្គការទស្សនៈពិភពលោក។ ក្នុងលក្ខណៈបែបណាក៏ដោយ កន្លែងស្រាវជ្រាវទាំងនេះ មិនគួរត្រូវ បានចាត់ទុកជាតំណាងនៃគោលដៅទេសចរណ៍ទាំងឡាយនៅក្នុងប្រទេសនីមួយៗឡើយ។



# ប្រទេសកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា មានទីតាំងស្ថិតនៅចន្លោះប្រទេសថៃ វៀតណាម និងឡាវ។ នៅឆ្នាំ២០១២ គេបានប៉ាន់ស្មានថា ចំនួនប្រជាជនក្នុងប្រទេសកម្ពុជាមានចំនួនប្រមាណជា ១៤,៨៦លាននាក់[៤១]។ ៩០%នៃប្រជាជនទាំងនេះ មានអំបូរជាជនជាតិខ្មែរ។ ក្រុមជនជាតិភាគតិចដទៃទៀត មានដូចជា ចិន វៀតណាម កុលសម្ព័ន្ធភ្នំ ចាម និងឡាវ[៤២]។ ទោះបីជាមានការរីកចម្រើនបន្តិចម្តងៗក៏ដោយ ប្រទេសកម្ពុជា នៅតែជាប្រទេសមួយក្រីក្របំផុតដែរនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ ដោយមានចំណូលជាតិសរុប (GNI) ក្នុង១នាក់ ៨៨០ ដុល្លារអាមេរិកហើយ២០,៥% នៃប្រជាជនទាំងនេះគឺរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ[៤៣]។ ប្រជាជនកម្ពុជាមួយភាគធំ ខ្វះខាតការអប់រំ និងជំនាញវិជ្ជាជីវៈ ជាពិសេស អ្នកនៅជនបទ ជាទីដែលមាន ប្រជាជនជាង៨០%កំពុងរស់នៅ។

ធនធានធម្មជាតិ និងកន្លែងប្រវត្តិសាស្ត្រ បានធ្វើឲ្យប្រទេសកម្ពុជាក្លាយជាទីកន្លែងទាក់ទាញ ភ្ញៀវទេសចរ ឲ្យទៅកំសាន្ត។ នៅឆ្នាំ២០១៣ ប្រទេសកម្ពុជា ទទួលបានភ្ញៀវទេសចរអន្តរជាតិ ដែលមកដល់ចំនួន ៤,២លាននាក់ គឺកើនឡើង១៨%ច្រើនជាងឆ្នាំ២០១២។ ក្រុមអ្នកដែលមកកំសាន្តធំៗបំផុត ចំនួនប្រាំមួយ សុទ្ធតែជាភ្ញៀវមកពីតំបន់អាស៊ី។ ភ្ញៀវវៀតណាមដែលធ្វើដំណើរមកប្រទេសកម្ពុជា មាន ចំនួន២០% ហើយក៏មានភ្ញៀវចិន កូរ៉េ និងសាធារណរដ្ឋប្រជាមានិតឡាវផងដែរ ដែលប្រទេសនីមួយៗមានភ្ញៀវមក កំសាន្តប្រមាណ ជា១០%។ ចំណូលដែលទទួលបានពីវិស័យទេសចរណ៍សរុបជាទឹកប្រាក់មានចំនួន ប្រហែល ជា ២៥៤៧លានដុល្លារនៅឆ្នាំ២០១៣[៤៤] ហើយវិស័យនេះ គឺជាឧស្សាហកម្មដ៏សំខាន់សម្រាប់ ប្រទេសកម្ពុជា ដែលរកចំណូលបាន១០% នៃផលិតផលក្នុងស្រុកសរុប (GDP)[៤៥]។

តាមរបាយការណ៍ កត្តាប្រវត្តិសាស្ត្រ និងរចនាសម្ព័ន្ធមួយចំនួន បានរួមចំណែកនៅក្នុងភាពងាយរងគ្រោះ របស់កុមារ ដោយសារការរំលោភបំពានផ្លូវភេទនៅក្នុងប្រទេសកម្ពុជារាប់បញ្ចូលទាំងការកើនឡើងយ៉ាង ឆាប់រហ័ស នៃឧស្សាហកម្មផ្លូវភេទ[៤៦] ការអភិវឌ្ឍសេដ្ឋកិច្ចមិនស្មើគ្នា ការផ្តល់សេរីភាពផ្នែកសេដ្ឋកិច្ច និងកំណើនឧស្សាហកម្មទេសចរណ៍[៤៧]។ ទោះបីជាជនល្មើសផ្លូវភេទកុមារ ភាគច្រើន គឺជាអ្នកនៅក្នុងស្រុក ក៏ដោយ (ករណីដូចជានៅក្នុងប្រទេសណាមួយ[៤៨]) ទំហំដ៏ធំនៃករណីរំលោភបំពានផ្លូវភេទកុមារពី ជនល្មើសជាអ្នកធ្វើដំណើរ នៅក្នុងប្រទសកម្ពុជា បើគិតលើទំនាក់ទំនងចំនួនប្រជាជន និងការបើកព្រំដែន ទេសចរណ៍អន្តរជាតិក្នុងពេលថ្មីៗនេះនៅពាក់កណ្តាលទសវត្សរ៍ទី៩០ បានធ្វើឲ្យប្រទេសនេះក្លាយជា គោលដៅដ៏ធំមួយរបស់ជនល្មើស[៤៩]។ ជារឿយៗ តាមសេចក្តីរាយការណ៍ កំណើនចំនួនភ្ញៀវមកកំសាន្ត នៅប្រទេសកម្ពុជា ដែលសង្ឃឹមថា ពេស្យាកម្មមានតម្លៃថោក ស្រួលរកបានកុមារ និង មិនមានទោស[៥០]។

យោងតាមអង្គការក្រៅរដ្ឋាភិបាលមួយគឺ សកម្មភាពដើម្បីកុមារ (APLE) ការកេងប្រវ័ញ្ចផ្លូវ ភេទកុមារ នៅក្នុងប្រទេសកម្ពុជា ជាធម្មតាកើតឡើងនៅក្នុងផ្នែកណាមួយនៅក្នុងផ្នែកទាំងបីគឺ៖ (១) ការកេងប្រវ័ញ្ច ផ្នែកលើកន្លែងកំសាន្ត ដែលសម្រួលដល់ការកំសាន្តផ្លូវភេទ និងដែលភ្ញៀវបុរសជាជនជាតិកម្ពុជា និងអាស៊ីដទៃទៀត តែងទៅលេងញឹកញាប់ ដោយអ្នកទាំងនេះ គឺជាជនល្មើសដោយស្ថានភាព ដែលចូល ចិត្តជនរងគ្រោះជាកុមារី (២) ការកេងប្រវ័ញ្ចតាមចិញ្ចើមថ្នល់ ជាទីដែលអ្នករំលោភបំពានផ្លូវភេទ ឬ មេអណ្តើកសំដៅទៅរកកុមារ នៅក្នុងទីសាធារណៈ ហើយជារឿយៗធ្វើបែបនេះ គឺជាសកម្មភាពរបស់ ភ្ញៀវទេសចរបរទេស និងជនបរទេសដែលមកធ្វើការ ដែលជនទាំងនេះ គឺជាជនល្មើសដោយរើសមុខ ហើយនិយមជនរងគ្រោះជាកុមារា និង (៣) ការកេងប្រវ័ញ្ចផ្នែកលើស្ថាប័ន ជាទីដែលបុគ្គលម្នាក់ៗ ប្រើប្រាស់ស្ថាប័នដែលមានគោលដៅផ្តល់អត្ថប្រយោជន៍ដល់សុខមាលភាពកុមារ ដើម្បីបានចូលទៅកាន់ បណ្តុះអារម្មណ៍ផ្លូវភេទ និង/ឬកេងប្រវ័ញ្ចផ្លូវភេទកុមារ ហើយហាក់ដូចជា អ្វីដែលជាទីពេញនិយម របស់ជនល្មើសផ្លូវភេទកុមារជាជនបរទេស ។ លើសពីនេះ មូលដ្ឋានទិន្នន័យរបស់ អង្គការ APLE បានបង្ហាញថា អ្នកបំពានផ្លូវភេទកុមារ ដែលមាន២៦សញ្ជាតិផ្សេងៗគ្នា (រាប់បញ្ចូលទាំង ប្រជាជន កម្ពុជា៤១% អាមេរិកកាំង ១២,៥% វៀតណាម ៩% និងបារាំង ៨,៧% និងអង់គ្លេស ៦,៣%)។ បើដក អ្នកសមគំនិតចេញ ជនល្មើសជាបុរស មានចំនួន១០០% ក្នុងគ្រប់ករណីទាំងអស់ដែលបានកំណត់[៥១]។

- ## ក្រុងសៀមរាប និង ឃុំពួក

ខេត្តសៀមរាប ត្រូវបានគេស្គាល់ថា ជាទីប្រជុំនៃប្រាសាទបុរាណគឺប្រាសាទអង្គរវត្តដែលអង្គការ UNESCO បានទទួលស្គាល់ថា ជាកេរដំណែលពិភពលោក។

[៤១] ឯកសារធនាគារពិភពលោក ស្តីពីសូចនាករ អភិវឌ្ឍន៍តាមអ៊ីនធឺណិត ៖ ប្រទេសកម្ពុជា ក្នុងវែបសាយ http://data.worldbank.org/country/cambodia ចូលមើលចុងក្រោយ នៅថ្ងៃទី២៣ មេសា ២០១៤ ។

[៤២] ឯកសាររបស់នាយកដ្ឋានរដ្ឋនៃសហរដ្ឋអាមេរិក (ថ្ងៃទី២៨ មករា ២០១១)៖ កំណត់សម្គាល់ស្តីពី ព្រឹត្តិការណ៍ជុំវិញ ៖ ប្រទេសកម្ពុជា ក្នុងគេហទំព័រ http://www.state.gov/r/pa/ei/bgn/2732.htm ចូលមើលចុងក្រោយនៅថ្ងៃទី២៦ កក្កដា ២០១១។

[៤៣] ឯកសារវាយតម្លៃសម្រាប់ឆ្នាំ២០១២ និង ឆ្នាំ២០១១ របស់ធនាគារពិភពលោក ស្តីពី សូចនាករ អភិវឌ្ឍន៍តាមអ៊ីនធឺណិត ៖ ប្រទេសកម្ពុជា ក្នុងវែបសាយ http://data.worldbank.org/country/cambodia ចូលមើលចុងក្រោយ នៅថ្ងៃទី២៣ មេសា ២០១៤ ។

[៤៤] ក្រសួងទេសចរណ៍នៃប្រទេសកម្ពុជា ។ វែបសាយ http://www.tourismcambodia.org/images/mot/

statistic_reports/tourism_statistics_annual_report_2013.pdf ចូលមើលចុងក្រោយ នៅថ្ងៃទី១០ មេសា ២០១៤។

[៤៥] ឯកសាររបស់ក្រុមប្រឹក្សាធ្វើដំណើរ និង ទេសចរណ៍ពិភពលោក ឆ្នាំ ២០១៤ ៖ របាយការណ៍ ស្តីពីផលប៉ះពាល់នៃសេដ្ឋកិច្ច ប្រទេសកម្ពុជា វែបសាយ http://www.wttc.org/site_media/uploads/downloads/cambodia2014.pdf ចូលមើលចុងក្រោយ នៅថ្ងៃទី១៧ មេសា ២០១៤ ។

[៤៦] តាមរបាយការណ៍បានបង្ហាញថា វត្តមាន នៃបុគ្គលិក អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការ សហប្រជាជាតិប្រចាំនៅកម្ពុជា UNTAC) ពីឆ្នាំ១៩៩១ ដល់១៩៩៣ បាន បង្កើតនូវតម្រូវ ការសេវាផ្លូវភេទនៅក្នុងបរិស្ថានមួយ ដែល មានកំហិត នយោបាយកាន់តែតិច។ ក្រោយពេលដែលបុគ្គលិក UNTAC បានដកចេញទៅនៅឆ្នាំ១៩៩៣ ឧស្សាហកម្ម អាជីវកម្មផ្លូវភេទនៅតែបន្តកើនឡើង ដោយសារសេរីភាពផ្នែកសេដ្ឋកិច្ច។ ការពង្រឹងសិទ្ធិមនុស្ស (ឆ្នាំ១៩៩៦) ប្រទេស កម្ពុជា ៖ ពេស្យាកម្ម និងការជួញដូរផ្លូវភេទ ៖ ការគំរាមកំហែងចំពោះសិទ្ធិមនុស្ស គឺស្ត្រី និង កុមារនៅតែកើនឡើងនៅក្នុងប្រទេស កម្ពុជា។ វែបសាយ http://www.hrsolidarity.net/mainfile.php/1996vol06no04/219/ ចូលមើលចុងក្រោយ នៅថ្ងៃទី១៨ មេសា ២០១៤។

[៤៧] ឯកសាររបស់ ECPAT Cambodia, NGOCRC, COSECAM, (2007-8) ៖ របាយការណ៍មូលដ្ឋាន ទិន្នន័យស្ថិតិរួមរួមរបស់ NGO ស្តីពីការជួញដូរ និងការរំលោភសេពសន្ថវៈ នៅក្នុងប្រទេសកម្ពុជា ២០០៧-២០០៨។

[៤៨] អង្គការសកម្មភាព ដើម្បីកុមារ (ខែកុម្ភៈ ឆ្នាំ ២០១៤), ការស៊ើបអង្កេតអំពីអ្នកដំណើរបំពាន ផ្លូវភេទកុមារ ៖ ការវិភាគស្តីពីនិន្នាការ និងការ ប្រឈមនៅក្នុងផ្នែកការបំពានផ្លូវភេទកុមារ និង ការកេងប្រវ័ញ្ច នៅក្នុងប្រទេសកម្ពុជា។

[៤៩] គម្រោងការពារ សាកលវិទ្យាល័យ Johns Hopkins (2007) ស្តីពីទេសចរណ៍ផ្លូវភេទ កុមារអន្តរជាតិ ៖ ទំហំនេះបញ្ហា និងករណី សិក្សាបែបប្រៀបធៀប។

[៥០] អង្គការ ECPAT International (2006a) អំពីរបាយការណ៍ត្រួតពិនិត្យទូទាំងពិភពលោក ស្តីពីស្ថានភាពសកម្មភាព ប្រឆាំងនឹងការកេង ប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ ៖ ប្រទេសកម្ពុជា ទីក្រុងបាងកក ទំព័រទី១២។

[៥១] អង្គការសកម្មភាព ដើម្បីកុមារ (ខែកុម្ភៈ ឆ្នាំ២០១៤), ការស៊ើបអង្កេតអំពីអ្នកដំណើរបំពាន ផ្លូវភេទកុមារ ៖ ការវិភាគស្តីពីនិន្នាការ និងការ ប្រឈមនៅក្នុងផ្នែកការ បំពានផ្លូវភេទកុមារ និង ការកេងប្រវ័ញ្ចនៅក្នុងប្រទេស កម្ពុជា។ ទិន្នន័យនេះ គឺជាវាយតម្លៃមួយទាប ព្រោះថា ទិន្នន័យនេះនៅមានកម្រិតនៅឡើយ ទៅលើករណីនានា ដែលអង្គការសកម្មភាព ដើម្បីកុមារបានអនុវត្ត។

ក្រុងសៀមរាប គឺជាស្រុកទីរួមខេត្ត និងជាគោលដៅទេសចរណ៍ដ៏ល្បី ដែលអាចផ្តល់ការកំសាន្តបានច្រើនប្រភេទដល់ភ្ញៀវទេសចរ ដែលត្រឡប់ពីធ្វើដំណើរកំសាន្តហើយ ត្រូវទៅកាន់ប្រាសាទនោះវិញ នៅពេលថ្ងៃ។ បន្ទប់ម៉ាស្សាភ្ញៀវ មានចំនួនច្រើនសន្ធឹកសន្ធាប់។ កុមារតូច ដែលខ្លះមានអាយុទើបតែប្រាំពីរឆ្នាំនោះ បានលក់ភេសជ្ជៈ និងវត្ថុអនុស្សាវរីយ៍ទៅឲ្យភ្ញៀវទេសចរ ជារឿយៗ រហូតដល់យប់។ ភ្ញៀវទេសចរក៏ទទួលបានឱកាសទៅកំសាន្តនៅមជ្ឈមណ្ឌលកុមារកំព្រាក្នុងមូលដ្ឋាន សម្រាប់ជាបទពិសោធន៍វប្បធម៌ដែរ ទោះបីជាមានកុមារជាច្រើន មិនមែនជាក្មេងកំព្រាក៏ដោយ[៥២]។

ឃុំពួកគឺជាទីរួមស្រុក ។ គេចំណាយពេលតែ៣០នាទីប៉ុណ្ណោះ នឹងអាចជិះទៅដល់ក្រុងសៀមរាប មិនខាន។ ទីប្រជុំជននេះ គឺជាតំបន់ដាច់ស្រយាល ដែលមានមនុស្សជាច្រើន រស់នៅតាមបែបប្រពៃណី។ ទោះបីជាមាន ភ្ញៀវទេសចរច្រើនទៅកំសាន្តនៅក្រុងសៀមរាបក៏ដោយ តំបន់ដាច់ស្រយាលដែលនៅជុំវិញក្រុងសៀមរាប នៅតែជាតំបន់ក្រីក្របំផុតមួយ នៅក្នុងប្រទេសកម្ពុជា។ នៅខេត្តសៀមរាប ប្រជាពលរដ្ឋប្រមាណជា៨២% គឺជាកសិករ[៥៣]។ មានទិន្នន័យតិចតួចដែល មានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយដែលនិយាយអំពីកម្មករចំណាកស្រុកវ័យក្មេងនៅក្នុងក្រុងនៃប្រទេសកម្ពុជា ទោះបីជាមាន របាយការណ៍បញ្ជាក់ថា មានកម្មករសំណង់ច្រើនសន្ធឹកសន្ធាប់នៅក្នុងទីក្រុងនានា ដូចជាក្រុងភ្នំពេញ និងសៀមរាបក៏ដោយ ចំណែកឯកំណើនលូតលាស់នៃសណ្ឋាគារ និងកន្លែងទេសចរណ៍ អមដោយ វិស័យសេវាកម្មនានា ចាប់ពីចុងទសវត្សរ៍ទី១៩៩០ រហូតដល់ទសវត្សរ៍ទីឆ្នាំ២០០០ បានបង្កើតតម្រូវ ការការងារនៅក្នុងតំបន់សៀមរាម[៥៤]។ ក្នុងពេលជាមួយគ្នានេះ កុមារងាយរងគ្រោះជាច្រើន ដែលរស់នៅ ប្រកបការងារ និងរស់នៅក្រោមការថែទាំរួម សុទ្ធតែមកពីតំបន់ជិតៗនោះ ដែលងាយនឹងបានជួបជាមួយ ភ្ញៀវទេសចរបរទេស ដែលទៅកំសាន្តនៅសៀមរាប។

- **ខេត្តមណ្ឌលគីរី និងទីរួមស្រុកសែនមនោរម្យ**

ខេត្តមណ្ឌលគីរី មានទីតាំងស្ថិតនៅភាគឥសាន្តនៃប្រទេសកម្ពុជានិងមានចម្ងាយប្រហែលជា ៤០០ គីឡូម៉ែត្រពីក្រុងភ្នំពេញ។ ខេត្តនេះ ត្រូវបានក្រសួងទេសចរណ៍អភិវឌ្ឍឲ្យក្លាយជាទិសដៅអេកូទេសចរណ៍មួយ ដោយមានកន្លែងសម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍នានា ដូចជា ទឹកជ្រោះប៊ូស្រា ព្រៃភ្នំ និងសត្វព្រៃជាដើម ហើយខេត្តនេះនៅតែជាខេត្តដាច់ស្រយាលមួយនៅក្នុងប្រទេសកម្ពុជា ទោះបីជាមានការស្ថាបនាផ្លូវថ្នល់សំខាន់ៗនៅក្នុងខេត្តនេះក៏ដោយ។ ខេត្តមណ្ឌគីរីមានប្រជាពលរដ្ឋ សរុបចំនួន ៥៧៦៦៦នាក់ នៅក្នុងនោះ មានប្រជាពលរដ្ឋចំនួន ២៩៦២៦នាក់ ឬ៥១% គឺជាជនជាតិព្នង[៥៥]។ អត្រាចុះឈ្មោះចូលរៀន នៅមានកម្រិតទាប រីឯអត្រាឈប់រៀនវិញមានកម្រិតខ្ពស់[៥៦]។ ទោះបីស្រុកមនោរម្យគឺជាទីរួមខេត្តក៏ដោយ វានៅតែស្ថិតនៅដាច់ស្រយាលខ្លាំង ដោយមានប្រជាពលរដ្ឋ៤០% ពឹងផ្អែកលើរបរកសិកម្មដើម្បីចិញ្ចឹមជីវិត។ ប្រជាជនសរុប គឺមានចំនួនតែ ១០០០០នាក់ប៉ុណ្ណោះ មានជនជាតិខ្មែរ ៥៤% ព្នង ៤៤% និងជនជាតិភាគតិចដទៃទៀតចំនួន ២%។

ទោះបីស្រុកនេះមានទំហំតូចក្តី អ្នកស្រាវជ្រាវបានសង្កេតឃើញថា ស្រុកនេះមានកន្លែងកំសាន្តជាច្រើន មានសណ្ឋាគារ និងផ្ទះសំណាក់២៣កន្លែង[៥៧]។ ទោះបីស្រុកសែនមនោរម្យ មិនបានទាក់ទាញភ្ញៀវ ទៅកំសាន្តច្រើនក៏ដោយ ទីរួមស្រុកនេះ នៅតែរីកចម្រើនទៅមុខ ដោយសារការហូរចូលនៃអ្នកចំណូលស្រុកជាជនជាតិខ្មែរ និងជនបរទេស ដែលមកធ្វើការនៅក្នុងឧស្សាហកម្មកៅស៊ូ វារីអគ្គិសនី និងឧស្សាហកម្មរ៉ែ។

# សាធារណរដ្ឋប្រជាមានិតឡាវ

សាធារណរដ្ឋប្រជាមានិតឡាវ គឺជាប្រទេសដែលមានព្រំដែនជាប់នឹងប្រទេសវៀតណាម ប្រទេស ចិន មីយ៉ាន់ម៉ា កម្ពុជា និងប្រទេសថៃ។ នៅឆ្នាំ២០១២ សាធារណរដ្ឋប្រជាមានិតឡាវ មានប្រជាជនប្រមាណជា៦,៦៥ លាននាក់ ក្នុងនោះ មានប្រជាជនជាង៤០% (២,៨៦លាននាក់) មានអាយុក្រោម ១៨ឆ្នាំ[៥៨]។ ប្រជានប្រមាណជាពាក់កណ្តាល គឺជាជនជាតិឡាវ ហើយប្រទេសនេះ គឺត្រូវគ្របដណ្តប់ដោយឥទ្ធិពលនយោបាយ និងវប្បធម៌។ កុលសម្ព័ន្ធភ្នំ មានដូចជាកុលសម្ព័ន្ធម៉ុងយ៉ាវ (Hmong-Yao) ទីប៊េតូភូមា (Tebeto-Burman) [គ័រ (Kor) និង ភូណយ (Phounoy)] ។ ហើយគេរកឃើញថាមាននៅសេសសល់អំបូរភាសាជនជាតិតៃ (Tai) នៅភាគខាងជើងនៃប្រទេសឡាវ។ កុលសម្ព័ន្ធអូស្ត្រូអាស៊ី (មនខ្មែរ និងវៀត-ម៉ុង) រស់នៅតំបន់ភ្នំផ្នែកកណ្តាល និងភាគខាងត្បូង។ ជាងដប់ប្រាំឆ្នាំកន្លងទៅនេះ គេបានឃើញថា ប្រទេសឡាវបានពង្រឹងការកាត់បន្ថយភាពក្រីក្រ

[៥២] ឯកសារ UNICEF Fact Sheet (គ្មានកាលបរិច្ឆេទ) ស្តីពីការថែទាំក្នុងកន្លែងរួមនៅក្នុងប្រទេសកម្ពុជា និង ឯកសារ UNICEF-EAPRO (2011) ស្តីពី បំណងដ៏ប្រសើរបំផុត ៖ ការសិក្សាស្តីពីឥរិយាបទ ឆ្ពោះទៅរកការថែទាំក្នុងកន្លែងរួមនៅក្នុងប្រទេសកម្ពុជា។

[៥៣] វែបសាយ http://db.ncdd.gov.kh/cdbonline/home/index.castle ចូលមើលនៅខែកក្កដា ឆ្នាំ២០១១។

[៥៤] ឯកសាររបស់អង្គការ CDRI និង UNFPA (ខែវិច្ឆិកា ២០០៧) ការធ្វើចំណាកស្រុករបស់យុវជន និងនគរូបនីយកម្ម ក្នុងប្រទេសកម្ពុជា។

[៥៥] វែបសាយ http://db.ncdd.gov.kh/cdbonline/home/index.castle ចូលមើលនៅខែកក្កដា ឆ្នាំ២០១១។

[៥៦] មានកុមារអាយុប្រាំមួយឆ្នាំ តែចំនួន ៧៤% ប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សា។ លើសពីនេះ យោងតាមការប៉ាន់តម្លៃឆ្នាំ២០០៩ ភាគរយនៃកុមារមានអាយុ១២ទៅ១៤ឆ្នាំ ដែលបានឈប់រៀន គឺមានកម្រិតខ្ពស់ (២៣%)។ វែបសាយ http://db.ncdd.gov.kh/cdbonline/home/index.castle ចូលមើលនៅខែកក្កដា ឆ្នាំ២០១១។

[៥៧] ទិន្នន័យ ដែលអ្នកស្រាវជ្រាវទទួលបានក្នុងពេលចូលទៅមើលក្នុងខែកក្កដា ២០១១។

[៥៨] ឯកសារអង្គការ UNICEF ស្ថិតិ ៖ សាធារណរដ្ឋប្រជាមានិតឡាវ វែបសាយ http://www.unicef.org/infobycountry/laopdr_statistics.html#78 ចូលមើលចុងក្រោយបំផុត នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ។

និងលើកកម្ពស់កំណើនសេដ្ឋកិច្ច ភាគច្រើន គឺដោយសារតែប្រទេសនេះ បានឆ្លងចូលទៅក្នុងសេដ្ឋកិច្ចទីផ្សារ និងការចូលរួមក្នុង សកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់[៥៩]។ តាមការប៉ាន់ស្មាន មានប្រជាជន ២៧,៦% ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ[៦០]។ ប្រទេសឡាវនៅតែជួបបញ្ហាប្រឈមសំខាន់ៗ ក្នុងការសម្រេចបាន គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ ២០១៥ របស់ខ្លួន។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការកាត់បន្ថយភាពក្រីក្រ ការបង្កើនអត្រា ចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា ការកាត់បន្ថយអត្រាមរណភាពកុមារ ការប្រឆាំងនឹងជំងឺរបេង គ្រុនចាញ់ និងការមានទឹកស្អាតប្រើប្រាស់ និងអនាម័យក្នុងតំបន់ទីក្រុងក៏ដោយ ក៏ប្រទេសឡាវនៅតែមានបញ្ហា ប្រឈមចម្បងៗជាច្រើនទៀត ដូចជា ការកាត់បន្ថយកង្វះអាហារូបត្ថម្ភកុមារ វិសមភាពដែលបន្តកើតមាន និងខ្លាំងក្លាលើប្រជាជនក្នុងការទទួលបានឱកាស និង សេវាសង្គមតាមភេទ ភូមិសាស្ត្រ និង ភាសាកំណើត កង្វះការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចនៅថ្នាក់ក្រោមជាតិ អត្រាមរណភាពមាតាខ្ពស់ និង អត្រាបាត់បង់ធនធានធម្មជាតិយ៉ាងរហ័ស[៦១]។

ប្រទេសឡាវបានបើកទូលាយឲ្យភ្ញៀវទេសចរអន្តរជាតិចូលមកទស្សនាក្នុងឆ្នាំ១៩៨៩។ ចាប់តាំងពីពេលនោះមក ប្រាក់ចំណូលវិស័យទេសចរបានកើនឡើងយ៉ាងច្រើន ដែលធ្វើឲ្យវិស័យទេសចរណ៍ក្លាយជាឧស្សាហកម្មនាំចេញដ៏ចម្បងមួយ[៦២]។ គោលនយោបាយវិស័យទេសចរណ៍របស់ប្រទេសឡាវផ្តោតលើទេសចរណ៍ធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ ដូចជា សោភ័ណ្ឌធម្មជាតិ ជីវៈចម្រុះ វប្បធម៌ និងប្រពៃណីរបស់ជនជាតិដើមភាគតិច និង រមណីយដ្ឋានប្រវត្តិសាស្ត្រ ដូចជា ទីក្រុង Luang Prabang[៦៣] ដែលជាសម្បត្តិបេតិកភ័ណ្ឌពិភពលោក។ ក្នុងឆ្នាំ២០១៣ មានភ្ញៀវទេសចរចូលមកទស្សនាប្រទេសឡាវ ចំនួន ៣,៨ លាននាក់ ពោលគឺកើនបាន ១៥% ធៀបនឹងឆ្នាំ២០១២[៦៤]។ អាស៊ាននៅតែជាប្រភពទីផ្សារដ៏ធំបំផុត ដោយមានកំណើនភ្ញៀវទេសចរ ១២% ស្មើនឹង ៣.០៤១.២៣៣ នាក់ ដែលភាគច្រើនភ្ញៀវទេសចរទាំងនោះធ្វើដំណើរតាមផ្លូវគោក ដែលរួមមានភ្ញៀវទេសចរថៃ (៥៥%) និងភ្ញៀវទេសចរវៀតណាម (២៤%)។ វិស័យទេសចរណ៍ប្រទេសឡាវរួមចំណែកបាន ៤,៧% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៣ ដែលស្មើនឹង ៣.៨៩៤ ពាន់លានគីប (ប្រហែល ៤៨៧.៦៥០.០០០ ដុល្លាអាមេរិក)[៦៥]។ ដោយសារមានការពង្រឹងការអនុវត្តច្បាប់ក្នុងប្រទេសថៃ និងប្រទេសកម្ពុជា មានការលើកឡើងមួយចំនួនថា ប្រទេសឡាវនឹងក្លាយជាតំបន់គោលដៅថ្មី សម្រាប់ឲ្យជនប្រព្រឹត្តិបទល្មើសផ្លូវភេទកុមារចូលមកកំសាន្តក្នុងរូបភាពជាភ្ញៀវទេសចរ ជាពិសេសដោយសារតែប្រទេសនេះផ្តល់អនាមិកភាព និងភាពឯកជនក្នុងកម្រិតខ្ពស់ ដែលបង្កលក្ខណៈងាយស្រួលដល់ជនប្រព្រឹត្តិបទល្មើសផ្លូវភេទកុមារក្នុងរូបភាពជាភ្ញៀវទេសចរ[៦៦]។

- ## ទីក្រុងវៀងច័ន្ទ

មានការជ្រើសរើសភូមិចំនួនបីក្នុងរដ្ឋធានីវៀងច័ន្ទរបស់ប្រទេសឡាវ រួមមាន ៖ ភូមិ Ban Mixay ក្នុងស្រុក Cantabile Ban ភូមិ Phiawat ក្នុងស្រុក Sistine និង ភូមិ Ban Hom ក្នុងស្រុក Hatxiafong ។ ភូមិ Ban Mixay និង ភូមិ Ban Phiawat គឺជាភូមិពីរក្នុងទីក្រុងដែលស្ថិតនៅតាមមាត់ទន្លេដែលសំបូរទៅដោយផ្ទះសំណាក់ សណ្ឋាគារ បានីយដ្ឋាន ភោជនីយដ្ឋាន និងហាង។ នៅភូមិ Ban Phiawat មានវិហារព្រះពុទ្ធសាសនាចំនួនពីរ ផ្ទះសំណាក់ចំនួនបី និងមាន ភោជនីយដ្ឋាន ឬកន្លែងញ៉ាំអាហារយ៉ាងតិច ៦។ នៅភូមិ Ban Mixay និង ភូមិ Ban Phiawat មានការដ្ឋានសំណង់ខ្នាតធំ និងតូចជាច្រើន ដើម្បីសាងសង់ផ្ទះសំណាក់ សណ្ឋាគារ និងមានប្រាសាទមួយដែលកំពុងស្ថិតនៅក្នុងការជួសជុលឡើងវិញ។ ភូមិ Ban Hom គឺជាភូមិជនបទមួយដែលស្ថិតនៅតាមច្រាំងទន្លេមេគង្គ ដោយត្រូវចំណាយពេលបើកបរប្រហែល ២០ នាទីពីទីក្រុងវៀងច័ន្ទ។ អ្នកភូមិភាគច្រើនធ្វើស្រែ ដាំបន្លែ និងផ្លែឈើ។ ក្នុងអំឡុងពេលស្រាវជ្រាវ ក្នុងភូមិនេះ គេឃើញមានផ្ទះសំណាក់តែពីរបីប៉ុណ្ណោះ។ ភូមិនេះមិនសូវមានភ្ញៀវទេសចរច្រើនដូចជាសហគមន៍ពីរផ្សេងទៀតនោះឡើយ។

- ## ទីក្រុង Luang Prabang

ទីក្រុង Luang Prabang គឺជាកន្លែងទាក់ទាញភ្ញៀវទេសចរ ដ៏ល្បីល្បាញមួយក្នុងប្រទេសឡាវ។ ទីក្រុងនេះ ត្រូវបានចាត់ទុកជារាជធានីរហូតមានការគ្រប់គ្រងដោយរបបកុម្មុយនីស្តក្នុងឆ្នាំ១៩៧៥ និងជាសម្បត្តិ បេតិកភ័ណ្ឌពិភពលោករបស់អង្គការ UNESCO ដ៏ល្បីល្បាញមួយ ដោយសារទីក្រុងនេះគឺជាទីតាំងប្រវត្តិសាស្ត្រ សំបូរទៅដោយធនធានធម្មជាតិ វិហារព្រះពុទ្ធសាសនា និងវត្តអារាមជាដើម។ ក្នុងស្រុក Luang Prabang មានការជ្រើសរើសភូមិចំនួនបី ដូចជា ភូមិ Ban Xieng Muan ភូមិ Ban Aphay និងភូមិ Ban Xieng Lek។

---

[៥៩] ឯកសាររដ្ឋាភិបាលអូស្ត្រាលី "ក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្ម ស្តីពីប្រទេសឡាវ៖ មូលហេតុត្រូវផ្តល់ជំនួយទៅឲ្យប្រទេសឡាវ" ក្នុងវេបសាយ http://aid.dfat.gov.au/countries/eastasia/laos/Pages/why-aid.aspx ចូលមើលចុងក្រោយ នៅថ្ងៃទី២៣ មេសា ឆ្នាំ២០១៤។

[៦០] ឯកសារធនាគារពិភពលោក ស្តីពី សូចនាករអភិវឌ្ឍន៍តាមអ៊ីនធឺណិត ៖ សាធារណរដ្ឋប្រជាមានិតឡាវ ក្នុងវេបសាយ http:// data.worldbank.org/country/lao-pdr ចូលមើលចុងក្រោយ នៅថ្ងៃទី២៣ មេសា ឆ្នាំ២០១៤។

[៦១] អង្គការ UNDP ប្រចាំនៅប្រទេសឡាវ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ប្រទេសឡាវ ៖ http://www.undplao.org/mdgs/ ដកស្រង់នៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១១។

[៦២] Yamauchi, S និង Lee, D (ខែមិថុនា ឆ្នាំ១៩៩៩) ការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងប្រទេសឡាវ ៖ ឯកសារពិភាក្សារបស់ផ្នែកកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ លេខ ST/ESA/1999/DP.9 ៖ http://www.un.org/esa/desa/papers/1999/esa99dp9.pdf ដកស្រង់នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១។

[៦៣] ប្រទេសឡាវ (ឆ្នាំ២០០៦) យុទ្ធសាស្ត្រវិស័យទេសចរណ៍របស់ឡាវ ៖ http://www.latalaos.org/doc/Strategy2006.pdf ដកស្រង់នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១។

[៦៤] UNWTO បារ៉ូម៉ែត្រវិស័យទេសចរណ៍ពិភពលោក ៖ http://www.innovasjonnorge.no/Documents/old/Documents/UNWTO_Barom14_01_Jan.pdf ដកស្រង់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤។

[៦៥] ក្រុមប្រឹក្សាទេសចរណ៍ពិភពលោក របាយការណ៍ ស្តីពីផលប៉ះពាល់សេដ្ឋកិច្ចឡាវ ឆ្នាំ ២០១៤ ៖ http://www.wttc.org/site_media/uploads/downloads/laos2014.pdf ដកស្រង់នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០១៤។

[៦៦] គម្រោងការពារកុមារ Johns Hopkins University (ឆ្នាំ២០០៧) ទេសចរណ៍ផ្លូវភេទកុមារអន្តរជាតិ ៖ វិសាលភាពបញ្ហា និងករណីសិក្សាបែបប្រៀបធៀប ទំព័រ ៣៥។

ដោយសារតែពេលវេលាមិនគ្រប់គ្រាន់ ក្រុមស្រាវជ្រាវមិនអាចប្រមូលទិន្នន័យក្នុងភូមិ Ban Xieng Lek ឡើយ។ ភូមិ Ban Xieng Muan ស្ថិតនៅតំបន់ហាមឃាត់ នៃទីតាំងបេតិកភណ្ឌពិភពលោក តាមច្រាំងទន្លេងមេគង្គ និងមានវិហារព្រះពុទ្ធសាសនាចំនួនពីរ ផ្ទះសំណាក់ចំនួន ១៥ កន្លែងស្ប៉ា និង ហាងម៉ាស្សាចំនួន ៤ ភោជនីយដ្ឋានចំនួន ៦ និងហាងលក់វត្ថុអនុស្សាវរីយ៍ជាច្រើន ផ្សេងទៀត។ ភូមិនេះគឺជាភូមិមួយក្នុងចំណោមភូមិចំនួន ១១ ផ្សេងទៀតដែលស្ថិតនៅក្នុងតំបន់នេះ ដែលសំបូរទៅដោយផ្ទះសំណាក់ដែលមិនបង្ហាញអត្តសញ្ញាណ។ ភូមិ Ban Aphay ស្ថិតនៅត្រង់ ចំណុចកោងនៃទន្លេ Khan ភាគអាគ្នេយ៍នៃខ្ពង់រាប Phousi។ ក្នុងអំឡុងពេលស្រាវជ្រាវ មានផ្ទះសំណាក់ ឬផ្ទះវីឡាប្រហែល ១០ និងសណ្ឋាគារមួយស្ថិតនៅជុំវិញផ្លូវ មាត់ទន្លេ និងមានកន្លែងលក់ស្រាមួយ បាពីរ និង ភោជនីយដ្ឋាន ៥។

## ប្រទេសថៃ

ប្រទេសថៃមានព្រំប្រទល់ជាប់ប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ មានការប៉ាន់ប្រមាណថា ក្នុងឆ្នាំ២០១២ ប្រជាជនថៃមានប្រមាណ ៦៦,៧៩ លាននាក់ ដោយមានប្រជាជនអាយុក្រោម ១៨ ឆ្នាំ ប្រមាណ ១៥,១២ លាននាក់[៦៧]។ ប្រជាជនច្រើនជាង ៨៥% និយាយភាសាថៃ និងមានវប្បធម៌រួម ទោះបីជាក្នុងតំបន់ផ្សេងទៀតនៃប្រទេសថៃ មានអត្តសញ្ញាណប្រចាំតំបន់ដ៏រឹងមាំមួយក៏ដោយ។ ប្រជាជនថៃជាច្រើននៅភាគឦសានមានកេរតំណែលពីជនជាតិឡាវ និងខ្មែរ ហើយជាតិពន្ធុម៉ាឡេស៊ីដែលកាន់សាសនាអ៊ីស្លាមមានច្រើននៅក្នុងខេត្តចំនួនបីនៅភាគខាងត្បូង[៦៨]។

វិស័យទេសចរណ៍គឺជាកត្តារួមចំណែកដល់វិស័យសេដ្ឋកិច្ចដ៏សំខាន់ក្នុងប្រទេសថៃ។ ក្នុងឆ្នាំ ២០១៣ មានភ្ញៀវទេសចរចូលមកទស្សនាក្នុងប្រទេសថៃប្រហែល ២៦,៧ លាននាក់ពោលគឺមានការកើនឡើង ២០ % ធៀបនឹងឆ្នាំ២០១២។ ភ្ញៀវទេសចរប្រហែល ៥៦% មកពីតំបន់អាស៊ីបូព៌ា ដោយមានទេសចរអាស៊ានប្រមាណ ២៨%។ ភ្ញៀវទេសចរអឺរ៉ុបជាប់លំដាប់លេខបី ដែលស្មើនឹង ២៥%។ សហរដ្ឋអាមេរិក អាស៊ីខាងត្បូង និងតំបន់ប៉ាស៊ីហ្វិចខាងត្បូងមានភ្ញៀវទេសចរប្រហែលជា ៥%[៦៩]។
វិស័យទេសចរណ៍រួមចំណែកបាន ៩% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសថៃដោយទទួលបានទឹកប្រាក់សរុបយ៉ាងច្រើនចំនួន ៣៣,៣ ពាន់លានដុល្លាអាមេរិកក្នុងឆ្នាំ២០១៣[៧០] ហើយបើធៀបនឹងឆ្នាំ ២០១២ មានការកើនឡើងបាន ២៧,៥% ពោលគឺជាកំណើនដ៏ខ្ពស់បំផុតលើស ប្រទេសផ្សេងៗក្នុងសកលលោក។

របាយការណ៍របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិបង្ហាញថា ប្រទេសថៃសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅថ្នាក់ជាតិយ៉ាងច្រើន លើសពីគោលដៅឆ្នាំ២០១៥។ យ៉ាងណាក៏ដោយ តំបន់ និងក្រុមមួយចំនួនកំពុងប្រឈមនឹងបញ្ហាវិសមភាពយ៉ាងខ្លាំង[៧១] ដោយសារនៅមានគម្លាតផ្នែកសេវាសុខភាព និងការទទួលបានសេវាសង្គមសម្រាប់ក្រុមងាយរងគ្រោះ រួមមាន មនុស្សចាស់ យុវជន អ្នករកស៊ីផ្លូវភេទ កម្មករចំណាកស្រុក និងប្រជាជនដែលគ្មានសញ្ជាតិ[៧២]។

មានការលើកឡើងថា កំណើនឧស្សាហកម្មផ្លូវភេទ នៅប្រទេសថៃបានជំរុញឲ្យមានកំណើនទីផ្សារនៃការរំលោភបំពានផ្លូវភេទកុមារពីជនបរទេស។ កាលពីដើមទសវត្សរ៍ឆ្នាំ ១៩៩០ នៅប្រទេសថៃ មានការបង្កើនការយល់ដឹងពីការជួញដូរផ្លូវភេទកុមារ និងបានកៀរគរមតិយោបល់ ពីសាធារណជនដើម្បី ប្រឆាំងនឹង *"ទេសចរណ៍ផ្លូវភេទកុមារ"*[៧៣]។ កាលពីឆ្នាំ២០០៦ អង្គការ NGO ECPAT International[៧៤] បានរាយការណ៍ថា អាជីវកម្មបម្រើសេវាកំសាន្តសម្រាប់ភ្ញៀវទេសចរ រួមមាន កន្លែងរកស៊ីផ្លូវភេទ និងការបង្ហាញផ្លូវភេទដែលមិនមែនមានតែមនុស្សពេញវ័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំបូរទៅដោយកុមារា និងកុមារីទៀតផង ដែលពួកគេទាំងនោះគឺជាអ្នកផ្តល់សេវាផ្លូវភេទ[៧៥]។ យ៉ាងណាក៏ដោយ ថ្មីៗនេះ មានការលើកឡើងថាកាន់តែមានការលំបាកក្នុងការស្វែងរកកុមារ ដែលត្រូវបានជួញដូរផ្លូវភេទនៅ ទីក្រុងបាងកក ដោយសារមានការរាយការណ៍មកថា ការជួញដូរផ្លូវភេទកុមារក្នុងរូបភាពជាភ្ញៀវទេសចរបានផ្លាស់ប្តូរពីការជួញដូរតាមកន្លែងទៅជាការជួញដូរតាមផ្លូវ ជាពិសេសចំពោះកុមារក្រីក្រ និងងាយរងគ្រោះ[៧៦]។ មានការរាយការណ៍ថាការបង្ក្រាបជាផ្លូវការ កាតព្វកិច្ចនៃការអប់រំសកល និងកំណើនការអភិវឌ្ឍសេដ្ឋកិច្ច បានរួមចំណែកកាត់បន្ថយអត្រាកើតមានការរំលោភបំពានផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍[៧៧] ទោះបីជាមិនមានទិន្នន័យគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីអំណះអំណាងនេះក៏ដោយ។

[៦៧] អង្គការ UNICEFស្ថិតិ ៖ ប្រទេសថៃ ៖ http://www.unicef.org/infobycountry/Thailand_statistics.html#91 ដកស្រង់នៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៤។

[៦៨] ក្រសួងការបរទេសសហរដ្ឋអាមេរិក (ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១១) កំណត់សម្គាល់សារតា ៖ ប្រទេសថៃ ៖ http://www.state.gov/r/pa/ei/bgn/2814.htm ដកស្រង់នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១១។

[៦៩] អាជ្ញាធរទេសចរណ៍ថៃ ៖ http://tourism.go.th/index.php?mod=WebTourism&file=details&dID=7&cID=276&dcID=621, ដកស្រង់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤។

[៧០] ក្រុមប្រឹក្សាទេសចរណ៍ពិភពលោក របាយការណ៍ស្តីពីផលប៉ះពាល់សេដ្ឋកិច្ចថៃ ឆ្នាំ២០១៤ ៖ http://www.undp.or.th/focusareas/mdgprogramme.html ដកស្រង់នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៤។

[៧១] UNDP គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ប្រទេសថៃ ៖ http://www.undp.or.th/focusareas/mdgprogramme.html

ដកស្រង់នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១១។

[៧២] ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម (ឆ្នាំ២០០៩) របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ប្រទេសថៃ ឆ្នាំ២០០៩ ទីក្រុងបាងកក ៖ http://www.undp.or.th/resources/documents/Thailand_MDGReport_2009.pdf ដកស្រង់នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១១ ទំព័រ ៦៥-៦៦។

[៧៣] Ennew J, Gopal, K, Heeran, J និង Montgomery, H (ឆ្នាំ១៩៩៦) កុមារ និងពេស្យាចារ ៖ តើយើងអាចត្រួតពិនិត្យ និងតាមដានការជួញដូរផ្លូវភេទកុមារបានយ៉ាងដូចម្តេច? ការពិនិត្យឡើងវិញលើឯកសារពីមុន និងចំណារគន្ថនិទ្ទេស។ ទីស្នាក់ការអង្គការ UNICEF ទីក្រុងញូវយក ផ្នែកកុមារស្ថិតក្នុងស្ថានភាពលំបាក មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវតាមគ្រួសារ សាកលវិទ្យាល័យ Cambridge និង អង្គការChildwatch International ការបោះពុម្ពលើកទីពីរ ៖ http://child-abuse.com/childhouse/childwatch/cwi/projects/indicators/prostitution/ ដកស្រង់នៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១១។

[៧៤] បញ្ឈប់ពេស្យាកម្មកុមារ រូបភាពអាសអាភាសរបស់កុមារ និងការជួញដូរកុមារដើម្បីបម្រើសេវាផ្លូវភេទ ៖ http://www.ecpat.net។

[៧៥] អង្គការ ECPAT អន្តរជាតិ (ឆ្នាំ២០០៦b) របាយការណ៍ពិនិត្យតាមដានសកលស្តីពីស្ថានភាពសកម្មភាពប្រឆាំងការជួញដូរផ្លូវភេទកុមារ ៖ ប្រទេសថៃ ទីក្រុងបាងកក។

[៧៦] គម្រោងការពារ Johns Hopkins University (ឆ្នាំ២០០៧) ទេសចរណ៍ផ្លូវភេទកុមារអន្តរជាតិ ៖ វិសាលភាពនៃបញ្ហា និងករណីសិក្សាបែបប្រៀបធៀប ទំព័រ ១៥៨-១៥៩។

[៧៧] Baker, S (ឆ្នាំ២០០៧) ពលកម្មកុមារ និងពេស្យាកម្មកុមារក្នុងប្រទេសថៃ ៖ ការផ្លាស់ប្តូរតថភាព White Lotus។

- ## ទីក្រុងផាត់តាយ៉ា

ទីក្រុងផាត់តាយ៉ាស្ថិតនៅចំណាយ ១៤៦ គីឡូម៉ែត្រពីទីក្រុងបាងកក និងមានប្រជាជនដែលមានជាតិពន្ធចម្រុះជាង ១០៤.៣១៨ នាក់ ដែលបានចុះបញ្ជីជាអ្នករស់នៅក្នុងទីក្រុងនោះ ទោះបីជាមានការប៉ាន់ប្រមាណថា ប្រជាជនសរុបនៅទីនោះមានរហូតដល់ ៣០០.០០០ នាក់ រាប់បញ្ចូលទាំងអ្នកដែលមិនទាន់បានចុះបញ្ជីផងដែរ[៧៨]។

ទីក្រុងផាត់តាយ៉ា បានក្លាយជាទីក្រុងដ៏គួរឲ្យចាប់អារម្មណ៍មួយដោយសារមានការចាប់ខ្លួនជនប្រព្រឹត្តិបទល្មើសផ្លូវភេទកុមារជាច្រើនក្រោមរូបភាពជាភ្ញៀវទេសចរ ដោយធ្វើឲ្យមានការព្រួយបារម្ភថា ផាត់តាយ៉ាគឺជាទីក្រុងដែលសំបូរទៅដោយការរំលោភបំពានផ្លូវភេទកុមារ។ ឆ្នេរខ្សាច់ផាត់តាយ៉ាមានប្រវែង ៤ គីឡូម៉ែត្រ ដោយមានផ្លូវមួយរត់តាមបណ្ដោយឆ្នេរ។ ទីក្រុងនេះគឺជាកន្លែងបម្រើ សេវាកំសាន្តដ៏សំខាន់ជាពិសេស គឺសេវាផ្លូវភេទ និងមានក្រុមក្មេងជើងកាងទីក្រុងជាច្រើន (នេះគឺជាកត្តាដែលរារាំងដល់ការស្រាវជ្រាវ ដោយសារតែអ្នករកស៊ីផ្លូវភេទមិនហ៊ាននិយាយជាមួយអ្នកស្រាវជ្រាវនោះឡើយ) ហើយទីក្រុងនេះបានទាក់ទាញជនចំណាកស្រុកវ័យក្មេងដែលប្រាថ្នាចង់រកប្រាក់ចំណូលបានលឿន និងងាយស្រួល។

- ## ទីក្រុងឈៀងម៉ៃ

ទីក្រុងឈៀងម៉ៃមានចម្ងាយ ៧០៦ គីឡូម៉ែត្រពីទីក្រុងបាងកក និងមានប្រជាជនចុះបញ្ជីចំនួន ១.៦៧០.៣១៧ នាក់ ហើយទីក្រុងនេះគឺជាទីក្រុងធំជាងគេ និងជាទីក្រុងដែលមានសម្បត្តិវប្បធម៌ដ៏សំខាន់បំផុតក្នុងភាគខាងជើងនៃប្រទេសថៃ។ ឈៀងម៉ៃគឺជារដ្ឋធានីចាស់ របស់ព្រះរាជាណាចក្រ Lanna (ឆ្នាំ ១២៩៦-១៧៦៨) ហើយទីក្រុងនេះសំបូរទៅដោយភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិ។ ចំនួនភ្ញៀវទេសចរអន្តរជាតិ បានធ្លាក់ចុះពី ៥,៣ លាននាក់ ក្នុងឆ្នាំ២០០៨ មកត្រឹម ៤,៣ លាននាក់ក្នុងឆ្នាំ២០០៩ ទោះបីជាចំនួនភ្ញៀវទេសចរ មានការកើនឡើងម្ដងទៀតដោយសារតែមានការចាប់អារម្មណ៍ពីទីផ្សារជប៉ុន និងកូរ៉េ[៧៩]។ ទីក្រុងឈៀងម៉ៃក៏បានទាក់ទាញភ្ញៀវទេសចរចិនយ៉ាងច្រើន (ចំនួនភ្ញៀវទេសចរកើនឡើងយ៉ាង ហោចណាស់ ៥០% នៅចន្លោះឆ្នាំ២០១២ និង ២០១៣) ពោលគឺជានិន្នាការមួយដែលត្រូវបានជំរុញតាមរយៈភាពយន្តចិនដ៏ល្បីមួយដែលមានចំណងជើងថា "Lost in Thailand" ដែលខ្សែភាពយន្តនេះត្រូវបានផលិតនៅក្នុងខេត្តនេះ[៨០]។ អ្វីដែលទាក់ទាញភ្ញៀវទេសចររួមមាន កុលសម្ព័ន្ធជាតិពន្ធភ្នំ ការធ្វើដំណើរដោយថ្មើរជើង វិហារព្រះពុទ្ធសាសនា ដំរីព្រៃ សាលាបង្រៀនធ្វើម្ហូប និងម៉ាស្សា ក្លិប Night Bazaar និង Sunday ដ៏ល្បីល្បាញ ទីផ្សារតាមចិញ្ចើមថ្នល់ ទេសចរណ៍ផ្នែកសុខាភិបាល រោងជាងសិប្បកម្ម និងការបង្ហាញវប្បធម៌។ នៅក្នុងទីក្រុងឈៀងម៉ៃ ក៏មានបនស្រីផងដែរ។ ក្រុមជនជាតិដើមភាគតិចដែលបានផ្លាស់ទីលំនៅ រស់នៅតាមសំណង់អនាធិបតេយ្យនៅជាយទីក្រុង និងរកប្រាក់ចំណូលបានពីការលក់វត្ថុអនុស្សាវរីយ៍ឲ្យភ្ញៀវទេសចរ ដោយឲ្យកូនរបស់ពួកគេជាអ្នកដើរលក់វត្ថុអនុស្សាវរីយ៍ទាំងនោះ។

# ប្រទេសវៀតណាម

ប្រទេសវៀតណាមប៉ែកខាងកើតជាប់នឹងសមុទ្រ ប៉ែកខាងជើងជាប់ប្រទេសចិន និងប៉ែកខាងលិចជាប់ប្រទេសឡាវ និងកម្ពុជា និងមានក្រុមជាតិពន្ធចំនួន ៥៤ ក្រុម ដោយរាប់ទាំងជាតិពន្ធវៀតណាម (ឬគីញ) ដែលមានប្រហែល ៨៥% នៃប្រជាជនសរុប។ ក្រុមជាតិពន្ធច្រើនបំផុតបន្ទាប់ពីគីញ គឺ Tay ដែលមានប្រមាណ ១,៨៩% និងថៃមានប្រមាណ ១,៨% នៃប្រជាជនសរុប ហើយប្រជាជនច្រើនរស់នៅប្រមូលផ្តុំនៅតំបន់ខ្ពង់រាបភាគខាងជើងនៃប្រទេស[៨១]។ ក្នុងឆ្នាំ២០១២ មានប្រជាជនវៀតណាមសរុបប្រមាណ ៩០,៨០ លាននាក់ ដែលក្នុងនោះប្រជាជនប្រមាណ ២៥,៣៤ លាននាក់មានអាយុក្រោម ១៨ឆ្នាំ[៨២]។

ឧស្សាហកម្មទេសចរណ៍នៅប្រទេសវៀតណាម មានការកើនឡើងយ៉ាងខ្លាំង តាំងពីមានកំណែទម្រង់សេដ្ឋកិច្ច របស់ប្រទេសវៀតណាមដែលមានឈ្មោះថា Doi Moi ដោយសារតែការបើកចំហរទីផ្សារសម្របសម្រួលវិស័យទេសចរណ៍របស់ប្រទេសវៀតណាម ដល់ការវិនិយោគដោយផ្ទាល់ពីបរទេស និងសហគ្រិនឯកជនក្នុងស្រុក[៨៣]។ ចំនួនភ្ញៀវទេសចរអន្តរជាតិដែលមកទស្សនាក្នុងប្រទេសនេះ បានកើន ១១% ចាប់ពីឆ្នាំ ២០១២ រហូតដល់ឆ្នាំ ២០១៣ ដោយមានភ្ញៀវទេសចរអន្តរជាតិសរុបប្រមាណ ៧,៦ លាននាក់។ ចំនួនភ្ញៀវទេសចរចិនមានច្រើនជាងគេដោយមានប្រមាណ ២៥% ពោលគឺជិត ២លាននាក់។

[៧៨] ស្ថិតិប្រជាជនទីក្រុងផាត់តាយ៉ា យោងតាមការចុះបញ្ជីប្រជាជន ឆ្នាំ១៩៩៧-២០០៧ (ប្រទេសថៃ) ទីក្រុងផាត់តាយ៉ា ៖ ការិយាល័យមន្ត្រីចុះបញ្ជី ដកស្រង់នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០៧។

[៧៩] ភ្ញៀវទេសចរនៅទីក្រុងឈៀងម៉ៃមានការកើនឡើង ផ្នែកទំនាក់ទំនងសាធារណៈរបស់រដ្ឋាភិបាលថៃ (ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០១១) ៖ *http://www.ecpat.net*

[៨០] Janjira Jarusupawat (ថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៣) "ភាពយន្តបានធ្វើឲ្យមានកំណើនភ្ញៀវទេសចរចិន មកកាន់ទីក្រុងឈៀងម៉ៃ" កាសែត The Nation ៖ http://www.nationmultimedia.com/business/Film-sparks-Chinese-touristboom-in-Chiang-Mai-30197745.html ដកស្រង់នៅថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៤។

[៨១] ក្រសួងការបរទេសសហរដ្ឋអាមេរិក (ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០១១) កំណត់សម្គាល់សារតា ៖ ប្រទេសវៀតណាម ៖ http://www.state.gov/r/pa/ei/bgn/4130.htm ដកស្រង់នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១១។

[៨២] អង្គការ UNICEFស្ថិតិ ៖ ប្រទេសវៀតណាម ៖ http://www.unicef.org/infobycountry/vietnam_statistics.html#78 ដកស្រង់នៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៤។

[៨៣] Suntikul, W, Butler, R និង Airey,D (ឆ្នាំ ២០០៨) " អំឡុងពេល នៃការអភិវឌ្ឍវិស័យទេសចរណ៍វៀតណាម ចាប់តាំងពីមានគោលនយោបាយបើកចំហរប្រទេស" ៖ ការស្រាវជ្រាវវិស័យទេសចរណ៍ ក្នុងទិន្នានុប្បវត្តិន៍អាស៊ីប៉ាស៊ីហ្វិច លេខ ១៣ (១) ទំព័រ ៦៧-៨០ ៖ http://epubs.surrey.ac.uk/1102/1/fulltext.pdf ដកស្រង់នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១១។

ភ្ញៀវទេសចរច្រើនបំផុតបន្ទាប់រួមមានភ្ញៀវទេសចរកូរ៉េ (១០%) ជប៉ុន (៨%) អាមេរិក (៦%) និងតៃវ៉ាន់ (៥%)[៨៤]។ វិស័យទេសចរណ៍បានរួមចំណែកដោយផ្ទាល់ដល់ផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៣ ប្រមាណ ៧ពាន់លានដុល្លាអាមេរិក ពោលគឺស្មើនឹង ៤,៦% នៃផលិតផលក្នុងស្រុកសរុប[៨៥]។

ប៉ុន្មានឆ្នាំថ្មីៗនេះ នៅប្រទេសវៀតណាម មានការចាប់ខ្លួនជនបរទេសដែលបានប្រព្រឹត្តិបទល្មើសផ្លូវភេទកុមារអស់ជាច្រើនករណី។ ក្នុងអំឡុង ១៨ ខែ ចន្លោះឆ្នាំ២០០៥ និង ២០០៦ ជនជាតិបរទេសចំនួន ៧នាក់ត្រូវបានចាប់ខ្លួនដោយសារការប្រព្រឹត្តិបទល្មើសផ្លូវភេទលើកុមារវៀតណាម[៨៦]។ ចាប់តាំងពីឆ្នាំ២០០៥ មកមិនមានការចាប់ខ្លួនណាមួយឡើយ ប៉ុន្តែប្រការនេះមិនអាចសន្និដ្ឋានបានថា មានការបញ្ឈប់ការជួញដូរផ្លូវភេទកុមារតាមរយៈជនបរទេសនោះឡើយ។ ករណីសិក្សាថ្មីរបស់អង្គការ UNICEF បានរកឃើញថាកុមារ ៧៦% ដែលផ្តល់បទសម្ភាសពីបញ្ហាជួញដូរផ្លូវភេទកុមារបានរាយការណ៍ថា “ភ្ញៀវ” របស់ពួកគេគឺមានទាំងជនបរទេសផងដែរ[៨៧]។ ការលើកឡើងនេះបង្ហាញថា មានកុមារជាច្រើនដែលត្រូវបាន ជួញដូរផ្លូវភេទតាមរយៈទំនាក់ទំនងពាណិជ្ជកម្ម ដូចជា ពេស្យាចារ ការជួញដូរផ្លូវភេទ ការរំលោភបំពានផ្លូវភេទក្នុងរូបភាពជាភ្ញៀវទេសចរ និងឯកសាររូបភាពការរំលោភបំពានផ្លូវភេទកុមារ។ ការសិក្សាថ្មីមួយ បានបង្ហាញថា និន្នាការដ៏គួរឲ្យព្រួយបារម្ភមួយទៀតនោះគឺការរកឃើញថា កុមារកំពុងប្រឡូកនឹងការជួញដូរផ្លូវភេទទាំងនៅវ័យក្មេង ដោយអាយុក្មេងបំផុតនោះគឺត្រឹមតែ ៨ ឆ្នាំប៉ុណ្ណោះ[៨៨]។

[៨៤] រដ្ឋបាលទេសចរណ៍ជាតិវៀតណាម ៖ http://vietnamtourism.gov.vn/english/index.php/items/6709 ដកស្រង់នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៤។

[៨៥] ក្រុមប្រឹក្សាទេសចរណ៍ពិភពលោក របាយការណ៍ ស្តីពីផលប៉ះពាល់សេដ្ឋកិច្ចវៀតណាម ៖ http://www.wttc.org/site_media/uploads/downloads/vietnam2014.pdf ដកស្រង់នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៤។

[៨៦] អង្គការ UNICEF (ឆ្នាំ២០១១)ការវិភាគពីការជួញដូរផ្លូវភេទកុមារតាមបណ្តាខេត្ត និងទីក្រុងមួយចំនួននៅប្រទេសវៀតណាម។

[៨៧] អង្គការ UNICEF (ឆ្នាំ២០១១)ការវិភាគពីការជួញដូរផ្លូវភេទកុមារតាមបណ្តាខេត្ត និងទីក្រុងមួយចំនួននៅប្រទេសវៀតណាម។

[៨៨] អង្គការ UNICEF (ឆ្នាំ២០១១)ការវិភាគពីការជួញដូរផ្លូវភេទកុមារតាមបណ្តាខេត្ត និងទីក្រុងមួយចំនួននៅប្រទេសវៀតណាម។

## • ទីក្រុងហូជីមិញ ៖ ស្រុក ៤ និង ៨

ទីក្រុងហូជីមិញគឺជាទីក្រុងដ៏ធំបំផុតរបស់ប្រទេសវៀតណាម និងជាមជ្ឈមណ្ឌលសេដ្ឋកិច្ច ដែលពីមុនមានឈ្មោះថា ទីក្រុង Saigon និងជាអតីតរដ្ឋធានីរបស់សាធារណៈរដ្ឋវៀតណាម (វៀតណាមខាងត្បូង)។ ទីក្រុងនេះ មានកន្លែងទេសចរណ៍ដ៏ច្រើនអណេក ដូចជាកន្លែងទេសចរណ៍ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម និង សាសនា។ ស្រុក ៤ គឺជាស្រុកតូចជាងគេបង្អស់នៅក្នុងទីក្រុងហូជីមិញដែលមានប្រជាជនប្រមាណ ១៨០.០០០ នាក់។ ស្រុកនេះ គឺជាស្រុកក្នុងក្រុងដែលក្រីក្របំផុត ទោះបីជាថ្មីៗនេះ អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ជាច្រើនបានចូលមករស់នៅក្នុងតំបន់នោះ និងបានធ្វើឲ្យមានគម្លាត រវាងអ្នកមាននិងអ្នកក្រកាន់តែខ្លាំងក៏ដោយ។ ស្រុក ៨ ស្ថិតនៅភាគនិរតីនៃទីក្រុងដោយមានប្រជាជនប្រមាណ ៤០៥,០០០ នាក់។

[៨៩] http://vietlandgroup.com/social%20significance.htm ដកស្រង់នៅខែកក្កដា ឆ្នាំ២០១១។

## • ឆ្នេរ Do Son និង Thuy Nguyen

Do Son គឺជាតំបន់ឆ្នេរទេសចរណ៍ដ៏ល្បីល្បាញមួយស្ថិតនៅភាគខាងជើង នៃប្រទេសវៀតណាម ដែលមានចម្ងាយ ២០ គីឡូម៉ែត្រពីភាគនិរតីនៃទីក្រុងហៃហ្វុង និង ១០៥ គីឡូម៉ែត្រពីភាគខាងកើតនៃទីក្រុងហាណូយ។ ទីក្រុងនេះមានប្រជាជនប្រមាណ ៣៥.០០០ នាក់។ រៀងរាល់ឆ្នាំតំបន់នេះមានភ្ញៀវទេសចរប្រហែល ៦លាននាក់ ដែល ២៥% ជាភ្ញៀវទេសចរបរទេស[៨៩]។ Do Son សំបូរទៅដោយផ្ទះបនស្រី ដោយមានសណ្ឋាគារតូចៗជាច្រើនប្រមូលផ្តុំ នៅលើកំណាត់ផ្លូវ តែមួយ។ សណ្ឋាគារទាំងនេះ គឺជាផ្ទះបនស្រីដែលទាក់ទាញភ្ញៀវទេសចរក្នុងមូលដ្ឋាន និងក្នុងតំបន់ជាច្រើនឲ្យមករកសេវាផ្លូវភេទជាមួយស្ត្រីក្មេងៗក្នុងមូលដ្ឋាន។

Thuy Nguyen គឺជាស្រុកជនបទ បើទោះជាឃុំចំនួនបីក្នុងស្រុកនេះ ដែលត្រូវបានជ្រើសរើសយកមកសិក្សា ហាក់មិនមានលក្ខណ:ជាជនបទក៏ដោយ។ សម្រាប់ភ្ញៀវទេសចរដើរកំសាន្តកន្លែងនេះ អាចរៀបចំជាពិធីបុណ្យ ព្រៃកដែលមានទេសភាពស្រស់បំព្រង វត្តអារាមល្បីៗ និងស្ថាបត្យកម្មដ៏គួរឲ្យចាប់អារម្មណ៍ផ្សេងទៀត។ ប្រជាជនប្រមាណ ៧០% រកប្រាក់ចំណូលបានគ្រប់គ្រាន់ពីការនេសាទត្រីខ្នាតធំ ហើយមានគ្រួសារជាច្រើនទទួលបានប្រាក់បញ្ញើរពីសាច់ញាតិរស់នៅឯក្រៅ ដែលបានចាកចេញពីប្រទេសវៀតណាមបន្ទាប់ពីបញ្ចប់សង្គ្រាមក្នុងឆ្នាំ ១៩៧៥ ឬប្រាក់របស់កូនស្រីដែលរៀបការជាមួយជនបរទេស (ភាគច្រើនជាជនបរទេសមកពីតំបន់អាស៊ីបូព៌ា)។ ស្រុកនេះប្រឈមនឹងបញ្ហាសង្គមជាច្រើនដែលបង្កឡើងដោយទ្រព្យសម្បត្តិ ជាជាងភាពក្រីក្រ ដូចជា ការចំណាយប្រាក់យ៉ាងច្រើនលើកូនៗ កង្វះការជំរុញទឹកចិត្តឲ្យរៀនសូត្រ និងអត្រាខ្ពស់នៃការបោះបង់ការសិក្សា ឪពុកម្តាយមិនសូវបានគ្រប់គ្រងកូនៗរបស់ខ្លួន វត្តមានស្ត្រីរកស៊ីផ្លូវភេទ នៅមុខសាលា សកម្មភាពផ្លូវភេទលួចលាក់ក្នុងបរិវេណសាលា និងវត្តមានបា បន្ទប់ខារ៉ាអូខេ និងកន្លែងលេងវីដេអូហ្គេមដ៏ច្រើននៅជុំវិញសាលា។

ជំពូក ២

# ការយល់ដឹងពីការរំលោភបំពានកុមារ



# ជំពូក ២ ៖ ការយល់ដឹងពីការរំលោភបំពានកុមារ

ប្រការសំខាន់ ត្រូវស្វែងយល់ពីស្ថានភាពនៃការកើតមានការរំលោភបំពានកុមារឲ្យបានកាន់តែទូលំទូលាយ ដើម្បីធ្វើការឆ្លើយតបសមស្របទៅនឹងការរំលោភបំពានផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍ដែលរួមមាន ការយល់ដឹងរបស់កុមារ និងមនុស្សពេញវ័យចំពោះកុមារភាព សិទ្ធិកុមារផ្លូវភេទ ការរំលោភបំពាន និងបញ្ហាពាក់ព័ន្ធផ្សេងទៀត។ ជំពូកនេះ នឹងពិភាក្សាពីរបៀបដែលកុមារនិងមនុស្សពេញវ័យបាន យល់ដឹងពីគោលគំនិតទាំងនេះ ហើយក៏នឹងលើកឡើងនូវចំណេះដឹងរបស់កុមារស្តីពីភេទ និងបង្ហាញពីការអប់រំ និងទំនាក់ទំនងផ្លូវភេទ ដែលកុមារទទួលបានក្នុងទីតាំងស្រាវជ្រាវនីមួយៗ ដែលបានផ្តល់ជាព័ត៌មានដល់ពួកគេពីការរំលោភបំពានផ្លូវភេទ។



## គោលគំនិតស្តីពីសិទ្ធិកុមារ និងការរំលោភបំពានកុមារ

### តើកុមារយល់ដឹងពីការរំលោភបំពានកុមារដោយរបៀបណា?

កុមារី និងកុមារាងាយរងគ្រោះទៅនឹងការរំលោភបំពានផ្លូវភេទនៅពេលដែលកុមារទាំងនោះមិនមានចំណេះដឹង ជំនាញ និងការជឿជាក់ក្នុងការការពារខ្លួន និងក្នុងករណីដែលឪពុកម្តាយរបស់ពួកគេមិនបានយល់ដឹងពីផលប៉ះពាល់ និងផលវិបាកនៃការរំលោភបំពានផ្លូវភេទកុមារ។ ការយល់ដឹងច្រើនពីអាកប្បកិរិយារំលោភបំពាន អាចជួយឲ្យកុមារកំណត់អត្តសញ្ញាណជនល្មើសសំខាន់ៗ និងអាចឲ្យកុមារទាំងនោះការពារខ្លួនបានយ៉ាងប្រសើរពីការរំលោភបំពានផ្លូវភេទ។

តាមរយៈការស្រាវជ្រាវ កុមារភាគច្រើនបានយល់ដឹងពីគោលគំនិតនៃការរំលោភបំពានកុមារ មិនថាជាលក្ខណៈផ្លូវការ ឬក្រៅផ្លូវការនោះឡើយ។ ការរំលោភបំពានច្រើនកើតមានក្នុងរូបភាពជាការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ ហើយសិស្សដែលរៀនជំនាញ កុមារដែលធ្វើការ និងកុមារតាមផ្លូវនិងសិស្សសាលាឯកជន មានការយល់ដឹង ពីបញ្ហានេះបានស៊ីជម្រៅជាងសិស្ស សាលារដ្ឋ។ ការរំលោភបំពានកុមារអាចរាប់ទាំងការបង្ខំឲ្យកុមាររួមភេទ ប្រើប្រាស់ថ្នាំញៀន ធ្វើការងារ ឬលួចឆក់ ព្រមទាំងលក់ ការជួញដូរ ការដាក់ទណ្ឌកម្ម ឬការកេងប្រវ័ញ្ចកុមារជាដើម ហើយបញ្ហាទាំង នេះមិនសូវទទួលបានការយកចិត្តទុកដាក់ឡើយ។ ការមិនផ្តល់ឱកាសឲ្យកុមារទទួលបាន ការអប់រំ ត្រូវបានចាត់ទុកជាការរំលោភបំពាន ក៏ប៉ុន្តែ ពលកម្មកុមារមិនសុទ្ធតែទុកថា ជាការរំលោភបំពាននៅគ្រប់កាលៈទេសៈទាំងអស់នោះឡើយ។ ជារួម កុមារមានការយល់ដឹងបានយ៉ាងប្រសើរពីផលវិបាក នៃការរំលោភបំពានផ្លូវភេទកុមារ ដូចជា ការបង្កការឈឺចាប់លើរាងយកាយ ការមានផ្ទៃពោះ ជំងឺកាមរោគ ជំងឺផ្លូវចិត្ត និងការបាត់បង់ឱកាសជាដើម។ ជាទូទៅ កុមារីងាយរងគ្រោះនឹងការរំលោភបំពានជាងកុមារា។

កុមារ និងមនុស្សពេញវ័យភាគច្រើនបានប្រឈមនឹងការរំលោភបំពានផ្លូវភេទកុមារដូចៗគ្នា ដូចជាការរំលោភសេពសន្ថវៈលើកុមារី និងការប៉ះពាល់លើរាងកាយកុមារីជាដើម។ ការវិនិច្ឆ័យពីការរំលោភបំពានផ្លូវភេទត្រូវផ្អែកតាមស្ថានភាពមួយចំនួន ដូចជា អាយុរបស់ដៃគូរួមភេទ ទំនាក់ទំនងរបស់បុគ្គលនោះជាមួយកុមារ និងថាតើកុមារីនោះនៅព្រហ្មចារី ឬយ៉ាងណា។ កុមារវៀតណាមដែលផ្តល់បទសម្ភាសបានឲ្យដឹងថា ការរួមភេទដោយមានការព្រមព្រៀងរវាងអនីតិជន និងមនុស្សពេញវ័យ មិនត្រូវបានចាត់ទុកជា ការរំលោភបំពានផ្លូវភេទនោះឡើយ ចំណែកសិស្សសាលានៅទីក្រុង ផាត់ថាយ៉ា នៃប្រទេសថៃ យល់ថា ការបង្ខំឲ្យកុមារីរួមភេទជាមួយមិត្តប្រុសរបស់ខ្លួនគឺជារឿងធម្មតា ហើយអ្នកផ្តល់បទសម្ភាសភាគច្រើនយល់ឃើញថា មិត្តប្រុសដែលរំលោភបំពានផ្លូវភេទដៃគូរបស់ខ្លួនមិនគួរទទួលការដាក់ទណ្ឌកម្មដូចជាជនប្រព្រឹត្តិផ្សេងទៀតនោះឡើយ ឬអាចនិយាយបានថា ទំនាក់ទំនងដែលមានការរំលោភបំពានផ្លូវភេទក្នុងចំណោមមិត្តភក្តិ (ដូចជា ដោយសារមិត្តប្រុស) មិនសុទ្ធតែត្រូវបានចាត់ទុកជាការរំលោភបំពាននោះឡើយ។ លទ្ធផលរកឃើញមានបញ្ជាក់ក្នុងឯកសារ ដែលបង្ហាញថា កុមារនៅក្នុងតំបន់កំពុងតែប្រឈមនឹងការរំលោភបំពានពីមិត្តភក្តិកាន់តែច្រើនឡើង[៩០]។

កុមារភាគតិច បានចាត់ទុកការរួមភេទតាមរន្ធគូទ តាមមាត់ ការចូលរួម/ការមើលរូបភាពអាសអាភាស ឬការសម្រេចកាមដោយខ្លួនឯងជាការរំលោភបំពានផ្លូវភេទ[៩១]។ មានតែក្រុមកុមារីជំទង់មួយក្រុមដែលរៀនជំនាញនៅទីក្រុងហូជីមិញនៃប្រទេសវៀតណាមប៉ុណ្ណោះ ដែលអាចកំណត់ពីសកម្មភាពជាច្រើនដែលអាច

[៩០] អង្គការ UNICEF-EAPRO (ឆ្នាំ ២០១២) ការរំលោភបំពានកុមារ ៖ ប្រេវ៉ាឡង់ ឧប្បត្តិហេតុ និងផលវិបាកនៃការរំលោភបំពានកុមារក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច ៖ ការពិនិត្យឡើងវិញលើការស្រាវជ្រាវជាប្រព័ន្ធ។

ចាត់ទុកជាការរំលោភបំពានផ្លូវភេទ។ កុមារីទាំងនោះ ស្គាល់ពីទម្រង់ផ្សេងៗនៃការរំលោភ បំពានផ្លូវភេទ ដូចជា ការរួមភេទដោយមិនដាក់បញ្ចូល និងការរួមភេទដោយដាក់បញ្ចូលអង្គជាតិ ទោះបីជាកុមារីទាំងនោះ មិនអាចផ្ដល់និយមន័យផ្លូវការពីការរំលោភបំពានផ្លូវភេទក៏ដោយ។ ពួកគេបានរៀបរាប់ថា សកម្មភាព ដែលត្រូវចាត់ទុកជាការរំលោភបំពានផ្លូវភេទរួមមាន "***ការបង្ខំឲ្យកុមាររួមភេទ***" "***ការបង្ហាញផ្នែកសំខាន់ៗនៃរាងកាយឲ្យអ្នកដទៃឃើញ***" "***ការទិញខោអាវទ្រនាប់ឲ្យកុមារី ឬការមើលភាពយន្តអាសអាភាសជាមួយកុមារី***" "***ការប៉ះពាល់ផ្នែកសំខាន់ៗនៃរាងកាយរបស់នរណាម្នាក់***" "***ការបញ្ចុះបញ្ចូលឲ្យនរណាម្នាក់មើលសិចជាមួយខ្លួន***" និង "***កុមារាដែលរួមភេទជាមួយកុមារាតាមរន្ធគូទ***"។

នៅប្រទេសឡាវ មានកុមារត្រឹមតែបីនាក់ប៉ុណ្ណោះដែលបានលើកឡើងថា ការប៉ះពាល់ និងការបៀតបៀនជាពាក្យសំដៅត្រូវចាត់ទុកជាការរំលោភបំពានផ្លូវភេទ។ កុមារីអាយុ ១៧ ឆ្នាំ នៅទីក្រុងវៀងច័ន្ទបានលើកឡើងថា"***ការរំលោភសេពសន្ថវៈគឺជាការរំលោភបំពានផ្លូវភេទ.ការប៉ះពាល់ និងការនិយាយពាក្យពេចន៍នាំឲ្យមានចំណង់ផ្លូវភេទក៏ត្រូវបានចាត់ទុកជាការរំលោភបំពានផ្លូវភេទផងដែរ***"។ ទោះបីជា កុមារឡាវមួយចំនួនដែលផ្ដល់បទសម្ភាសបានរាយការណ៍ថាធ្លាប់បានឃើញរូបភាពមនុស្សស្រាតក៏ដោយ ក៏មិនមាននរណាម្នាក់ចាត់ទុកការបង្ខំឲ្យកុមារមើលរូបភាពអាសអាភាស ឬការរំលោភបំពានផ្លូវភេទកុមារ និងការថតរូបភាពទាំងនោះ ជាការរំលោភបំពាននោះឡើយ។

សម្រាប់កុមារភាគច្រើន ការយល់ថា កុមារាអាចទទួលរងការរំលោភបំពានផ្លូវភេទគឺជាគោលគំនិតមួយដ៏ចម្លែក លើកលែងតែកុមារនៅទីក្រុងផាត់តាយ៉ាដែលបានផ្ដល់បទសម្ភាស និងកុមារមួយចំនួនដែលរៀនជំនាញ កុមារតាមផ្លូវ និងកុមារដែលលក់វត្ថុអនុស្សាវរីយ៍តាមផ្លូវ ក្នុងប្រទេសវៀតណាមប៉ុណ្ណោះ។ សហគមន៍បានដឹងថា បុរសបរទេសអាចជាជនប្រព្រឹត្តិបទល្មើសផ្លូវភេទលើកុមារាដែលត្រូវចាត់ទុកថាជាការរំលោភបំពាន។ តាមការស្រាវជ្រាវនៅទីតាំងផ្សេងទៀតបានបង្ហាញថា អ្នកផ្ដល់បទសម្ភាសដែលជឿជាក់ថា កុមារាអាចជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ យល់ថា ជាទូទៅជនបរទេស គឺជាអ្នកប្រព្រឹត្តិបទល្មើស។ នៅប្រទេសវៀតណាមមានសិស្សត្រឹមតែ ២ ទៅ ៣នាក់ប៉ុណ្ណោះ ដែល បានចូលរួមក្នុងសិក្ខាសាលាស្ដីពីការបង្ការការឆ្លងមេរោគអេដស៍ ឬសិក្ខាសាលា របស់អង្គការ World Visionជឿថា ការរំលោភបំពានផ្លូវភេទកុមារអាចកើតមានទាំងលើកុមារា និងកុមារី។ កុមារដែលរៀន ជំនាញកុមារតាមផ្លូវ និងកុមារដែលលក់វត្ថុអនុស្សាវរីយ៍តាមផ្លូវ ដែលផ្ដល់បទសម្ភាស ភាគច្រើន បានដឹង ថា កុមារាក៏ត្រូវទទួលរងការរំលោភបំពានផ្លូវភេទផងដែរ។ នេះគឺជាបញ្ហាមួយដែលពួក គេបានដឹងតាមរយៈការស្ដាប់លឺ ឬបានឃើញករណីរំលោភបំពានផ្លូវភេទលើកុមារាក្នុងកន្លែងដែលពួកគេ រស់នៅ និងធ្វើការ[៩២]។ នៅប្រទេសឡាវមិនមានអ្នកផ្ដល់បទសម្ភាសណាម្នាក់ លើកឡើងពីការរំលោភបំពានផ្លូវភេទលើកុមារាឡើយ។

មានការយល់ដឹងជាទូទៅថា ការរំលោភបំពានផ្លូវភេទគឺជាទង្វើដែលកើតមាននៅក្រៅគ្រួសារ និងសហគមន៍ជាពិសេស នៅពេលដែលមានការព្រួយបារម្ភពីការរំលោភបំពានផ្លូវភេទលើកុមារា។ វិធីសាស្ត្រក្នុងការលួងលោមរបស់ជនល្មើសបរទេស និងក្នុងមូលដ្ឋាន កម្រចាត់ទុកថាជាទម្រង់នៃការរំលោភបំពានណាស់។

ដោយសារទីក្រុងផាត់តាយ៉ា មានភាពល្បីល្បាញថាជាកន្លែងទេសចរណ៍ផ្លូវភេទកុមារ អ្នកផ្ដល់បទសម្ភាសនៅទីក្រុងនេះ មានការព្រួយបារម្ភខ្លាំងខ្លាចជនបរទេសប្រព្រឹត្តិបទល្មើសផ្លូវភេទលើកុមារ ជាងទីតាំងស្រាវជ្រាវផ្សេងទៀត។ កុមារនៅក្នុងទីក្រុងផាត់តាយ៉ា ចាត់ទុកជនចម្លែកថាជាជនបង្កគ្រោះថ្នាក់ ដូចដែលសិស្សស្រីអាយុ ១២ ឆ្នាំម្នាក់បានលើកឡើងថា "***ខ្ញុំខ្លាចជនចម្លែក ពីព្រោះជនចម្លែកទាំងនោះអាចចាប់ខ្លួនខ្ញុំ និងលក់ខ្ញុំ ឬអាចចាប់រំលោភខ្ញុំ***"។ ទោះជាយ៉ាងណា ការស្រាវជ្រាវនេះបានបង្ហាញថា ការយល់ដឹង របៀបនេះគឺជាករណីពិសេស មិនមែនជាលក្ខណៈទូទៅនោះឡើយ។ ទោះជាកុមារមានការយល់ដឹងពីគ្រោះថ្នាក់ដែលបង្កឡើងដោយភ្ញៀវទេសចរ និងជនបរទេសក៏ដោយ កុមារភាគច្រើនមិនសូវមានជំនាញ ឬយុទ្ធសាស្ត្រក្នុងការការពារខ្លួនពីការរំលោភបំពានទាំងនោះឡើយ។

នេះគឺជាករណីពិសេសមួយទាក់ទងនឹងកុមារី ៣ នាក់ រស់នៅក្នុងទីក្រុងហូជីមិញ នៃប្រទេសវៀតណាមដែលជាអ្នកលក់វត្ថុអនុស្សាវរីយ៍តាមផ្លូវ។ ទោះបីជាកុមារីទាំងនោះរស់នៅឆ្ងាយពីឪពុកម្ដាយ និងត្រូវធ្វើការក្នុងអំឡុងរដូវក្ដៅដើម្បីផ្គត់ផ្គង់គ្រួសាររបស់ខ្លួនក៏ដោយ កុមារីទាំងបីនោះនៅតែបន្តការសិក្សា និង ទទួលបានចំណាត់ថ្នាក់ល្អទៀតផង។ កុមារីទាំងនោះបានរៀនសូត្រពីរបៀបការពារខ្លួនពីឪពុកម្ដាយរបស់ខ្លួនដើម្បីការពារខ្លួនពីការរំលោភបំពាន និងគ្រោះថ្នាក់ និងបានយកមកអនុវត្តប្រកបដោយ ប្រសិទ្ធភាព។

[៩១] ការពិនិត្យឡើងវិញលើការស្រាវជ្រាវបង្ហាញថា ក្មេងប្រុសក្លាយជាជនរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទមិនផ្ទាល់ ច្រើនជាងក្មេងស្រី។ អង្គការ UNICEF-EAPRO (ឆ្នាំ២០១២)។ ការរំលោភបំពានកុមារ ៖ ប្រេវ៉ាឡង់ ឧប្បត្តិហេតុ និង ផលវិបាកនៃការរំលោភបំពានកុមារក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច ៖ ការពិនិត្យឡើងវិញលើការស្រាវជ្រាវប្រព័ន្ធ។

[៩២ត] ការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា ជនប្រព្រឹត្តិបទល្មើសផ្លូវភេទ តាមស្ថានភាព ភាគច្រើនចូលចិត្តស្ត្រី ខណៈដែលជនប្រព្រឹត្តិបទល្មើសផ្លូវភេទ ភាគច្រើនផ្សេងទៀតចូលចិត្តបុរស។ ស្ថិតិរបស់ APLE បង្ហាញថា បុរសអាស៊ីចូលចិត្តជនរងគ្រោះជាស្ត្រី ខណៈដែលបុរសអឺរ៉ុបចូលចិត្តជនរងគ្រោះជាបុរស។ អង្គការ Action Pour Les Enfants (ខែកុម្ភៈ ឆ្នាំ២០១៤) ការស៊ើបអង្កេតជន ប្រព្រឹត្តិបទល្មើសផ្លូវភេទលើកុមារក្រោមរូបភាព ជាភ្ញៀវទេសចរ ៖ ការវិភាគនិន្នាការ និងបញ្ហាប្រឈមនៃការរំលោភបំពានផ្លូវភេទកុមារ និងការកេងប្រវ័ញ្ចលើកុមារនៅកម្ពុជា។

កុមារីទាំងបីនាក់ បានរៀបរាប់ពីយុទ្ធសាស្ត្រការពារខ្លួន ដែលពួកគេបានរៀនសូត្រ ៖ *"មិនត្រូវទុកចិត្តជនចម្លែក" "មិនត្រូវដើរតាមភ្ញៀវទេសចររហូតដល់បន្ទប់ក្នុងសណ្ឋាគារនោះឡើយ" "មិនត្រូវលក់វត្ថុអនុស្សាវរីយ៍ឲ្យភ្ញៀវទេសចរដែលស្រវឹង" "ស្រែកឲ្យអ្នកដទៃជួយ ប្រសិនបើ ភ្ញៀវទេសចរមួយចំនួនព្យាយាមថើប ឬអោបអ្នក" "ត្រូវប្រុងប្រយ័ត្នចំពោះក្រុមកុមារីដែលលក់វត្ថុ អនុស្សាវរីយ៍"* និង *"មិនត្រូវញ៉ាំស្ករគ្រាប់ ឬភេសជ្ជៈដែលភ្ញៀវទេសចរទិញឲ្យនោះឡើយ"*។

តាមរយៈបុគ្គលិកមួយរូបរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា បានឲ្យដឹងថា *"ឪពុកម្តាយនៅតែមានការយល់ដឹងតិចតួចពេលខ្លះ ពួកគាត់មិនបានដឹងពីបញ្ហារបស់កូនៗនោះទេ។ ឧ. ពួកគាត់មិនបានដឹងថា កូនរបស់គាត់ត្រូវបានគេចាប់រំលោភឡើយ ហើយបើទោះជាពួកគាត់ដឹង ក៏ពួកគាត់មិនអាចជួយអ្វីបានដែរ "*។

## តើមនុស្សពេញវ័យស្វែងយល់ពីការរំលោភបំពានកុមារដោយរបៀបណា ?

យោងតាមតាមការស្រាវជ្រាវ អ្នកផ្តល់បទសម្ភាសជាមនុស្សពេញវ័យ មានទស្សនៈដូចកុមារដែរ ដោយយល់ថា ការរំលោភបំពានផ្លូវភេទលើកុមារគឺច្រើនជាការរំលោភសេពសន្ថវៈកុមារី។ ដូចគ្នានេះដែរ មនុស្សពេញវ័យ បានកត់សម្គាល់ឃើញថា ការរំលោភបំពានកុមារភាគច្រើនគឺកើតមានក្នុងទម្រង់ ជាការរំលោភបំពានផ្លូវកាយ ជាពាក្យសំដី ការមិនអើពើ និងការរំលោភបំពានផ្លូវភេទ។ ឪពុកម្តាយជនជាតិវៀតណាម ដែលបាន ចូលរួមក្នុងការសិក្សា មិនអាចផ្តល់និយមន័យឲ្យបានច្បាស់ ឬលើកឡើងនូវឧទាហរណ៍នៃ ការរំលោភបំពានផ្លូវភេទឡើយ។ កត្តានេះអាចបង្ហាញពីកម្រិតនៃភាពខុសគ្នារវាងគោលគំនិត ផ្លូវការទាក់ទងនឹង *"ការរំលោភបំពានផ្លូវភេទកុមារ"* និងអត្ថន័យក្រៅផ្លូវការដែលឪពុកម្តាយច្រើនប្រើប្រាស់ក្នុងការ ប្រាស្រ័យទាក់ទងជាមួយកូនៗ[៩៣]។ ផ្ទុយទៅវិញ នៅប្រទេសឡាវ អ្នកមានកាតព្វកិច្ច នៅមិនទាន់យល់ពីពាក្យ ***"ការរំលោភបំពានកុមារ"*** បានច្បាស់នៅឡើយទេ ដោយមួយចំនួន បានយោងទៅលើអត្ថបទច្បាប់ដូចថា *អនុសញ្ញាស្តីពីសិទ្ធិកុមារ ច្បាប់ស្តីពីការការពារ សិទ្ធិកុមារ និងអត្ថប្រយោជន៍របស់កុមារ និងច្បាប់រដ្ឋប្បវេណី*។

ជារួម ចម្លើយតបរបស់អ្នកមានកាតព្វកិច្ចដែលបានពីការស្រាវជ្រាវ បានលើកឡើងថា ឪពុកម្តាយ និងកូនៗ មិនទាន់មានការយល់ដឹងឲ្យបានស៊ីជម្រៅពីការរំលោភបំពានផ្លូវភេទកុមារ និងមធ្យោបាយក្នុងការកំណត់ពីការរំលោភបំពាន ការការពារ ឬការឆ្លើយតបទៅនឹងការរំលោភបំពានឡើយ។ ខាងក្រោមនេះគឺជាការលើកឡើងរបស់បុគ្គលិកមួយរូបនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា ៖

> *"ឪពុកម្តាយនៅតែមានការយល់ដឹងតិចតួចពេលខ្លះ ពួកគាត់មិនបានដឹងពីបញ្ហារបស់កូនៗនោះទេ។ ឧ. ពួកគាត់មិនបានដឹងថា កូនរបស់គាត់ត្រូវបានគេចាប់រំលោភឡើយ ហើយបើទោះជាពួកគាត់ដឹង ក៏ពួកគាត់មិនអាចដោះស្រាយអ្វីបានដែរ។"*

អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ លទ្ធផលរកឃើញបានបង្ហាញថា ពេលខ្លះ កង្វះការយល់ដឹងបានធ្វើឲ្យឪពុកម្តាយ និងអ្នកមានកាតព្វកិច្ច មិនអាចកំណត់ការរំលោភបំពានបាន សូម្បីតែការរំលោភបំពាននោះបានកើតរួចហើយក៏ដោយ។ ឪពុកម្តាយមានការព្រួយបារម្ភខ្លាំងពីការមានដៃគូរួមភេទច្រើន និងការមានផ្ទៃពោះដោយចៃដន្យ ជាងការរំលោភបំពានផ្លូវភេទ។ បញ្ហាដែលគួរឲ្យព្រួយបារម្ភនោះ អាជ្ញាធរ និងគ្រូបង្រៀន មិនបានឆ្លើយតបទៅនឹងករណីនៃការរំលោភបំពានឡើយ ដោយសារពួកគាត់ចាត់ទុកការរំលោភបំពាននោះជា "បញ្ហាក្នុងគ្រួសារ"។ អ្នកមានកាតព្វកិច្ចម្នាក់នៅទីក្រុងឈៀងម៉ៃ នៃប្រទេសថៃ បានលើកឡើងថា ៖

> *"មានកុមារាម្នាក់មិនដែលចូលរួមក្នុងសកម្មភាពរបស់យើងឡើយ ទោះបីជាយើងខំប្រឹងបញ្ចុះបញ្ចូលគេយ៉ាងណាក៏ដោយ។ បន្ទាប់ពីចេញពីរៀន កុមារានេះមមាញឹកនឹងការលក់វត្ថុអនុស្សាវរីយ៍ណាស់...ខ្ញុំមើលឃើញថា ក្មេងប្រុសម្នាក់នោះ មានសភាពស្ងប់ស្ងៀម និងឯកោណាស់។ ខ្ញុំបានឃើញស្នាមរបួស ជាច្រើនលើខ្លួនរបស់គេ ប៉ុន្តែខ្ញុំមិនបានចាត់វិធានការអ្វីឡើយ រហូតទាល់តែដល់ថ្ងៃមួយដែលគេបានបាត់ខ្លួន។"*

[៩៣] មិនទាន់មាននិយមន័យ តាមផ្លូវច្បាប់ឲ្យច្បាស់លាស់ ស្តីពីគោលគំនិតនៃការរំលោភបំពានផ្លូវភេទក្នុងច្បាប់របស់ប្រទេសវៀតណាមឡើយ ៖ គ្រប់ករណីដែលមនុស្សម្នាក់រួមភេទជាមួយកុមារក្រោមអាយុ ១៣ឆ្នាំ ត្រូវចាត់ទុកជាការរំលោភសេពសន្ថវៈកុមារ។ យ៉ាងណាក៏ដោយ ពាក្យ "ការរំលោភបំពានផ្លូវភេទកុមារ" មិនទាន់មាននិយមន័យតាមផ្លូវច្បាប់ជាផ្លូវការនៅឡើយទេ ហើយពាក្យនេះ ត្រូវបានយកមកប្រើប្រាស់ដោយមិនស៊ីសង្វាក់គ្នាក្នុងច្បាប់ និងបទប្បញ្ញត្តិ។ MOLISA និងអង្គការ UNICEF នៃប្រទេសវៀតណាម (ឆ្នាំ២០០៩) ការបង្កើតបរិយាកាសដែលមានការការពារកុមារក្នុងប្រទេសវៀតណាម ៖ ការប៉ាន់ប្រមាណច្បាប់ និងគោលនយោបាយការពារកុមារ ជាពិសេសកុមារស្ថិតក្នុងស្ថានភាពពិសេសនៅប្រទេសវៀតណាម។

*យោងតាមអ្នកមានកាតព្វកិច្ចម្នាក់ នៅទីក្រុងឈៀងម៉ៃ នៃប្រទេសថៃ បានលើកឡើងថា "មានកុមារាម្នាក់មិនដែលចូលរួមក្នុងសកម្មភាពរបស់យើងឡើយ ទោះបីជា យើងខំប្រឹងបញ្ចុះបញ្ចូលគេយ៉ាងណាក៏ដោយ។ បន្ទាប់ពីចេញពីរៀន កុមារានេះមមាញឹកនឹងការលក់វត្ថុអនុស្សាវរីយ៍ណាស់...ខ្ញុំមើលឃើញថា ក្មេងប្រុសម្នាក់នោះ មានសភាពស្ងប់ស្ងៀម និងឯកោណាស់។ ខ្ញុំបានឃើញស្នាមរបួសជាច្រើនលើខ្លួនរបស់គេ ប៉ុន្តែខ្ញុំមិនបានចាត់វិធានការអ្វីឡើយ រហូតទាល់តែដល់ថ្ងៃមួយដែលគេបានបាត់ខ្លួន "។*

ទោះបីជាឪពុកម្តាយ តែងតែណែនាំកូនៗរបស់ខ្លួនពីគ្រោះថ្នាក់ដែលបង្កឡើងដោយជនចម្លែក ក៏មនុស្សពេញវ័យនៅមិនទាន់មានការយល់ដឹងពីរបៀប និងវិធីសាស្ត្រលួងលោមរបស់ជនប្រព្រឹត្តិបទល្មើសផ្លូវភេទលើកុមារមួយចំនួននៅឡើយ។ អ្នកមានកាតព្វកិច្ចម្នាក់ក្នុងខេត្តមណ្ឌលគិរី នៃប្រទេសកម្ពុជា យល់ថាច្រើនមានបញ្ហាទំនាក់ទំនងផ្លូវភេទរវាងកុមារតូចៗ ដែលច្រើនទទួលរងសម្ពាធពីមិត្តភក្តិ ជាជាងពីជនបរទេស ៖ "*បច្ចុប្បន្ននេះ សិស្សសាលាមួយចំនួនដែលរៀននៅអនុវិទ្យាល័យប្រឡូកក្នុងទំនាក់ទំនងផ្លូវភេទ។ នេះជាបញ្ហាដែលខ្ញុំព្រួយបារម្ភ ប៉ុន្តែខ្ញុំមិនបានព្រួយបារម្ភច្រើនពីការរំលោភបំពានកុមារតាមរយៈជនបរទេសនោះឡើយ។ ត្រូវមានការយកចិត្តទុកដាក់ពីបញ្ហា និងអាទិភាពក្នុងមូលដ្ឋាន និងត្រូវសហការរាល់អន្តរាគមន៍ ក្នុងសហគមន៍ជុំវិញបញ្ហាការរំលោភបំពានផ្លូវភេទលើកុមារ។*"

# ព័ត៌មាន និងការអប់រំពីផ្លូវភេទ

ផ្នែកនេះនឹងបង្ហាញពីមធ្យោបាយដែលកុមារទទួលបានព័ត៌មានពីបញ្ហាផ្លូវភេទ អាកប្បកិរិយា និងគុណតម្លៃ និងការជះឥទ្ធិពលដល់ជីវិតរស់នៅ និងភាពងាយរងគ្រោះទៅនឹងការរំលោភបំពានទៅតាមទីតាំងស្រាវជ្រាវនីមួយៗ។ យ៉ាងហោចណាស់ មានប្រភពព័ត៌មានសំខាន់ៗចំនួន ៥ រួមមាន ប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធអ៊ីនធើរណិត មិត្តភក្តិ កម្មវិធីអប់រំនៅសាលា យុទ្ធនាការផ្សព្វផ្សាយព័ត៌មានជា សាធារណៈ និងការអង្កេត និងបទពិសោធន៍ផ្ទាល់ខ្លួន។.

## សាលារៀន

កម្មវិធីអប់រំពីបញ្ហាផ្លូវភេទដែលសិស្សម្នាក់ៗបានរៀនសូត្រ ផ្តោតលើប្រធានបទ ដូចជា កាយវិភាគសាស្ត្រ សុខភាពបន្តពូជ ការពន្យារកំណើត និងជំងឺកាមរោគដែលមានលក្ខណៈលម្អិត។ យ៉ាងណាក៏ដោយ កម្រមានការផ្សព្វផ្សាយពីព័ត៌មានទាក់ទងនឹងការកំណត់ និងការពារការរំលោភបំពានផ្លូវភេទណាស់ លើកលែងតែសាលាមួយនៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ ដែលបង្រៀនសិស្សពីរបៀបការពារផ្នែកសំខាន់ៗនៃរាងកាយ និងកំណត់ពីស្ថានភាពដែលមានគ្រោះថ្នាក់។ ពេលខ្លះ ដំបូន្មាន ឬព័ត៌មានដែលបានផ្តល់ឲ្យនោះ ហាក់រក្សានូវកេរ្តិ៍ឈ្មោះរបស់សាលា ជាជាងការពារកុមារ ដូចជា នាយកសាលាម្នាក់ក្នុងខេត្តសៀមរាបនៃប្រទេសកម្ពុជា បានលើកឡើងថា "យើងចង់ឲ្យសិស្សសាលាទាំងអស់ក្លាយជាសិស្សល្អ ពីព្រោះប្រសិនបើមានសិស្សណាម្នាក់មានឈ្មោះមិនល្អ នោះកេរ្តិ៍ឈ្មោះរបស់សាលាក៏ត្រូវបាត់បង់ទៅតាមនោះដែរ"។ នៅប្រទេសវៀតណាម គ្រូបង្រៀនមានលក្ខណៈបើកចំហរក្នុងការរៀបចំកម្មវិធីសិក្សាពីបញ្ហាផ្លូវភេទដល់សិស្ស ជាងឪពុកម្តាយរបស់សិស្ស ប៉ុន្តែមិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបង្រៀនវគ្គនេះឡើយ ដោយសំអាងថា មានតែគ្រូចិត្តវិទ្យាប៉ុណ្ណោះ ដែលអាចបង្រៀនមេរៀននេះបាន។ ជារួម ឱកាសក្នុងការបង្រៀនមេរៀនស្តីពីបញ្ហាផ្លូវភេទក្នុងសាលាដែលផ្តោតលើទំនាក់ទំនង និងការរំលោភបំពាន ត្រូវបានកំណត់យ៉ាងច្បាស់លាស់។

## ឪពុកម្តាយ

ការសិក្សាបានបង្ហាញថា ឪពុកម្តាយមិនអាចផ្តល់ប្រភពព័ត៌មានគ្រប់គ្រាន់ដល់កូនៗរបស់ខ្លួនពីបញ្ហា សិទ្ធិកុមារ និងការរំលោភបំពានផ្លូវភេទកុមារឡើយ ទោះបីជា ជារឿយៗ កុមារបានរាយការណ៍ថា ឪពុកម្តាយ គឺជាបុគ្គលដែលមានឥទ្ធិពលខ្លាំងបំផុតលើជីវិតរស់នៅរបស់ពួកគេក៏ដោយ។ ជាទូទៅ ឪពុកម្តាយ មិនបានដឹងថា កូនៗរបស់ខ្លួនទទួលបានព័ត៌មានទាក់ទងនឹងបញ្ហាផ្លូវភេទតាមរបៀបណានោះឡើយ។ មនុស្សពេញវ័យភាគច្រើន ដូចជាឪពុកម្តាយ មិនពេញចិត្តនឹងកម្មវិធីសិក្សាពីបញ្ហាផ្លូវភេទនោះទេ ដោយបារម្ភថា កម្មវិធីនេះនឹងធ្វើឲ្យកូនៗរបស់គាត់កាន់តែចង់ដឹង និងឈានទៅរកការប្រឡូកក្នុងការរួមភេទ និងមានអាកប្បកិរិយាមិនសមរម្យ។

គ្រូម្នាក់នៅទីក្រុងវៀងច័ន្ទ នៃប្រទេសឡាវ បានលើកឡើងថា "*ឪពុកម្តាយកម្រពិភាក្សាពីបញ្ហាផ្លូវភេទជាមួយកូនៗរបស់ខ្លួនណាស់ ហើយឪពុកម្តាយមួយចំនួនធំ មិនទាំងដឹងពីបញ្ហាដែលត្រូវពិភាក្សាផង*"។



ជាទូទៅ ឪពុកម្តាយបានណែនាំ និងផ្តល់ដំបូន្មានល្អៗដល់កូនៗរបស់ខ្លួន ប៉ុន្តែមិនបានផ្តល់ចំណេះដឹង ឬជំនាញក្នុងការបញ្ចៀសពីការរំលោភបំពានទាំងនោះឡើយ។ ឧ. ឪពុកម្តាយប្រាប់កូនស្រីរបស់ខ្លួនពីគ្រោះថ្នាក់នៅពេលដែលឲ្យអ្នកដទៃប៉ះពាល់ខ្លួន ឬមើលឃើញរាងកាយក្នុងស្ថានភាពដែលមិនមាន សំលៀកបំពាក់បិទបាំង ប៉ុន្តែមិនបានពន្យល់ប្រាប់ពីប្រភេទមនុស្សដែលអាចក្លាយជាជនល្មើស ឬផ្តល់ព័ត៌មាន លម្អិតពីគ្រោះថ្នាក់នោះឡើយ។ ម្តាយម្នាក់នៅទីក្រុង Luang Prabang ប្រទេសឡាវ បានបង្ហាញថា "***ឪពុកម្តាយមិនបានពិភាក្សាពីបញ្ហាផ្លូវភេទជាមួយកូនៗរបស់ខ្លួនឡើយ ប៉ុន្តែខ្ញុំបានព្យាយាមពិភាក្សាពីបញ្ហានេះ ដោយសារខ្ញុំចង់ឲ្យពួកគេដឹងពីបញ្ហានេះ និងការពារពួកគេ ដោយស្វែងរកចម្លើយពីប្រភពផ្សេងៗដែលខ្ញុំមិនបានដឹង***"។ គ្រូបង្រៀនម្នាក់នៅទីក្រុងវៀងច័ន្ទនៃប្រទេសឡាវ ក៏បានបង្ហាញ ពីបញ្ហាដូចគ្នានេះថា "***ឪពុកម្តាយកម្រពិភាក្សាពីបញ្ហាផ្លូវភេទជាមួយកូនៗរបស់ខ្លួនណាស់ ហើយឪពុកម្តាយមួយចំនួនធំ មិនទាំងដឹងពីបញ្ហាដែលត្រូវពិភាក្សាផង***"។ អ្នកមានកាតព្វកិច្ចមក់ក្នុងខេត្តមណ្ឌលគិរីនៃប្រទេសកម្ពុជាយល់ថា "***សិស្សបានរៀនសូត្រពីបញ្ហាផ្លូវភេទពីសាលា ឬពីអង្គការមិនមែនរដ្ឋាភិបាលជាជាងពីឪពុកម្តាយរបស់ខ្លួន***"។ ជាទូទៅ ឪពុកម្តាយមានអាកប្បកិរិយា ការពារកូនៗរបស់ខ្លួនក្នុងកម្រិតមួយដែលពួកគាត់អាចធ្វើបាន។ យ៉ាងណាក៏ដោយ ឪពុកម្តាយមួយចំនួនមិនទទួលបានព័ត៌មាន គ្រប់គ្រាន់ពីតថភាពពិតនៃការរំលោភបំពានផ្លូវភេទលើកុមារនោះឡើយ។

ការស្រាវជ្រាវបានបង្ហាញថា ភាគច្រើន កុមារពិភាក្សាពីការព្រួយបារម្ភ ឬបញ្ហាផ្ទាល់ខ្លួនជាមួយមិត្តភក្តិជាជាងពិភាក្សាជាមួយឪពុកម្តាយ គ្រូបង្រៀន ឬមនុស្សពេញវ័យផ្សេងទៀត។ កុមារីម្នាក់ក្នុងខេត្តមណ្ឌលគិរីប្រទេសកម្ពុជា បានលើកឡើងថា "***ជាទូទៅ ខ្ញុំទៅលេងមិត្តភក្តិរបស់ខ្ញុំដើម្បីប្រាប់ពីរឿងរ៉ាវដែលធ្វើឲ្យខ្ញុំមិនសប្បាយចិត្ត***"។ កុមារីវៀតណាមម្នាក់ អាយុ ១៧ ឆ្នាំ មិនបានប្រាប់ឪពុកម្តាយរបស់នាងពីរឿងដែលនាងមានមិត្តប្រុសនោះឡើយ ៖ "***ខ្ញុំនឹងមិនប្រាប់ឪពុកម្តាយរបស់ខ្ញុំឡើយ ពីព្រោះពួកគាត់នឹងពិបាកចិត្ត និងព្រួយបារម្ភទៀតផង***"។ យោងតាមកុមារផ្ទាល់ ហេតុផលដែលពួកគេសម្រេចមិនប្រាប់បញ្ហាផ្ទាល់ខ្លួនដល់ឪពុកម្តាយនោះគឺ "***ខ្ញុំមិនចង់ឲ្យឪពុកម្តាយរបស់ខ្ញុំពិបាកចិត្តឡើយ***" "***ខ្ញុំខ្លាចគាត់ស្តីបន្ទោស ឬវាយដំខ្ញុំ***" ***ហើយ*** "***ខ្ញុំមិនចង់ឲ្យគាត់រងការឈឺចាប់ដោយសារតែខ្ញុំឡើយ***"។

ជាទូទៅ កុមារធំៗ ច្រើនពិភាក្សាពីបញ្ហាផ្ទាល់ខ្លួនជាមួយមិត្តភក្តិ ជាជាងជាមួយឪពុកម្តាយរបស់ខ្លួន ហើយការណ៍ដែលមិនបានប្រាប់ឪពុកម្តាយរបស់ខ្លួនពីស្ថានភាពដែលខ្លួនរង ការរំលោភបំពាននេះ នឹងរឹតតែធ្វើឲ្យពួកគេ ប្រឈមនឹងភាពងាយរងគ្រោះកាន់តែខ្លាំង។ ឧទាហរណ៍ កុមារីវៀតណាមម្នាក់អាយុ ១៧ ឆ្នាំ បានរាយការណ៍មកថា នាងត្រូវបានផ្ទេរពីសាលាចាស់របស់នាង ទៅសាលាថ្មី ដែលឪពុកម្តាយរបស់នាងគិតថា ជាសាលាដែលមានកេរ្តិ៍ឈ្មោះ និងមានកម្មវិធីសិក្សាល្អ។ យ៉ាងណាក៏ដោយ នៅសាលាថ្មីនោះ នាងទទួលរងការគំរាមកំហែង និងមិនអាចមានមិត្តភក្តិបានឡើយ ហើយនាង យល់ថា លំហាត់នៅសាលានេះមានការលំបាកជាងលំហាត់នៅសាលាចាស់របស់នាង ហើយនាង ត្រូវរៀនត្រួតថ្នាក់ទី ១០ ទៀត។ បញ្ហានេះ បានធ្វើឲ្យឪពុកម្តាយរបស់នាង ខកចិត្តយ៉ាងខ្លាំង។

ដោយសារភាពមានៈរបស់ឪពុកម្តាយនាង បានធ្វើឲ្យនាងប្រឡូកក្នុងសកម្មភាពផ្លូវភេទ ជាមួយបុរសម្នាក់អាយុ ២៤ ឆ្នាំ ដែលធ្លាប់មានមិត្តស្រីរួចមកហើយ ( គាត់នៅតែបន្តទំនាក់ទំនង ជាមួយមិត្តស្រីនោះ )។ កុមារីនោះ ដឹងថា បុរសនោះមានមិត្តស្រីរួចហើយ ហើយបុរសនោះទុកនាងគ្រាន់តែជាឧបករណ៍កំសាន្តអារម្មណ៍តែប៉ុណ្ណោះ ប៉ុន្តែយ៉ាងណាក៏ដោយ នាងនៅតែបន្តទំនាក់ទំនងជាមួយបុរសនោះ ហើយនាងបានស្រឡាញ់បុរសនោះដោយមិនអាចអត់រូបគេបានឡើយ។ ឪពុកម្តាយរបស់កុមារីនេះមិនបានដឹងពីទំនាក់ទំនងស្នេហា ឬវិបត្តិផ្លូវចិត្តរបស់នាងឡើយ។

## បទពិសោធន៍/ការអង្កេត

កុមារតាមដងផ្លូវ កុមារដែលធ្វើការ និងសិស្សដែលរៀនជំនាញបានបង្ហាញពីការយល់ដឹងយ៉ាងច្រើនទាក់ទងនឹងបញ្ហាផ្លូវភេទ ជាជាងសិស្សសាលា ដូចជា តាមរយៈការទទួលបានព័ត៌មានពី ការអង្កេតដោយផ្ទាល់ ការពិភាក្សាជាមួយមិត្តភក្តិ និងបទពិសោធន៍ផ្ទាល់ខ្លួន។ ឧ. កុមារតាមដងផ្លូវ ក្នុងទីក្រុងហូជីមិញ និងហៃហ្វុង នៃប្រទេសវៀតណាម ច្រើនពិភាក្សាពីប្រធានបទទាក់ទងនឹងផ្លូវភេទ ហើយកុមារមួយចំនួនបានឃើញការរួមភេទក្នុងបន្ទប់ទឹក ឬកន្លែងផ្សេងទៀត។ កុមារទាំងនោះ មិនទទួលបានការអប់រំផ្លូវការពីបញ្ហាផ្លូវភេទឡើយ ដោយសារពួកគេបានឈប់រៀនមុនថ្នាក់ទី ៧ ឬ ទី៨ បើទោះជាពួកគេប្រឡងជាប់ក៏ដោយ។ អ្នកថែទាំម្នាក់នៅសាលាមធ្យមសិក្សាមួយ នៅប្រទេសវៀតណាម បានលើកឡើងថា ជារឿយៗ គាត់បានបោសសំអាតស្រោមអនាម័យ និងខោអាវទ្រនាប់ដែលបាន បោះ ចោលជិតបន្ទប់ទឹក។ សិស្សសាលាជំនាញម្នាក់បានរៀបរាប់ថា នាងបានដឹងថា បងប្រុសរបស់នាងបានរួមភេទជាមួយមិត្តស្រីរបស់គាត់ក្រោយរាំងននដ៏ស្តើងក្នុងបន្ទប់តូចមួយក្រោមដំបូលផ្ទះដែលក្រុមគ្រួសារ របស់នាងសម្រាក ចំណែកកុមារីម្នាក់ទៀតបានលើកឡើងថា នាងបានឃើញបុរសម្នាក់អាយុប្រហែល ៣០ ឆ្នាំ រួមភេទជាមួយកុមារីម្នាក់អាយុប្រហែល ១៥ ឆ្នាំ ក្នុងបង្គន់។ កុមារពីរនាក់ទៀតបានរៀបរាប់ថា ធ្លាប់មានជនចម្លែកដើរតាមពីក្រោយ និងបានហុចកញ្ចប់ តូចៗឲ្យខ្លួនយកទៅតាមកន្លែងផ្សេងៗ ខណៈ ដែលកុមារាអាយុ ១២ឆ្នាំបានរៀបរាប់ថាខ្លួនស្ទើរតែត្រូវ បានគេចាប់ជំរិតកាលពី ៣ ឆ្នាំមុន។ អ្នកជិត ខាងម្នាក់បានឃើញហេតុការណ៍នេះ និងបានស្រែក ហើយអ្នកចាប់ជំរិតក៏រត់បាត់ទៅ។ កុមារីភាគច្រើន ដែលជាអ្នកលក់វត្ថុអនុស្សាវរីយ៍តាមផ្លូវ ក៏ធ្លាប់ត្រូវបានមនុស្សចម្លែកដើរតាម ដោយសន្យាថានឹងចិញ្ចឹម  និងមើលថែពួកគេផងដែរ។

## ប្រព័ន្ធផ្សព្វផ្សាយ បច្ចេកវិទ្យាឌីជីថល និងបណ្តាញអ៊ីនធើរណិត

កុមារភាគច្រើនដែលផ្តល់បទសម្ភាស បានលើកឡើងថា ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ការផ្ញើរសារ និងកម្មវិធីហ្គេមតាមអ៊ីនធើរណិតកំពុងមានការកើនឡើងយ៉ាងគំហុក។ កុមារត្រូវការព័ត៌មានជាច្រើនទាក់ទង នឹងផ្លូវភេទ និងព័ត៌មានដែលត្រឹមត្រូវពីបណ្តាញក្រៅផ្លូវការ ដូចជា មិត្តភក្តិ ទូរទស្សន៍ ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញអ៊ីនធើណិត។ រូបភាព និងព័ត៌មានស្តីពីបញ្ហាផ្លូវភេទត្រូវបានរាយការណ៍គ្រប់ទីកន្លែង។ តាមការស្រាវជ្រាវ កុមារងាយនឹងទទួលបានព័ត៌មានពីបញ្ហាផ្លូវភេទ ឬជជែកជាមួយជនចម្លែកតាមបណ្តាញផ្សព្វផ្សាយសង្គម។ មនុស្សពេញវ័យមិនបានគ្រប់គ្រងកុមារដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ អ៊ីនធើរណិត និងទម្រង់ផ្សេងទៀតនៃបច្ចេកវិទ្យាឡើយ។

មនុស្សពេញវ័យបានរៀបរាប់ថា ការញៀននឹងការជជែកកំសាន្ត វីដេអូហ្គេម ការមើលរូបភាពអាសអាភាស ការល្បួងបញ្ឆោតតាមអ៊ីនធើរណិត និងការលួចប្រាក់យកទៅលេងហ្គេម សុទ្ធតែជាបញ្ហាបង្កឡើង ដោយបច្ចេកវិទ្យាឌីជីថល និងអ៊ីនធើរណិត។ គ្រូបង្រៀន និងឪពុកម្តាយច្រើនត្អូញត្អែរថា កន្លែងដែលបើកបម្រើសេវាអ៊ីនធើរណិត និងហ្គេម ច្រើនប្រមូលផ្តុំនៅជុំវិញបរិវេណសាលា ហើយកត្តានេះហើយដែលធ្វើឲ្យសិស្សជាច្រើនមិនចូលរៀនដើម្បីទៅលេងហ្គេម និងជជែកកំសាន្តក្នុងកន្លែងទាំងនេះ។ អ្នកមានកាតព្វកិច្ច និងអាជ្ញាធរបានសន្និដ្ឋានថា ភាពចង់ដឹងចង់លឺរបស់កុមារ និងចំណង់ផ្លូវភេទ ត្រូវបានជំរុញតាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ជាពិសេស បណ្តាញអ៊ីនធើរណិតដោយសេរី។

ស្របពេលជាមួយគ្នានេះ មានការរាយការណ៍មកថា ជនប្រព្រឹត្តិបទល្មើសផ្លូវភេទ កំពុងតែប្រើប្រាស់បណ្តាញអ៊ីនធើរណិតកាន់តែច្រើន ទាំងឧបករណ៍ទាក់ទាញដែលបង្កើតបានជាមធ្យោបាយទំនាក់ទំនងនៅក្រៅប្រទេស និងពង្វក់កុមារឲ្យប្រឡូកក្នុងសកម្មភាពរំលោភបំពាន[៩៤]។ ជនប្រព្រឹត្តិបទល្មើសច្រើនផលិតជារូបភាពរំលោភបំពានកុមារ ដែលអាចចែកចាយទាំងក្នុង និងក្រៅប្រទេសតាមបណ្តាញរបស់

[៩៤] Keane, K (ឆ្នាំ២០០៦) ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមដងផ្លូវនៅទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ៖ រឿងរ៉ាវរបស់ជនរងគ្រោះ អង្គការ Action Pour Les Enfants។

ជនប្រព្រឹត្តិបទល្មើសផ្លូវភេទតាមអ៊ីនធើរណិត[៩៥]។ ជារួម កុមារហាក់មិនបានដឹងពីគ្រោះថ្នាក់ដែលជនចម្លែក បង្កឡើងតាមបណ្តាញអ៊ីនធើណិតនោះឡើយ ទោះបីជាមានការកើនឡើងនូវការរាយការណ៍ពីឧប្បត្តិហេតុដែលទើបកើតមានថ្មីៗ ដូចជា "ការបង្ហាញដងខ្លួន" និង "ការជជែកកំសាន្តពីបញ្ហាផ្លូវភេទ" ដែលបានធ្វើឲ្យកុមារយល់ព្រម ឬបង្ខំចិត្តបង្ហោះយករូបភាពទាក់ទងនឹងផ្លូវភេទ ឬបង្ហាញដងខ្លួនរបស់ពួកគេតាមកម្មវិធី webcam ជាដើម[៩៦]។

ព័ត៌មានទូទៅទាក់ទងនឹងការការពារអត្តសញ្ញាណ ព្រមទាំងការយល់ដឹងពីការគំរាមកំហែង ដូចជាការលួងលោម តាមបណ្តាញអ៊ីនធើរណិតនៅមានកម្រិត ហើយកុមារមួយចំនួនដែលបានផ្តល់បទសម្ភាសបានរាយការណ៍ថា ពួកគេបានលាក់បាំងព័ត៌មានផ្ទាល់ខ្លួន ដែលពួកគេយល់ថា មិនអាចប្រាប់ទៅមិត្តភក្តិ ឬសមាជិកគ្រួសារឲ្យដឹងថា ពួកគេកំពុងជជែកកំសាន្តតាមបណ្តាញអ៊ីនធើរណិតជាមួយជនចម្លែកឡើយ។ សិស្សវិទ្យាល័យជនជាតិវៀតណាមអាយុ ១៦ ឆ្នាំ ម្នាក់ បានរាយការណ៍ថា បច្ចុប្បន្ននេះ នាងមាន yahoo IDs ចំនួន ២០ ក្នុងចំណោម yahoo IDs ២០០ ក្នុងតារាងទំនាក់ទំនង ដែល yahoo IDs ទាំងនោះគឺជា yahoo IDs របស់ជនចម្លែកដែលនាងចាត់ទុកជាមិត្តភក្តិរបស់នាង។ នាងបានឲ្យលេខទូរស័ព្ទទៅមនុស្សចម្លែក ៥នាក់ ដែល ៤ នាក់ជាមនុស្សប្រុស។ បន្ទាប់ពីឲ្យលេខទូរស័ព្ទគ្នាទៅវិញទៅមក ការជជែកកំសាន្តតាមបណ្តាញអ៊ីនធើរណិតបានប្តូរជាទៅជាការផ្ញើរសារតាមទូរស័ព្ទ និងការទូរស័ព្ទទៅវិញទៅមក។

### យុទ្ធនាការជាសាធារណៈ:

យុទ្ធនារការផ្សព្វផ្សាយ ដែលសំដៅលើកកម្ពស់ការយល់ដឹងពីបញ្ហាការរំលោភបំពានផ្លូវភេទកុមារ ផ្តោតលើកុមារ និងអ្នកមានកាតព្វកិច្ច។ ដូចដែលអ្នកមានកាតព្វកិច្ចម្នាក់បានលើកឡើងថា ៖

> *"ក្មេងៗ ត្រូវដឹងពីរបៀបការពារខ្លួនពីគ្រោះថ្នាក់ពាក់ព័ន្ធនឹងផ្លូវភេទឲ្យបានច្រើន។ ដោយសារតែទីក្រុង ផាត់តាយ៉ា ជាមជ្ឈមណ្ឌលទេសចរណ៍ផ្លូវភេទ។ ក្មេងៗទាំងនោះកំពុងរៀនសូត្រ និងរស់នៅក្នុងកន្លែងកំសាន្តរបស់មនុស្សពេញវ័យ។ ហេតុដូច្នេះហើយ ពួកគេត្រូវការការណែនាំ និងស្វែងយល់ពីបញ្ហាឲ្យបានកាន់តែប្រសើរតាំងពីនៅក្មេង ពោលគឺចាប់ពីអាយុ ៩ ឬ ១០ ឆ្នាំ "*។



មានការបង្ហាញថា សិស្សសាលានៅទីក្រុង ហៃ ហ្វុង ប្រទេសវៀតណាម ដែលធ្លាប់ចូលរួម ក្នុងសិក្ខាសាលា ស្តីពីការការពារកុមាររបស់អង្គការ World Vision មានការយល់ដឹងយ៉ាងច្រើន ពីការរំលោភបំពានផ្លូវភេទកុមារ ជាងកុមារវៀតណាមផ្សេងទៀត ដែលបានផ្តល់បទសម្ភាស។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ ជាទូទៅ មិនមានការផ្តល់វគ្គបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹង ដល់ឪពុកម្តាយនោះឡើយ លើកលែងតែករណីមួយក្នុង ទីក្រុងឈៀងម៉ៃនៃប្រទេសថៃ ដែលអង្គការមិនមែនរដ្ឋាភិបាលមួយបានផ្តល់វគ្គអប់រំដល់ សហគមន៍ស្តីពីបញ្ហាផ្លូវភេទ និងការសម្របសម្រួលរវាងឪពុកម្តាយ និងកូន។

## ចំណេះដឹងពីច្បាប់ និងសិទ្ធិ

### កុមារភាព និងសិទ្ធិកុមារ

ពាក្យ "កុមារភាព" មាននិយមន័យខុសៗគ្នា ទៅតាមអ្នកផ្តល់បទសម្ភាសតាមទីតាំងស្រាវជ្រាវ នីមួយៗ។ ឧ. យោងតាមការស្រាវជ្រាវក្នុងចំណោមមនុស្សពេញវ័យ និងកុមារនៅប្រទេសឡាវ បានបង្ហាញថា ពាក់ព័ន្ធនឹងការកំណត់និយមន័យពាក្យ "កុមារភាព និងភាពពេញវ័យ" ទំនួលខុសត្រូវរបស់មនុស្សម្នាក់ ពិតជាមានសារៈសំខាន់ជាងអាយុជាក់ស្តែងរបស់បុគ្គលនោះ។ តាមការស្រាវជ្រាវ កុមារត្រូវគោរព និង ស្តាប់បង្គាប់ឪពុកម្តាយរបស់ខ្លួន។ យ៉ាងណាក៏ដោយ កុមារដែលផ្តល់បទសម្ភាសក្នុងទីតាំងស្រាវជ្រាវនីមួយៗ មានការយល់ដឹងបានយ៉ាងប្រសើរថា កុមារគួរទទួលការការពារពីគ្រោះថ្នាក់ ទទួលបានការថែទាំ និងមានឱកាសចូលរៀន។

ជាទូទៅ កុមារក្នុងប្រទេសកម្ពុជា ថៃ និងវៀតណាម មានការយល់ដឹង ពីគោលគំនិតស្តីពីសិទ្ធិកុមារ។ កុមារនៅកម្ពុជា និងវៀតណាម បង្ហាញពីការយល់ដឹងយ៉ាងប្រសើរពីនិយមន័យផ្លូវការ។

[៩៥] Keane, K (ឆ្នាំ២០០៦) ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមដងផ្លូវនៅទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ៖ រឿងរ៉ាវរបស់ជនរងគ្រោះ អង្គការ Action Pour Les Enfants។

[៩៦] អង្គការ UNICEF (ឆ្នាំ២០១១) ការវិភាគពីការជួញដូរផ្លូវភេទកុមារតាមបណ្តាខេត្ត និងទីក្រុងមួយចំនួនក្នុងប្រទេសវៀតណាម។

កុមារតាមផ្លូវ និងសិស្សសាលាភាគច្រើនក្នុងខេត្តសៀមរាបនៃប្រទេសកម្ពុជា សុទ្ធតែយល់ពាក្យ "សិទ្ធិកុមារ" និង "ការការពារកុមារ"។ នៅឃុំពួក សិស្សសាលាបានយល់ពីខ្លឹមសារក្នុងអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងអាចរៀបរាប់ពីសិទ្ធិរបស់ខ្លួនប្រាប់ទៅអ្នកស្រាវជ្រាវទៀតផង។ នៅប្រទេសវៀតណាម សិស្សសាលាយល់ពីពាក្យ "សិទ្ធិកុមារ" ដែលមានបង្រៀនក្នុងម៉ោងសិក្សាសង្គម។ កុមារមួយចំនួនបានលើកឡើងថា ពួកគេធ្លាប់ដឹងសិទ្ធិកុមារតាមរយៈ ការមើលទូរទស្សន៍ ឬការអានកាសែត។ ទោះបីជា កាលពីទស្សវត្សរ៍កន្លងទៅ រដ្ឋាភិបាលបានលើកឡើងពីភាពចាំបាច់ក្នុងការផ្តល់ការថែទាំ និងការការពារកុមារ[៩៧]ឲ្យបានប្រសើរក៏ដោយ បញ្ហាសិទ្ធិកុមារ និងការការពារកុមារ នៅតែជាពាក្យមួយថ្មីសម្រាប់គ្រួសារ និងសហគមន៍ក្នុងប្រទេសឡាវ។

តាមរយៈការស្រាវជ្រាវ អ្នកមានកាតព្វកិច្ច និងមន្ត្រី ដែលត្រូវបានសាកសួរក្នុងអំឡុងពេលស្រាវជ្រាវ ក៏មានការយល់ដឹងទូទៅពីសិទ្ធិកុមារផងដែរ ហើយបន្ថែមពីនេះ មន្ត្រីទាំងនោះដឹងថា រដ្ឋមានកាតព្វកិច្ចការពារកុមារពីគ្រោះថ្នាក់នានា។ ទោះជាយ៉ាងណា មិនមានមន្ត្រីណាម្នាក់អាចប្រាប់ពីសកម្មភាពដែលកំពុងអនុវត្ត ដើម្បីការពារកុមារក្នុងតំបន់របស់ខ្លួនពីជនរំលោភបំពានផ្លូវភេទឡើយ។ នៅពេលសាកសួរសំណួរកាន់តែ លម្អិតពីកិច្ចការរបស់រដ្ឋាភិបាលក្នុងការការពារកុមារ អ្នកមានកាតព្វកិច្ច និងមន្ត្រីទាំងនោះបានផ្តល់អំណះអំណាងដូចៗគ្នា ដូចជា ពួកគេគួរ "អនុវត្តច្បាប់" ឬ "ត្រូវធានាថាកុមារមិនមានគ្រោះថ្នាក់"។ ខណៈដែលបុគ្គលិករដ្ឋ ដូចជា បុគ្គលិកសង្គម អ្នកផ្តល់សេវាសុខភាព ប៉ូលិស និងបុគ្គលិកអង្គការមិនមែន រដ្ឋាភិបាល មានការយល់ដឹងទូទៅពីសិទ្ធិកុមារ និងការការពារកុមារ ហើយនោះ ក៏ការយល់ដឹងមាន កម្រិតខុសៗគ្នាតាមទីតាំងដែលបានស្រាវជ្រាវ។ ជាទូទៅ មានការកំណត់គម្លាតរវាងចំណេះដឹង និងការផ្តល់សិទ្ធិកុមារ។

[៩៧] MLSW និងអង្គការ UNICEF (ឆ្នាំ២០០៩) ប្រព័ន្ធសុខុមាលភាពសង្គមក្នុងប្រទេសឡាវ ៖ ការវិភាគពីសេវាសុខុមាលភាពសម្រាប់ការការពារ និងការឆ្លើយតបទៅនឹងការរំលោភបំពាន អំពើហិង្សា និងការកេងប្រវ័ញ្ចកុមារ។

កុមារាអាយុ ១៦ ឆ្នាំ ម្នាក់ដែលរស់នៅតាមផ្លូវ បានលើកឡើងថា *"នៅពេលដែលអ្នកជាក្មេងតាមផ្លូវ និងរកស៊ីផ្លូវភេទ វានឹងមានការលំបាកដោយសារតែអ្នកមិនទាន់គ្រប់អាយុ។ អ្នកភ័យខ្លាចគ្រប់យ៉ាង ដូចជា ខ្លាចកុមារាធំៗតាមដងផ្លូវ និងប៉ូលិសជាដើម។ អ្នកមិនអាចបង្ហាញខ្លួនតាមផ្លូវ ហើយមិនមានបាណាមួយ ទទួលយកអ្នកឲ្យធ្វើការនោះឡើយ ពីព្រោះប៉ូលិសនឹងចាប់ខ្លួនអ្នក"*។

## អាយុគ្រប់ការតាមផ្លូវច្បាប់

អាយុគ្រប់ការដែលអាចរួមភេទបាន បង្ហាញពីអាយុដែលមនុស្សម្នាក់ត្រូវបានចាត់ទុកថា មានសមត្ថភាពទទួលខុសត្រូវលើការរួមភេទតាមផ្លូវច្បាប់។ អាយុគ្រប់ការតាមផ្លូវច្បាប់លើពិភពលោកមានលក្ខណៈខុសៗគ្នា និងទៅតាមភេទ ពោលគឺចាប់ពី ១៤ ដល់ ២១ ឆ្នាំ។ មានការទទួលស្គាល់ជាទូទៅថា មានកាលៈទេសៈ មួយចំនួនដែលបុគ្គលម្នាក់មិនមានសមត្ថភាពយល់ព្រមពេញលេញ និងព្រមព្រៀងដោយផ្អែកតាមព័ត៌មាន គ្រប់គ្រាន់ ដូចជា ករណីដែលមនុស្សម្នាក់បាត់បង់សមត្ថភាព ផ្នែកប្រាជ្ញាដោយសារពិការភាព ស្ថិតក្រោមឥទ្ធិពលថ្នាំញៀន ឬករណីដែលកុមារ មានអាយុតិចជាងអាយុគ្រប់ការតាមផ្លូវច្បាប់។ ប្រសិនបើជនរងគ្រោះត្រូវបានចាត់ទុកថា បាត់បង់សមត្ថភាពណាមួយ បុគ្គលដែលត្រូវបានចោទប្រកាន់ថាបានរំលោភសេពសន្ថវៈនោះ មិនអាចរួចខ្លួនដោយសំអាងថា ជនរងគ្រោះបានព្រមព្រៀងនោះឡើយ។ ហេតុនេះ អាយុគ្រប់ការ គឺសម្រាប់ការពារកុមារពីការរំលោភបំពានផ្លូវភេទ និងការរំលោភសេពសន្ថវៈ។ ដូច្នេះ ទស្សនៈវិស័យជាមូលដ្ឋាននៃការយល់ដឹងពីការរំលោភបំពានកុមារ គឺការទទួលបានចំណេះដឹងពីចំណុចដែលមានចែងក្នុងច្បាប់ទាក់ទងនឹងអាយុគ្រប់ការ។

អ្នកផ្តល់បទសម្ភាសក្នុងតំបន់ មិនបានចាត់ទុកអាយុគ្រប់ការស្របច្បាប់ថាជាយន្តការការពារ ការរំលោភបំពានផ្លូវភេទកុមារឡើយ។ ច្បាប់ស្តីពីអាយុគ្រប់ការត្រូវបានចាត់ទុកជាការដាក់ទណ្ឌកម្ម ជាជាងការការពារ។ ឧ. កុមារាអាយុ ១៦ ឆ្នាំម្នាក់ ដែលរស់នៅតាមផ្លូវបាននិយាយថា ៖

*"នៅពេលដែលអ្នកជាក្មេងតាមផ្លូវ និងរកស៊ីផ្លូវភេទ វានឹងមានការលំបាកដោយសារតែអ្នកមិនទាន់គ្រប់អាយុ។ អ្នកភ័យខ្លាចគ្រប់យ៉ាង ដូចជា ភ័យខ្លាចកុមារាធំៗតាមដងផ្លូវ និងប៉ូលិសជាដើម។ អ្នកមិនអាចបង្ហាញខ្លួនតាមផ្លូវ ហើយមិនមានបាណាមួយ ទទួលយកអ្នកឲ្យអ្នកធ្វើការនោះឡើយ ពីព្រោះប៉ូលិសនឹងចាប់ខ្លួនអ្នក។ "*

កុមារាដដែលនោះ ក៏បានរាយការណ៍ថា ប៉ូលិសក្នុងមូលដ្ឋានបានគំរាមកំហែងខ្លួន ដោយចោទប្រកាន់ថាបានប្រព្រឹត្តិល្មើសនឹងច្បាប់ ( ពេស្យាចារ ) នៅពេលដែលកុមារានោះ ព្យាយាមរាយការណ៍ពី ការរំលោភបំពានមកលើខ្លួន។ ក៏មានការយល់ដឹងផងដែរថា អាយុគ្រប់ការស្របច្បាប់គឺជាអាយុសម្រាប់កុមារី។ កុមារាអាយុ ១៤ ឆ្នាំម្នាក់បាននិយាយថា ៖

*"ខ្ញុំមិនធ្លាប់រួមភេទឡើយ...ប៉ុន្តែខ្ញុំគិតថា វាមិនមែនជាបញ្ហានោះឡើយ ទោះជាស្ថិតក្នុងអាយុណាក៏ដោយ។ កុមារាអាចធ្វើអ្វីគ្រប់យ៉ាងតាមចិត្តរបស់ខ្លួន និងអាចរួមភេទនៅពេលដែលមានចំណង់ផ្លូវភេទ។"*

សម្រាប់ករណីមួយចំនួន ឪពុកម្តាយ និងសមាជិកគ្រួសារមានការព្រួយបារម្ភខ្លាំង នៅពេលដែលមានវប្បធម៌ ដែលចាត់ទុកការរួមភេទជារឿងសមស្រប ( ឧ. បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ )។ ពួកគាត់យល់ថា សិស្សសាលាមិនគួររួមភេទនោះឡើយ ទោះបីជាពួកគេឈានដល់អាយុគ្រប់ការតាមផ្លូវច្បាប់ក៏ដោយ។

ចំណែកនៅកម្ពុជា ខណៈដែលសិស្សសាលាមានការយល់ដឹងយ៉ាងស៊ីជម្រៅពីសិទ្ធិកុមារ មិនមានសិស្សណាម្នាក់ ដឹងពីអាយុគ្រប់ការអប្បបរមាតាមផ្លូវច្បាប់ក្នុងការមានទំនាក់ទំនងផ្លូវភេទ ឬអាយុគ្រប់ការនោះឡើយ។ កុមារភាគច្រើនយល់ថា មានតែមនុស្សដែលមានអាយុច្រើនជាង ១៨ ឆ្នាំប៉ុណ្ណោះទើបអាចរួមភេទបាន ពោលគឺជាអាយុមួយដែលមនុស្សអាចរៀបការតាមផ្លូវច្បាប់បាន។ នៅប្រទេសវៀតណាម មិនមានកុមារ ឬឪពុកម្តាយណាម្នាក់ដឹងពីអាយុគ្រប់ការ ឬយល់ពីអត្ថន័យនៃពាក្យថាអាយុគ្រប់ការនោះឡើយ។ មនុស្សពេញវ័យជាច្រើននៅកម្ពុជា ដែលបានផ្តល់បទសម្ភាសរួមទាំង មន្ត្រីអនុវត្តច្បាប់ សុទ្ធតែមិនបានដឹងពីអាយុគ្រប់ការដូចគ្នា។

ចំណែកនៅប្រទេសឡាវវិញ អ្នកផ្តល់ព័ត៌មានភាគច្រើនបាននិយាយថា ប្រជាជនត្រូវមានអាយុយ៉ាងតិច ១៨ឆ្នាំ ទើបអាចរួមភេទបាន។ កុមារធំៗមួយចំនួនតូច បាននិយាយថា ការរួមភេទនៅអាយុ ១៥ ក៏សង្គមទទួលស្គាល់ផងដែរ ហើយក្រុមអាយុក្មេងៗ ពោលគឺអាយុ ១២ឆ្នាំ និងតិចជាងនេះ បានរៀបរាប់ថា ការរួមភេទគឺជារឿងដែលអាចទទួលយកបាន នៅពេលដែលបុគ្គលនោះមានអាយុ ២០ឆ្នាំ ឬច្រើនជាងនេះ។

នៅទីក្រុង ផាត់តាយ៉ា នៃប្រទេសថៃ កុមារភាគច្រើនដឹងពី "អាយុគ្រប់ការ" និងដឹងថា អាយុស្របច្បាប់ដែលកុមារមិនអាចរួមភេទបានគឺនៅអាយុ ១៥ ឆ្នាំ។ ផ្ទុយទៅវិញ នៅទីក្រុងឈៀងម៉ៃ សិស្សសាលាភាគច្រើនមិនទាន់ច្បាស់ពីអាយុដែលកុមារីមានសមត្ថភាពទទួលខុសត្រូវតាមផ្លូវច្បាប់ក្នុងការព្រមព្រៀងរួមភេទ ហើយភាគច្រើនគិតថា កុមារីអាចរួមភេទបានបន្ទាប់ពីរៀបការរួច ឬនៅពេលដែលកុមារីអាចរស់នៅដោយខ្លួនឯងបាន។ អ្នកមានកាតព្វកិច្ចនៅទីក្រុងឈៀងម៉ៃ និងផាត់តាយ៉ា ដឹងថានេះគឺជាអាយុគ្រប់ការស្របច្បាប់ ខណៈដែលមានតែឪពុកម្តាយនៅទីក្រុងផាត់ តាយ៉ាប៉ុណ្ណោះដែលដឹងពីបញ្ហានេះ។

ផ្ទុយទៅវិញ មន្ត្រីមូលដ្ឋាននៅប្រទេសវៀតណាម បានយល់យ៉ាងច្បាស់ពីគោលគំនិតនៃអាយុគ្រប់ការ ប៉ុន្តែភាន់ច្រឡំពីបញ្ហានេះ ដោយសារតែការរំលោភបំពានផ្លូវភេទលើកុមារមិនមានចែងក្នុងច្បាប់ពាក់ព័ន្ធ ហើយការរំលោភបំពានផ្លូវភេទត្រូវបានកំណត់ជាផ្លូវការថាជា "ការរួមភេទ"[៩៨]។

[៩៨] ក្រមព្រហ្មទណ្ឌ មាត្រា ១១២ បានចែងថា "គ្រប់ករណីដែលបុគ្គលម្នាក់រួមភេទជាមួយកុមារអាយុក្រោម ១៣ ឆ្នាំ ត្រូវចាត់ទុកជាការរំលោភសេពសន្ថវៈលើកុមារ" ( ការបង្កើតបរិយាកាសការពារកុមារនៅវៀតណាម ) ក្រសួងការងារជនពិការ និងសង្គមកិច្ច និងអង្គការ UNICEF ប្រចាំវៀតណាម ឆ្នាំ២០០៩ )។

ជំពូក ៣

# ឥរិយាបថ និងការអនុវត្ត



# ជំពូក ៣៖ ឥរិយាបថ និងការអនុវត្ត



**នៅក្នុងជំពូកមុន មានការពិភាក្សាពីចំណេះដឹងរបស់កុមារ និងមនុស្សពេញវ័យទាក់ទងគោលគំនិតនៃការរំលោភបំពានកុមារ ពោលគឺការរំលោភបំពានផ្លូវភេទកុមារ។ ជំពូកនេះ នឹងរៀបរាប់ពីការយកគោលគំនិតទាំងនោះទៅអនុវត្ត និងប្រព្រឹត្តិជាក់ស្តែង របៀបដែលការប្រព្រឹត្តិនេះមានទំនាក់ទំនងជាមួយកត្តាជំរុញបរិយាកាសកុមារ ទស្សនៈរបស់បុគ្គលម្នាក់ៗ សង្គម ការឆ្លើយតបទៅនឹងការអនុវត្ត និងការកើតមានការរំលោភបំពាន។**

## គុណតម្លៃ និងទំនៀមទម្លាប់

### ព្រហ្មចារី និងការប្រព្រឹត្តិផ្លូវភេទ

ការស្រាវជ្រាវបានបង្ហាញពីសារៈសំខាន់ផ្នែកវប្បធម៌ ដែលបានកំណត់លើកុមារីក្នុងតំបន់ឲ្យរក្សា ព្រហ្មចារីរហូតដល់ពេលរៀបការ។ ករណីនេះគឺសម្រាប់កុមារ និងមនុស្សពេញវ័យ ទោះបីជាបញ្ហានេះហាក់ដូចជាមានសារៈសំខាន់ខ្លាំងសម្រាប់មនុស្សពេញវ័យក៏ដោយ។ ខណៈដែលកុមារភាគច្រើនផ្តល់ តម្លៃលើព្រហ្មចារីរបស់ស្រ្តី ពួកគេមិនបានរាយការណ៍ពីការបញ្ចៀសការរួមភេទក្នុងស្ថានភាព ជាក់ស្តែងឡើយ។

នៅទីក្រុងឈៀងម៉ៃ នៃប្រទេសថៃ ទាំងឪពុកម្តាយ និងកូនៗ ចាត់ទុកកុមារីដែលបានបាត់បង់ ព្រហ្មចារីថាជាកុមារីមិន"ល្អ" ឬ "ធ្លាប់រងការប៉ះពាល់ (ផ្លូវភេទ)"។ នៅប្រទេសកម្ពុជា កុមារីដែលបានបាត់បង់ព្រហ្មចារីត្រូវបានចាត់ទុកថាអស់តម្លៃ ខណៈដែលនៅវៀតណាមសិស្សទាំងអស់ រាប់ទាំងសិស្សប្រុសនិងសិស្សស្រី បានផ្តោតលើសារៈសំខាន់នៃព្រហ្មចារីរបស់ស្រ្តី។ ផ្អែកតាមវប្បធម៌នៅប្រទេសឡាវ ប្រសិនបើកុមារីបាត់បង់ព្រហ្មចារីមុនពេលរៀបការ នាងត្រូវបានចាត់ទុកជា"មនុស្សធ្លាប់រងការប៉ះពាល់(ផ្លូវភេទ)"។

ឪពុកម្តាយតែងទូន្មានកូនស្រីរបស់ខ្លួនមិនឲ្យដើរលេងយប់ព្រលប់តែម្នាក់ឯង ដើម្បីការពារពី ការរំលោភបំពាន ឬការរំលោភសេពសន្ថវៈ។ អ្នកផ្តល់បទសម្ភាសមួយចំនួនក៏បានលើកឡើងថាប្រសិនបើកូនស្រីរងការរំលោភសេពសន្ថវៈ គ្រួសាររបស់ខ្លួននឹងរងភាពអាម៉ាស់ ហើយដោយសារតែការឲ្យតម្លៃខ្លាំង លើព្រហ្មចារីនេះហើយទើបគ្រួសារជាច្រើនសម្រេចចិត្តដោះស្រាយ បញ្ហាក្នុងរង្វង់គ្រួសារដោយមិនឲ្យអ្នកខាងក្រៅដឹងឡើយ។ បន្ថែមពីនេះ ឪពុកម្តាយមិនសូវខ្វាយខ្វល់ ពីសុវត្ថិភាពរបស់កូនប្រុសដូចកូនស្រីឡើយ។ ដូចជាករណីរបស់កុមារាឡាវម្នាក់ ឪពុកម្តាយរបស់ខ្លួនច្រើន ខ្វល់ខ្វាយតែពីបញ្ហាញៀនថ្នាំ និងស្រា។ លទ្ធផលរកឃើញបានបង្ហាញថា ការរំលោភបំពានផ្លូវភេទកុមារ និងការរំលោភសេពសន្ថវៈកុមារីត្រូវបានចាត់ទុកថាជាបញ្ហា "មុខមាត់" និងកេរ្តិ៍ឈ្មោះរបស់ គ្រួសារជាជាងសុខុមាលភាពនិងការការពារកុមារ។ ជាលទ្ធផល នៅពេលមានករណីបែបនេះកើតឡើង ក្រុមគ្រួសារច្រើននៅស្ងៀមនិងដោះស្រាយបញ្ហាដោយសងជំងឺចិត្ត។ មូលហេតុនៃការមិនយកចិត្តទុក ដាក់ការពារកូនប្រុសឲ្យបានច្រើននោះក៏ត្រូវបានលើកមកបង្ហាញផងដែរ។ បញ្ហាព្រួយបារម្ភខ្លាំងនោះ គឺការមិនបានយកចិត្តទុកដាក់លើតម្រូវការរបស់កុមារដែលរងការរំលោភបំពាន។

ការសិក្សាពីឥរិយាបថរបស់កុមារ និងមនុស្សពេញវ័យក្នុងទីក្រុងផាត់តាយ៉ានៃប្រទេសថៃ បានបង្ហាញថាមិនសូវមានលក្ខណៈអភិរក្សដូចជានៅទីតាំងស្រាវជ្រាវផ្សេងទៀតនោះឡើយ។ ដោយសារតែមានឧស្សាហកម្មបម្រើសេវាកំសាន្តក្នុងមូលដ្ឋានសម្រាប់វិស័យទេសចរណ៍ ព្រហ្មចារីត្រូវបានចាត់ទុកជាគោលគំនិតអរូបីមួយ។ កុមារនៅទីក្រុងផាត់តាយ៉ា មិនបានចាត់ទុកព្រហ្មចារីថា មានសារៈសំខាន់ដូចជាមនុស្សចាស់ៗក្នុងគ្រួសារឡើយ។ ឪពុកម្តាយព្រួយបារម្ភខ្លាំង ខ្លាចកូនមានផ្ទៃពោះ ជាជាងការណ៍ដែល កូនស្រីរបស់ខ្លួនបាត់បង់ព្រហ្មចារី។ ចំណែកការស្រាវជ្រាវនៅកន្លែងផ្សេងទៀត បង្ហាញឲ្យឃើញថា ព្រហ្មចារីរបស់កុមារីមិនចាត់ទុកថាមានសារៈសំខាន់សម្រាប់រក្សាកេរ្តិ៍ឈ្មោះគ្រួសារនោះឡើយ។ កត្តានេះហើយដែលបង្ហាញពីការរាយការណ៍ពីករណីរំលោភបំពានកាន់តែច្រើននៅទីក្រុងផាត់តាយ៉ា ជាជាងនៅទីក្រុងឈៀងម៉ៃ ដោយសារក្រុមគ្រួសារ អាចនិយាយបានដោយបើកចំហរពីបញ្ហាព្រហ្មចារី និងកេរ្តិ៍ឈ្មោះដោយមិនមានសម្ពាធពីសង្គម។ ដោយសារតែព្រហ្មចារីហាក់មានតម្លៃផ្នែកហិរញ្ញវត្ថុដោយប្រយោលនោះដូចករណី មានការព្រមព្រៀងសងជំងឺចិត្ត រវាងគ្រួសារទាំងពីរ ក្នុងករណីរួមភេទមុនពេល រៀបការ (ដើម្បី

សងជំងឺចិត្តលើការបាត់បង់ព្រហ្មចារីរបស់កុមារី ) គ្រួសារមួយចំនួនមានការព្រួយបារម្ភថា ការបាត់បង់ព្រហ្មចារីរបស់កុមារី ឬស្ត្រីវ័យក្មេង អាចដាក់សម្ពាធកាន់តែខ្លាំងថែមទៀតលើការលក់ផ្លូវភេទរបស់នាង ដើម្បីបានសំណងជំងឺចិត្តជាប្រាក់មកវិញ។

នៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ ការមាក់ងាយកុមារីដែលបាត់បង់ព្រហ្មចារីមានការធ្លាក់ចុះខ្លាំង ប៉ុន្តែគេនៅតែសង្កេតឃើញមានការមាក់ងាយនេះនៅឡើយ។ កុមារីត្រូវបានចាត់ទុកជាអ្នកដែលទាក់ទាញ និងជំរុញឲ្យបុរស និងកុមារាមានចំណង់ផ្លូវភេទ។ “កុមារីមិនល្អ” មិនទទួលបានការយកចិត្តទុកដាក់ពីសហគមន៍ឡើយ ហើយអ្នកផ្តល់បទសម្ភាសមួយចំនួនយល់ឃើញថា កុមារីមិនល្អទាំងនោះសមនឹងទទួលរងការរំលោភសេពសន្ថវៈ។ គ្រូម្នាក់នៅទីក្រុងផាត់តាយ៉ា បានលើកឡើងថា ៖

> *“បើដឹងថាស្លៀកពាក់បែបនេះខ្លីខ្លាំង ឬរឹបខ្លាំងហើយ ហេតុអ្វីក៏កុមារីទាំងនោះនូវតែស្លៀកពាក់បែបនេះទៀត ? បើដឹងថាពេលនេះយប់ជ្រៅ និងងងឹតហើយ ហេតុអ្វីក៏កុមារីទាំងនោះនៅតែទៅកន្លែងទាំងនោះទៀត ?"*

ទោះបីជានៅទីក្រុងឈៀងម៉ៃ នៃប្រទេសថៃមានការបញ្ជាក់ពីសារៈសំខាន់នៃព្រហ្មចារីយ៉ាងណាក៏ដោយ ការរួមភេទមុនរៀបការ ត្រូវចាត់ទុកជារឿងទូទៅសម្រាប់ទីតាំងស្រាវជ្រាវទាំងពីរ។ បន្ថែមពីនេះ សិស្ស គ្រូ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣រូប ក្នុងទីតាំងស្រាវជ្រាវទាំងពីរ បានរាយការណ៍ថា កុមារ “ជាច្រើន” តែងតែផ្លាស់ប្តូរដៃគូរួមភេទ និងថាមានការដាក់សម្ពាធពីមិត្តភក្តិដើម្បីប្រកួតប្រជែងគ្នាទៅវិញទៅមក។ នៅទីក្រុងឈៀងម៉ៃ សកម្មភាពនេះមានលក្ខណៈបិទបាំង ខណៈដែលនៅទីក្រុងផាត់តាយ៉ាវិញ សកម្មភាពបែបនេះត្រូវបានយកមកពិភាក្សាដោយបើកចំហរ។ នៅទីក្រុងឈៀងម៉ៃ អ្នកផ្តល់បទសម្ភាសបានរាយការណ៍ថា កុមារីដែលរស់នៅក្នុងអន្តេវាសិកដ្ឋានរបស់សាកលវិទ្យាល័យ ច្រើនឆ្លៀតពេលដែលខ្លួន “មានសេរីភាព” ប្រព្រឹត្តិឥរិយាបថជំរុញផ្លូវភេទកាន់តែច្រើន ធៀបនឹងអ្នកជំនាន់មុន។ អ្នកមានកាតព្វកិច្ចម្នាក់បានរាយការណ៍ថាបានឃើញកុមារីម្នាក់ដែលរស់នៅក្នុង អន្តេវាសិកដ្ឋានសាកលវិទ្យាល័យ *“ដើរលេងពេលយប់ ផឹកស្រាស្រវឹង និងស្លៀកពាក់មិនសមរម្យ”* ។

ទោះជាកុមារ និងយុវជនឡាវ ទទួលស្គាល់តម្លៃប្រពៃណី ប៉ុន្តែអ្នកទាំងនោះ មិនបានប្រកាន់ខ្ជាប់តម្លៃនោះឡើយ។ កម្មការនីរោងចក្រមកពីតំបន់ជនបទអាយុ ១៨ ឆ្នាំម្នាក់ ធ្វើការនៅទីក្រុង វៀងច័ន្ទ បានលើកឡើងថា នាងដឹងយ៉ាងច្បាស់ថា នារីឡាវត្រូវរក្សាព្រហ្មចារី រហូតដល់ថ្ងៃនាង រៀបការ។ យ៉ាងណាក៏ដោយ នាងយល់ថា ការបាត់បង់ ព្រហ្មចារីមុនពេលរៀបការ ក៏ជារឿងមួយដែលអាចទទួលយកបានផងដែរ ប្រសិន បើនាងបាត់បង់ដោយសារតែមិត្តប្រុសរបស់នាង  ហើយឥរិយាបថចំពោះព្រហ្មចារីរបស់យុវជនក៏ហាក់មានការផ្លាស់ប្តូរផងដែរ។

យោងតាមការស្រាវជ្រាវ នៅប្រទេសវៀតណាម ការរួមភេទមុនពេលរៀបការក៏ត្រូវបានចាត់ទុកជារឿងទូទៅផងដែរ។ ក្រុមស្រាវជ្រាវបានធ្វើបទសម្ភាសបុរសមួយក្រុម នៅទីក្រុងហៃហ្វុង ដែលបានចំណាយប្រាក់ពេលវេលា និងការប្រឹងប្រែងយ៉ាងច្រើន ក្នុងការទិញផ្លូវភេទសិស្សស្រី ដែលនៅមានព្រហ្មចារី[៩៩]។ បុរសដែល “ស្វែងរកសេវាផ្លូវភេទ” ទាំងនេះបានលើកឡើងពីសារៈសំខាន់ នៃការជម្នះកុមារី “ដែលប្រឆាំង” នឹងពួកគេ និងបានធ្វើឲ្យពួកគេយល់ថា ( ការភាន់ច្រឡំ ) ថានាងជាមនុស្សដែលមាន ការអប់រំខ្ពស់ ពោលគឺអ្វីមួយដែលធ្វើឲ្យពួកគេកាន់តែក្លាយជាបុរសពិត។ ផ្ទុយទៅវិញ បុរសយល់ឃើញថា ការបង្កើតទំនាក់ទំនងផ្លូវភេទជាមួយសិស្សស្រីក្នុងមូលដ្ឋាន និងស្ត្រីវ័យក្មេងដែលរង់ចាំរៀបការជាមួយ បុរសមកពីអាស៊ីបូព៌ានោះគឺជារឿងងាយស្រួលបំផុត។ កុមារីទាំងនោះមិនសូវខ្វល់ខ្វាយពីការបាត់បង់ ព្រហ្មចារីរបស់ខ្លួនឡើយ និង យល់ថាពួកគេស្ថិតនៅក្រៅក្រុមសង្គម។ បុរសបានលើកឡើងថា កុមារីទាំងនោះចង់មានដៃគូរួមភេទច្រើន មុនពេលពួកគេ “ប្រថុយ” ទៅរស់នៅជាមួយបុរសដែលជាប្តីថ្មីរបស់នាងនៅបរទេស។ ទោះយ៉ាងណាបុរសមិនបានឲ្យតម្លៃផ្លូវភេទដែលមានលក្ខណៈ “ងាយពេក” នោះឡើយ។ យោងតាមទស្សនៈវប្បធម៌ ការការពារព្រហ្មចារីគឺជាទំនួលខុសត្រូវរបស់ “កុមារីដែលមានចរិតល្អ” ហើយការប្រឆាំងតបនឹង ឬសើចចំអកដំណើរនាំដល់ការរួមភេទរបស់កុមារាគឺជាលក្ខណវិនិច្ឆ័យរបស់ “កុមារីដែលមានចរិតល្អ”។ ហេតុដូច្នេះ វប្បធម៌ចៃចង់នៅវៀតណាម ត្រូវបានចាត់ទុកថាសំខាន់ ដើម្បីបន្លំថា សកម្មភាពផ្លូវភេទគឺជារឿងចៃដន្យ។ យោងតាមវប្បធម៌នេះ ការព្រមព្រៀងពីកុមារីដែលត្រូវបានចាត់ទុកថា “មិនសមស្រប” បានធ្វើឲ្យយុវវ័យប្រឈមនឹងគ្រោះថ្នាក់ខ្ពស់នៃការរំលោភបំពានផ្លូវភេទ និងធ្វើឲ្យមានការ រួមភេទដោយមិនមានការការពារ ( ឧ.ការយកស្រោមអនាម័យតាមខ្លួនអាចបង្ហាញពីការប៉ុនប៉ងទុកជាមុន )។

[៩៩] ក្នុងចំណោមបុរស ៧ នាក់ ដែលផ្តល់បទសម្ភាស មានបុរស ៦ នាក់ បោះបង់ការសិក្សានៅពេលដែលគេរៀននៅអនុវិទ្យាល័យ ឬវិទ្យាល័យ។ មានបុរសម្នាក់មានសញ្ញាបត្រសាកលវិទ្យាល័យ។ បុរសទាំង ៧ នាក់នោះមិនមានការងារធ្វើនោះឡើយ ហើយពួកគេសំបូរប្រាក់ចាយដោយសារតែទ្រព្យសម្បត្តិរបស់គ្រួសារពួកគេ។ ក្រៅពីការចាប់អារម្មណ៍លើការស្វែងរក និងការជម្នះ បុរសដែលស្ថិតក្នុងក្រុម “ស្វែងរកសេវាផ្លូវភេទ” ក៏បានចាត់ទុកសិស្សស្រី និងនិស្សិតស្រីជា “បន្លែស្អាត” ដែលពួកគេជឿថាក្មេងស្រីទាំងនោះ មិនទាន់ប្រឡូកក្នុងសកម្មភាពផ្លូវភេទ និងឆ្លងជំងឺកាមរោគនោះឡើយ។

## ការលក់ផ្លូវភេទ និងការប្ដូរយកសម្ភារ

ជាទូទៅ ការលក់ផ្លូវភេទជាថ្នូរនឹងប្រាក់គឺជាទង្វើដែលបំបាក់ទឹកចិត្ត ឬចាត់ទុកជាទង្វើមិនសមរម្យ។ កុមារដែលងាយរងគ្រោះ ដូចជាកុមារតាមផ្លូវយល់ថាពួកគេគ្មានជម្រើសក្រៅពីលក់ផ្លូវភេទរបស់ខ្លួន ដើម្បីបានប្រាក់ចិញ្ចឹមជីវិតនោះឡើយ[១០០]។ ការចំណាយលើការអប់រំ សុខភាព និងការផ្គត់ផ្គង់គ្រួសារ ក៏ត្រូវបាន ចាត់ទុកជាហេតុផលដែលធ្វើឲ្យមានការលក់ផ្លូវភេទផងដែរ ដោយយកប្រាក់ដែលរកបានមក បំពេញបន្ថែម ប្រាក់ចំណូលដ៏ទាបដែលបានពីការធ្វើការក្នុងរោងចក្រ បានីយដ្ឋាន ឬការងារតាមផ្ទះ។ ទោះបីជាកុមារជាច្រើនអាចលក់ផ្លូវភេទរបស់ខ្លួនដោយសារតែជួបបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរក៏ដោយ ប៉ុន្តែ ជារឿយៗ កុមារដែលត្រូវបានជួញដូរនៅក្នុងផ្ទះបន ត្រូវបានមេបនយកប្រាក់ដែលពួកគេរកបាន ដោយទទួលបាន ប្រាក់តិចជាងអ្វីដែលមេបននោះធ្លាប់សន្យា ឬត្រូវជាប់បំណុលដែលមេបននោះបាន ចំណាយលើឪពុកម្ដាយរបស់កុមារនោះកាលពីទិញកុមារនោះមក និងត្រូវបង្ខំឲ្យកុមារធ្វើការក្នុង ផ្ទះបន រហូតទាល់តែកុមារនោះសងគ្រប់បំណុលដែលមេបននោះបានផ្ដល់ឲ្យឪពុកម្ដាយរបស់ខ្លួន និងចំណាយផ្សេងទៀតឲ្យបាន អស់សិន[១០១]។

[១០០] មិនមែនកុមាររងគ្រោះទាំងអស់សុទ្ធតែយល់ដឹងពីការលក់ផ្លូវភេទដើម្បីបានប្រាក់ មុនពេលមានការជួញដូរពួកគេនោះឡើយ។ Keane (ឆ្នាំ២០០៦) បានរកឃើញថា កុមារ ១ ភាគ ៣ ដែលគាត់បានធ្វើបទសម្ភាស មិនបានដឹងថា ទំនាក់ទំនងរបស់ខ្លួនជាមួយជនជាតិបរទេសអាចនាំទៅរកការលក់ដូរផ្លូវភេទ ដើម្បីប្រាក់នោះឡើយ។

[១០១] អង្គការ UNICEF-EAPRO (ឆ្នាំ ២០១២) ការរំលោភបំពានកុមារ ៖ ប្រេវ៉ាឡង់ ឧប្បត្តិហេតុ និង ផលវិបាកនៃការរំលោភបំពានកុមារក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច ៖ ការពិនិត្យឡើងវិញលើការស្រាវជ្រាវជប្រព័ន្ធ

*ប្រធានភូមិម្នាក់នៅទីក្រុង លួងប្រាបាន ប្រទេសឡាវ បានរៀបរាប់ថា "កុមារមួយចំនួនមកពីតំបន់ជនបទ ដើម្បីមករៀននៅទីក្រុង ប៉ុន្តែមិនទទួលបានការផ្គត់ផ្គង់គ្រប់គ្រាន់ពីក្រុមគ្រួសាររបស់ខ្លួនឡើយ។ កត្តានេះហើយដែលធ្វើឲ្យពួកគេស្វែងរកការងារធ្វើ និងលក់ផ្លូវភេទ"។*



អតីតអ្នករកស៊ីផ្លូវភេទម្នាក់នៅទីក្រុងវៀងច័ន្ទនៃប្រទេសឡាវ បានឲ្យដឹងថា មានម្ដាយម្នាក់បានមកដល់កន្លែងធ្វើការរបស់គាត់ និងព្រមលក់កូនស្រីរបស់ខ្លួនទៅឲ្យអ្នករកស៊ីផ្លូវភេទ ដើម្បីសងបំណុល។ អ្នករកស៊ីផ្លូវភេទក៏បានរៀបចំឲ្យកុមារីនោះគេងជាមួយភ្ញៀវ។ ក្នុងករណីមួយទៀតនោះ មានមន្ត្រីប៉ូលិសជាន់ខ្ពស់ម្នាក់ បានរៀបរាប់ថា គាត់បានជួបសិស្សស្រីម្នាក់អាយុ ១៦ ឆ្នាំ ដែលធ្វើការក្នុងហាងខារ៉ាអូខេមួយ នៅទីក្រុងវៀងច័ន្ទ ដែលគាត់ធ្លាប់ទៅញ៉ាំអាហារ ពេលយប់ជាមួយមិត្តភក្តិ។ គាត់ដឹងថា កុមារីនោះមិនទាន់គ្រប់អាយុទេ និងបាននិយាយទៅរកនាងដោយមិនបានបង្ហាញពីអត្តសញ្ញាណរបស់គាត់ឡើយ។ នាងបានប្រាប់គាត់ថា មុនពេលនាងមកធ្វើការនៅទីនេះ នាងបានលក់ព្រហ្មចារីរបស់នាងក្នុងតម្លៃ ៤០.០០០ គីប (ប្រហែល ៥ ដុល្លារអាមេរិក)។ កុមារីនោះក៏បានស្ម័គ្រចិត្តធ្វើជាប្រពន្ធចុង ឬស្រីកំណាន់ ប្រសិនបើភ្ញៀវនោះព្រមផ្ដល់ប្រាក់ឲ្យនាង ២៥.០០០ គីប (ប្រហែល ៣ ដុល្លារអាមេរិក) ក្នុងមួយខែ។

នៅទីក្រុង លួងប្រាបាន ប្រទេសឡាវ កុមារដែលលក់ផ្លូវភេទ ដើម្បីយកប្រាក់ទៅផ្គត់ផ្គង់ការសិក្សារបស់ខ្លួនត្រូវបានចាត់ទុកជា "គម្រោងការសិក្សា"។ ការលក់ផ្លូវភេទដើម្បីយកប្រាក់មកសិក្សា ត្រូវបានចាត់ទុកថាជារឿងទូទៅសម្រាប់កុមារមកពីខេត្តមកសិក្សានៅទីក្រុងវៀងច័ន្ទ។ មេភូមិម្នាក់នៅទីក្រុង លួងប្រាបាន បានរៀបរាប់ថា ៖

> *"កុមារមួយចំនួនមកពីតំបន់ជនបទ ដើម្បីមករៀននៅទីក្រុង ប៉ុន្តែមិនទទួលបានការផ្គត់ផ្គង់គ្រប់គ្រាន់ពីក្រុមគ្រួសាររបស់ខ្លួនឡើយ។ កត្តានេះហើយដែលធ្វើឲ្យពួកគេ ស្វែងរកការងារធ្វើ និងលក់ផ្លូវភេទ។"*

ការស្រាវជ្រាវដែលមានស្រាប់បានបង្ហាញឲ្យឃើញថា កុមារក្នុងតំបន់អាចត្រូវបានលក់ដូរ ជួញដូរ បោកប្រាស ឬអាចនឹងស្ម័គ្រចិត្តលក់ព្រហ្មចារីរបស់ខ្លួន ដើម្បីផ្គត់ផ្គង់គ្រួសារ។ ក្នុងករណីខ្លះ កុមារត្រូវបាន ទិញយកមកពីតំបន់ជនបទ និងរក្សាទុកនៅក្នុងផ្ទះបនស្រី និងចិញ្ចឹមរហូតដល់ធំល្មម នឹងអាចបម្រើផ្លូវភេទបាន។ ក្នុងករណីផ្សេងទៀត កុមារីបានលក់ព្រហ្មចារីរបស់នាង ដោយមានការព្រមព្រៀងពីគ្រួសារ ដែលបន្ទាប់ពីនោះមក នាងអាចត្រឡប់ទៅផ្ទះវិញបាន។ ពេលខ្លះ កុមារដែលបាន

លក់ព្រហ្មចារីរបស់ខ្លួននៅតែជួញដូរផ្លូវភេទរបស់ខ្លួនដោយសារតែជំពាក់បំណុល និងភាពអាម៉ាស[១០២]។ នៅប្រទេសវៀតណាម និងកម្ពុជា ករណីមួយចំនួន ត្រូវបានរាយការណ៍ក្នុងការសិក្សាថ្មីៗនេះ ទាក់ទងនឹងជនប្រព្រឹត្តិបទល្មើសដែលបានព្រមព្រៀងជាមួយក្រុមគ្រួសារកុមារីដើម្បីរៀបការជាមួយនាង (មិនទាន់គ្រប់អាយុ)។

[១០២] Thomas, F និង Mathews, L (ឆ្នាំ២០០៦) តើនរណាខ្លះជាភ្ញៀវទេសចរផ្លូវភេទកុមារនៅ កម្ពុជា? Child Wise។

*ជីដូនកុមារាម្នាក់នៅទីក្រុងផាត់តាយ៉ា នៃប្រទេសថៃ បានរៀបរាប់ថា "ខ្ញុំមិនចង់ដឹងថាចៅរបស់ខ្ញុំធ្វើអ្វីជាមួយបុរសបរទេស (ចំណាស់) នេះឡើយ ដរាបណាចៅរបស់ខ្ញុំនៅតែផ្តល់ប្រាក់ដល់ខ្ញុំនោះ គឺខ្ញុំសប្បាយចិត្តហើយ"។*

ក៏មានការរកឃើញផងដែរថា ក្មេងៗមួយចំនួន ដែលលក់ផ្លូវភេទដើម្បីប្រាក់ គឺដោយសារតែវប្បធម៌នៃការប្រើប្រាស់សម្ភារ ឬដោយសារតែសម្ភារនិយម តម្រូវការជីវភាពរស់នៅប្រសើរ ឬការចង់បានផលិតផលទើបចេញថ្មីបំផុត ឬផលិតផលល្អបំផុត។ ទាំងនេះសុទ្ធតែជាកត្តាជំរុញឲ្យកុមារី និងកុមារាប្រឡូកក្នុងសកម្មភាពផ្លូវភេទដើម្បីប្រាក់។ សកម្មភាពទាំងនេះអាចជាការលក់ផ្លូវភេទបែបប្រពៃណី ឬការដោះដូរផ្លូវភេទ ដើម្បីសម្ភារ។ នៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ កុមារាពីរនាក់អាយុក្រោម ១៨ ឆ្នាំ ដែលលក់ផ្លូវភេទ យល់ឃើញថា ការលក់ផ្លូវភេទគឺជាប្រភពដ៏សំខាន់នៃប្រាក់ចំណូល ចំណែកជីដូនកុមារាតាមផ្លូវម្នាក់បានលើកឡើងថា គាត់អាចទទួលយកការរំលោភបំពានផ្លូវភេទលើចៅរបស់គាត់បាន ដរាបណា ចៅរបស់គាត់អាចរកប្រាក់ឲ្យគាត់បាន។

> *"ខ្ញុំមិនចង់ដឹងថាចៅរបស់ខ្ញុំធ្វើអ្វីជាមួយបុរសបរទេស (ចំណាស់) នោះឡើយ ដរាបណាចៅរបស់ខ្ញុំ នៅតែផ្តល់ប្រាក់ដល់ខ្ញុំនោះ គឺខ្ញុំសប្បាយចិត្តហើយ"។*

នៅប្រទេសឡាវ អ្នកផ្តល់បទសម្ភាសមួយចំនួនយល់ថា កុមារាមួយចំនួន ជំរុញឲ្យមិត្តស្រីផ្គត់ផ្គង់ ខ្លួនតាមរយៈការលក់ផ្លូវភេទ ចំណែកនៅទីក្រុងហូជីមិញនៃប្រទេសវៀតណាម អ្នកផ្តល់បទសម្ភាសមួយចំនួនចាត់ទុកការរួមភេទដើម្បីប្រាក់ ឬសម្ភារជាសកម្មភាពដ៏គួរឲ្យចាប់អារម្មណ៍។

នៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ កុមារ និងមនុស្សពេញវ័យបានលើកឡើងថា កុមារងាយទទួលយកនិន្នាការនៃការលក់ផ្លូវភេទដើម្បីប្រាក់ ដោយសារសម្ពាធពីប្រព័ន្ធផ្សព្វផ្សាយ និងសង្គម ដើម្បីមានសម្ភារទំនើបប្រើប្រាស់ ដូចជា ទូរស័ព្ទដៃជាដើម។ កុមារដែលរួមភេទជាមួយ ជនបរទេសម្តងអាចរកបានចន្លោះពី ៥០០ ទៅ ១០០០ បាត (១៥ ទៅ ៣០ ដុល្លាអាមេរិក)[១០៣]។ អ្នកផ្តល់បទសម្ភាសទាំងនោះ បានបង្ហាញពីការព្រួយបារម្ភចំពោះកុមារដែល "សំញែង" សម្ភារប្រើប្រាស់ ដូចជា ទូរស័ព្ទទំនើប ដល់មិត្តភក្តិខ្លួនដែលអាកប្បកិរិយានេះអាចទាក់ទាញ ឬដាក់សម្ពាធលើមិត្តភក្តិទាំងនោះឲ្យចាប់អារម្មណ៍ក្នុងការ "រក" ប្រាក់តាមមធ្យោបាយនោះដែរ។

[១០៣] តួលេខគឺផ្អែកតាមចម្លើយរបស់ក្មេងប្រុសតាមផ្លូវម្នាក់ដែលជាអ្នករកស៊ីផ្លូវភេទ មន្ត្រីរដ្ឋាភិបាលម្នាក់ ឪពុកម្តាយ ២ នាក់ និងគ្រូបង្រៀន ២ នាក់។

*"ម្តាយម្នាក់នៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃបានឲ្យដឹងថា កុមារាច្រើនញៀននឹង ការលេងហ្គេមតាមអ៊ីនធើរណិត ហើយមិត្តភក្តិរបស់កូនខ្ញុំម្នាក់ ធ្លាប់ចេញក្រៅជាមួយបុរសចំណាស់ម្នាក់ទៅកន្លែងមួយដើម្បីជួយសម្រួលអារម្មណ៍ផ្លូវភេទរបស់គេ ដោយស្ទាបអង្អែលផ្លូវភេទរបស់បុរសនោះ និងបាននិយាយថា "ការស្ទាបអង្អែលនោះចំណាយពេលត្រឹមតែ ២ ឬ ៣ នាទីប៉ុណ្ណោះ។ វាមិនបង្កការឈឺចាប់ឡើយ ហើយខ្ញុំអាចរកប្រាក់បានយ៉ាងច្រើន"។*

អ្នកផ្តល់បទសម្ភាសក៏បានផ្សាភ្ជាប់សេវារកស៊ីផ្លូវភេទទៅនឹងនិន្នាការគ្រោះថ្នាក់ និងគួរឲ្យព្រួយបារម្ភផ្សេងទៀត ដូចជា ការប្រើប្រាស់ថ្នាំញៀន និងការលេងហ្គេមតាមអ៊ីនធើរណិត។ កុមារីម្នាក់នៅទីក្រុងផាត់តាយ៉ា បានរាយការណ៍ថា មិត្តភក្តិរបស់នាងបានលក់ខ្លួន ដើម្បីយកប្រាក់ទិញថ្នាំញៀន ហើយទើបតែបញ្ឈប់ការជក់ថ្នាំនៅពេលដែលប៉ូលិសចាប់ខ្លួននាង។ ម្តាយមួយរូបបានរៀបរាប់ពីគ្រោះថ្នាក់នៃការញៀននឹងហ្គេម ដូចខាងក្រោម ៖

> *"កុមារាច្រើនញៀននឹងការលេងហ្គេមតាមអ៊ីនធើរណិត ហើយមិត្តភក្តិរបស់កូនខ្ញុំម្នាក់ ធ្លាប់ចេញក្រៅជាមួយបុរសចំណាស់ម្នាក់ទៅកន្លែងមួយ ដើម្បីជួយសម្រួលអារម្មណ៍ផ្លូវភេទរបស់គេដោយស្ទាបអង្អែលផ្លូវភេទរបស់បុរសនោះ និងបាននិយាយថា "ការស្ទាបអង្អែលនោះចំណាយពេលត្រឹមតែ ២ ឬ ៣ នាទីប៉ុណ្ណោះ។ វាមិនបង្កការឈឺចាប់ឡើយ ហើយខ្ញុំអាចរកប្រាក់បានយ៉ាងច្រើន។"*

ចំណែកនៅទីក្រុង Luang Prabang នៃប្រទេសឡាវ ក្មេងៗតែងស្រម៉ៃចង់មានម៉ូតូផ្ទាល់ខ្លួន ទូរស័ព្ទដៃ ឬសម្ភារប្រើប្រាស់ផ្សេងទៀត ដែលគ្រួសាររបស់ពួកគេមិនអាចផ្តល់ឲ្យបាន ហើយក្មេងៗ ទាំងនោះមិនទាន់មានជំនាញគ្រប់គ្រាន់ក្នុងការរកការងារធ្វើឡើយ ដូចដែលឪពុកមួយរូបបានលើកឡើងថា ៖

> *"កុមារដែលចង់បានសម្ភារល្អៗ ត្រូវតែស្វែងរកការងារធ្វើ ប៉ុន្តែការងាររបស់ពួកគេមានកម្រិតដោយសារកង្វះការអប់រំ ហើយការងារសម្រាប់ពួកគេគឺជាការងារផ្នែកសេវាកម្ម ដែលភាគច្រើនបានធ្វើឲ្យកុមារងាយរងគ្រោះនឹងការរំលោភបំពាន និងកេងប្រវ័ញ្ច។ "*

បុរសអាយុ ២៥ ឆ្នាំ ម្នាក់ នៅទីក្រុងហៃហ្វុងនៃប្រទេសវៀតណាម បានរៀបរាប់ថា *"នៅពេលដែលកុមារីម្នាក់បានប្រាប់ខ្ញុំថា នាងចង់ដើរទិញអីវ៉ាន់ ខ្ញុំនឹងជូននាងទៅ។ ច្បាស់ណាស់ថា ខ្ញុំនឹងមិនផ្តល់អ្វីឲ្យនាងដោយគ្មានអ្វីជាសំណងនោះឡើយ។ បន្ទាប់ពីដើរទិញអីវ៉ាន់រួច ខ្ញុំក៏បាននាំនាងទៅញ៉ាំស្រាបៀរ ហើយធ្វើពុតជាស្រវឹង និងប្រាប់នាងថាខ្ញុំចង់ទៅរកកន្លែងសម្រាក។ កន្លែងសម្រាកនោះគឺសណ្ឋាគារ។ អ្នកប្រាកដជាដឹងថានឹងមានអ្វីកើតឡើង"*។

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់នៅទីក្រុងឈៀងម៉ៃនៃប្រទេសថៃ បានរាយការណ៍ថា កុមារីរស់នៅក្នុងអន្តេវាសិកដ្ឋាន ងាយរងគ្រោះទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទ ដោយសារតែចង់បានបែបផែនរស់នៅជាក់លាក់មួយ៖

> *"កុមារីទាំងនេះមកពីតំបន់ដាច់ស្រយាល ហើយមិនសូវបានដើរលេងយប់នោះឡើយ។ នៅទីនេះ ពួកគេបានរស់នៅដោយខ្លួនឯង មានសេរីភាពក្នុងការស្លៀកពាក់ ចេញដើរលេង និងមានអាកប្បកិរិយា ដូចជាមិត្តភក្តិផ្សេងទៀតដែលរស់នៅទីក្រុង។ កុមារីទាំងនោះ នឹងរាប់អានមិត្តប្រុសដែលពួកគេជួបនៅក្លឹបរាត្រី ហើយដើម្បីបន្តបែបផែនជីវិតបែបនេះ ពួកគេត្រូវប្រឡូកក្នុងការលក់ផ្លូវភេទ។ "*

បុរសអាយុ ២៥ឆ្នាំ ម្នាក់បានបន្ថែមទៀត បុរសដែល "ស្វែងរកសេវាផ្លូវភេទ" ក្នុងទីក្រុងហៃហ្វុងនៃប្រទេសវៀតណាម ក៏បានផ្តល់យោបល់មួយចំនួនទាក់ទងនឹងមធ្យោបាយជាច្រើនក្នុងការដោះដូរផ្លូវភេទដើម្បីទទួលបានសម្ភារប្រើប្រាស់ដោយមិនចាត់ទុកជា "ការធ្វើអាជីវកម្មផ្លូវភេទ"។

> *" នៅពេលដែលកុមារីម្នាក់បានប្រាប់ខ្ញុំថា នាងចង់ដើរទិញអីវ៉ាន់ ខ្ញុំនឹងជូននាងទៅ។ ច្បាស់ណាស់ថា ខ្ញុំនឹងមិនផ្តល់អ្វីឲ្យនាងដោយគ្មានអ្វីជាសំណងនោះឡើយ។ បន្ទាប់ពីដើរទិញ អីវ៉ាន់រួចខ្ញុំក៏បាន នាំនាងទៅញ៉ាំស្រាបៀរ ហើយធ្វើពុតជាស្រវឹង និងប្រាប់នាងថាខ្ញុំចង់ទៅរកកន្លែងសម្រាក។ កន្លែងសម្រាកនោះគឺសណ្ឋាគារ។ អ្នកប្រាកដជាដឹងថានឹងមានអ្វីកើតឡើង។ "*

ការលួងលោម ឬការផ្តល់ប្រាក់ និងរង្វាន់ សម្រាប់ជួយដល់កុមារ ឬគ្រួសារ ត្រូវបានចាត់ទុកថាជាវិធីទូទៅបំផុតរបស់ជនប្រព្រឹត្តិបទល្មើសផ្លូវភេទ។ ជនប្រព្រឹត្តិបទល្មើសត្រូវធ្វើជា មនុស្សដែលចិត្តល្អផ្តល់ប្រាក់កាសដល់គ្រួសាររបស់កុមារ ដែលពួកគេបានរំលោភបំពាន ហើយពេលខ្លះដើរតួដូចជាឪពុកដែលត្រូវផ្គត់ផ្គង់ប្រាក់ ណែនាំពីវិន័យ ផ្តល់ការសិក្សា ( ដូចជាបង្រៀនភាសាអង់គ្លេសជាដើម ) ព្រមទាំងផ្តល់ជាចំណីអាហារ និងជម្រកជាដើម។ ក្នុងករណីផ្សេងទៀត ទោះបីជាឪពុកម្តាយ ឬសមាជិក គ្រួសារដឹងថា នេះជាការរំលោភបំពានផ្លូវភេទក៏ដោយ ក៏ពួកគេនៅតែមិនហ៊ានធ្វើអ្វីឲ្យប៉ះពាល់ដល់ទំនាក់ទំនងនោះឡើយ ដោយសារតែពួកគេទទួលបានប្រាក់ពីជនប្រព្រឹត្តិបទល្មើសទាំងនោះ[១០៤]។ ការសិក្សាមួយក្នុងប្រទេសវៀតណាម បានចងក្រងពីកំណើននៃការផ្តល់ "ការឧបត្ថម្ភ" ដល់កុមារី ( កុមារីតូចបំផុតមានអាយុ ២ ឆ្នាំ ) ដោយបុរសជនជាតិបរទេស ( ដូចជា អាស៊ី និងផ្សេងទៀត មាន ពួកស្បែកសជាដើម )[១០៥]។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់នៅខេត្តសៀមរាប នៃប្រទេសកម្ពុជា បានលើកឡើងនូវករណី ៤ ផ្សេងគ្នាក្នុងខេត្តសៀមរាប ដែលជនប្រព្រឹត្តិបទល្មើសផ្លូវភេទបានប្រើវិធីសាស្ត្រ លួងលោម[១០៦]។ សម្រាប់ករណីមួយផ្សេងទៀតនៅក្នុងខេត្តសៀមរាប ជនបរទេសម្នាក់ដែលមានប្រពន្ធជាជនជាតិកម្ពុជា បានចាប់រំលោភកុមារីជាច្រើននាក់ ដែលជាអ្នកបម្រើក្នុងផ្ទះរបស់ខ្លួន។ ប្រពន្ធបានរួមគំនិតជាមួយប្តីដោយខំបង្កើតទំនុកចិត្តដល់គ្រួសាររបស់កុមារទាំងនោះដែលមានជីវភាពក្រីក្រខ្លាំង។

## ការស្រឡាញ់ភេទដូចគ្នា

ការស្រាវជ្រាវក្នុងតំបន់ភាគច្រើនបានបង្ហាញថា ការស្រឡាញ់ភេទដូចគ្នាត្រូវបានសង្គមមាក់ងាយ និងមិនអាចទទួលយកបានឡើយ។ នៅទីក្រុងឈៀងម៉ៃនៃប្រទេសថៃ អ្នកផ្តល់បទសម្ភាសបានបដិសេធដាច់ខាតនូវការស្រឡាញ់ភេទដូចគ្នាក្នុងសហគមន៍។ សិស្សប្រុសអាយុ ១៤ ឆ្នាំម្នាក់បាននិយាយថា" *គ្រាន់តែគិតដល់រឿងដែលបុរសរួមភេទជាមួយបុរសនោះ វាគួរឲ្យខ្ពើមទៅហើយ*"។ បន្ថែមពីនេះ កុមារ និងមនុស្សពេញវ័យជាច្រើននៅទីក្រុងឈៀងម៉ៃ ចាត់ទុកបញ្ហាការរំលោភបំពានផ្លូវភេទកុមារាជា "បញ្ហាក្រៅតំបន់" ( ខេត្ត ឬប្រទេសផ្សេងទៀត ) ដោយសារតែពួកគេមិនធ្លាប់ជួបប្រទះបញ្ហាបែបនេះក្នុងជីវិតឡើយ។

ជាទូទៅ ប្រព័ន្ធផ្សព្វផ្សាយ និងសង្គមវៀតណាម ចាត់ទុកការស្រឡាញ់ភេទដូចគ្នាជា "ជំងឺ" មួយ ហើយស្របពេលជាមួយគ្នានោះ ការស្រាវជ្រាវនាពេលថ្មីៗនៅវៀតណាមបង្ហាញថា មានការកើនឡើងយ៉ាងច្រើននូវកុមារាដែលប្រឡូកក្នុងការជួញដូរផ្លូវភេទ[១០៧]។ កុមារាវៀតណាមទាំងនេះ មានការអៀនខ្មាស និងភ័យខ្លាច ប្រសិនបើគ្រួសាររបស់ពួកគេបានដឹងពីបញ្ហានេះ[១០៨]។ អ្នកផ្តល់បទ សម្ភាស នៅប្រទេសកម្ពុជាស្ទើរតែទាំងអស់ បានចាត់ទុកទំនាក់ទំនងភេទខ្ទើយជាទំនាក់ទំនង "*មិនសមរម្យ*"។ អ្នក មានកាតព្វកិច្ចម្នាក់ នៅខេត្តមណ្ឌលគិរី នៃប្រទេសកម្ពុជា បានបង្ហាញថា ដោយសារតែការមានអាកប្បកិរិយាបែបនេះទើបកុមារាងាយប្រឈមនឹងការរំលោភបំពាន ឬមិនហ៊ានរាយការណ៍ពីការរំលោភបំពាន នេះឡើយ ដូចជាក្នុងករណីដែលបុរសម្នាក់រំលោភសេពសន្ថវៈកុមារទាំងនោះ។ ទោះបីជាសិស្សសាលា ភាគច្រើនបានដឹងថាកុមារាទទួលរងរំលោភបំពានផ្លូវភេទក៏ដោយ ក៏សិស្សទាំងនោះ មិនជឿថារឿងនោះ ពិតជាកើតមាននៅកម្ពុជា ឬមិនជឿថា បុរសកម្ពុជា ប្រព្រឹត្តិបទល្មើសបែបនោះឡើយ ពីព្រោះពួកគេ យល់ថា កុមារាភាគច្រើន រងការរំលោភបំពានពីជនបរទេសនៅតាមកន្លែងទេសចរណ៍នានា។

ចំណែកនៅប្រទេសឡាវ និងទីក្រុងផាត់តាយ៉ានៃប្រទេសថៃ ការស្រឡាញ់ភេទដូចគ្នាត្រូវបានសង្គមទទួលយក។ នៅទីក្រុងផាត់តាយ៉ា កុមារបានឃើញពីគុណប្រយោជន៍មួយចំនួននៃភេទខ្ទើយ ដូចជាអាចធ្វើ ជាមិត្តភក្តិជាមួយកុមារាក៏បានកុមារីក៏បាន និងអាចបញ្ចៀសបាននូវការជាប់ពាក់ព័ន្ធជាមួយក្រុមក្មេងទំនើង ទៀតផង។ សហគមន៍ក៏បានដឹងថា ភ្ញៀវទេសចរបរទេសជាបុរស គឺជាជនប្រព្រឹត្តិបទល្មើសផ្លូវភេទលើកុមារា។

ក្រុមស្រាវជ្រាវនៅប្រទេសឡាវ បានសង្កេតឃើញមានបុរសជាច្រើនដែលស្លៀកពាក់ដូចស្ត្រី ( ខ្ទើយប្រុស ) ស្ត្រីក្មេងៗដែលស្លៀកពាក់ដូចបុរស ( ខ្ទើយស្រី ) និងយុវជនដែលដើរតាមភ្ញៀវទេសចរបុរស។ ប្រជាជនក្នុងមូលដ្ឋានបានរាយការណ៍ថា ថ្មីៗនេះ មានការកើនឡើង នូវចំនួនមនុស្សស្រឡាញ់ភេទដូចគ្នា ហើយមនុស្សស្រឡាញ់ភេទដូចគ្នា និងមនុស្សខ្ទើយមួយចំនួន ធ្វើការក្នុងវិស័យឧស្សាហកម្ម ទេសចរណ៍។

[១០៤] អង្គការ Action Pour Les Enfants (ខែកក្កដា ឆ្នាំ២០០៦) ជនប្រព្រឹត្តិបទល្មើសផ្លូវភេទក្នុងរូបភាពជាអ្នកទេសចរ ៖ ការលួងលោមឲ្យទៅរស់នៅបរទេស ៖ បរិបទកម្ពុជា។ អង្គការ APLE បានលើកឡើងពីករណីក្មេងស្រីម្នាក់ នៅខេត្តបាត់ដំបងដែលរងការរំលោភបំពានចាប់តាំងពីពេលនាងមានអាយុ ៨ ឆ្នាំ រហូត ដល់ ១២ ឆ្នាំ។ ក្រុមគ្រួសាររបស់នាងពិតជាបានដឹងពីបញ្ហានេះ ប៉ុន្តែមិនបានបញ្ឈប់ ឬរាយការណ៍ឲ្យនរណាដឹងឡើយ។ សូមមើល Putman-Cramer (ឆ្នាំ២០០៥)។

[១០៥] Reimer, JK (ឆ្នាំ២០០៦) តើកិត្តយសមានតម្លៃប៉ុណ្ណា? ការសិក្សាបែបគុណភាពពីការជួញដូរក្មេងស្រីវៀតណាមក្នុងប្រទេសឲ្យប្រកបអាជីវកម្មផ្លូវភេទ ៖ Chab Dai ទីក្រុងភ្នំពេញ។

[១០៦] UngChansophal (ឆ្នាំ២០០៤) អន្ទាក់ផ្លូវភេទ ៖ មជ្ឈមណ្ឌលកម្ពុជាជួយស្ត្រី មានវិបត្តិ ទីក្រុងភ្នំពេញ។

[១០៧] តម្រូវឲ្យមានទិន្នន័យបញ្ជាក់បន្ថែមថា តើមានការកើនឡើងពិតមែន ឬយ៉ាងណា ឬក៏កើនឡើងជាក់ស្តែងមែននោះ។ អង្គការ UNICEF (ឆ្នាំ២០១១) ការវិភាគពីការជួញដូរផ្លូវភេទកុមារតាមបណ្តាខេត្ត និងទីក្រុងមួយចំនួនក្នុងប្រទេសវៀតណាម។

[១០៨] Yen, et al (ឆ្នាំ២០១២) ការស្រាវជ្រាវ ៖ ការជួញដូរក្មេងប្រុសក្នុងប្រទេសវៀតណាម IOM។

អ្នកផ្តល់បទសម្ភាសមួយចំនួន បានស្គាល់កន្លែងប្រមូលផ្តុំមនុស្សខ្ទើយល្បីៗ នៅទីក្រុងរៀងច័ន្ទ។ តាមការសម្ភាស កុមារឡាវភាគច្រើនបានឲ្យដឹងថា ពួកគេធ្លាប់បានឃើញមនុស្សប្រុសខ្ទើយ និង មនុស្សស្រីខ្ទើយដើរតាមផ្លូវ ឬបង្ហាញខ្លួនក្នុងកញ្ចក់ទូរទស្សន៍ថៃ ប៉ុន្តែមិនបានរើសអើងពួកគេឡើយ។ កុមារីអាយុ ១៧ ឆ្នាំ នៅទីក្រុងវៀងច័ន្ទបានឲ្យដឹងថា

> *"ខ្ញុំមិនស្អប់ខ្ពើមមនុស្សខ្ទើយទេ ដោយសារតែនេះមិនមែនជាកំហុសរបស់ពួកគេឡើយ។ ពួកគេកើតមកមាន ភេទតែមួយ ប៉ុន្តែចំណង់ពីក្នុងខ្លួនគឺចង់បានភេទផ្ទុយពីភេទរបស់ខ្លួន"* ។

## ទំនាក់ទំនងអំណាច-គ្រួសារ

ទំនាក់ទំនងអំណាចក្នុងគ្រួសារ និងសហគមន៍បានបង្ហាញពីស្ថានភាពផ្សេងៗ របស់សមាជិកគ្រួសារ និងសហគមន៍ និងទំនាក់ទំនងទៅវិញទៅមកនៃការឆ្លើយតបនឹងការរំលោភបំពានផ្លូវភេទកុមារ។ ទំនាក់ទំនងអំណាចទាំងនេះ ក៏បានបង្ហាញពីមូលហេតុនៃការប្រព្រឹត្ត និងលទ្ធផលទំនាក់ទំនង នៅពេលមានការសង្ស័យ ឬកំណត់បានការរំលោភបំពាន។

តាមការស្រាវជ្រាវ កុមារត្រូវគោរព និងស្តាប់តាមឪពុកម្តាយរបស់ខ្លួន។ ឧ. មនុស្សពេញវ័យទាំងពីរភេទនៅប្រទេសថៃ បានបង្ហាញពីគំនិតរបស់ខ្លួនថា "*កុមារគឺជាទ្រព្យសម្បត្តិ របស់ឪពុកម្តាយ*" ចំណែកនៅទីក្រុងឈៀងម៉ៃនៃប្រទេសថៃ កុមារមិនអាចបដិសេធសំណើរបស់មនុស្សចាស់បានឡើយ។ អំណះអំណាងនេះ បង្ហាញពីការខ្វះខាតទីភ្ជាក់ងារទំនាក់ទំនងរវាងកុមារ និងឪពុកម្តាយ។ នៅប្រទេសវៀតណាម កុមារអាចបញ្ចេញយោបល់តិចតួច ឬមិនមានទាល់តែសោះទាក់ទងនឹងបញ្ហាជីវិត និងត្រូវធ្វើតាមបំណងប្រាថ្នា ឬតម្រូវការរបស់ឪពុកម្តាយ។ បទសម្ភាសជាមួយកូនៗ និងឪពុកម្តាយជនជាតិឡាវបានបង្ហាញពីគុណតម្លៃនៃការគោរពមនុស្សចាស់ និងឪពុកម្តាយ ប៉ុន្តែនៅទីក្រុងផាត់តាយ៉ា នៃប្រទេសថៃ កុមារមានភាពឯករាជ្យច្រើន និងត្រូវមើលថែខ្លួនឯង ឬរស់នៅក្នុងគ្រួសារដែលមានសមាជិកច្រើននាក់។ ឪពុកម្តាយធ្វើការច្រើន និងមិនសូវមានពេលគ្រប់គ្រងកូនឡើយ។ ទោះបីជាកុមារទាំងអស់មានការយល់ដឹងទូទៅពីសិទ្ធិកុមារក៏ដោយ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងកុមារទាំងនោះមិនត្រូវទាមទារសិទ្ធិទាំងនេះឡើយ។ ប្រការនេះពិតជាបង្កផលវិបាកដល់ការការពារកុមារ[១០៩]។

កាតព្វកិច្ចក្នុងញាតិព័ន្ធ និងការសងគុណឪពុកម្តាយ ជាពិសេសក្នុងនាមជាកូនស្រី គឺជាគោលគំនិតមួយដែលមាននៅក្នុងឯកសារនេះ និងលទ្ធផលស្រាវជ្រាវក្នុងតំបន់[១១០]។ ស្ថានភាពនេះមានលក្ខណៈកាន់តែធ្ងន់ធ្ងរដោយសារអសមភាពយេនឌ័រ និងការផ្តល់អាទិភាពលើការអប់រំដល់កុមារាច្រើនជាង ការអប់រំកុមារីដែលបានធ្វើកុមារីមិនសូវមានឱកាសទទួលបានការអប់រំ និងការងារ។ ដូច្នេះ ពួកគេត្រូវប្រឡូកក្នុងឧស្សាហកម្មផ្លូវភេទ ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ និងបំពេញកាតព្វកិច្ចជាកូន។

នៅខេត្តមណ្ឌលគិរីនៃប្រទេសកម្ពុជា មានការរាយការណ៍ពីករណីស្ត្រីម្នាក់ដែលប្រឡូកក្នុងការជួញដូរផ្លូវភេទនៅអាយុ ១៥ ឆ្នាំ បន្ទាប់ពីម្តាយរបស់នាងប្រាប់នាងថា នាងគួរតែជួយរកបាក់ផ្គត់ផ្គង់គ្រួសារ។ យោងតាមមន្ត្រីរដ្ឋាភិបាល គ្រួសារមួយចំនួននៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ បានជំរុញឲ្យកូនៗរបស់ខ្លួនរកស៊ីផ្លូវភេទ ដើម្បីជួយលើកកម្ពស់ស្ថានភាពរស់នៅក្នុងគ្រួសារ។ របាយការណ៍ពីប្រទេសវៀតណាមក៏បានបង្ហាញថា ឪពុកម្តាយ និងសាច់ញាតិកាន់តែច្រើនបានលក់កូនរបស់ខ្លួន[១១១]។ មានការផ្តល់យោបល់ថា អ្នកស្រាវជ្រាវអាចនឹងផ្តោតខ្លាំងពេកលើកាតព្វកិច្ចក្នុងញាតិព័ន្ធថាជាមូលហេតុដែលធ្វើឲ្យមានការប្រឡូក ក្នុងការជួញដូរផ្លូវភេទ ដោយអះអាងថា នេះជាមធ្យោបាយតែមួយដែលអាចឲ្យកុមារី និងគ្រួសារស្រោចស្រង់ស្ថានភាពដ៏លំបាក ទើបមិនបានដឹងពីមូលហេតុនៃភាពក្រីក្រ[១១២]។

## ការភ័យខ្លាចចំពោះការបាត់បង់កិត្តិយស

យោងតាមការស្រាវជ្រាវ ការភ័យខ្លាចចំពោះការបាត់បង់កិត្តិយសបានក្លាយជាប្រធានបទមួយថ្មីទៀតសម្រាប់ការពិភាក្សាពីព្រហ្មចារីរបស់កុមារី និងការប្រព្រឹត្តិផ្លូវភេទ។ ខណៈដែលកុមារាមិនត្រូវបានចាត់ទុកថាខូចខាតខ្លួន និងអាចប្រឡូកក្នុងសកម្មភាពផ្លូវភេទបាននោះ ព្រហ្មចារីរបស់កុមារី ត្រូវបានចាត់ទុក

---

[១០៩] Gourley (ឆ្នាំ២០០៩) លើកឡើងថា សារៈសំខាន់ផ្នែកវប្បធម៌លើគ្រួសារ និង កេរ្តិ៍ឈ្មោះឪពុកម្តាយ ឬ "សេចក្តីថ្លៃថ្នូរ" និង ឥទ្ធិពលនៃឋានានុក្រម និងបិតាធិបតេយ្យ សម្រាប់ទំនាក់ទំនងរវាងកូន និងឪពុកបានបង្កឧបសគ្គដល់ការសម្រេចបានសិទ្ធិកុមារ ក្នុងផ្នែកជាច្រើនក្នុងជីវិត រួមមានសិទ្ធិទទួលបានការការពារពីការរំលោភបំពានផ្លូវភេទជាដើម។ Gourley (ឆ្នាំ២០០៩) ផ្លូវកណ្តាល៖ ការបង្កើត គម្លាតរវាងវប្បធម៌កម្ពុជា និងសិទ្ធិកុមារ គណៈកម្មាធិការស្តីពីសិទ្ធិកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ទីក្រុងភ្នំពេញ។

[១១០] ឧទាហរណ៍ ៖ Montgomery, H (ឆ្នាំ២០០១) ទីក្រុង Babylon សម័យថ្មី? ពេស្យាកម្មកុមារនៅប្រទេសថៃ Berghahn Books ទីក្រុងញូវយ៉ក។

[១១១] អង្គការ UNICEF (ឆ្នាំ២០១១) ការវិភាគពីការជួញដូរផ្លូវភេទកុមារតាមបណ្តាខេត្ត និងទីក្រុងមួយចំនួនក្នុងប្រទេសវៀតណាម។

[១១២] Baker, S (ឆ្នាំ២០០៤) ពេស្យាកម្មកុមារ និងមេរោគអេដស៍/ជំងឺអេដស៍ក្នុងប្រទេសថៃ ៖ ការកែប្រែតថភាពសម្រាប់កុមារថៃ និងកុលសម្ព័ន្ធតាមតំបន់ភ្នំ ៖ ឯកសារដែលមិនទាន់បោះពុម្ព។

ជាលក្ខណវិនិច្ឆ័យមួយដែលអាចរក្សា ឬធ្វើឲ្យបាត់បង់មុខមាត់គ្រួសារ ( កិត្តិយសឬកេរ្តិ៍ឈ្មោះ )។ ព្រហ្មចារីមានតម្លៃខ្ពស់ណាស់សម្រាប់កុមារី ហើយប្រសិនបើកុមារីបាត់បង់ ព្រហ្មចារីមុនពេលរៀបការ នោះកុមារីអាចនឹងត្រូវបានបណ្តេញចេញពីផ្ទះ មិនទទួលបានការយកចិត្តទុកដាក់ និង/ឬ រងការមាក់ងាយពីខាងក្រៅ។ បញ្ហានេះអាចក្លាយជាចំណុចនាំទៅរកការជួញដូរផ្លូវភេទ ឬការធ្វើអាជីវកម្មផ្លូវភេទ។ បញ្ហាដែលកុមារី បាត់បង់ព្រហ្មចារីដោយសារតែខ្លួនឯង ឬដោយសារការរំលោភសេពសន្ថវៈនោះគឺមិនសំខាន់ឡើយ[១១៣]។ កុមារីមិនបានលាតត្រដាងពីបញ្ហារបស់ខ្លួនដោយសារតែភាពខ្មាសអៀន និងភាពខុសឆ្គង ហើយមានកុមារីមួយចំនួនទៀត ត្រូវបង្ខំចិត្តរៀបការជាមួយជនល្មើស ដើម្បីការពារកេរ្តិ៍ឈ្មោះ របស់គ្រួសារ[១១៤]។

កាលពីពីរបីឆ្នាំមុន មានការរាយការណ៍ពីករណីរំលោភបំពានផ្លូវភេទលើសិស្សសាលា តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់វៀតណាម[១១៥]។ បន្ទាប់ពីមានការផ្សព្វផ្សាយករណីទាំងនេះជាសាធារណៈ មានការរាយការណ៍ថា កុមារីដែលជាជនរងគ្រោះបានបោះបង់ការសិក្សា ដោយសារតែរងការមាក់ងាយ ពីសង្គម និងការចំអកពីមិត្តរួមថ្នាក់ និងសហគមន៍[១១៦]។ ក្រៅពីនេះ គ្រូពេទ្យវិកលចរិតម្នាក់ នៅទីក្រុងឈៀងម៉ៃ នៃប្រទេសថៃ បានរៀបរាប់ករណីដែលគួរឲ្យព្រួយបារម្ភដូចខាងក្រោម ៖

## ករណីសិក្សា

កុមារីអាយុ ១០ ឆ្នាំ ម្នាក់ត្រូវបានឪពុកចិញ្ចឹមរបស់នាងចាប់រំលោភ។ បុរសនោះបានរៀបការ និងមានកូនពីរនាក់រួចទៅហើយ។ ម្តាយរបស់កុមារីនោះបានដឹងពីបញ្ហានេះ និងមិនព្រមសម្របសម្រួលជាមួយជនល្មើសឡើយ។ នៅពេលរឿងនេះបានលេចលឺដល់សហគមន៍ ជនល្មើសមានអារម្មណ៍អៀនខ្មាស និងតានតឹង ហើយគាត់ក៏បានសម្លាប់ខ្លួនក្នុងអំឡុងពេលកាត់ទោស។ អ្នកភូមិគិតថា កុមារីនោះជាមូលហេតុ ដែលធ្វើឲ្យគ្រួសារនោះបែកបាក់ ឬមិនអាច ផ្គត់ផ្គង់ជីវភាពរស់នៅបាន។ អ្នកភូមិមានការអាណិតអាសូរយ៉ាងខ្លាំងដល់ម្តាយ និងកូនៗដែលបានបាត់បង់មេគ្រួសារ និងជាអ្នករកប្រាក់ចំណូលដ៏សំខាន់ ហើយពួកគេគិតថា កត្តានេះនឹងរិតតែធ្វើឲ្យមានបញ្ហាដល់សហគមន៍ថែមទៀត ប្រសិនបើកូនៗ មិនអាចរៀនចប់ និងរកការងារបានធ្វើទេនោះ។ អ្នកភូមិសន្និដ្ឋានថា កុមារីនោះបានល្បួងទាក់ទាញ ជនល្មើស និងជាមូលហេតុដែលធ្វើឲ្យរឿងនេះកើតឡើង។ បញ្ហានេះបានធ្វើឲ្យអ្នកភូមិបន្តនិយាយមិនល្អ និងសំដែងការមិនពេញចិត្ត ដោយសារតែវាបានបំផ្លាញកេរ្តិ៍ឈ្មោះភូមិ។ សមាជិកសហគមន៍យល់ថា "បាត់បង់កិត្តិយស" និងអៀនខ្មាសមិនចង់រស់នៅក្នុងភូមិនោះទៀត។ ដោយសារតែឃើញសហគមន៍បង្ហាញពីប្រតិកម្ម "មិនពេញចិត្ត" ក្រុមគ្រួសារក៏បានបណ្តេញនាងចេញពីភូមិ ( នៅជាយក្រុងឈៀងម៉ៃ ) ទៅនៅផ្ទះមួយក្នុងទីក្រុង។ នៅទីនោះ នាងមានអារម្មណ៍ឯកោណាស់ ពីព្រោះនាងយល់ថា នាងមិនមានសុវត្ថិភាពឡើយ នៅពេលស្ថិតនៅក្នុងចំណោមមនុស្សផ្សេងទៀត។ នាងមានអារម្មណ៍ថាខុសឆ្គង និងភ័យខ្លាចគ្រប់ពេលវេលា។ ទោះបីជាពេលវេលាកន្លងផុតទៅ ពីរបីឆ្នាំក៏ដោយ នាងនៅតែត្រូវការការមើលថែជាប្រចាំ។

ក្រុមស្រាវជ្រាវនៅប្រទេសវៀតណាមបានបង្ហាញថា មានឪពុកមួយរូប នៅក្នុងកិច្ចពិភាក្សា ក្រុមបានបង្ហូរទឹកភ្នែក និងបានរៀបរាប់ថា គាត់បានរៀបការកូនស្រីរបស់គាត់អាយុ ១៦ ឆ្នាំ ឲ្យទៅបុរសជនជាតិអាស៊ីម្នាក់ដើម្បីកុំឲ្យគ្រួសាររបស់នាងរងការអាម៉ាស ដោយសារតែកូនស្រីរបស់គាត់បានរត់ទៅតាមមិត្តប្រុសរបស់នាងអស់រយៈពេលពីរបីថ្ងៃ។ ដោយសារគាត់មានការព្រួយបារម្ភខ្លាំងពេកដោយខ្លាចថា កូនស្រីរបស់គាត់ បានបាត់បង់ព្រហ្មចារី និងអាចមានផ្ទៃពោះទៀតនោះ គាត់ក៏បានសូកប៉ាន់មន្ត្រីមូលដ្ឋានម្នាក់ឲ្យដំឡើងអាយុកូនស្រីរបស់ខ្លួនឲ្យគ្រប់អាយុ ១៨ ឆ្នាំ ដើម្បីបានរៀបការជាមួយបុរសអាស៊ីម្នាក់ ដែលមានវ័យ ៤០ ឆ្នាំ ក្នុងគោលបំណងការពារកិត្តិយសរបស់គ្រួសារ។ កូនស្រីរបស់គាត់ បានទូរស័ព្ទមក និងប្រាប់គាត់ថា នាងនឹកផ្ទះខ្លាំងណាស់។ ករណីនេះអាចបង្ហាញថា ពេលខ្លះ កូនៗមិនត្រូវបានចាត់ទុកជាបុគ្គលឯករាជនោះឡើយ ប៉ុន្តែជាអ្នកគ្រប់គ្រងកិត្តិយសគ្រួសារ និងជាទ្រព្យសម្បត្តិរបស់ឪពុកម្តាយ។

---

[១១៣] មានការបង្ហាញកាន់តែច្រើនពីការរំលោភបំពានផ្លូវភេទកុមារក្នុងតំបន់ ដោយបង្ហាញថា យុវជនភាគច្រើនប្រឡូកក្នុងសកម្មភាពផ្លូវភេទដំបូងដោយសារការចាប់បង្ខំ។ អង្គការ UNICEF-EAPRO ( ឆ្នាំ ២០១២ )ការរំលោភបំពានកុមារ ៖ ប្រេវ៉ាឡង់ ឧប្បត្តិហេតុ និងផលវិបាកនៃការរំលោភបំពានកុមារក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច ៖ ការពិនិត្យឡើងវិញលើការស្រាវជ្រាវជាប្រព័ន្ធ។

[114] អង្គការ Action Pour Les Enfants ( ខែកុម្ភៈ ឆ្នាំ២០១៤ ) ការស៊ើបអង្កេតជនប្រព្រឹត្តិបទល្មើសផ្លូវភេទក្នុងរូបភាពជាភ្ញៀវទេសចរ ៖ ការវិភាគនិន្នាការ និងបញ្ហាប្រឈមក្នុងការរំលោភបំពានផ្លូវភេទកុមារ និងការជួញដូរផ្លូវភេទកុមារនៅកម្ពុជា។

[១១៥] http://www .baomoi .com/Khi-thay-giao-cuong-dam-voi-hoc-sinh-cua-minh/104/7974408 .epi; http://www .baomoi .com/Tinh-tiet-moi-trong-vu-Sam-Duc-Xuong/104/4160329 .epi

[១១៦] របាយការណ៍ របស់ប្រព័ន្ធផ្សព្វផ្សាយជាច្រើន ស្តីពីការរំលោភបំពានផ្លូវភេទកុមារ បានបង្ហាញអក្សរដំបូង នៃឈ្មោះជនរងគ្រោះ ឬក៏របាយការណ៍បានបញ្ជាក់ថា ឈ្មោះជនរងគ្រោះ ត្រូវបានប្តូរដើម្បីរក្សាការសម្ងាត់។ យ៉ាងណាក៏ដោយ ដើម្បីធ្វើឲ្យមានការភ្ញាក់ផ្អើលចំពោះព័ត៌មាននោះ អ្នករាយការណ៍បានបង្ហើបប្រាប់ឈ្មោះសាលារបស់ជនរងគ្រោះ ឈ្មោះទីកន្លែងដែលជនរងគ្រោះរស់នៅ និងរូបថតផ្ទះរបស់ជនរងគ្រោះ។ ព័ត៌មានលម្អិតទាំងនេះបានបង្ហាញពីអត្តសញ្ញាណរបស់ជនរងគ្រោះ(http://www .zing .vn/news/xa-hoi/hieu-truong-sam-duc-xuong-hoang-dam-nhu-the-nao/a102523 .html; http://vnexpress .net/gl/phap-luat/2012/03/thay-giao-phu-nhan-dua-tro-vao-nha-nghi/)។



[117] Keane, K (ឆ្នាំ២០០៦) ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមដងផ្លូវនៅទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ៖ រឿងរ៉ាវរបស់ជនរងគ្រោះ អង្គការ Action Pour Les Enfants ៖ http://aplecambodia .org/images/reportresearch/A%20profile%20of%20victims .pdf ដកស្រង់នៅថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០១១។

## ឥទ្ធិពលពីមិត្តភក្តិ

ទំនាក់ទំនងមិត្តភក្តិគឺជាផ្នែកមួយដ៏សំខាន់នៃការអភិវឌ្ឍរបស់កុមារ។ តួយ៉ាង កុមារដែលមានមិត្តភក្តិប្រឡូកក្នុងការជួញដូរផ្លូវភេទ ក៏ងាយរងគ្រោះទៅនឹងការជួញដូរផ្លូវភេទដូច្នោះដែរ[117]។ កុមារនិងឪពុកម្តាយ បានយល់ឃើញថា វ័យជំទង់ច្រើនធ្វើតាមអ្វីដែលមិត្តភក្តិខ្លួនកំពុងធ្វើ ដូចជារបៀបស្លៀកពាក់ ម៉ូដសក់ និងការប្រើប្រាស់ទូរស័ព្ទដៃជាដើម។ នៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ សិស្សសាលាបានបង្ហាញពីឥទ្ធិពល របស់មិត្តភក្តិចំពោះការធ្វើសេចក្តីសម្រេចទាក់ទងនឹងផ្លូវភេទ។ តាមរបាយការណ៍បានបង្ហាញថា កុមារីដែលធ្លាប់ប្រឡូកក្នុងសកម្មភាពផ្លូវភេទ ច្រើនជំរុញឲ្យមិត្តភក្តិស្រីរបស់ខ្លួនប្រឡូកក្នុងសកម្មភាពនោះដែរ ដោយនិយាយថា "*មើលតែខ្ញុំទៅ ខ្ញុំធ្លាប់ប្រឡូកក្នុងសកម្មភាពផ្លូវភេទ ប៉ុន្តែខ្ញុំគ្មានបញ្ហា អ្វីផង*"។ កុមារី និងកុមារាយល់ថា ខ្លួនត្រូវចែករំលែកបទពិសោធន៍រួមភេទជាមួយមិត្តភក្តិ វាដូចជាការស្វែងរកការទទួលយកដូច្នោះដែរ។ សិស្សប្រុសជនជាតិឡាវម្នាក់ (អាយុ ១៨ឆ្នាំ) បាននិយាយថា "*មិត្តរួមថ្នាក់របស់ខ្ញុំភាគច្រើនមានមិត្តប្រុស ឬមិត្តស្រី ចំណែកខ្ញុំវិញមិនមាននោះឡើយ ហើយខ្ញុំមានអារម្មណ៍ ឯកោណាស់។*" កុមារីអាយុ ១៨ ឆ្នាំ ម្នាក់ រស់នៅទីក្រុងវៀងច័ន្ទនៃប្រទេសឡាវ បានលើកឡើងថា កុមារជាច្រើនបាន បង្ហាញថា វ័យជំទង់ងាយប្រឈមនឹងគ្រោះថ្នាក់ ដោយសារតែពួកគេចូលចិត្តដើរលេងជាមួយមិត្តភក្តិ ៖ "*យុវជនងាយប្រឈមនឹងគ្រោះថ្នាក់ ដោយសារតែនៅវ័យនេះ ពួកគេចូលចិត្តដើរលេង និងរាប់អានមិត្តភក្តិ* "។ គ្រូបង្រៀន និងសិស្សសាលាមួយចំនួន បានបញ្ជាក់ថា នៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ ក្មេងម្នាក់អាច មានភាពល្បីល្បាញដោយសារតែការផ្លាស់ប្តូរដៃគូរួមភេទ។ ឥទ្ធិពលរបស់មិត្តភក្តិអាចធ្វើឲ្យយុវជនប្រកាន់យកអាកប្បកិរិយាប្រកបដោយគ្រោះថ្នាក់ ដូចជាការលេងហ្គេមតាមអ៊ីនធើរណិត ឬការទៅលេងនៅកន្លែងគ្រោះថ្នាក់ ដូចជា កន្លែងបម្រើសេវាកំសាន្តផ្លូវភេទជាដើម។

អ្វីដែលកាន់តែព្រួយបារម្ភទៅទៀតនោះគឺលទ្ធផលរកឃើញបានបង្ហាញថា ការប្រកួតប្រជែង និងឥទ្ធិពលពីមិត្តភក្តិមានតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឲ្យសិស្សសាលាប្រឡូកក្នុងសកម្មភាពផ្លូវភេទ ដើម្បីទទួលបានរង្វាន់។ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកមានកាតព្វកិច្ចនៅទីក្រុងឈៀងម៉ៃនៃប្រទេសថៃ បានរាយការណ៍ ពីនិន្នាការដ៏គួរឲ្យព្រួយបារម្ភដែលសិស្សស្រីដាក់សម្ពាធលើគ្នាទៅវិញទៅមកឲ្យប្រឡូកក្នុងការរួមភេទដើម្បីទទួលបានសម្ភារ។ កុមារី "ដែលទទួលរងឥទ្ធិពលទាំងនោះ" ចាប់ផ្តើមផុងខ្លួនក្នុងសកម្មភាពផ្លូវភេទ ដោយសារមិត្តភក្តិរបស់ខ្លួន ដែលបានចែករំលែកបទពិសោធន៍ និងព័ត៌មាន និងដើរតួជា អ្នកជួយរកភ្ញៀវឲ្យទៀតផង។

ក្រុមស្រាវជ្រាវនៅវៀតណាមបានរកឃើញថា ជួនកាល កុមារីដែលគេងជាមួយមនុស្សប្រុស ដើម្បីប្តូរយករង្វាន់ និងប្រាក់ អាចប្រើប្រាស់ការច្រណែនដើម្បីជំរុញឲ្យមិត្តភិក្តរបស់ខ្លួនលក់ផ្លូវភេទ។ ឪពុកម្តាយនៅទីក្រុងហៃហ្វុងនៃប្រទេសវៀតណាម បានរាយការណ៍ថា កូនស្រីរបស់គាត់ (អាយុ ១៦ ឆ្នាំ) បានរៀបរាប់ពីកិច្ចសន្ទនារបស់មិត្តស្រីរួមសាលាពីរនាក់ ដែលនាងបានស្តាប់លឺដោយចៃដន្យ ដោយសិស្សស្រីម្នាក់បានសួរទៅសិស្សស្រីម្នាក់ទៀតថាតើនាងអាចទិញអាវទ្រនាប់ដ៏មានតម្លៃថ្លៃនេះនៅឯណា។ កុមារីនោះក៏បានឆ្លើយថា អាវនេះជារង្វាន់ដែលបុរសម្នាក់បានឲ្យខ្ញុំដោយសារខ្ញុំដើរលេងជាមួយគាត់ និងបានប្រាប់ថាបើសិនជាកុមារីនោះចង់បានដូចនាងដែរ នាងនឹងទាក់ទងទៅបុរសអ្នកមានពីរបីនាក់ទៀតឲ្យនាងស្គាល់។ កុមារីនោះក៏បានយល់ព្រមជាមួយមិត្តភក្តិរបស់នាង។

## ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកវិទ្យាឌីជីថល

តាមការស្រាវជ្រាវទាំងអស់បានឲ្យដឹងថា ឥទ្ធិពលអ៊ីនធើរណិត និងបច្ចេកវិទ្យាឌីជីថល ដូចជា ទូរស័ព្ទទំនើប និងប្រភពប្រព័ន្ធផ្សព្វផ្សាយ ដូចជា ទូរទស្សន៍ វិទ្យុ ទស្សនាវដ្តី និងភាពយន្តអាសអាភាស ដែលមានបង្ហាញពីឥរិយាបថ និងការប្រព្រឹត្តិផ្លូវភេទរបស់កុមារ កាន់តែបង្ហាញច្បាស់ឡើង។ ផលប៉ះពាល់នៃពត៌មានតាមអ៊ីនធើណិត មានច្រើនជាងប្រព័ន្ធ និងបណ្តាញផ្សព្វផ្សាយផ្សេងទៀត។

នៅកម្ពុជា សិស្សសាលាដែលរស់នៅក្រៅទីក្រុង មិនទាន់មានអ៊ីនធើរណិតប្រើប្រាស់នៅឡើយទេ ប៉ុន្តែចំពោះ កុមារជាច្រើនដែលរស់នៅទីប្រជុំជន និងទីក្រុង គឺអាចប្រើប្រាស់អ៊ីនធើរណិតតាមហាង ឬតាមទូរស័ព្ទដៃ។ សិស្សសាលាភាគច្រើន (នៅទីរួមខេត្តសែនមនោរម្យ) ក្នុងខេត្តមណ្ឌលគិរី មានគណនីបណ្តាញសង្គមហ្វេសប៊ុក និងប្រើអ៊ីនធើរណិតទូរស័ព្ទដៃដើម្បីលេងកំសាន្ត។ នៅវៀតណាម

អ្នកមានកាតព្វកិច្ចម្នាក់នៅខេត្តមណ្ឌលគិរី ប្រទេសកម្ពុជា បានលើកឡើងថា *"ទូរស័ព្ទចល័តមានវីដេអូដែលអាចឲ្យអ្នកប្រើប្រាស់ចែកចាយរូបភាពអាសអាភាស ហើយបន្ទាប់ពីកុមារបានឃើញរូបភាពទាំងនេះ ពួកគេនឹងចង់សាកល្បង"*។

សិស្សសាលាភាគច្រើនមានទូរស័ព្ទចល័ត និងផ្ញើរសារដើម្បីទាក់ទងជាមួយមិត្តភក្តិ ហើយសិស្សផ្សេងទៀតភ្ជាប់អ៊ីនធើរណិតតាមកុំព្យូទ័រយួរដៃ ឬតាមហាងកាហ្វេ។ ក្នុងចំណោមសិស្សឡាវ ៣៦ នាក់ មានតែ ៥ នាក់ប៉ុណ្ណោះ ដែលមិនធ្លាប់ប្រើទូរស័ព្ទដៃ។ កុមារដែលមានអាយុចាប់ពី ១៥ ដល់ ១៨ ឆ្នាំ សុទ្ធតែបានប្រើប្រាស់ទូរស័ព្ទដៃ។ ក្រុមស្រាវជ្រាវក៏បានសង្កេតឃើញថា សិស្សសាលាបឋមសិក្សាជាច្រើនមានទូរស័ព្ទដៃប្រើប្រាស់នៅសាលាផងដែរ។

ជាទូទៅ ឪពុកម្តាយ និងអ្នកមានកាតព្វកិច្ច មិនបានដឹងពីផលប៉ះពាល់នៃការលេងហ្គេមតាមអ៊ីនធើរណិត កម្មវិធីជជែកកំសាន្ត បណ្តាញទំនាក់ទំនងសង្គម ដូចជា ហ្វេសប៊ុក និងគេហទំព័រផ្សព្វផ្សាយព័ត៌មានសង្គមផ្សេងទៀត លើជំនឿខាងផ្លូវភេទ ការប្រព្រឹត្តិ និងបណ្តាញកុមារនោះឡើយ។ អ្នកស្រាវជ្រាវ ក៏បានបង្ហាញថា មិនទាន់មានការគ្រប់គ្រងលើការប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់កុមារនៅឡើយទេ ហើយឪពុកម្តាយ និងអ្នកមានកាតព្វកិច្ចមានការព្រួយបារម្ភខ្លាចកូនររបស់ខ្លួន ញៀននឹងវីដេអូហ្គេម ឬមើលរូបភាពអាសអាភាសជាដើម។ អ្នកមានកាតព្វកិច្ចម្នាក់នៅខេត្តមណ្ឌលគិរី ប្រទេសកម្ពុជា បានរៀបរាប់ថា ៖

> “" *ទូរស័ព្ទចល័តមានវីដេអូដែលអាចឲ្យអ្នកប្រើប្រាស់ចែកចាយរូបភាពអាសអាភាស ហើយបន្ទាប់ពីកុមារបានឃើញរូបភាពទាំងនេះ ពួកគេនឹងចង់សាកល្បង* " ។

កំណើននៃការញៀននឹងហ្គេមអ៊ីនធើរណិត គ្រោះថ្នាក់ពាក់ព័ន្ធនឹងបំណុល និង គ្រោះថ្នាក់ចំពោះការជួញដូរផ្លូវភេទ គឺដោយសារតែបច្ចេកវិទ្យាឌីជីថលកាន់តែរីកចម្រើន ដែលមានបញ្ជាក់ដោយទិន្នន័យតាមមូលដ្ឋាន។ អ្នកផ្តល់បទសម្ភាសយល់ថា ការលក់ផ្លូវភេទធ្វើឲ្យមានគ្រោះថ្នាក់ផ្សេងទៀត និងនិន្នាការនៃការសេពគ្រឿងញៀន និងការលេងហ្គេមតាមអ៊ីនធើរណិត ហើយក៏មានរបាយការណ៍កាន់តែច្រើនពីករណីនៃការរំលោភបំពានកុមារ និងប្រព័ន្ធផ្សព្វផ្សាយរូបភាពអាសអាភាសផងដែរ[១១៨]។ ដូចដែលបានរៀបរាប់នៅខាងដើមជំពូកនេះ កុមារីម្នាក់នៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ បានរៀបរាប់ថា មិត្តភក្តិរបស់នាងបានលក់ផ្លូវភេទ ដើម្បីយកប្រាក់ទិញថ្នាំញៀន និងបានឈប់ជក់ថ្នាំនៅពេលដែលនាងត្រូវបានចាប់ខ្លួន ហើយម្តាយមួយរូបនៅទីក្រុងផាត់តាយ៉ាក៏បានរៀបរាប់ពីករណីមិត្តភក្តិរបស់កូនគាត់ ដែលព្រមឲ្យបុរសបរទេសម្នាក់បំពានលើរាងកាយ ដើម្បីបានប្រាក់យកទៅលេងហ្គេមតាមអ៊ីនធើរណិត។

ទោះបីជាអ្នកផ្តល់បទសម្ភាសមួយចំនួនបានលើកឡើងពីជនប្រព្រឹត្តិបទល្មើសផ្លូវភេទ ដែលបានប្រើប្រាស់អ៊ីនធើរណិតដើម្បីទាក់ទង និងបង្កើតមិត្តភក្តិជាមួយកុមារ មានអ្នកផ្តល់បទសម្ភាសមួយចំនួន បានបង្ហាញពីការយល់ដឹងពីបច្ចេកទេសទាក់ទង ដូចជាការបង្កើតអត្តសញ្ញាណក្លែងក្លាយតាមអ៊ីនធើរណិតដើម្បីសន្ទនាបញ្ហាផ្លូវភេទជាមួយកុមារ។ នៅប្រទេសវៀតណាម កុមារីម្នាក់បាននិយាយថា នៅពេលដែលម្តាយរបស់នាងស្តីបន្ទោសនាង នាងចង់ជជែកលេងជាមួយ “មិត្ត” របស់នាងតាមអ៊ីនធើរណិត។ *“គាត់ជាមនុស្សដែលយល់ចិត្តណាស់ ដោយគាត់បានផ្តល់ដំបូន្មានដល់ខ្ញុំ និងធ្វើឲ្យខ្ញុំមានអារម្មណ៍ធូរស្រាល”*។ សិស្សប្រុសអាយុ ១៧ ឆ្នាំ ម្នាក់ទៀតបានរៀបរាប់ថា “ខ្ញុំអាចប្រាប់ពីបញ្ហារបស់ខ្ញុំដល់មនុស្សនោះ ដោយមិនខ្លាចថាមនុស្សនោះប្រាប់មិត្តរួមថ្នាក់ ឬគ្រូ ឬឪពុកម្តាយរបស់ខ្ញុំឲ្យដឹងនោះឡើយ”។ វាហាក់បង្ហាញថាមធ្យោបាយអនាមិកភាពនេះជំរុញឲ្យកុមារ និងយុវជនបង្ហាញរឿងសម្ងាត់ ដែលឪពុកម្តាយ ឬមិត្តភក្តិមិនដឹង។ ឧ. ករណីកុមារីម្នាក់នៅខេត្តមណ្ឌលគិរី ដែលច្រើននិយាយពីបញ្ហារបស់នាងប្រាប់ទៅមិត្តតាមអ៊ីនធើរណិតរបស់នាង។

[១១៨] Child Frontier (ឆ្នាំ២០០៩) របាយការណ៍ ពង្រាងស្តីពីការជួញដូរផ្លូវភេទកុមារនៅប្រទេស ឡាវ។

កុមារភាគច្រើនបានឲ្យដឹងថា ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលអាចធ្វើឲ្យមនុស្សប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពាន ប៉ុន្តែមានកុមារតិចតួចណាស់ដែលយល់ពីដំណើរការនៃការប្រឈមនឹងគ្រោះថ្នាក់នេះ។ សិស្សស្រីអាយុ ១០ ឆ្នាំម្នាក់នៅទីក្រុង Luang Prabang នៃប្រទេសឡាវ បានបញ្ជាក់ថា ៖

> *"មនុស្សអាក្រក់អាចប្រើប្រាស់ទូរស័ព្ទដៃដើម្បីផ្ញើសារបោកប្រាស់ម្ចាស់ទូរស័ព្ទ ហើយឪពុកម្ដាយមិនបានគ្រប់គ្រងការប្រើប្រាស់ទូរស័ព្ទដៃ និងអ៊ីនធើរណិតរបស់កូនឡើយ"*។

យោងតាម សិស្សស្រីអាយុ ១០ ឆ្នាំម្នាក់នៅទីក្រុង លួងប្រាបាន នៃប្រទេសឡាវបាន ឲ្យដឹងថា *"មនុស្សអាក្រក់អាចប្រើប្រាស់ទូរស័ព្ទដៃដើម្បីផ្ញើសារបោកប្រាស់ម្ចាស់ទូរស័ព្ទ ហើយឪពុកម្ដាយមិនបានគ្រប់គ្រងការប្រើប្រាស់ទូរស័ព្ទដៃ និងអ៊ីនធើរណិតរបស់កូនឡើយ"*។

កុមារភាគច្រើនមិនបានដឹងពី "សេវាទូរស័ព្ទជំនួយ" ដែលជាបណ្ដាញសម្រាប់ឲ្យកុមារ ទទួលបានព័ត៌មាន និងដំបូន្មានជាសម្ងាត់ទាក់ទងនឹងបញ្ហារបស់ពួកគេឡើយ[១១៩] លើកលែងកុមារមួយចំនួននៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ និងប្រទេសឡាវ។

# ការឆ្លើយតបចំពោះការរំលោភបំពាន

## កម្រិតគ្រួសារ

ការឆ្លើយតបចំពោះការរំលោភបំពានមានភាពខុសគ្នាទៅតាមទីកន្លែងផ្សេងៗ។ ជាទូទៅ ការឆ្លើយតបគឺអាស្រ័យលើភាពបើកចំហរនៃទំនាក់ទំនងរវាងឪពុកម្ដាយ និងកូន និងទំហំនៃការផ្ដល់តម្លៃដល់កិត្តិយស និងកេរ្តិ៍ឈ្មោះគ្រួសារ។

កុមារឡាវដែលផ្ដល់បទសម្ភាសបានបញ្ជាក់ថា ពួកគេនឹងរាយការណ៍ពីការកើតមានការរំលោភបំពាន ឬអំពើហិង្សាទៅកាន់ឪពុកម្ដាយរបស់ខ្លួន ហើយឪពុកម្ដាយទាំងនោះ យល់ឃើញថា ពួកគាត់ពិតជាមានសារៈសំខាន់ក្នុងការការពារកូន មើលថែទាំកូន និងផ្ដល់ដំបូន្មានដល់កូនពីគ្រោះថ្នាក់ផ្សេងៗ ហើយ ពួកគាត់ក៏រំពឹងថា អាជ្ញាធរនឹងគាំទ្រពួកគាត់ក្នុងការបំពេញភារកិច្ចនេះ។

នៅវៀតណាម និងកម្ពុជា កុមារមិនប្រាប់រឿងសម្ងាត់ ឬបញ្ហា ដូចជា ការរំលោភបំពានផ្លូវភេទដល់ ឪពុកម្ដាយ ឬមនុស្សពេញវ័យនោះឡើយ[១២០]។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ ក្មេងលក់វត្ថុអនុស្សាវរីយ៍តាមផ្លូវ និងក្មេងតាមផ្លូវនៅវៀតណាម បានរាយការណ៍ថា នៅពេលដែលពួកគេប្រឈមនឹង ការរំលោភបំពានផ្លូវភេទ ពួកគេនឹងប្រាប់ឪពុកម្ដាយឲ្យបានដឹង ខណៈដែលសិស្សសាលានិយាយថា ពួកគេនឹងមិនប្រាប់ឪពុកម្ដាយពីបញ្ហានេះឡើយ។ កត្តានេះគឺក៏ដោយសារតែឪពុកម្ដាយ ដែលស្ថិតក្នុងវណ្ណៈការងារ មិនសូវប្រឈមនឹងការមាក់ងាយរបស់សង្គមទៅលើមុខមាត់គ្រួសារ ភាពខ្មាសអៀន និងការអាប់អោនកិត្តិយសដូចឪពុកម្ដាយដែលស្ថិតក្នុងវណ្ណៈកណ្ដាលនោះឡើយ។

នៅទីក្រុងឈៀងម៉ៃនៃប្រទេសថៃ មានការផ្ដោតសំខាន់លើការ "រក្សាមុខមាត់" និងកេរ្តិ៍ឈ្មោះរបស់គ្រួសារ។ ការឆ្លើយតបរបស់គ្រួសារក៏អាចអាស្រ័យលើចំណេះដឹងពីការរំលោភបំពានផ្លូវភេទ សារៈសំខាន់របស់គ្រួសារក្នុងសហគមន៍ និងទីតាំងនៃការរំលោភបំពាន ហើយបញ្ហាដែលគួរឲ្យព្រួយបារម្ភនោះគឺការដោះស្រាយបញ្ហាតាមរយៈសំណងជំងឺចិត្ត។

នៅទីក្រុងផាត់តាយ៉ា សម្ភាជផ្នែកវប្បធម៌ពីសហគមន៍ក្នុងមូលដ្ឋាន មិនសូវជាសំខាន់ប៉ុន្មាននោះ

[១១៩] មានសេវាទូរស័ព្ទជំនួយថ្នាក់ជាតិជាច្រើនសម្រាប់កុមារនៅវៀតណាម និងថៃ។ បណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា នៅថ្នាក់ជាតិ ក៏មានផងដែរ ប៉ុន្តែនៅអំឡុងពេលកំពុងសិក្សា មិនទាន់មានការផ្សព្វផ្សាយនៅក្រៅទីក្រុងភ្នំពេញនៅឡើយទេ។ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ក៏មានសេវាទូរស័ព្ទជំនួយទាក់ទងនឹងសុខភាពផ្លូវភេទសម្រាប់យុវជន ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលសុខភាព និងការអភិវឌ្ឍយុវជនវៀងច័ន្ទក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ក្រុងវៀងច័ន្ទ។

[១២០] Grillot (ឆ្នាំ២០០៥) បានមើលឃើញថា កុមារនៅកម្ពុជាមិនត្រូវបានលើកទឹកចិត្តឲ្យបញ្ចេញពីខ្លួនឯងឡើយ ប៉ុន្តែត្រូវយល់ស្របទៅនឹងគំនិតរបស់មនុស្សចាស់ ដែលអាចមានផលវិបាកក្នុងការរាយការណ៍ពីការរំលោភបំពាន។ Grillot, C (ឆ្នាំ២០០៥) ចំណង់ផ្លូវភេទលើកុមារតាមដងផ្លូវនៅកម្ពុជា-ការសិក្សាពីទិដ្ឋភាពទីក្រុងភ្នំពេញ និងជនរងគ្រោះ អង្គការ Action Pour Les Enfants។

ឡើយ។ ដូច្នេះ ក្រុមគ្រួសារដែលមានកូនរងការរំលោភបំពាន ច្រើនទូរស័ព្ទប្ដឹងប៉ូលិស ក្នុងករណីមានការរំលោភបំពាន។

## អ្នកមានកាតព្វកិច្ច

នៅទីក្រុងឈៀងម៉ៃនៃប្រទេសថៃ ការឆ្លើយតបផ្លូវការចំពោះការរំលោភបំពាន ធ្វើឡើងនៅត្រឹមកម្រិតសង្គមស៊ីវិល និងកម្មវិធីរបស់រដ្ឋាភិបាល ដូចជា ការផ្ដល់ទីជម្រកស្នាក់នៅជាដើម។ អន្តរាគមន៍ របស់ប៉ូលិសមានការពិបាក ដោយសារតែសហគមន៍មានការព្រួយបារម្ភពីផលប៉ះពាល់លើកេរ្តិ៍ឈ្មោះរបស់ខ្លួន។ ចំណែកនៅតំបន់ឆ្ងាយជុំវិញទីក្រុងឈៀងម៉ៃ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានចោទប្រកាន់អាជ្ញាធរ មូលដ្ឋានដែលបានបិទបាំងករណីរំលោភបំពានផ្លូវភេទកុមារ ដោយសារតែពួកគេ គឺជាជនប្រព្រឹត្តិ ឬ ព្យាយាមការពារផលប្រយោជន៍របស់ជនប្រព្រឹត្តិ។



ចំណែកនៅផាត់តាយ៉ា នៃប្រទេសថៃ អន្តរាគមន៍មួយចំនួន ទទួលបានការគាំទ្រពីប៉ូលិសបរទេស ដូចជា ការការពារការជួញដូរកុមារ និងផ្ដល់ជំនួយតាមអ៊ីនធើរណិត( CEOP)ក្រោមការគ្រប់គ្រងរបស់ទីភ្នាក់ងារឧក្រិដ្ឋកម្មជាតិ របស់ចក្រភពអង់គ្លេស ឬទីភ្នាក់ងារពង្រឹងពន្ធគយ និងអន្តោប្រវេសន៍ របស់សហរដ្ឋអាមេរិក( ICE)។ អ្នកមានកាតព្វកិច្ចបានស្នើឲ្យមានជំនួយអន្តរជាតិ ហើយការដាក់សម្ពាធ នេះគឺជាកត្តាសំខាន់ដើម្បីបង្ហាញថា រាល់ករណីដែលមានការជួយជ្រោមជ្រែងពីប៉ូលិសបរទេស ទទួលបានជោគជ័យ ច្រើនជាងករណីដែលមានការជួយជ្រោមជ្រែងពីប៉ូលិសក្នុងមូលដ្ឋាន។

យោងតាមករណីដូចមាននៅតាមទីតាំងស្រាវជ្រាវផ្សេងទៀត អ្នកមានកាតព្វកិច្ច និងមន្ត្រីរដ្ឋាភិបាលនៅទីក្រុងផាត់តាយ៉ា បានរាយការណ៍ថា អំពើពុករលួយរបស់អាជ្ញាធរគឺជាឧបសគ្គនៃការឆ្លើយតប ចំពោះការរំលោភបំពានផ្លូវភេទកុមារ ដែលបង្កឡើងដោយជនបរទេស។ មន្ត្រីរដ្ឋាភិបាលម្នាក់ បានរៀបរាប់ថា រាល់លើកដែលមានជំនួយពីអាជ្ញាធរមូលដ្ឋានក្នុងការចាប់ខ្លួនជនប្រព្រឹត្តិបទល្មើសផ្លូវភេទនោះ មិនដែលបានទទួលជោគជ័យនោះឡើយ។ គាត់ក៏បានបញ្ជាក់ទៀតថា អាជ្ញាធរមូលដ្ឋានហាក់មានទំនាក់ទំនងជាមួយម្ចាស់បានីយដ្ឋាន ដែលអនុញ្ញាតឲ្យមានសកម្មភាពខុសច្បាប់បែបនេះកើតឡើង ដូចជា ការជួលអនីតិជនដើម្បីទាក់ទាញភ្ញៀវ និង/ឬអនុញ្ញាតឲ្យអនីតិជនធ្វើការក្នុងបានីយដ្ឋានដើម្បីបម្រើសេវាផ្លូវភេទដល់ភ្ញៀវជាដើម។

នៅកម្ពុជា សិស្សសាលា និងអ្នកមានកាតព្វកិច្ចយល់ថា អ្នកជិតខាងដែលមានទំនួលខុសត្រូវ និងអ្នកភូមិផ្សេងមានតួនាទីយ៉ាងសំខាន់ក្នុងការបង្ការការរំលោភបំពានផ្លូវភេទកុមារ តាមរយៈការអប់រំកុមារ និងការចុះអន្តរាគមន៍ដោយផ្ទាល់។ ឧ. អ្នកភូមិចេះដឹងម្នាក់បានឃើញក្រុមបុរស កំពុងបញ្ចុះបញ្ចូលកុមារីដែលរស់នៅក្នុងមូលដ្ឋានជាមួយគាត់ឲ្យចូលទៅក្នុងឡាន ហើយគាត់ក៏បាននិយាយទៅកាន់កុមារីទាំងនោះ និងទូរស័ព្ទប្ដឹងប៉ូលិស។ ចំណែកគណៈកម្មាធិការទ្រទ្រង់សាលាក្នុងមូលដ្ឋាន ក្នុងខេត្តសៀមរាប នៃប្រទេសកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំកុមារពីរបៀបការពារសុវត្ថិភាព ព្រមទាំងធ្វើអន្តរាគមន៍ ឲ្យកុមារទៀតផង។

ចំណែកនៅប្រទេសឡាវ ការដោះស្រាយបញ្ហាការការពារកុមារនៅកម្រិតភូមិ ត្រូវប្រឈមនឹងរចនាសម្ព័ន្ធ មួយចំនួន។ អង្គភាពសម្របសម្រួលភូមិនៅក្នុងភូមិនីមួយៗ ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលជម្លោះរវាងគូភាគី និងរវាងសមាជិកគ្រួសារ។ អាជ្ញាធរភូមិបំពេញការងារ បានល្អក្នុងការកំណត់ និងឆ្លើយតបករណីផ្សេងៗ ដូចជា ការសេពគ្រឿងញៀន និង កុមារដែលមានអាកប្បកិរិយាមិនសមស្រប ប៉ុន្តែបើតាមបទសម្ភាស មិនមានប្រធានភូមិណាមួយធ្លាប់ដោះស្រាយបញ្ហារំលោភបំពានកុមារឡើយ។ ប្រសិនបើមានរបាយការណ៍ពីការរំលោភបំពានកុមារ ករណីនោះត្រូវឆ្លងកាត់ដំណើរការសម្របសម្រួល។ បុរសជាឪពុកជនជាតិឡាវបានរាយការណ៍ថា មានករណីនៃការរំលោភបំពានកុមារក្នុងភូមិរបស់គាត់ដែលមិនបានរាយការណ៍ និងកត់ត្រាទុក ដោយសារតែអាជ្ញាធរខ្លាច "អាប់មុខ" ដោយសារភូមិនោះត្រូវបានប្រកាសថាជាភូមិដែលមិនមានឧក្រិដ្ឋកម្ម[១២១]។

១២១ រដ្ឋាភិបាលឡាវ មានគោលនយោបាយមួយក្នុងការផ្ដល់រង្វាន់ ដល់ភូមិដែលមានអត្រាអំពើឧក្រិដ្ឋកម្មទាប ពោលគឺទាក់ទងនឹងការដែលមិនសូវមាន ការរាយការណ៍ពីការរំលោភបំពានកុមារ។

នៅប្រទេសវៀតណាម ការស្រាវជ្រាវ បានបង្ហាញពីឥរិយាបថក្នុងការបដិសេធចោល របស់អាជ្ញាធរមូលដ្ឋាន ចំពោះការកើតមានការរំលោភបំពានផ្លូវភេទកុមារ ក្នុងសហគមន៍របស់ខ្លួន។ អាជ្ញាធរមូលដ្ឋានចាត់ទុកករណីរំលោភបំពានជាកិច្ចការរបស់មូលដ្ឋាន ឬបញ្ហារបស់ប្រជាជន ជាជាងអំពើឧក្រិដ្ឋកម្ម និងកម្រមានអន្តរាគមន៍ណាស់។ ឧ. ប៉ូលិសពីរនាក់ មានការសប្បាយចិត្តត្រង់ថា ដំណោះស្រាយរដ្ឋប្បវេណីចំពោះករណីរំលោភបំពានផ្លូវភេទកុមារ មានភាពប្រសើរជាង ការឃុំឃាំងជនប្រព្រឹត្តិបទល្មើស ដោយសារករណីបែបនេះ យ៉ាងហោចណាស់ អាចធ្វើឲ្យជនប្រព្រឹត្តិព្រមរៀបការ ឬសងជំងឺចិត្តជាប្រាក់ ដល់ជនរងគ្រោះ។ ក្រៅពីនេះ ជនរងគ្រោះជាកុមារមិនអាចដាក់ពាក្យបណ្តឹងដោយខ្លួនឯងបានឡើយ ហើយ ប៉ូលិសនឹងចាត់វិធានការសមស្របនៅពេលដែលសមាជិកគ្រួសារជនរងគ្រោះ ឬសាក្សីផ្សេងទៀតដាក់ពាក្យបណ្តឹង។

ជំពូក ៤

# ភាពងាយរងគ្រោះ និងឱកាស



# ជំពូក ៤ ៖ ភាពងាយរងគ្រោះ និងឱកាស



ជំពូកនេះរំលឹកពីគ្រោះថ្នាក់ផ្សេងទៀតចំពោះកុមារដែលរងការរំលោភបំពានផ្លូវភេទ ដូចជា ភ្ញៀវទេសចរ និងអ្នកធ្វើដំណើរទៅកាន់ទីកន្លែងដែលពួកគេរស់នៅ និងស្ថានភាពក្រៅពីនេះ។ ផ្នែកនេះក៏ពិនិត្យមើល កាលៈទេសៈខាងក្នុង និងខាងក្រៅ និងលក្ខខណ្ឌដែលបង្កើន ឬការកាត់បន្ថយភាពងាយរងគ្រោះទៅនឹង ការរំលោភបំពាននេះ។ ក្រៅពីនេះមានការបង្ហាញពី ឧបសគ្គដែលរាំងស្ទះដល់ការទទួលបានអន្តរាគមន៍ សមស្រប ព្រមទាំងឱកាសក្នុងការផ្តល់ព័ត៌មាន និងការគាំទ្រដល់កុមារផងដែរ។

## ស្ថានភាពសមាជិកគ្រួសារ និង គ្រួសារទាំងមូល

មានការកំណត់កត្តាជាច្រើនពាក់ព័ន្ធនឹងសមាជិកគ្រួសារ និងគ្រួសារទាំងមូល ដែលធ្វើឲ្យកុមារងាយ រងគ្រោះទៅនឹងការរំលោភបំពានផ្លូវភេទ ដែលកត្តាទាំងនេះរួមមាន ការសេពគ្រឿងញៀនក្នុងចំណោម សមាជិកគ្រួសារ អំពើហិង្សាក្នុងគ្រួសារ ការបែកបាក់ ឬការបាត់បង់សមត្ថភាព រកប្រាក់ចិញ្ចឹមគ្រួសារ ភាពក្រីក្រ បំណុល និងចំណាកស្រុកពីតំបន់ជនបទទៅទីក្រុង។ ការស្រាវជ្រាវភាគ ច្រើនបាន បង្ហាញឲ្យ ឃើញថា អ្នកផ្តល់បទសម្ភាសបានចាត់ទុកភាពក្រីក្រក្នុងគ្រួសារ និងស្ថានភាពសេដ្ឋកិច្ចសង្គមទាប ជា កត្តាចម្បងដែលធ្វើឲ្យកុមារងាយប្រឈមនឹងការរំលោភបំពាន ដែលកត្តាទាំងនេះអាចធ្វើឲ្យឪពុកម្តាយដាច់ ចិត្តបញ្ជូនកូនរបស់ខ្លួនឲ្យទៅធ្វើការនៅកន្លែងដែលមានគ្រោះថ្នាក់ និងទទួលបានប្រាក់កម្រៃទាប ដូចជា ការលក់ដូរតាមផ្លូវ ការងារតាមផ្ទះ ឬធ្វើជាកម្មកររោងចក្រដែលនៅឆ្ងាយពីផ្ទះ។ នៅពេលដែលកុមារ ត្រូវ បានបញ្ជូនឲ្យទៅធ្វើជាអ្នកលក់វត្ថុអនុស្សាវរីយ៍ ក្នុងតំបន់ទេសចរណ៍ដែលល្បីល្បាញ ឬ កន្លែងដែលមាន ផ្ទះ បនស្រីច្រើន ឬ ក៏សមាជិកគ្រួសារណាម្នាក់ ប្រឡូកដោយ ផ្ទាល់ក្នុងឧស្សាហកម្មទេសចរណ៍ផ្លូវភេទ មនុស្សពេញវ័យ កុមារងាយប្រឈមទៅនឹង ការរំលោភបំពានកាន់តែខ្លាំង។

អវត្តមានរបស់ឪពុកម្តាយ ក៏អាចធ្វើឲ្យកុមារមានគ្រោះថ្នាក់ខ្ពស់ក្នុងការប្រឈមនឹងការរំលោភបំពានផ្លូវ ភេទផងដែរ។ ឧ. មានការបង្ហាញថា នៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ ឪពុកម្តាយភាគច្រើនចេញទៅធ្វើ ការនៅកន្លែងបម្រើសេវាកំសាន្តតាំងពីរសៀលរហូតដល់យប់ជ្រៅ។ ដូច្នេះ កូនៗត្រូវបានទុកចោលនៅផ្ទះ ដោយមិនមានការគ្រប់គ្រង និងរស់នៅក្នុងកន្លែងដែលសំបូរដោយសកម្មភាពគ្រោះថ្នាក់ ដូចជា ផ្លូវភេទ ការសេពគ្រឿងញៀន  និងអាកប្បកិរិយាដែលប្រឈមនឹងគ្រោះថ្នាក់ និងជាកន្លែងសប្បាយដែលអាច ឲ្យកុមារប្រឡូកក្នុងការជួញដូរផ្លូវភេទ។

នៅតាមមូលដ្ឋានក្នុងប្រទេសកម្ពុជា ឪពុកម្តាយជាច្រើនមិនបានចូលរួមផ្តល់បទសម្ភាសឡើយ ដោ យសារតែពួកគាត់ជាប់រវល់នឹងការរកស៊ី ចំណែកនៅខេត្ត ទុយង្វៀន ក្នុងទីក្រុងហៃហ្វុងប្រទេស វៀតណាមវិញ ប្តី និងឪពុកត្រូវចេញទៅនេសាទត្រីនៅសមុទ្ររាប់សប្តាហ៍ ឬរាប់ខែ ទើបត្រឡប់មកវិញ ខណៈដែលស្ត្រីក្មេងៗជាច្រើន ត្រូវធ្វើចំណាកស្រុកទៅបរទេស ដើម្បីរៀបការជាមួយបុរសមកពីតំបន់ អាស៊ីបូព៌ា។ នៅទីក្រុងហៃហ្វុង ឪពុកម្តាយបានទិញរបស់ និងផ្តល់ជាប្រាក់ដល់កូនដោយសារតែមិនបាន នៅជាមួយកូនៗ។ នៅថ្ងៃធ្វើបទសម្ភាសជាក្រុមនោះ មានសិស្សម្នាក់បានរៀបរាប់ថា ឪពុកម្តាយរបស់គាត់ បានដកប្រាក់ពីហោប៉ៅឲ្យគាត់ចំនួនពីរលានដុង (១០០ ដុល្លារអាមេរិក)។ ម្តាយអាយុ ៥៣ ឆ្នាំម្នាក់នៅ ទីក្រុងវៀងច័ន្ទនៃប្រទេសឡាវ បានរៀបរាប់ស្ថានភាពដូចខាងក្រោម៖

> *"សម្រាប់កូនដែលឪពុកម្តាយរបស់ខ្លួនមិនមានពេលវេលាគ្រប់គ្រាន់ នៅជាមួយពួកគេ ដោយសារតែជាប់រវល់នឹងការងារ ឬគ្រួសារបែកបាក់ ឬគ្រួសារដែលបាត់បង់ឱកាស កូនទាំង នោះនឹងនៅឯកោតែម្នាក់ឯង ធ្វើអ្វីដោយខ្លួនឯង និងមានចរិតកោងកាច។ ចំណែកឪពុកម្តាយមួយ ចំនួនដែលចិញ្ចឹមកូនដោយតែងតែផ្តល់លុយ និងរបស់គ្រប់យ៉ាងដែលកូនចង់បាននោះ នឹងធ្វើឲ្យ កូនរបស់ខ្លួនក្លាយជាមនុស្សទម្រើស។"*

គ្រួសារបែកបាក់ និងបាត់បង់សមត្ថភាពរកប្រាក់ចំណូលក៏ត្រូវបានចាត់ទុកថាជាកត្តាបង្កគ្រោះថ្នាក់មួយ ផងដែរ។ សិស្សសាលាវិជ្ជាជីវៈនៅទីក្រុងហូជីមិញ និងក្មេងលក់វត្ថុអនុស្សាវរីយ៍ តាមផ្លូវនៅវៀតណាម មានគ្រោះថ្នាក់ខ្ពស់ទៅនឹងការរំលោភបំពានផ្លូវភេទ នៅពេលដែលពួកគេរស់នៅតែក្នុងផ្ទះជាមួយ

ម្ដាយដែលបានលែងលះ ឬរៀបការម្ដងទៀត និងឪពុកចុងដែលមានសមាជិកជាច្រើនផ្សេងទៀត។ មិនមានវិធានការការពារមិនឲ្យមានការរំលោភបំពានផ្លូវភេទកុមារឡើយ ជាពិសេសការរៀបចំកន្លែងគេង ហើយការកំព្រាឪពុកម្ដាយ ឬការបង្កជម្លោះ ឬការបែកបាក់គ្រួសារ គឺជាកត្តាគ្រោះថ្នាក់សំខាន់ៗផ្សេងទៀត ដែលធ្វើឲ្យកុមារកាន់តែងាយរងគ្រោះទៅនឹងការរំលោភបំពានផ្លូវភេទ។

គ្រួសារដែលឪពុកម្ដាយ ឬអ្នកថែទាំមានឥរិយាបថរំលោភបំពានផ្លូវកាយ ឬផ្លូវចិត្ត ឬញៀនគ្រឿងញៀន ក៏អាចធ្វើឲ្យកុមារបាត់បង់ការយកចិត្តទុកដាក់ និងរងការកេងប្រវ័ញ្ចផងដែរ ហើយនៅដំណាក់កាលចុងក្រោយកុមារនឹងត្រូវរត់ចេញពីផ្ទះទៅកន្លែងផ្សេងទៀត ដូចជា ទីក្រុងផាត់តាយ៉ានៃប្រទេសថៃ ដែលរបៀបរបបរស់នៅទីនោះតែងតែមានលក្ខណៈកេងប្រវ័ញ្ចគ្នា។

ការសិក្សាបានបង្ហាញថា កុមារដែលរស់នៅ និងធ្វើការតាមផ្លូវងាយរងគ្រោះបំផុតទៅនឹងការរំលោភបំពានផ្លូវភេទ។ អស់រយៈពេលជាងមួយទស្សវត្សរ៍នៃការធ្វើការជាមួយកុមារនៅក្នុងទីក្រុងផាត់តាយ៉ានៃប្រទេសថៃ ប្រធានគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាលម្នាក់ (បច្ចុប្បន្ននៅទីក្រុងឈៀងម៉ៃ) បានមើលឃើញទំនាក់ទំនងផ្ទាល់រវាងការងារនៅតាមផ្លូវ និងការជួញដូរផ្លូវភេទ ៖

> *"ជាទូទៅ កុមារដែលធ្វើការតាមផ្លូវមានអាយុចាប់ពី ៨ ទៅ ១៣ ឆ្នាំ ពោលគឺមិនសូវមានកុមារអាយុលើស ១៤ឆ្នាំឡើយ។ នៅពេលចម្រើនវ័យកាន់តែធំ កុមារទាំងនោះមិនសូវរកប្រាក់បានច្រើននោះឡើយ ចំណែក "អ្នកមើលថែទាំ" បាត់បង់ចំណាប់អារម្មណ៍លើពួកគេ ហើយពួកគេមានអារម្មណ៍ អៀនខ្មាសដែលបានប្រព្រឹត្តិសកម្មភាពដែលមិនទាន់គ្រប់អាយុ។ កុមារទាំងនោះ អាចបង្ខំចិត្តរកស៊ីផ្លូវភេទជាជាងលក់ផ្កា ដើម្បីបានប្រាក់ចិញ្ចឹមជីវិត"*។

ទោះបីជាកុមារតាមផ្លូវមួយចំនួនមានជម្រកស្នាក់នៅ និងទទួលបានអាហារបរិភោគក៏ដោយ ជម្រកស្នាក់នៅនោះអាចជាកន្លែងសម្រាប់ឲ្យកុមារប្រឡូកក្នុងសកម្មភាពជួញដូរផ្លូវភេទ ដោយសារតែសកម្មភាពរបស់កុមារផ្សេងទៀត។ ក្រៅពីនេះ បុគ្គលិកដែលធ្វើការទីនោះ អាចនឹងរំលោភបំពានកុមារដោយសារតែគោលនយោបាយការពារកុមារមានភាពធូររលុង ឬមិនទាន់មានការរៀបចំគោលនយោបាយទាំងនោះ។.

## វិស័យទេសចរណ៍

វត្តមាននៃឧស្សាហកម្មទេសចរណ៍ គឺជាកត្តាគ្រោះថ្នាក់មួយផ្សេងទៀតដែលធ្វើឲ្យកុមារ ងាយរងគ្រោះ។ ទោះយ៉ាងណាការសិក្សាបានបង្ហាញថា កុមារ និងមនុស្សពេញវ័យមិនចាត់ទុកភ្ញៀវទេសចរ ជាជនបង្កគ្រោះថ្នាក់នោះឡើយ។ ឧទាហរណ៍ កុមារឡាវ សប្បាយចិត្តនៅពេលដែលឃើញជនបរទេសចូលមកទស្សនាក្នុងប្រទេសរបស់ខ្លួន ដោយសារតែវិស័យទេសចរណ៍គឺជាប្រភពប្រាក់ចំណូលដ៏សំខាន់សម្រាប់គ្រួសារ និងប្រទេសជាតិ។

> *" ក្នុងកិច្ចពិភាក្សាក្រុមគោលដៅ សិស្សប្រុសអាយុ ១០ ឆ្នាំម្នាក់ មកពីទីក្រុង* Luang Prabang *បានឲ្យដឹងថា "យើងបានឃើញភ្ញៀវទេសចរជាច្រើនកំពុងធ្វើដំណើរតាមផ្លូវក្នុងទីក្រុង។ ភ្ញៀវទេសចរបារាំង អឺរ៉ុប និងអាស៊ីកំពុងតែទិញអីវ៉ាន់ក្នុងហាង និងញ៉ាំអាហារនៅតាមភោជនីយដ្ឋាននានា។ យើងមិនខ្មាសអៀនក្នុងការប្រាប់ផ្លូវដល់ភ្ញៀវទេសចរទាំងនោះឡើយ។ យើងបានរៀនភាសាបារាំងនៅសាលា ហើយយើងរីករាយនឹងនិយាយភាសាបារាំង និងអង់គ្លេសជាមួយភ្ញៀវទាំងនោះ។"*

សិស្សសាលាមធ្យមសិក្សានៅខេត្តមណ្ឌលគិរីនៃប្រទេសកម្ពុជា យល់ឃើញថា ភ្ញៀវទេសចរអាចផ្ដល់អត្ថប្រយោជន៍ដល់ខេត្តរបស់ខ្លួន ដូចជា ការងារ និងឱកាសក្នុងការហាត់និយាយភាសាអង់គ្លេស។ នៅទីក្រុង ឈៀងម៉ៃ នៃប្រទេសថៃ សិស្សស្រីជនជាតិ Hmong អាយុ ១៣ ឆ្នាំម្នាក់ ដែលបានជួបជនបរទេសបន្ទាប់ពីនាងចេញពីសាលារៀន បានរៀបរាប់ថា *"នៅពេលដែលខ្ញុំឃើញជនបរទេសស្បែកស លេងជាមួយក្មេងៗ ខ្ញុំគិតថា គាត់គឺជាមនុស្សចិត្តល្អ"*។ ក្រៅពីនេះ ក្រុមជាតិពន្ធុនៅទីក្រុងឈៀងម៉ៃ មានគំនិតវិជ្ជមានលើជនបរទេសដែលបានចិញ្ចឹមកុមារ ឬផ្ដល់ប្រាក់ឧបត្ថម្ភការសិក្សារបស់កុមារ។

កុមារឡាវពីរបីនាក់ បានបង្ហាញពីការព្រួយបារម្ភថា កុមារទាំងនោះអាចនឹងរងឥទ្ធិពល និងធ្វើតាមទម្លាប់មិនល្អ ដូចជាសម្លៀកបំពាក់មិនសមរម្យ ការថើប និងអោបគ្នាក្នុងទីសាធារណៈ ហើយកុមារមួយចំនួនទៀតព្រួយខ្លាចថា ភ្ញៀវទេសចរអាចមានជាប់ពាក់ព័ន្ធនឹងការរំលោភបំពានកុមារ និងមិនលើកទឹកចិត្តឲ្យកុមារសន្ទនាជាមួយភ្ញៀវទេសចរទាំងនោះ ៖ "*វិស័យទេសចរណ៍អាចបណ្តាលឲ្យមានការរំលោភបំពានកុមារ ដោយសារតែមិនមែនភ្ញៀវទេសចរទាំងអស់សុទ្ធតែជាមនុស្សល្អនោះឡើយ និងអាចជាឧក្រិដ្ឋជនជនសេពគ្រឿងញៀន ឬជនប្រព្រឹត្តិបទល្មើសផ្លូវភេទ*" (ឪពុកមួយរូប នៅទីក្រុងវៀងច័ន្ទ)។ ឪពុកម្តាយជាច្រើនបានលើកឡើងថា ពួកគេបានឃើញព័ត៌មានតាមកញ្ចក់ទូរទស្សន៍ថៃស្តីពីការជួញដូរកុមារីឡាវ ប៉ុន្តែចំណុចនេះ មិនបានធ្វើឲ្យឪពុកម្តាយទាំងនោះបញ្ឈប់កូនៗពីការដើរលក់វត្ថុអនុស្សាវរីយ៍តាមផ្លូវ ឬតាមហាង ឬហាមឃាត់កូនមិនឲ្យទាក់ទងជាមួយភ្ញៀវទេសចរឡើយ។

> *"យោងតាម កុមារាអាយុ ១៧ឆ្នាំ នៅទីក្រុងវៀងច័ន្ទ នៃប្រទេសឡាវ បានលើកឡើងថា ភាពក្រីក្រ អាចធ្វើឲ្យកុមារដែលមកពីគ្រួសារក្រីក្រ ត្រូវបង្ខំចិត្តរកការងារធ្វើ និង ព្រមធ្វើគ្រប់កិច្ចការដែលខ្លួនរកបាន"។*

បន្ថែមពីនេះ កន្លែងកំសាន្តផ្លូវភេទស្ទើរតែទាំងអស់ផ្តល់ឱកាសយ៉ាងច្រើនដល់កុមារក្នុងការរកប្រាក់ដោយធ្វើជាអ្នកបម្រើ អ្នកលក់ស្រាបៀរ អ្នកបម្រើតាមផ្ទះ ឬអ្នករកស៊ីផ្លូវភេទ ដែលប្រការនេះធ្វើឲ្យកុមារទាំងនោះត្រូវប្រឈមគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ និងទទួលបានការការពារតិចតួច។ យោងតាមកុមារាអាយុ ១៧ ឆ្នាំ នៅទីក្រុងវៀងច័ន្ទនៃប្រទេសឡាវបានលើកឡើងថា "*ភាពក្រីក្រអាចធ្វើឲ្យកុមារដែលមកពីគ្រួសារក្រីក្រត្រូវបង្ខំចិត្តរកការងារធ្វើ និងព្រមធ្វើគ្រប់កិច្ចការដែលខ្លួនរកបាន*"។ សិស្សស្រីកម្ពុជាអាយុ ១៧ ឆ្នាំ ម្នាក់បានរំលឹកថា បងប្អូនជីដូនមួយរបស់នាងដែលជាស្ត្រីរកស៊ីផ្លូវភេទ ទទួលរកការរំលោភបំពានយ៉ាងធ្ងន់ធ្ងរពីក្រុមបុរស ៖

> *បងប្អូនជីដូនមួយរបស់ខ្ញុំដែលមានអាយុ ២០ ឆ្នាំ និងជាអ្នករកស៊ីផ្លូវភេទក្នុងហាងខារ៉ាអូខេមួយក្នុង ខេត្តសៀមរាប ទទួលរងការវាយដំពីភ្ញៀវជនជាតិអាស៊ី ស្ទើរតែរៀងរាល់ថ្ងៃ បន្ទាប់ពីភ្ញៀវនោះបានរួមភេទជាមួយគាត់រួច។ ជាសំណាងល្អ ថ្ងៃមួយនៅពេលដែលប៉ូលិសឆ្មក់ចូលក្នុងហាងនោះ គាត់ក៏អាចរត់គេចខ្លួនបាន។ គាត់ស្ទើរតែដើរមិនរួច ដោយសារតែមានស្នាមជាំពេញខ្លួន។ ចំណែកប៉ូលីសបានដោះលែងភ្ញៀវទេសចរទាំងនោះ។ ប្រសិនបើប៉ូលីសចាប់បានស្រីៗដែលធ្វើការក្នុងហាងខារ៉ាអូខេនោះ ស្រីៗទាំងនោះ នឹងត្រូវឈឺចាប់កាន់តែខ្លាំង ហើយត្រូវបង់ប្រាក់ឲ្យប៉ូលីសដើម្បីបានរួចខ្លួន។*

ទាក់ទងនឹងការរំលោភបំពានផ្លូវភេទអ្នករកស៊ីផ្លូវភេទ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ក្នុងខេត្តសៀមរាបនៃប្រទេសកម្ពុជា បានចង្អុលបង្ហាញថា "មិនមាននរណាម្នាក់ព្រួយបារម្ភពីអ្នករកស៊ីផ្លូវភេទទាំងនោះឡើយ ហើយក៏គ្មាននរណាម្នាក់គិតថា នេះជាការរំលោភបំពានដែរ"។

អ្វីដែលគួរឲ្យព្រួយបារម្ភនោះគឺភ្ញៀវទេសចរដែលមកពីប្រទេសជិតខាងចំនួនពីរជាប់នឹងប្រទេសឡាវមានតម្រូវការផ្លូវភេទកុមារីដែលនៅព្រហ្មចារី[១២២]។ ឪពុកម្នាក់នៅទីក្រុងវៀងច័ន្ទបានរាយការណ៍ថា កុមារី ដែលមានអាយុចាប់ពី ១៤ ដល់ ១៦ ឆ្នាំ ធ្វើការក្នុងហាងលក់ស្រាបៀរ និងខារ៉ាអូខេ ព្រមទាំងបម្រើសេវាផ្លូវភេទ ដល់ភ្ញៀវទៀតផង។ ភ្ញៀវអាចស្នើសុំឲ្យកុមារីមួយចំនួន ជាពិសេស សិស្សសាលា ឬកុមារីដែលនៅព្រហ្មចារីបម្រើខ្លួន តាមរយៈមេការ ឬម៉ែយ៉ែមដែលមានតារាងឈ្មោះកុមារីទៅតាមចំណាត់ និងអាស្រ័យលើប្រភេទអតិថិជន។

ក្រៅពីឧស្សាហកម្មផ្លូវភេទ កុមារច្រើនធ្វើជាអ្នកលក់វត្ថុអនុស្សាវរីយ៍តាមផ្លូវ និងជាអ្នកប្រាប់ផ្លូវលក់របស់ឲ្យភ្ញៀវទេសចរ ដូចជាផ្កា សៀវភៅ វត្ថុអនុស្សាវរីយ៍ ចំណីអាហារ និងភេសជ្ជៈដល់ភ្ញៀវទេសចរ។ ការសិក្សាបានបង្ហាញថា ជនប្រព្រឹត្តិបទល្មើសដែលឆ្លៀតឱកាស ច្រើនរកបានជនរងគ្រោះនៅកន្លែងសាធារណៈ។ ទំនាក់ទំនងដ៏ជិតស្និទ្ធនេះ បានផ្តល់ឲ្យជនប្រព្រឹត្តិបទល្មើសផ្លូវភេទនូវមធ្យោបាយមួយដែលមានឥទ្ធិពល និងអាចលួងលោមកុមារដោយផ្ទាល់ និងមិនបាច់ឆ្លងកាត់មនុស្សពេញវ័យ

[១២២] Child Frontier (ឆ្នាំ២០១១) របាយការណ៍ពង្រាងស្តីពីការជួញដូរផ្លូវភេទកុមារនៅឡាវ។

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ក្នុងខេត្តសៀមរាបនៃប្រទេសកម្ពុជា បានចង្អុលបង្ហាញថា *"មិនមាននរណាម្នាក់ព្រួយបារម្ភពីអ្នករកស៊ីផ្លូវភេទទាំងនោះឡើយ ហើយក៏គ្មាននរណាម្នាក់គិតថា នេះជា ការរំលោភបំពានដែរ"។*

ដូចជា ឪពុកម្តាយ ឬគ្រូបង្រៀនឡើយ។ ហេតុដូច្នេះ កាលណាកុមារកាន់តែនៅក្បែរភ្ញៀវទេសចរ កុមារនឹងត្រូវរងគ្រោះពីការជួញដូរកាន់តែខ្លាំង។

ក្រុមស្រាវជ្រាវបានអង្កេតឃើញថា កុមារដែលលក់វត្ថុអនុស្សាវរីយ៍ក្នុងខេត្តសៀមរាបនៃប្រទេស កម្ពុជា ច្រើនទៅជិតភ្ញៀវទេសចរ និងមានអាកប្បកិរិយារួសរាយរាក់ទាក់ដាក់ភ្ញៀវទាំងនោះ ដែលតែងតែជំរុញឲ្យភ្ញៀវទេសចរថតរូបពួកគេដោយនិយាយជាច្រើនភាសា។ កុមារីលក់វត្ថុអនុស្សាវរីយ៍ម្នាក់បាននិយាយថា៖

> *"ភ្ញៀវទេសចរ ជាមនុស្សល្អ ហើយខ្ញុំចូលចិត្តភ្ញៀវទាំងនោះណាស់ ដោយសារតែពួកគាត់ចិត្តល្អ និងផ្តល់ប្រាក់បន្ថែមដល់ខ្ញុំ បន្ទាប់ពីពួកគាត់បានជួយទិញវត្ថុអនុស្សាវរីយ៍របស់ខ្ញុំ"។*

នៅពេលដែលសួរថា តើកុមារទាំងនោះព្រួយបារម្ភពីការរំលោភបំពានដែរ ឬទេ កុមារភាគច្រើនបានឆ្លើយថា ពួកគេមិនព្រួយបារម្ភឡើយ។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ដែលធ្វើការលើបញ្ហាការពារកុមារក្នុងខេត្តសៀមរាបអស់រយៈពេលជាង ១០ ឆ្នាំ ហើយនោះ បានបញ្ជាក់ថា ភ្ញៀវទេសចរមួយចំនួនតែងជួញដូរ ផ្លូវភេទដោយអាកប្បកិរិយារួសរាយរាក់ទាក់ចំពោះកុមារទាំងនោះ។ គាត់បាននឹកឃើញករណីមួយដែលជនបរទេសម្នាក់នៅក្រុងសៀមរាបបានធ្វើឲ្យកុមារីអាយុ១៥ ឆ្នាំម្នាក់ដែលលក់វត្ថុអនុស្សាវរីយ៍ជឿជាក់លើខ្លួន ដោយធ្វើជាជួយទិញវត្ថុអនុស្សាវរីយ៍ និងឲ្យលុយទឹកតែនាងថែមទៀត។ ជនបរទេសនោះ ក៏បានសុំឲ្យនាងយកវត្ថុអនុស្សាវរីយ៍ជាច្រើនទៅបន្ទប់សណ្ឋាគារដែលគាត់ស្នាក់នៅ ប៉ុន្តែនៅពេលកុមារីនោះទៅដល់គាត់ក៏បានចាប់រំលោភនាង[១២៣]។.

[១២៣] រឿងរ៉ាវនេះ គឺជារឿងមួយក្នុងចំណោមករណីសិក្សាទាំងប្រាំក្នុង Ung. C (ឆ្នាំ២០០៤) អន្ទាក់ផ្លូវភេទ មជ្ឈមណ្ឌលកម្ពុជាជួយស្ត្រីមានវិបត្តិ ទីក្រុងភ្នំពេញ។

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ក្នុងខេត្តមណ្ឌលគិរីនៃប្រទេសកម្ពុជា បានលើកឡើងថា *"ខ្ញុំទទួលបានព័ត៌មានថា កុមារីអាយុ ១០ ឆ្នាំ ត្រូវបានស្នើសុំឲ្យជូនភ្ញៀវទេសចរ/ជនបរទេស ចូលទៅលេងក្នុងព្រៃ ហើយជាធម្មតា កុមារីទាំងនេះ ត្រូវស្នាក់នៅជាមួយភ្ញៀវចាប់ពី ៣ ទៅ ៤ ថ្ងៃ។ ខ្ញុំពិតជាមានការព្រួយបារម្ភពីសុវត្ថិភាពនៅពេលដែលកុមារីទាំងនោះនៅជាមួយជនបរទេស/ភ្ញៀវទេសចរទាំងនោះណាស់។ មិនមាន នរណាម្នាក់ដឹងពីអ្វីដែលបានកើតឡើងនៅកណ្តាលព្រៃឡើយ ដោយសារតែនៅទីនោះស្ងាត់ ហើយឆ្ងាយពីមនុស្សផ្សេងទៀត ហើយក៏អាចកើតមានការរំលោភបំពានផ្លូវភេទកុមារនៅទីនោះផងដែរ ប៉ុន្តែមិនមាននរណាម្នាក់រាយការណ៍ពីករណីទាំងនេះ ឬដាក់ពាក្យបណ្តឹងនោះឡើយ។ ពួកគេត្រូវការប្រាក់ជាសំខាន់"។*

នៅខេត្តមណ្ឌលគិរី ប្រទេសកម្ពុជា មានការរាយការណ៍មកថា កុមារអាយុ ១០ ឆ្នាំ ធ្វើជាអ្នកនាំភ្ញៀវទេសចរ ដោយធ្វើដំណើរជាមួយភ្ញៀវទេសចរទៅក្នុងព្រៃយ៉ាងជ្រៅអស់រយៈពេលជាច្រើនថ្ងៃ ដោយមិនទទួលបានការមើលថែពីមនុស្សពេញវ័យឡើយ។ អ្នកមានកាតព្វកិច្ចក្នុងមូលដ្ឋានជាច្រើន បានបង្ហាញពីការព្រួយបារម្ភលើគ្រោះថ្នាក់នៃការរំលោភបំពានកុមារ។

> *បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ក្នុងខេត្តមណ្ឌលគិរី ប្រទេសកម្ពុជា បានលើកឡើងថា "ខ្ញុំទទួលបានព័ត៌មានថា កុមារីអាយុ ១០ ឆ្នាំ ត្រូវបានស្នើសុំឲ្យជូនភ្ញៀវទេសចរ/ជនបរទេសចូលទៅលេងក្នុងព្រៃ ហើយជាធម្មតា កុមារីទាំងនេះ ត្រូវស្នាក់នៅជាមួយភ្ញៀវចាប់ពី ៣ ទៅ ៤ ថ្ងៃ។ ខ្ញុំពិតជាមានការព្រួយបារម្ភពីសុវត្ថិភាពនៅពេលដែលកុមារីទាំងនោះនៅជាមួយជនបរទេស/ភ្ញៀវទេសចរទាំងនោះណាស់។ មិនមានរណាម្នាក់ដឹងពីអ្វីដែលបានកើតឡើងនៅកណ្តាល*

*ព្រៃ ដោយសារតែនៅទីនោះស្ងាត់ និងឆ្ងាយពីមនុស្សផ្សេងទៀត ហើយក៏អាចកើតមានការរំលោភបំពានផ្លូវភេទកុមារនៅទីនោះផងដែរ ប៉ុន្តែមិនមាននរណាម្នាក់រាយការណ៍ពីករណីទាំងនេះ ឬដាក់ពាក្យបណ្តឹងនោះឡើយ។ ពួកគេត្រូវការប្រាក់ជាសំខាន់។ "*

របាយការណ៍ស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយបង្ហាញថា អ្នកបើករថយន្តតាក់ស៊ី និងអ្នករត់ម៉ូតូឌុប គឺជាអ្នកសម្របសម្រួល រវាងជនប្រព្រឹត្តិបទល្មើស និងកុមាររងគ្រោះ[១២៤]។ ករណីបែបនេះកើតមានកាន់តែច្រើន ដោយសារយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងកិច្ចខិតខំប្រឹងប្រែងការពារ បានធ្វើឲ្យជនប្រព្រឹត្តិបទល្មើសផ្លូវភេទកាន់តែមានការប្រុងប្រយ័ត្ន និងត្រូវបង្ខំចិត្តប្រើប្រាស់វិធីសាស្ត្រថ្មីៗ។ អ្នកបើករថយន្តតាក់ស៊ី និងអ្នករត់ម៉ូតូឌុបមិនត្រឹមតែយកជនប្រព្រឹត្តិបទល្មើសផ្លូវភេទទៅផ្ទះបនស្រី ឬកន្លែងផ្សេងទៀតដែលអាចជួបជាមួយកុមារប៉ុណ្ណោះទេ ប៉ុន្តែក៏បាននាំយកកុមារទៅផ្ទះបនស្រ្តីដូចជាអ្នកទិញដូរកុមារផងដែរ ក្នុងករណីដែលភ្ញៀវទេសចរស្នើឲ្យជួយរកឲ្យ[១២៥]។ អ្នករត់ម៉ូឌុបមួយចំនួនទទួលបានកម្រៃជើងសារពី ការសម្របសម្រួលកិច្ចការនេះ។ ការស្រាវជ្រាវពីឧស្សាហកម្មផ្លូវភេទនៅប្រទេសកម្ពុជាក៏បានបង្ហាញពីទិន្នន័យនេះផងដែរ ដោយអ្នកបើករថយន្តតាក់ស៊ី និងអ្នករត់ម៉ូតូឌុប បានបង្ហាញថា ខ្លួនស្គាល់កន្លែងលក់ផ្លូវភេទក្នុងតំបន់គោលដៅមួយចំនួន[១២៦]។ បន្ថែមពីនេះ បុគ្គលិកក្នុងសណ្ឋាគារ និងផ្ទះសំណាក់ គឺជាអ្នកសម្របសម្រួលផ្ទាល់ក្នុងការយកកុមារឲ្យទៅគេងជាមួយភ្ញៀវទេសចរ ហើយអ្នកទាំងនោះក៏ផ្តល់លទ្ធភាពឲ្យមានការជួញដូរកុមារមិនផ្ទាល់ដោយ "ធ្វើមិនដឹងមិនលឺ" ចំពោះអ្វីដែលកើតមាននៅចំពោះមុខ ដោយសារតែពួកគេខ្លាចបាត់បង់ភ្ញៀវ[១២៧]។ អ្នកមានកាតព្វកិច្ចមួយចំនួនបានរាយការណ៍មកថា ភ្ញៀវទេសចរមួយចំនួន គឺជាអ្នកសម្របសម្រួល រវាងជនប្រព្រឹត្តិបទល្មើសផ្លូវភេទ និងជនរងគ្រោះ។

របាយការណ៍ស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយបានបញ្ជាក់ពីបរិយាកាសអំណោយផលរបស់ វិស័យទេសចរណ៍។ នៅពេលដែលមានឧស្សាហកម្មផ្លូវភេទ មនុស្សពេញវ័យសម្រាប់ភ្ញៀវទេសចរ ជាទូទៅ សណ្ឋាគារ និងផ្ទះសំណាក់ ផ្តល់លទ្ធភាពឲ្យភ្ញៀវទេសចរនាំស្ត្រីរកស៊ីផ្លូវភេទនោះមកជាមួយ ដោយគ្រាន់តែបង់ប្រាក់បន្ថែម។ ភស្តុតាងបន្ថែមទៀតក៏បានបង្ហាញថា ភាគីទីបី ឬអ្នកជួញដូរ មានការយល់ដឹងដោយសារតែយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងគ្រោះថ្នាក់ដ៏ខ្ពស់នៃការប្តឹង ចោទប្រកាន់[១២៨]។

---

[១២៤] គម្រោងការពារកុមារ Johns Hopkins University (ឆ្នាំ២០០៧) ទេសចរណ៍ផ្លូវភេទកុមារអន្តរជាតិ ៖ វិសាលភាពនៃបញ្ហា និងករណីសិក្សាបែបប្រៀបធៀប។ លទ្ធផលសិក្សាទាំងនេះគឺផ្អែកតាមការស្រាវជ្រាវតាមមូលដ្ឋានក្នុងទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តសៀមរាប។

[១២៥] Niron, N, Viriya, Y, Gray, L (ឆ្នាំ២០០១) ការងាររបស់កុមារ ការប្រឡូករបស់មនុស្សពេញវ័យ ៖ ទេសចរណ៍ផ្លូវភេទកុមារ-បញ្ហាក្នុងប្រទេសកម្ពុជា ៖ អង្គការ World Vision។

[១២៦] Steinfatt, T. (ឆ្នាំ២០០៥) ការប៉ាន់ប្រមាណចំនួនស្ត្រី និងកុមារដែលត្រូវបានជួញដូរនៅកម្ពុជា ៖ ការសិក្សាតាមមូលដ្ឋានដោយធ្វើការអង្កេតដោយផ្ទាល់ ៖ USAID។

[១២៧] គម្រោងការពារកុមារ Johns Hopkins University (ឆ្នាំ២០០៧) ទេសចរណ៍ផ្លូវភេទកុមារអន្តរជាតិ ៖ វិសាលភាពបញ្ហា និងករណីសិក្សាបែបប្រៀបធៀប។

[១២៨] អង្គការ Save The Children (ខែកុម្ភៈ ឆ្នាំ២០០៩) ជនប្រព្រឹត្តិបទល្មើសផ្លូវភេទនៅគ្រប់ទីកន្លែង ៖ ការស៊ើបអង្កេតពីការរំលោភបំពានផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍ នៅប្រទេសថៃ កម្ពុជា និងភូមា។

---

**បុរសអ្នកស្ម័គ្រចិត្ត បម្រើខ្សែទូរស័ព្ទរាយការណ៍ទាន់ហេតុការណ៍ ក្នុងប្រទេសឡាវបានលើកឡើងថា** *"កុមារ ឬប្រជាជនមកពីខេត្ត ត្រូវប្រឈមនឹងគ្រោះថ្នាក់ខ្ពស់បំផុតនៃការរំលោភបំពាន ដោយសារតែពួកគេមិនធ្លាប់រស់នៅក្នុងទីក្រុង និងមិនទទួលបានព័ត៌មាននោះឡើយ "*។

## ការធ្វើចំណាកស្រុក

បណ្តុំឧស្សាហកម្មទេសចរណ៍បានទាក់ទាញជនចំណាកស្រុកទាំងក្នុងប្រទេស និងក្រៅប្រទេស ដោយសារតែឱកាសដ៏ច្រើនក្នុងការរកប្រាក់ចំណូល។ ការផ្លាស់ប្តូរទីលំនៅគឺជាមូលហេតុមួយផ្សេងទៀតនៃការធ្វើចំណាកស្រុកទៅកាន់រមណីយដ្ឋានទេសចរណ៍។ នៅសំណង់អនាធិបតេយ្យក្នុងទីក្រុងឈៀងម៉ៃ ភាគខាងជើងនៃប្រទេសថៃ មានក្រុមជាតិពន្ធុជាច្រើនបានធ្វើចំណាកស្រុកពីកន្លែងកំណើតរបស់ខ្លួនមករស់នៅទីកន្លែងនោះ។ នៅខេត្តមណ្ឌលគិរីនៃប្រទេសកម្ពុជា មានគ្រួសារខ្មែរ និងជាតិពន្ធុជាច្រើនរស់នៅជាប់ៗគ្នា ចំណែកជនចំណាកស្រុកដែលមកពីខេត្តក្រៅក្នុងប្រទេសវៀតណាមបានមកស្វែងរកការងារធ្វើនៅទីក្រុងហៃហ្វុង។ កុមារដែលរស់នៅក្នុងគ្រួសារចំណាកស្រុកទាំងនេះ មានឱកាសតិចតួចក្នុងការបញ្ចប់ការសិក្សារបស់ខ្លួន ហើយតែងតែមានការបង្ខិតបង្ខំឲ្យកុមារទាំងនោះធ្វើការតាមផ្លូវ[១២៩]។

កត្តាដែលជំរុញឲ្យមានភាពរងគ្រោះផ្សេងទៀត នៃការធ្វើចំណាកស្រុកគឺការបាត់បង់បណ្តាញការងារសង្គម និង សហគមន៍ដែលការពារសមាជិករបស់ខ្លួន។ ដើម្បីបង្កើតបណ្តាញការងារសង្គមនៅកន្លែងថ្មីមួយ ត្រូវចំណាយពេលយូរ ដោយធ្វើឲ្យគ្រួសារ និងកូនៗងាយរងគ្រោះខ្លាំង ទៅនឹងការរំលោភបំពាន និងការជួញដូរ ជាពិសេសនៅតាមកន្លែងដែលគ្រួសារចំណាកស្រុកកំពុងរស់នៅ និងធ្វើការក្នុងលក្ខខណ្ឌស្តង់ដាទាប និងខុសច្បាប់ ជាពិសេស កុមារអាចរងផលប៉ះពាល់យ៉ាងខ្លាំងដោយ

---

[១២៩] អង្គការ UNICEF-EAPRO (ឆ្នាំ២០១២) ការរំលោភបំពានកុមារ ៖ ប្រេវ៉ាឡង់ ឧប្បត្តិហេតុ និង ផលវិបាកនៃការរំលោភបំពានកុមារក្នុងតំបន់អាស៊ីប៉ូស៊ីហ្វិក ៖ ការពិនិត្យឡើងវិញលើការស្រាវជ្រាវជាប្រព័ន្ធ។

*អ្នកមានកាតព្វកិច្ចម្នាក់ នៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ បានលើកឡើងថា "ក្នុងអំឡុងពេលវិសម្បកាលប្រចាំឆ្នាំដ៏យូរ ចាប់ពីខែមេសា ដល់ខែឧសភា សិស្សស្រីគ្រប់អាយុ បានទៅទីក្រុងផាត់តាយ៉ាដើម្បីលក់ខ្លួន...ពួកគេទៅរកការងារធ្វើ និងសន្សំប្រាក់សម្រាប់ឆមាសបន្ទាប់។ នៅពេលបញ្ចប់វិសម្បកាលរដូវក្តៅ សិស្សទាំងនោះបានត្រឡប់មករៀនវិញដោយមានប្រាក់ចាយយ៉ាងច្រើន"។*

សារ ខ្វះខាតក្របខណ្ឌគាំទ្រសម្រាប់គ្រួសារ មិត្តភក្តិ និងសាច់ញាតិ។ ករណីមួយចំនួនផ្សេងទៀត កុមារ មិនមានលទ្ធភាពចូលរៀន និងមិនអាចចូលរួមក្នុងបណ្តាញការងារដែលផ្តល់ផល ដល់ការអភិវឌ្ឍរបស់កុមារទាំងនោះឡើយ។ ក្រៅពីនេះ អ្នកមកតាំងទីលំនៅថ្មី មិនបានដឹងពីគ្រោះថ្នាក់ដែលកើតមាននៅកន្លែងនោះ ដូចអ្នកធ្លាប់រស់នៅ ទីនោះនោះឡើយ។ ឧទាហរណ៍ អ្នកផ្តល់ព័ត៌មានជនជាតិឡាវជាច្រើន បានលើកឡើងថា ***"កុមារដែលធ្វើចំណាកស្រុកពីខេត្តទៅរស់នៅទីក្រុង ដើម្បីស្វែងរកការងារធ្វើ ឬ បន្តសិក្សា គឺងាយរងគ្រោះខ្លាំងទៅនឹងការរំលោភបំពាន"***។ យោងតាមបុរសអ្នកស្ម័គ្រចិត្តបម្រើខ្សែទូរស័ព្ទពិសេស"កុមារ ឬ ប្រជាជនមកពីខេត្ត ត្រូវប្រឈមនឹងគ្រោះថ្នាក់ខ្ពស់បំផុត នៃការរំលោភបំពានដោយសារតែពួកគេមិនធ្លាប់រស់នៅក្នុងទីក្រុង និងមិនទទួលបានព័ត៌មាន។ កុមារីអាយុ ១៨ ឆ្នាំ ម្នាក់រស់នៅទីក្រុងវៀងច័ន្ទ បានលើកឡើងថា ***"ឧបសគ្គផ្នែកភាសាក៏ជាបញ្ហាផងដែរ ៖ "ក្មេងៗនៅតំបន់ជនបទត្រូវប្រឈមនឹងគ្រោះថ្នាក់ដោយសារតែពួកគេមិនបានដឹងច្រើនពីបញ្ហាដែលកំពុងកើតមានក្រៅ ភូមិរបស់ខ្លួនឡើយ ហើយក៏មានការប្រើប្រាស់ភាសា ខុសៗគ្នាផងដែរ។ ក្មេងៗនៅជនបទមិនចេះនិយាយ និងមិនអាចការពារខ្លួនបានឡើយ"***។

ការមិនផ្តល់តម្លៃដល់ជនចំណាកស្រុកខុសច្បាប់តែងតែជំរុញឲ្យពួកគេធ្វើការក្រៅប្រព័ន្ធ ការងារដែលមិនត្រូវការជំនាញ ឬសកម្មភាពរកប្រាក់ចំណូលប្រកបដោយគ្រោះថ្នាក់ ហើយគ្រោះថ្នាក់  ទៅនឹងការជួញដូរផ្លូវភេទក៏មានខ្ពស់ផងដែរ ដូចមានករណីសិក្សាក្នុងទីក្រុងហៃហ្វុង បានបង្ហាញថា៖

### ករណីសិក្សា

**កុមារីអាយុ ១៧ឆ្នាំ បានរៀបរាប់ប្រាប់ថា នាងត្រូវបានបុរសម្នាក់ចាប់រំលោភសេពសន្ថវៈ នៅតំបន់ក្បែរខាង (ក្នុងខេត្តផ្សេង) នៅពេលនាងមានអាយុ ១៥ ឆ្នាំ។ ពេលនាងអាយុបាន ១៦ ឆ្នាំ នាងក៏បានទៅធ្វើការនៅផ្ទះបនស្រីក្នុងទីក្រុងហៃហ្វុងនៃប្រទេសវៀតណាម និងធ្វើជាអ្នកបម្រើក្នុងសណ្ឋាគារមួយ។ យ៉ាងណាក៏ដោយ ម្ចាស់សណ្ឋាគារនោះ មិនសូវមានកុមារីៗបម្រើភ្ញៀវនោះឡើយ ពេលនោះ ម្ចាស់សណ្ឋាគារនោះក៏បានសុំឲ្យនាងជួយបម្រើសេវាផ្លូវភេទដល់ភ្ញៀវ។**

កុមារីអាយុ ១៧ ឆ្នាំ បានរៀបរាប់ប្រាប់ថា នាងត្រូវបានបុរសម្នាក់ចាប់រំលោភសេពសន្ថវៈ នៅតំបន់ក្បែរខាង (ក្នុងខេត្តផ្សេង) នៅពេលនាងមានអាយុ ១៥ ឆ្នាំ។ ពេលនាងអាយុបាន ១៦ ឆ្នាំ នាងក៏បានទៅធ្វើការនៅផ្ទះបនស្រីក្នុងទីក្រុងហៃហ្វុងនៃប្រទេសវៀតណាម និងធ្វើជាអ្នកបម្រើក្នុងសណ្ឋាគារមួយ។ យ៉ាងណាក៏ដោយ ម្ចាស់សណ្ឋាគារនោះ មិនសូវមានកុមារីៗបម្រើភ្ញៀវនោះឡើយ ពេលនោះ ម្ចាស់សណ្ឋាគារ នោះក៏បានសុំឲ្យនាងជួយបម្រើសេវាផ្លូវភេទដល់ភ្ញៀវ។

> *"ក្នុងអំឡុងពេលវិសម្បកាលប្រចាំឆ្នាំដ៏យូរចាប់ពីខែមេសា ដល់ខែឧសភា សិស្សស្រីគ្រប់អាយុ បានទៅទីក្រុងផាត់តាយ៉ាដើម្បីលក់ខ្លួន...ពួកគេទៅរកការងារធ្វើ និងសន្សំប្រាក់សម្រាប់ឆមាសបន្ទាប់។ នៅពេលបញ្ចប់វិសម្បកាលរដូវក្តៅ សិស្សទាំងនោះបានត្រឡប់មករៀនវិញដោយមានប្រាក់ចាយយ៉ាងច្រើន។ "*

ក្រុមស្រាវជ្រាវនៅប្រទេសវៀតណាមបានសម្ភាសជនចំណាកស្រុកជាកុមារជាច្រើនដែលមកពីខេត្តនានាៗជាប់ទីក្រុងហៃហ្វុង ដើម្បីលក់ដូរម្ហូបអាហារ និងវត្ថុអនុស្សាវរីយ៍ដល់ភ្ញៀវទេសចរ។ បើប្រៀបធៀបជាមួយ

អ្នកលក់វត្ថុអនុស្សាវរីយ៍តាមរដូវកាលដែលមកពីវៀតណាមកណ្ដាល ទៅកាន់តំបន់នៅទីក្រុងហូជីមិញ ដើម្បីលក់វត្ថុអនុស្សាវរីយ៍ក្នុងរដូវក្ដៅ កុមារដែលជាអ្នកលក់វត្ថុអនុស្សាវរីយ៍ពេញម៉ោងចំនួន ៧នាក់ នៅតំបន់ទេសចរណ៍ក្នុងទីក្រុងហៃហ្វុង ប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានទាំងក្នុង និងក្រៅគ្រួសារ។ កុមារមួយចំនួនមានឪពុកម្ដាយជាជនញៀនថ្នាំ ជាអតីអ្នករកស៊ីផ្លូវភេទ ឬជាអ្នកផ្ទុកមេរោគអេដស៍។ កុមារមួយចំនួនបានរាយការណ៍ថា មានជនចម្លែកបានមករកពួកគេដើម្បីឲ្យពួកគេលក់គ្រឿងញៀន ឬធ្វើជាអ្នកបម្រើ។

ក្រៅពីក្លាយជាជនរងគ្រោះនៃការរំលោភបំពាន ក៏មានការកត់សម្គាល់ពីកម្រិតនៃការសង្ស័យ និងការព្រួយបារម្ភទាក់ទងនឹងជនចំណាកស្រុក (មនុស្សពេញវ័យ) ដែលជាជនប្រព្រឹត្តិបទល្មើសក្នុង អំឡុងពេលស្រាវជ្រាវផងដែរ។ មានការយល់ឃើញថា កម្មករចំណាកស្រុកមានបណ្ដាញតិចតួចជាមួយសហគមន៍មូលដ្ឋាន និងមិនបានព្រួយបារម្ភពីស្ថានភាពសង្គម ឬ “ការអាម៉ាសមុខ” នៅពេលចាប់បានបន្ទាប់ពីប្រព្រឹត្តិបទល្មើសនោះឡើយ។ អ្នកមានកាតព្វកិច្ចម្នាក់នៅខេត្តមណ្ឌលគិរីនៃប្រទេសកម្ពុជា បានរៀបរាប់ថា មានករណីរំលោភសេពសន្ថវៈកុមារជាច្រើនក្នុងភូមិជិតនោះ ដោយសារតែមានជនចំណាកស្រុកជាច្រើនមកធ្វើការក្នុងកសិដ្ឋាន និងចំការកៅស៊ូ។ សិស្សប្រុសអាយុ ១៧ ឆ្នាំម្នាក់នៅខេត្តមណ្ឌលគិរីបានបង្ហាញពីបញ្ហាកង្វល់ថា ជនចំណាកស្រុកដែលមកពីខេត្តផ្សេងទៀតមាននិន្នាការរំលោភសេពសន្ថវៈកុមារក្នុងមូលដ្ឋាន ហើយបន្ទាប់មកនឹងរត់គេចខ្លួន ដោយសារតែអ្នកទាំងនោះមិនបានចុះបញ្ជីស្នាក់នៅជាមួយអាជ្ញាធរមូលដ្ឋានឡើយ។.

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ក្នុងខេត្តសៀមរាប នៃប្រទេសកម្ពុជា បានលើកឡើងថា *"ដោយសារតែមិនមានអាជ្ញាធរមានសមត្ថកិច្ច ហើយកន្លែងទាំងនោះជាកន្លែងស្ងាត់ទៀតនោះ មានករណីរំលោភបំពានផ្លូវភេទជាច្រើនក្នុងតំបន់ជនបទ។ យ៉ាងណាក៏ដោយ យើងមិនបានដឹងពីវិសាលភាពនៃបញ្ហានោះឡើយ ដោយសារតែយើងមិនមានធនធានគ្រប់គ្រាន់សម្រាប់ប្រមូលទិន្នន័យទាំងនេះ"*។

## បរិយាកាសមូលដ្ឋាន និងតំបន់កៀ្បរខាង

បរិកាសមូលដ្ឋានអាចបង្កគ្រោះថ្នាក់ដល់កុមារ ដូចជា នៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ មានការអង្កេតឃើញថា កុមារមិនអាចជៀសផុតពីកន្លែងបម្រើសេវាកំសាន្តផ្លូវភេទបានឡើយ។ ឧស្សាហកម្មផ្លូវភេទបានកើតឡើងទន្ទឹមនឹងការមានសាលា វត្តអារាម និងសហគមន៍។ មានសូចនាករបង្ហាញយ៉ាងច្បាស់ថា កុមារងាយប្រឈមនឹងការលួងលោមឲ្យប្រឡូកក្នុងសកម្មភាពផ្លូវភេទពីជនបរទេស ដោយសារជនបរទេសទាំងនោះបានផ្ដល់ប្រាក់ជាច្រើនដល់កុមារ។ កុមារាអាយុ ១៣ឆ្នាំ បានរំលឹកថា ៖

> *" ជនបរទេសម្នាក់ដែលកំពុងអង្គុយញ៉ាំអាហារក្នុងភោជនីយដ្ឋានមួយបានហៅខ្ញុំ ដោយឲ្យប្រាក់ខ្ញុំចំនួន ៣០០ បាត។ ពីដំបូង ខ្ញុំមិនហ៊ានទៅជួបគាត់ទេ ប៉ុន្តែដោយសារតែខ្ញុំចង់បានប្រាក់ដើម្បីដើរលេងជាមួយមិត្តភក្តិ ទើបខ្ញុំសម្រេចចិត្តទៅជួបគាត់។ យើងបានដើរជាមួយគ្នា ហើយខ្ញុំក៏បានឆក់លុយពីដៃរបស់គាត់ និងបានរត់បាត់។"*

នៅខេត្តមណ្ឌលគិរីនៃប្រទេសកម្ពុជា សិស្សសាលាដោយមួយចំនួនដែលទើបតែរៀនថ្នាក់ទី ៧ បានទៅច្រៀងខារ៉ាអូខ នៅក្នុងទីក្រុង ដោយសារតែពួកគេចង់ឃើញថាមានអ្វីកើតឡើងនៅទីនោះ។ ការស្រាវជ្រាវក៏បានកំណត់រកកន្លែងផ្សេងទៀតដែលមានជាប់ពាក់ព័ន្ធនឹងកត្តា ដែលអាចរួមចំណែកធ្វើឲ្យកុមារងាយរងគ្រោះផងដែរ ដូចជា ការធ្វើដំណើរតែម្នាក់ឯងតាមផ្លូវទៅផ្ទះ ឬកុមារដែលដើរលេងតែម្នាក់ឯងនៅកន្លែងដាច់ស្រយាលដោយមិនមានមើលថៃ (ដូចជា ងូតទឹកតែម្នាក់ឯងក្នុងទន្លេ ចូលទៅលេងក្នុងព្រៃ ឬទៅដងទឹកតែម្នាក់ឯង)។

កន្លែងដែលនៅដាច់តែឯងក៏អាចបង្កការវិបាកដល់ការអន្តរាគមន៍ផងដែរ ហេតុដូច្នេះ រឹតតែបង្កើនគ្រោះ

ថ្នាក់ដល់កុមារទៅនឹងការរំលោភបំពានដែលបង្កឡើងដោយជនប្រព្រឹត្តិបទល្មើសផ្លូវភេទ។ ឧ. មានការរាយការណ៍ពីការរំលោភបំពានផ្លូវភេទក្នុងតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ដោយលើកឡើងថា មន្ត្រីនគរបាលស្ទាក់ស្ទើរមិនហ៊ានទៅ ឬមានភាពយឺតយ៉ាវដោយសារតែផ្លូវធ្វើដំណើរពិបាក និងឆ្ងាយ។ សិស្សសាលាក្នុងខេត្តសៀមរាប បានស្នើឡើងថា អន្តរាគមន៍ការពារមិនគួរមានតែនៅទីក្រុងប៉ុណ្ណោះទេ ប៉ុន្តែគួរតែមាននៅតាមតំបន់ជនបទដាច់ស្រយាលផងដែរ។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់នៅក្នុងខេត្តសៀមរាប បានលើកឡើងថា *"ប៉ូលិសមិនបានទៅកន្លែងទាំងនោះឡើយ"*។

> *"ដោយសារតែមិនមានអាជ្ញាធរមានសមត្ថកិច្ច ហើយកន្លែងទាំងនោះជាកន្លែងស្ងាត់ទៀតនោះ មានករណីរំលោភបំពានផ្លូវភេទជាច្រើនក្នុងតំបន់ជនបទ។ យ៉ាងណាក៏ដោយ យើងមិនបានដឹងពីវិសាលភាពនៃបញ្ហានោះឡើយ ដោយសារតែយើងមិនមានធនធានគ្រប់គ្រាន់សម្រាប់ប្រមូលទិន្នន័យទាំងនេះ។"*



នៅខេត្តមណ្ឌលគិរី បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក៏បានសង្កេតឃើញថា តំបន់នៅឆ្ងាយ និងដាច់ស្រយាលដែលមានជនជាតិដើមភាគតិចរស់នៅ គឺជាគោលដៅរបស់ជនប្រព្រឹត្តិ បទល្មើសផ្លូវភេទកុមារ។ គាត់បានរៀបរាប់ថា *"មិនមានផ្លូវចូលទៅក្នុងភូមិ ហើយឪពុកម្តាយមួយមានការយល់ដឹងតិចតួចពីរបៀបការពារកូនរបស់ខ្លួន។ ហេតុផលទាំងនេះបានធ្វើឲ្យកុមារមួយចំនួនទទួលរងការរំលោភសេពសន្ថវៈ"*។ នេះគឺជាការព្រួយបារម្ភមួយក្នុងការស្រាវជ្រាវថ្មីៗនេះ ដោយបង្ហាញថា ជនប្រព្រឹត្តិបទល្មើស ផ្លូវភេទបានធ្វើដំណើរពីទីក្រុងទៅតំបន់ដាច់ស្រយាល ដែលមានការយល់ដឹងតិចតួចពីការរំលោភបំពាន ផ្លូវភេទ និងការកេងប្រវ័ញ្ច ហើយអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមានភាពស្ទាក់ស្ទើរ ឬមិនអាចទៅកាន់កន្លែងទាំងនោះឡើយ[១៣០]។

## ពិការភាព

ការស្រាវជ្រាវអន្តរជាតិបានលើកឡើងថា ជនពិការគឺងាយរងគ្រោះខ្លាំងទៅនឹងក ាររំលោភបំពានផ្លូវភេទ ដោយសារការរើសរើងពីសង្គម និងការរើសអើងជារចនាសម្ព័ន្ធចំពោះជនពិការដែលបានចាក់ ឫសយ៉ាងជ្រៅ[១៣១]។ យ៉ាងណាក៏ដោយ នេះមិនមែនជាការយល់ដឹងរបស់អ្នកសិក្សាមួយចំនួនឡើយ។ អ្នកផ្តល់បទសម្ភាសនៅកម្ពុជា បានអះអាងថាធ្លាប់បានឃើញ និងលឺថា អង្គការមិនមែនរដ្ឋាភិបាលបានជួយសង្គ្រោះកុមារពិការទាំងនោះ និងផ្តល់ទីជម្រក ហេតុដូច្នេះ កុមារពិការទាំងនោះហាក់មានសំណាងជាងកុមារដែលមិនពិការផ្សេងទៀត។

វេជ្ជបណ្ឌិតម្នាក់នៃមជ្ឈមណ្ឌលកុមារពិការក្នុងទីក្រុងហូជីមិញនៃប្រទេសវៀតណាម បានពន្យល់ថា ឪពុកម្តាយ កុមារពិការមិនសូវយកចិត្តទុកដាក់នឹងបញ្ហាផ្លូវភេទឡើយ ដោយសារតែពួកគាត់សន្និដ្ឋានថា កូនរបស់ពួកគាត់មិនមានសមត្ថភាពយល់ពីបញ្ហានេះ។ ដើម្បីការពារកុមារពីគ្រោះថ្នាក់ នៃការរំលោភបំពាន វេជ្ជបណ្ឌិតនោះ បានស្នើឲ្យមានការទំនាក់ទំនង និងផ្តល់ព័ត៌មាន ដល់ឪពុកម្តាយរបស់កុមារពិការ ពីផលប៉ះពាល់អវិជ្ជមាន នៃការប្រឡូកនឹងសកម្មភាពផ្លូវភេទ។ អ្នកផ្តល់បទសម្ភាសមិនបានទទួលស្គាល់រាល់ការលំបាកដែលកុមារពិការបានជួបប្រទះឡើយ។

## កង្វះទំនុកចិត្តលើអាជ្ញាធរ និងអំពើពុករលួយ

អ្នកផ្តល់បទសម្ភាសតាមទីតាំងស្រាវជ្រាវជាច្រើន បានបង្ហាញពីកង្វះទំនុកចិត្តលើសមត្ថភាពរបស់ប៉ូលិសក្នុងការឆ្លើយតប និងដោះស្រាយបញ្ហារំលោភបំពានផ្លូវភេទកុមារ។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ក្នុងខេត្តសៀមរាប នៃប្រទេសកម្ពុជា បានរំលឹករឿងរ៉ាវដូចខាងក្រោម ៖

> *"កុមារីម្នាក់ដែលឪពុកម្តាយបានស្លាប់ចោល ត្រូវបានពូរបស់នាងយកទៅចិញ្ចឹម។ ពូ របស់នាងអាយុ ៧៧ ឆ្នាំ និងជាអាចារ្យមួយរូប[១៣២]។ ពូរបស់នាងបានចាប់រំលោភសេពសន្ថវៈនាងកាលពី ៤ ឆ្នាំមុន នៅពេលដែលនាងមានអាយុ ៦ ឆ្នាំ។ បច្ចុប្បន្ននេះ នាងរស់នៅក្នុងជម្រកមួយរបស់ អង្គការមិនមែនរដ្ឋាភិបាល។ ពូរបស់នាងបានទូរស័ព្ទមកនាងកាលពីរឆ្នាំកន្លងទៅ និងបានប្រាប់នាងថា គាត់ចង់រួមភេទជាមួយនាងម្តងទៀត។ នាយិកាអង្គការមិនមែនរដ្ឋាភិបាលនោះក៏បានថតសម្លេង សន្ទនានោះទុក ប៉ុន្តែមិនបានប្តឹងប៉ូលិសឡើយ ដោយសារគាត់មិនជឿជាក់ថា ប៉ូលិសនឹងដោះស្រាយរឿងក្តីនេះដោយយុត្តិធម៌ឡើយ"*។.

---

[១៣០] អង្គការ Action Pour Les Enfants (ខែកុម្ភៈ ឆ្នាំ២០១៤) ការស៊ើបអង្កេតជនប្រព្រឹត្តិបទល្មើសផ្លូវភេទ លើកុមារក្រោមរូបភាពជាភ្ញៀវទេសចរ ៖ ការវិភាគនិន្នាការ និងបញ្ហាប្រឈម នៃការរំលោភបំពានផ្លូវភេទកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា។ សូមមើលអង្គការ UNICEF ឆ្នាំ២០១១ ៖ ការវិភាគពីការជួញដូរផ្លូវភេទកុមារតាមបណ្តាខេត្ត និងទីក្រុង មួយចំនួនក្នុងប្រទេសវៀតណាម។

[១៣១] អង្គការ Handicap International/Save The Children (ឆ្នាំ២០១១) ចាកចេញពីស្បៃអន្តកាល ៖ អំពើហិង្សាផ្លូវភេទលើកុមារពិការ។

[១៣២] អាចារ្យគឺជាអ្នកដែលត្រូវបានគេអញ្ជើញឲ្យធ្វើជាប្រធានក្នុងពិធីបុណ្យក្នុងភូមិ។

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល បានបង្ហាញពីឧបសគ្គជាច្រើនក្នុងការជំរុញឲ្យប៉ូលិស ស៊ើបអង្កេតករណីទាំងនេះ ដោយសារខ្វះខាតធនធាន មិនមានការសម្របសម្រួលរវាងមន្ទីរ និងអង្គភាព មិនទាន់យល់ដឹងពីច្បាប់ និងនីតិវិធី មិនមានការសហការពីគ្រួសារ និងឧបសគ្គផ្នែកភស្តុភារ។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ក្នុងខេត្តសៀមរាបបានលើកឡើងថា ៖

> *"ករណីភាគច្រើនដែលបញ្ជូនមកការិយាល័យរបស់ខ្ញុំគឺមានភាពយឺតយ៉ាវពេក ហើយនៅពេលនោះ មានការបាត់បង់ភស្តុតាងជាច្រើន។ ប៉ូលិសក៏មិនទាន់យល់ច្បាស់ពីនីតិវិធីផ្លូវច្បាប់នៅឡើយ។ "*

ទោះបីជាអ្នកផ្តល់បទសម្ភាសភាគច្រើនក្នុងទីតាំងស្រាវជ្រាវនៅកម្ពុជា បានចាត់ទុកជម្រកដែលអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍ផ្តល់ឲ្យនោះជាកន្លែងដែលមានសុវត្ថិភាព សម្រាប់កុមារកំព្រាជនរងគ្រោះដោយសារការរំលោភបំពាន និងកុមារតាមផ្លូវក៏ដោយ តាមរយៈបទសម្ភាសជាមួយប្រធានគ្រប់គ្រងជម្រកទាំងបីបានបង្ហាញឲ្យឃើញថា មិនមានប្រធានគ្រប់គ្រងណាម្នាក់មានគោលនយោបាយការពារកុមារ នោះឡើយ។ ប្រធានគ្រប់គ្រងជម្រកម្នាក់នៅក្នុងខេត្តសៀមរាបបានរៀបរាប់ពីការ សម្រេចចិត្តរបស់ខ្លួនក្នុងការទទួលយកបុគ្គលិកម្នាក់ឲ្យមកធ្វើការវិញ បន្ទាប់ពីបុគ្គលិកនោះបានរំលោភបំពានលើកុមារនៅក្នុងជម្រក ដោយសារតែបុគ្គលិកនោះបាន "អង្វរករ និងសន្យាថាមិនធ្វើដូច្នោះម្តងទៀតឡើយ"។ យ៉ាងណាក៏ដោយ ក្រោយមកទៀត គាត់បានចាប់ផ្តើមមាន "ទំនាក់ទំនងស្នេហាជាមួយកុមារីម្នាក់ដែលស្នាក់នៅទីនោះ។ បន្ទាប់ពីនោះមក ក៏មានកុមារីម្នាក់បានឃើញ ហើយបុគ្គលិកនោះក៏ត្រូវបានបណ្តេញចេញ ប៉ុន្តែមិនមានការដាក់បណ្តឹងអាជ្ញាចំពោះបុគ្គលិកនោះឡើយ។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់នៅខេត្តមណ្ឌលគិរីក៏បានរៀបរាប់រឿងរ៉ាវស្រដៀងគ្នាដែលមាននិយោជិតរបស់អង្គការមិនមែនរដ្ឋាភិបាល មួយផ្សេងទៀតបានបំពានផ្លូវភេទ និងមានបំណងរួមភេទជាមួយកុមារីអាយុ ១៣ ឆ្នាំ បន្ទាប់ពីគ្រួសាររបស់កុមារីជឿជាក់លើរូបគេ។ បញ្ហានេះបង្ហាញពីការព្រួយបារម្ភថា ស្ថាប័នដែលធ្វើការជាមួយកុមារ អាចទាក់ទាញជនប្រព្រឹត្តបទល្មើសផ្លូវភេទកុមារ ហើយបុគ្គលិករបស់ស្ថាប័ននោះ អាចលួងលោមឲ្យកុមារជួបជាមួយជនប្រព្រឹត្តិបទល្មើស។ ដូច្នេះ ត្រូវលើកឡើងពីតម្រូវការចាំបាច់ក្នុងការរៀបចំគោលនយោបាយ និងនីតិវិធីការពារកុមារឲ្យបានច្បាស់លាស់ និងអនុវត្តបាន។

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ក្នុងខេត្តសៀមរាបបានលើកឡើងថា ៖ *"ករណីភាគច្រើនដែល បញ្ជូនមកការិយាល័យរបស់ខ្ញុំគឺមានភាពយឺតយ៉ាវពេក ហើយនៅពេលនោះ មានការបាត់បង់ភស្តុតាងជាច្រើន។ ប៉ូលិសក៏មិនទាន់យល់ច្បាស់ពីនីតិវិធីផ្លូវច្បាប់នៅឡើយ"*។

មានការរាយការណ៍ពីករណីផ្សេងទៀតនៃ ជនប្រព្រឹត្តិបទល្មើសដែលព្យាយាមជួបជាមួយកុមារដោយធ្វើការ ឬស្ម័គ្រចិត្តធ្វើការនៅតាមអង្គការកុមារ[១៣៣]។ ចំនួនស្ថាប័នដែលធ្វើការពាក់ព័ន្ធនឹងការជួញដូរកុមារនៅកម្ពុជាមានការកើនឡើង ដោយសារតែជនប្រព្រឹត្តិបទល្មើសត្រូវបង្ខំចិត្តប្រើប្រាស់ វិធីសាស្ត្រថ្មី ដោយសារតែមានការលើកកម្ពស់ការយល់ដឹងកាន់តែច្រើន និងគ្រោះថ្នាក់នៃការប្តឹងចោទប្រកាន់ [១៣៤]។

ការស្រាវជ្រាវថ្មីៗបង្ហាញថា ជនប្រព្រឹត្តិបទល្មើសផ្លូវភេទមួយចំនួនគឺជាគ្រូបង្រៀនភាសាអង់គ្លេស ឬបានបង្កើតអង្គការរបស់ខ្លួន និងផ្តល់ជាទីជម្រកដល់កុមារ (នេះគឺជានីតិវិធីងាយៗនៅកម្ពុជា)[១៣៥]។ អ្នកផ្តល់បទសម្ភាសមួយចំនួននៅប្រទេសថៃ បានបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអំពើពុករលួយក្នុងមូលដ្ឋាន ដែលអាចរាំងស្ទះដល់ការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរផ្លូវភេទ។ បុគ្គលិកអង្គការ មិនមែនរដ្ឋាភិបាលម្នាក់នៅទីក្រុងផាត់តាយ៉ា បានលើកឡើងថា ៖

> *"មានករណីជាច្រើនដែលប៉ូលិសអន្តរជាតិបានខិតខំប្រឹងប្រែងបង្ក្រាបជនប្រព្រឹត្តិបទល្មើសក្នុងរូបភាពជាភ្ញៀវទេសចរ ដោយតាមដានជនប្រព្រឹត្តិបទល្មើសទាំងនេះក្នុងប្រទេសជាច្រើន។ បន្ទាប់ពីមានការចាប់ខ្លួនពីប៉ូលិសក្នុងប្រទេសថៃ ជនប្រព្រឹត្តិបទល្មើសជាច្រើនត្រូវបានតុលាការដោះលែង ដោយសារតែអំពើពុករលួយ។ "*

[១៣៣] អង្គការ Olszewski, P (ឆ្នាំ២០១១) បុរសក្នុងទីក្រុង ៖ កាសែតភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១។ សូមមើលអង្គការ Action Pour Les Enfants (ខែកុម្ភៈ ឆ្នាំ២០១៤) ការស៊ើបអង្កេត ជនប្រព្រឹត្តិបទល្មើសផ្លូវភេទលើកុមារក្រោមរូបភាពជាភ្ញៀវទេសចរ ៖ ការវិភាគនិន្នាការ និងបញ្ហាប្រឈមនៃការរំលោភបំពានផ្លូវភេទកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា។

[១៣៤] សូមមើលអង្គការ Action Pour Les Enfants (ខែកុម្ភៈ ឆ្នាំ២០១៤) ការស៊ើបអង្កេតជនប្រព្រឹត្តិ បទល្មើសផ្លូវភេទលើកុមារក្រោមរូបភាពជាភ្ញៀវ ទេសចរ ៖ ការវិភាគនិន្នាការ និងបញ្ហាប្រឈមនៃការរំលោភបំពានផ្លូវភេទកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា។

[១៣៥] អង្គការ Save The Children (ខែកុម្ភៈ ឆ្នាំ ២០០៩) ជនប្រព្រឹត្តិបទល្មើសផ្លូវភេទនៅគ្រប់ទីកន្លែង ៖ ការស៊ើបអង្កេតពីការបំពានផ្លូវភេទ និងការជួញដូរកុមារក្នុងវិស័យទេសចរនៅថៃ កម្ពុជា និងភូមា។

> បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងខេត្តសៀមរាប បានលើកឡើងថា ៖ *"ពេលខ្លះ ជនរំលោភបំពានគឺជាសាច់ញាតិរបស់អ្នកមានអំណាច។ ករណីបែបនេះ ច្រើនតែមានការលាក់បាំង"។*

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ក្នុងខេត្តសៀមរាបនៃប្រទេសកម្ពុជា យល់ថា ខណៈដែលមានច្បាប់ប្រឆាំងអំពើពុករលួយ ប្រាក់បៀវត្សរ៍ដ៏ទាបរបស់អាជ្ញាធរមានសមត្ថកិច្ចបានជំរុញឲ្យពួកគេពុករលួយដើម្បីរកបានប្រាក់បៀវត្សន៍ដ៏សមរម្យមួយ។ គាត់បានពន្យល់ថា ពេលខ្លះ ករណីរំលោភបំពានផ្លូវភេទត្រូវបាន ចាត់ទុកថាមិនសូវផ្តល់ប្រាក់ច្រើនដល់អាជ្ញាធរ ហើយអាជ្ញាធរផ្ទាល់ក៏អាចពាក់ព័ន្ធក្នុងការរំលោភបំពាន ឬករណីដែលជនប្រព្រឹត្តិបទល្មើសជាអ្នកមាន ឬមានអំណាច។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងខេត្តសៀមរាប បានបង្ហាញពីការព្រួយបារម្ភ ៖ "***ពេលខ្លះ ជនរំលោភបំពានគឺជាសាច់ញាតិរបស់អ្នកមានអំណាច។ ករណីបែបនេះ ច្រើនតែមានការលាក់បាំង។***"

នៅទីក្រុងហៃហ្វុងនៃប្រទេសវៀតណាម សិស្សសាលាឯកជនមួយ ក្រុមហាក់ទទួលស្គាល់ថាការប្រើប្រាស់អំណាច និងប្រាក់ខុសច្បាប់គឺជាតថភាពដែលកើតមានក្នុងសាលា និងសហគមន៍ របស់ខ្លួន។ សិស្សជាច្រើនក៏បានដឹងថា ឪពុកម្តាយរបស់ខ្លួនសូកប៉ាន់ជាមួយអាជ្ញាធរមូលដ្ឋាន ក្លែងបន្លំសំបុត្រកំណើត ដើម្បីរៀបការកូនស្រីដែលមិនទាន់គ្រប់អាយុឲ្យបុរសអាស៊ីបូព៌ា ដើម្បីបានប្រាក់។ ជាទូទៅ ជនប្រព្រឹត្តិបទល្មើសមិនបានទទួលខុសត្រូវលើអាកប្បកិរិយារំលោភបំពានរបស់ខ្លួនឡើយ ៖ ***"ប្រសិនបើ  មនុស្សពេញវ័យមិនបានចាត់ទុកការរំលោភបំពានជាករណីធ្ងន់ធ្ងរផង ហេតុអ្វីបានជាយើងត្រូវខ្វល់នោះ?"***

តាមការស្រាវជ្រាវ ជាទូទៅច្រើនមានការចរចាក្រៅប្រព័ន្ធតុលាការរវាងជនរងគ្រោះ និងជនប្រព្រឹត្តិបទល្មើស។ ឧទាហរណ៍ នៅទីក្រុងឈៀងម៉ៃនៃប្រទេសថៃ មានការរកឃើញថា នៅពេលមានករណីសកម្មភាពផ្លូវភេទមិនទាន់គ្រប់អាយុក្នុងទំនាក់ទំនងស្នេហារបស់កុមារ ដូចជាកុមាររំលោភសេពសន្ថវៈមិត្តស្រីរបស់ខ្លួន ឪពុកម្តាយច្រើនស្វែងរកការសម្រុះសម្រួលរវាងគ្រួសារទាំងពីរជាជាងចាត់វិធានការតាមផ្លូវច្បាប់។ សិស្សបានលើកឡើងនូវករណីឪពុកម្តាយកុមារីដែលជាជនរងគ្រោះការរំលោភសេពសន្ថវៈ (ព្រមទាំងកុមារីដែលបានព្រមព្រៀងរួមភេទជាមួយមិត្តប្រុសរបស់ខ្លួន) បានគំរាមកំហែងថានឹងចាត់វិធានការតាមផ្លូវច្បាប់ដើម្បីទទួលបានសំណងជំងឺចិត្តពីឪពុកម្តាយខាងប្រុស។ ប៉ូលិសនៅប្រទេសវៀតណាមចាត់ទុកករណីរំលោភបំពានផ្លូវភេទជាករណីរដ្ឋប្បវេណី ដោយទាក់ទងនឹងកិច្ចការរបស់គ្រួសារជាជាងករណីព្រហ្មទណ្ឌ។

> បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងខេត្តសៀមរាប បានលើកឡើងថា ៖ *"ពេលខ្លះ ជនរំលោភបំពាន គឺជាសាច់ញាតិរបស់អ្នកមានអំណាច។ ករណីបែបនេះ ច្រើនតែមានការលាក់បាំង"។*

នៅទីក្រុងហៃហ្វុងនៃប្រទេសវៀតណាម សិស្សសាលាឯកជនមួយ ក្រុមហាក់ទទួលស្គាល់ថាការប្រើប្រាស់អំណាច និងប្រាក់ខុសច្បាប់គឺជាតថភាពដែលកើតមានក្នុងសាលា និងសហគមន៍របស់ខ្លួន។ សិស្សជាច្រើនក៏បានដឹងថា ឪពុកម្តាយរបស់ខ្លួនសូកប៉ាន់ ជាមួយអាជ្ញាធរមូលដ្ឋាន ក្លែងបន្លំសំបុត្រកំណើត ដើម្បីរៀបការកូនស្រីដែលមិនទាន់គ្រប់អាយុឲ្យបុរសអាស៊ីបូព៌ា ដើម្បីបានប្រាក់។ ជាទូទៅ ជនប្រព្រឹត្តិបទល្មើស មិនបានទទួលខុសត្រូវលើអាកប្បកិរិយារំលោភបំពានរបស់ខ្លួនឡើយ ៖ ***"ប្រសិនបើមនុស្សពេញវ័យ មិនបានចាត់ទុកការរំលោភបំពានជាករណីធ្ងន់ធ្ងរផង ហេតុអ្វីបានជាយើងត្រូវខ្វល់នោះ?"*** ប្រពៃណី ឬជំនឿតាមមូលដ្ឋានក៏ជាផ្នែកមួយ ដែលរារាំងដល់កិច្ច ខិតខំប្រឹងប្រែងការពារកុមារផងដែរ ដូចដែលបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់

*សិស្សស្រីម្នាក់នៅកម្ពុជាបានរៀបរាប់ថា "កុមារាអាយុ ៧ ឆ្នាំម្នាក់ ត្រូវបានលោកសង្ឃក្នុងវត្តមួយចាប់រំលោភនៅពេលដែលកុមារានោះមករៀនភាសាអង់គ្លេស ហើយមិនមានសិស្សផ្សេងទៀតនៅទីនោះ។ លោកសង្ឃម្នាក់នោះត្រូវបានចាប់ខ្លួន ប៉ុន្តែគ្រួសាររបស់លោកសង្ឃនោះ បានសូកប៉ាន់ប៉ូលិសដើម្បីដោះលែងខ្លួនលោកពីមន្ទីរឃុំឃាំង។ បច្ចុប្បន្ននេះ កុមារានោះមានសភាពស្ងៀមស្ងាត់ និងមិនសូវនិយាយស្តីជាមួយអ្នកជិតខាង ឬមិត្តចាស់របស់ខ្លួនឡើយ"។*

នៅខេត្តមណ្ឌលគិរីនៃប្រទេសកម្ពុជា បានបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងពីជំនឿរបស់ជនជាតិដើមភាគតិចក្នុង ក្នុងការទទួល យកសំណងក្នុងទម្រង់ជាអំណោយ ប្រាក់ ឬសត្វពាហនៈពីអ្នកប្រព្រឹត្តិខុសដែលកំពុងតែនៅអនុវត្តនៅឡើយ។ គាត់បានពន្យល់ថា ប្រសិនបើរកឃើញថា បុគ្គលម្នាក់ក្នុងភូមិបានចាប់រំលោភសេពសន្ថវៈក្មេងម្នាក់ នោះគ្រួសាររបស់ជនរងគ្រោះអាចទាមទារ អំណោយពីជនប្រព្រឹត្តិបទល្មើសជាជាងបញ្ជូនជនប្រព្រឹត្តិបទល្មើសនោះទៅតុលាការ ឬប៉ូលិស។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលនេះបានបញ្ជាក់ថា មានប្រជាជនប្រហែល ៦០% ដែលនៅប្រកាន់ ខ្ជាប់ទម្លាប់បែបនេះ[១៣៦] ហើយយល់ថាការ ដាក់ពិន័យនេះមិនទាន់សមនឹងទង្វើដែលបានប្រព្រឹត្តិ ឬរារាំង ជនប្រព្រឹត្តិបទល្មើសនោះឡើយដោយសារ តែវាអាចនឹងជំរុញឲ្យជនប្រព្រឹត្តិបទល្មើសប្រព្រឹត្តិបទឧក្រិដ្ឋនោះម្តងហើយម្តងទៀត"។ គាត់ក៏បានលើកឡើងករណីរំលោភសេពសន្ថវៈដែលបុរសអាយុ ៤៣ ឆ្នាំ ម្នាក់បានប្រព្រឹត្តិលើកុមារីអាយុ ៤ ឆ្នាំម្នាក់បន្ទាប់ពីគ្រួសារជនរងគ្រោះទទួលបានសំណងជំងឺចិត្តពីជនប្រព្រឹត្តិបទល្មើស។ សិស្សស្រីម្នាក់បានរៀបរាប់ករណីដូចខាងក្រោម ៖

> *"កុមារាអាយុ ៧ ឆ្នាំ ម្នាក់ ត្រូវបានលោកសង្ឃក្នុងវត្តមួយចាប់រំលោភនៅពេលដែលកុមារានោះមករៀនភាសាអង់គ្លេស ហើយមិនមានសិស្សផ្សេងទៀតនៅទីនោះ។ លោកសង្ឃម្នាក់នោះត្រូវបានចាប់ខ្លួន ប៉ុន្តែគ្រួសាររបស់លោកសង្ឃនោះ បានសូកប៉ាន់ប៉ូលិសដើម្បីដោះលែងខ្លួនលោកពីមន្ទីរឃុំឃាំង។ បច្ចុប្បន្ននេះ កុមារានោះមានសភាពស្ងៀមស្ងាត់ និងមិនសូវនិយាយស្តីជាមួយអ្នកជិតខាង ឬមិត្តចាស់របស់ខ្លួនឡើយ។"*

[១៣៦] យោងតាម Gourley (ឆ្នាំ២០០៩) គុណតម្លៃផ្នែកវប្បធម៌នៃការការពារកេរ្តិ៍ឈ្មោះគ្រួសារ សុខុដុមនីយភាពសង្គម និងការគោរពតាមឋានានុក្រម ធ្វើឲ្យឪពុកម្តាយទទួលយកដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ការរៀបការកូនជាមួយជនប្រព្រឹត្តិបទល្មើស និងការរំលូតកូនជាដំណោះស្រាយដែលអាចទទួលយកបានចំពោះការរំលោភបំពានផ្លូវភេទ។ Gourley, S (ឆ្នាំ២០០៩) ផ្លូវកណ្តាល ៖ ការបំពេញចំណុចខ្វះខាតរវាងវប្បធម៌ប្រជាជនកម្ពុជា និងសិទ្ធិកុមារ ៖ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលស្តីពីសិទ្ធិកុមារ ទីក្រុងភ្នំពេញ។

ជំពូក ៥

# សេចក្ដីសន្និដ្ឋាន



# ជំពូក ៥ ៖ សេចក្តីសន្និដ្ឋាន



ផ្នែកនេះបង្ហាញពីសេចក្តីសន្និដ្ឋានសំខាន់ៗនៃការស្រាវជ្រាវ សម្រាប់សមាសធាតុសំខាន់ៗនៃការសិក្សា ដូចជា ចំណេះដឹង ឥរិយាបទ និងការប្រព្រឹត្តព្រមទាំងភាពងាយរងគ្រោះ និងជម្រើសនានាដែលធ្វើឡើង ដោយគម្រោងសសរស្តម្ភបង្ការកុមារភាព។ អនុសាសន៍ជាយុទ្ធសាស្ត្រសម្រាប់ ការធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ក៏ត្រូវបានដាក់បញ្ចូលផងដែរ។

## ការស្វែងយល់អំពីការរំលោភបំពានផ្លូវភេទកុមារ

អ្នកផ្តល់បទសម្ភាសភាគច្រើន មានចំណេះដឹងមូលដ្ឋានតិចតួច អំពីការរំលោភបំពានកុមារ និង សិទ្ធិកុមារ។ ការរំលោភបំពានផ្លូវភេទកុមារ ត្រូវបានមនុស្សពេញវ័យ និងកុមារយល់ក្នុងលក្ខណៈ ចង្អៀតថាជាការចាប់រំលោភកុមារី។ កុមារ និងមនុស្សពេញវ័យភាគច្រើន យល់ឃើញអំពីច្បាប់ដែលពាក់ព័ន្ធនឹងអាយុយល់ព្រមរួមភេទភាគច្រើនថាជាទម្រង់មួយនៃភាពគ្រប់ដណ្តប់ មិនមែនយល់ថាជាយន្តការការពារមួយសម្រាប់កុមារទេ។ ការវិច្ឆ័យលើអ្វីដែលអាចបង្កើតបានជាការរំលោភបំពានផ្លូវភេទ ច្រើនតែពឹងផ្អែកលើកាលៈទេសៈមួយចំនួន គិតរួមទាំងអាយុរបស់ដៃគូរួមភេទ ទំនាក់ទំនងរបស់បុគ្គលនោះជាមួយកុមារ និងទោះជាកុមារីនោះ ជាស្ត្រីបរិសុទ្ធ ឬមិនមែនក៏ដោយ។

សិស្សដែលរៀនជំនាញ កុមារដែលធ្វើការងារ និងកុមារនៅតាមផ្លូវ ព្រមទាំងសិស្សសាលាឯកជនហាក់បីដូចជាមានការយល់ដឹងអំពីការរំលោភបំពានផ្លូវភេទកុមារ បានច្រើនជាងសិស្សសាលារដ្ឋ។ មិនតែប៉ុណ្ណោះ អ្នកផ្តល់បទសម្ភាសភាគច្រើន មានអារម្មណ៍ថា ជាទូទៅ កុមារីច្រើនតែងាយរងគ្រោះពីការរំលោភបំពាន ច្រើនជាងកុមារា។ ជាការពិត ការរំលោភបំពានផ្លូវភេទ មិនត្រូវបានគេយល់ឃើញទូលំទូលាយថាជាអ្វីដែលអាចកើតមានចំពោះកុមារាឡើយ ដែលវាមានភាពជាប់ទាក់ទងយ៉ាងខ្លាំងសម្រាប់ការកំណត់អត្តសញ្ញាណ និងការឆ្លើយតបទៅនឹងការរំលោភបំពានផ្លូវភេទលើកុមារា។

សរុបមក មនុស្សពេញវ័យ និងកុមារជាច្រើន ហាក់បីដូចជាពុំមានការយល់ដឹងគ្រប់គ្រាន់អំពីការរំលោភបំពានផ្លូវភេទកុមារ និងវិធីជាក់ស្តែងក្នុងការកំណត់ ការបង្ការ ឬការឆ្លើយតប ទៅនឹងការរំលោភបំពានផ្លូវភេទកុមារនោះឡើយ។ ក្នុងចំណោមក្រុមទាំងអស់ដែលបានសម្ភាស ឪពុកម្តាយ បានបង្ហាញអំពីកម្រិតនៃការយល់ដឹងទាបបំផុតអំពីបញ្ហាការរំលោភបំពានផ្លូវភេទកុមារ។ ជារួម លទ្ធផលរកឃើញនេះ អាចមានសារៈសំខាន់ខ្លាំងបំផុតក្នុងការពិចារណា អំពីការបង្កើតភាពខ្លាំង និងការឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងសហគមន៍។ កង្វះការយល់ ដឹងអំពីមូលដ្ឋាននៃការរំលោភបំពានផ្លូវភេទកុមារ មានន័យថា ឪពុកម្តាយ និងអ្នកមានកាតព្វកិច្ច ទំនងជាពុំបានកំណត់ពីគ្រោះថ្នាក់ និងករណីនានាទុកជាមុនក្នុងអំឡុងពេលទំនាក់ទំនងដែលមាន ការរំលោភបំពាន។ ដោយហេតុនេះ ទើបធ្វើឱ្យមានការរាំងស្ទះដល់ឱកាសក្នុងការធ្វើអន្តរាគមន៍ ក៏ដូចជាការឆ្លើយតបជារួមរបស់អ្នកពួកគេ ទៅនឹងតម្រូវការរបស់កុមារ។

កុមារមួយចំនួន បានកំណត់ពីការរួមភេទតាមរន្ធគូថ ការរួមភេទតាមមាត់ ការចូលរួម/ការមើលរូបភាពអាសអាភាស ឬការសម្រេចកាមដោយខ្លួនឯង ថាជាសកម្មភាពផ្លូវភេទដែលមានការរំលោភបំពាន។ ការយល់ដឹងជាទូទៅ ហាក់ដូចជាបង្ហាញថា ការចំពានផ្លូវភេទ គឺជាអ្វីដែលកើតចេញពីប្រភពខាងក្រៅគ្រួសារ និងសហគមន៍ ជាពិសេស គឺនៅកន្លែងដែលមានការរំលោភបំពានផ្លូវភេទលើកុមារនោះ។ ទោះបីជាយ៉ាងនេះក្តី ក្នុងពេលជាមួយគ្នានេះ បច្ចេកវិទ្យាដ៏ទាក់ទាញដែលប្រើប្រាស់ដោយអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទបរទេស និងក្នុងស្រុក កម្រនឹងកំណត់បានថាជាបែបបទ ឬទម្រង់ នៃការរំលោភបំពានណាស់។ នៅពេលដែលកុមារ បានដឹងពីគ្រោះថ្នាក់ដែលធ្វើឡើង ដោយអ្នករំលោភបំពាន កុមារទាំងនោះភាគច្រើនតែងពុំមានជំនាញ ឬយុទ្ធសាស្ត្រគ្រប់គ្រាន់ក្នុងការការពារខ្លួនឯងពីការរំលោភបំពានដែលអាចកើតមាន។ បញ្ហានេះ ត្រូវបានកំណត់ថាជាកត្តាគ្រោះថ្នាក់ដ៏សំខាន់មួយ ដោយសារគេបានដឹងថា អ្នកប្រព្រឹត្តបទល្មើសផ្លូវភេទលើកុមារ បានយកប្រៀបលើគ្រួសារ និងឪពុកម្តាយដែលគ្មានមន្ទិលសង្ស័យ ដើម្បីមានលទ្ធភាពចូលទៅរកកុមារ។

អ្នកស្រាវជ្រាវបានកំណត់ប្រភពសំខាន់ៗចំនួន ៥ អំពីផ្លូវភេទ និងបញ្ហាពាក់ព័ន្ធនឹងផ្លូវភេទសម្រាប់កុមារ មានដូចជា ប្រព័ន្ធផ្សព្វផ្សាយ និងអ៊ីនធើរណិត មិត្តភក្តិ សាលារៀន យុទ្ធនាការព័ត៌មានជាសាធារណៈ និងបទពិសោធន៍ផ្ទាល់ខ្លួន ព្រមទាំងការសង្កេតនានា។ ទោះបីជាកុមារបានកំណត់ថា ឪពុកម្តាយរបស់ខ្លួន គឺជាអ្នកដែលមានឥទ្ធិពលបំផុតនៅក្នុងជីវិតរបស់ពួកគេ ប៉ុន្តែឪពុកម្តាយមិនបានរកឃើញថាជាប្រភព ផ្តល់ព័ត៌មានដ៏សំខាន់នោះទេ។ អ្វីដែលលើសពីនោះ កុមារជាច្រើនបានបង្ហាញពីភាពភ័យខ្លាចក្នុងការ លាតត្រដាងអំពីបញ្ហាផ្ទាល់ខ្លួនជាមួយឪពុកម្តាយរបស់ខ្លួន រួមទាំងបញ្ហាផ្លូវភេទផងដែរ។ កុមារដែល បានចូលរៀន បានទទួលព័ត៌មានអំពីកាយវិភាគសាស្ត្រ និងសុខភាពបន្តពូជ នៅឯសាលារៀន និង ពីអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែកុមារទាំងនោះកម្រទទួលបានព័ត៌មានលម្អិត ដែលផ្តោតជាពិសេស លើយុទ្ធសាស្ត្របង្ការការរំលោភបំពានផ្លូវភេទកុមារណាស់។ នេះគឺជាចំណុចខ្វះខាតដ៏ធំមួយក្នុងឱកាស នៃការបង្ការ និងការពារកុមារពីការរំលោភបំពានផ្លូវភេទ។

បន្ថែមពីលើនេះ លំនាំដ៏គួរឱ្យកត់សម្គាល់មួយដែលត្រូវបានរកឃើញនៅក្នុងការសិក្សាទាំងមូល គឺភាពរឹងទទឹងរបស់ឪពុកម្តាយ និងគ្រូបង្រៀនក្នុងការផ្តល់ការអប់រំអំពីបញ្ហាផ្លូវភេទដល់កុមារ ដោយសារពួកគេខ្លាចថា ការធ្វើដូចនេះ អាចជម្រុញឱ្យមានការសាកល្បង និងការប្រើអាកប្បកិរិយា មិនសមទំនងក្នុងបញ្ហាផ្លូវភេទ។ បើទោះបីជាមានបញ្ហាដូចនេះក្តី ក៏កុមារជាច្រើននៅក្នុងទីតាំង ស្រាវជ្រាវនៅក្នុងប្រទេសថៃ និងប្រទេសវៀតណាម បានចូលពាក់ព័ន្ធក្នុងទំនាក់ទំនងផ្លូវភេទទៅ ហើយ និងពុំទទួលបានព័ត៌មានត្រឹមត្រូវ និងគួរឱ្យទុកចិត្តបានគ្រប់គ្រាន់អំពីបញ្ហាផ្លូវភេទពីមនុស្ស ពេញវ័យដែលអាចទុកចិត្តបានឡើយ មានន័យថា កុមារបានទទួលព័ត៌មានជាច្រើនអំពីបញ្ហានោះ ដែលអាចមានលក្ខណៈត្រឹមត្រូវ ឬមិនត្រឹមត្រូវពីប្រភពព័ត៌មានក្រៅផ្លូវការ ដូចជា ពីមិត្តភក្តិ ទូរទស្សន៍ ប្រព័ន្ធផ្សព្វផ្សាយ និងអ៊ីនធើរ    ណិត។ ទង្វើនេះគឺជារឿងមួយដ៏គួរឱ្យព្រួយបារម្ភ ដោយសារថា វាបាន ធ្វើឱ្យកុមារ ស្ថិតនៅក្នុងគ្រោះថ្នាក់នៃការប្រឈមនឹងឥរិយាបទរួមភេទ ដែលប្រកបដោយគ្រោះថ្នាក់ និង ទទួលរងនូវការកេងប្រវ័ញ្ចផ្លូវភេទកាន់តែខ្លាំង ហើយជាលទ្ធផលធ្វើឱ្យកុមារទាំងនោះងាយ រងគ្រោះដោយសារជំងឺកាមរោគ ការមានកូនចៃដន្យ ជំងឺផ្នែកស្មារតី និងផលវិបាកនៃការរំលោភបំពាន ផ្លូវភេទកុមារ។ មិនតែប៉ុណ្ណោះ កង្វះការប្រាស្រ័យទាក់ទងរវាងមនុស្សពេញវ័យដែលអាចទុកចិត្តបាន និងកុមារ អាចធ្វើឱ្យកុមាររងគ្រោះដោយសារការដាក់សម្ពាធពីមិត្ត ឬការបង្ហាញពីព័ត៌មានជាមួយ "មិត្តភក្តិ" តាមអ៊ីនធើរណិត ដែលធ្វើឱ្យកុមារទាំងនោះ ប្រឈមទៅនឹងដំណើរនៃភាពទាក់ទាញ និងការរំលោភបំពានផ្លូវភេទ។ ទោះបីជាយ៉ាងនេះក្តី ឪពុកម្តាយ និងសាលារៀន ពុំបានរកឃើញថា ជាប្រភពផ្តល់ព័ត៌មានដ៏សំខាន់អំពីបញ្ហាផ្លូវភេទ និងការរំលោភបំពានផ្លូវភេទកុមារទេ ប៉ុន្តែ អ្នកទាំងនោះ បានផ្តល់នូវឱកាសសម្រាប់ការឆ្លើយតប ការធ្វើអន្តរាគមន៍ និងគ្រោះថ្នាក់ដែលអាចបង្ការបាន។

## ឥរិយាបថ និងការប្រព្រឹត្ត

ឥរិយាបថ ជំនឿ និងការប្រព្រឹត្តមួយចំនួន ត្រូវបានរកឃើញនៅក្នុងទីតាំងស្រាវជ្រាវនីមួយៗ ដែលមាន សក្តានុពលក្នុងការរួមចំណែកដល់ភាពងាយរងគ្រោះរបស់កុមារ ដោយសារការរំលោភបំពានផ្លូវភេទ។ បញ្ហាទាំងនេះ គឺរួមបញ្ចូលទាំងការហាមឃាត់មិនឱ្យពិភាក្សាអំពីបញ្ហាផ្លូវភេទដោយចំហ ដែលអាច បង្អាក់ដល់ការផ្សព្វផ្សាយ និងការអប់រំអំពីការរំលោភបំពានផ្លូវភេទ និងរបៀបបង្ការបញ្ហានោះ បញ្ហា វិសមភាពយេនឌ័រ និងទំនាក់ទំនងតាមឋានុក្រមរវាងឪពុកម្តាយ និងកូន ដែលអាចធ្វើឱ្យមានកង្វះខាត លើការផ្តល់សិទ្ធិអំណាចសម្រាប់ឱកាសនៃការអប់រំ និងកង្វះការទទួលស្គាល់ នូវសិទ្ធិរបស់កុមារ ជា ពិសេសកុមារី និងការផ្តោតជាសំខាន់លើភាពបរិសុទ្ធរបស់មនុស្សស្រី និងកិត្តិយសគ្រួសារ ព្រមទាំង កិត្តិនាមរបស់សហគមន៍ ដែលបណ្តាលឱ្យមានទំនោរជាទូទៅក្នុងការស្តីបន្ទោសដល់កុមារីដោយសារ "ការចាប់រំលោភ" ឬទម្រង់ណាមួយនៃភាពមិនគប្បីនៃបញ្ហាផ្លូវភេទ និងធ្វើឱ្យរារាំងដល់ការឆ្លើយតប សមស្របទៅនឹងការរំលោភបំពានផ្លូវភេទកុមារ តាមរយៈការបង្កើតឱ្យមានវប្បធម៌នៃភាពស្ងប់ស្ងាត់ និងការបដិសេធមិនទទួលយក។

ការស្រាវជ្រាវនេះ ផ្តោតលើសារៈសំខាន់នៃវប្បធម៌ដ៏រឹងមាំ ដែលបានដាក់បន្ទុកលើកុមារី នៅទូទាំងតំបន់ ដែលតម្រូវឱ្យស្ត្រីទាំងនោះត្រូវរក្សាព្រហ្មចារីនៅមុនពេលរៀបអាពាហ៍ពិពាហ៍ បើទោះបីជាក្នុងការអនុវត្ត ជាក់ស្តែង កុមារជាច្រើន ត្រូវបានរាយការណ៍ថា មានទំនាក់ទំនងបែបនមនោសញ្ចេតនា ឬមានទំនាក់ ទំនងផ្លូវភេទក៏ដោយ។ កុមារីច្រើនតែរងការស្តីបន្ទោស មាក់ងាយ និងជួបការលំបាក ដោយសារ

ឥរិយាបទផ្លូវភេទ មុនពេលរៀបអាពាហ៍ពិពាហ៍ ហើយបើទោះបីជាពួកគេជាជនរងគ្រោះពី ការរំលោភបំពានក៏ដោយ ក៏ឧបសគ្គដ៏ចម្បងមួយនោះគឺ ការកំណត់ និងការរាយការណ៍អំពីការរំលោភបំពានផ្លូវភេទកុមារ។ លើសពីនេះទៀត ការផ្តោតលើការរក្សាកិត្តិយស របស់កុមារី គឺមានសារៈសំខាន់ក្នុងការក្លែងធ្វើជាថា សកម្មភាពផ្លូវភេទនោះកើតឡើងមិនមែនតាមបំណង ឬកើតឡើងដោយសារការព្រមព្រៀងនោះទេ ហើយសកម្មភាពរួមភេទដែលពុំមានការព្រមព្រៀងនេះ រួមបញ្ចូលនូវគ្រោះថ្នាក់នៃការប្រព្រឹត្តតាមផ្លូវភេទដែលគ្មានសុវត្ថិភាព និងបន្តឱ្យមានការរំលោភបំពាន។ អន្តរាគមន៍នៃកម្មវិធី ដែលឆ្លើយតបទៅនឹងវប្បធម៌ជាទូទៅនៃការស្តីបន្ទោសឱ្យជនរងគ្រោះ និងលើកទឹកចិត្តឱ្យប្រជាជនវ័យក្មេងដែលរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទឱ្យ និយាយចេញមកក្រៅ គឺមានសារៈសំខាន់។.

ទំនាក់ទំនងផ្លូវភេទជាមួយភេទដូចគ្នា ជាពិសេសសម្រាប់បុរសៗ ត្រូវបានគេមាក់ងាយ និងចាត់ទុកថាមិនអាចទទួលយកបាននៅក្នុងសង្គម នៅគ្រប់ទីតាំងសិក្សាទាំងអស់ លើកលែងតែនៅប្រទេសឡាវ និងនៅទីក្រុងផាត់តាយ៉ានៃប្រទេសថៃ។ ទោះបីជាអ្នកផ្តល់សម្ភាសមួយចំនួន បានដឹងលឺអំពីករណីនានា ឬបានដឹងអំពីការរំលោភបំពានផ្លូវភេទលើកុមារាពីសំណាក់អ្នកប្រព្រឹត្តល្មើសក្រៅស្រុក និង/ឬក្នុងស្រុក ប៉ុន្តែការរំលោភបំពានផ្លូវភេទលើកុមារា មិនត្រូវបានចាត់ទុកថាជាការគំរាមកំហែង ឬជាបញ្ហាមួយដ៏ពិតប្រាកដទេ។ កង្វះការយល់ដឹង និងការទទួលស្គាល់នេះ បង្ហាញនូវគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរមួយសម្រាប់កុមារា ដែលកំពុងរងគ្រោះថ្នាក់ ឬរងការឈឺចាប់ដោយសារការរំលោភបំពាន។ ជនរងគ្រោះភេទប្រុសទាំងនោះ អាចមានការអាមាស់ក្នុងការរាយការណ៍អំពីការរំលោភបំពានមកលើខ្លួន ឬម៉្យាងវិញទៀត ការរាយការណ៍របស់ពួកគេអាចនឹងត្រូវបានគេប្រានចោល។ ដើម្បីដោះស្រាយនូវបញ្ហាបន្ទាន់នេះ ចាំបាច់ត្រូវការការខិតខំប្រឹងប្រែងជាច្រើន ក្នុងការផ្តល់ព័ត៌មានដល់កុមារ មនុស្សពេញវ័យ អ្នកមានកាតព្វកិច្ច និងអាជ្ញាធរនានា អំពីគ្រោះថ្នាក់ដ៏ពិតប្រាកដមួយរបស់កុមារា និងកុមារី ដែលអាចនឹងត្រូវរងការរំលោភបំពានផ្លូវភេទ។



ភាពក្រីក្រ ភាពចាំបាច់ក្នុងការផ្តល់ថវិកាសម្រាប់ការអប់រំ និងបញ្ហាសុខភាព គឺជាបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាទាំងឡាយដែលធ្វើឱ្យធ្លាក់ចូលទៅក្នុងបញ្ហាជួញដូរផ្លូវភេទ។ បញ្ហានេះបង្ហាញអំពីការរៀបចំកម្មវិធី និងគោលនយោបាយសម្រាប់លើកកម្ពស់ឱកាសការអប់រំ និងវិជ្ជាជីវៈសម្រាប់កុមារដែលជួបការលំបាក ជាពិសេសកុមារទាំងឡាយណាដែលធ្វើការ ឬរស់នៅតាមផ្លូវ និងកុមារដែលងាយរងគ្រោះបំផុតទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទ ដោយសារតែស្ថានភាពដ៏គួរឱ្យភ័យខ្លាចរបស់ពួកគេ។ បន្ថែមពីលើនេះ ក្នុងទីតាំងស្រាវជ្រាវទាំងអស់ កុមារត្រូវបានរំពឹងថាឱ្យស្តាប់ដំបូន្មាន និងគោរពឪពុកម្តាយរបស់ពួកគេ។ កាតព្វកិច្ចនៃសាច់សារលោហិត និងភាពចាំបាច់ក្នុងការទ្រទ្រង់គ្រួសាររបស់ពួកគេ ជាញឹកញាប់ ត្រូវបានកំណត់ថាជាមូលហេតុដែលធ្វើឱ្យកុមារីធ្លាក់ចូលទៅក្នុងការជួញដូរផ្លូវភេទ។ លទ្ធផលរកឃើញនេះបង្ហាញអំពីសារៈសំខាន់នៃការគាំទ្រផ្នែកហិរញ្ញវត្ថុ និងសង្គមសម្រាប់គ្រួសារ និងសហគមន៍ ដើម្បីការពារកុមារពីការរំលោភបំពានឱ្យបានកាន់តែប្រសើរជាងមុន។

ឥទ្ធិពលពីមិត្តភក្តិ ក៏ត្រូវបានរកឃើញផងដែរថាជាកត្តារួមចំណែកដល់គ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ ជាពិសេស នៅពេលដែលកុមារបានជម្រុញឱ្យមិត្តភក្តិរបស់ខ្លួន ចូលពាក់ព័ន្ធក្នុងការដោះដូរផ្លូវភេទ។ ការសិក្សាក៏បានរកឃើញទៀតថា ការលក់ខ្លួនដើម្បីប្រាក់សម្រាប់មនុស្សវ័យក្មេងមួយចំនួនគឺជាវិធីម៉្យាងដើម្បីដើរឱ្យទាន់នូវវប្បធម៌របស់ភ្ញៀវ។ ការលក់ខ្លួននេះ អាចធ្វើឡើងក្នុងទម្រង់ជាទំនិញផ្លូវភេទជាធម្មតា ឬអាចក្នុងទម្រង់ជា" ការដោះដូរជាសម្ភារ" ដែលមានលក្ខណៈប្រយោលជាងនេះដែលពាក់ព័ន្ធ នឹងអំណោយជារបស់របរពីភ្ញៀវ។ ករណីដ៏ទាក់ទាញ ដែលច្រើនតែពាក់ព័ន្ធនឹងការគាំទ្រផ្នែកហិរញ្ញវត្ថុ និងអំណោយជាសម្ភារ ក៏ត្រូវបានកត់ត្រាទុកជាឯកសារ នៅបណ្តាទីតាំងស្រាវជ្រាវផងដែរ។ ការលើកកម្ពស់ការយល់ដឹងឱ្យបានប្រសើរជាងមុនអំពីគ្រោះថ្នាក់នៃការដោះដូរជាសម្ភារ អំណោយ និងវិធីសាស្ត្រទាក់ទាញផ្សេងទៀត ដែលប្រើប្រាស់ដោយអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទលើកុមារ ដើម្បីអាចមានលទ្ធភាពចូលទៅរកជនរងគ្រោះ ឬរាំងជនរងគ្រោះមិនឱ្យនិយាយប្រាប់អ្នកដទៃចាំបាច់ត្រូវធ្វើឡើងសម្រាប់កុមារ និងមនុស្សពេញវ័យ។

នៅគ្រប់ទីតាំងទាំងអស់ ឥទ្ធិពលនៃអ៊ីនធើរណិត ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកវិទ្យាឌីជីថល អំពីអាកប្បកិរិយា និងឥរិយាបថផ្លូវភេទរបស់កុមារ បានបង្ហាញឱ្យឃើញយ៉ាងច្បាស់។ ជាទូទៅ ឪពុកម្តាយ

និងអ្នកមានកាតព្វកិច្ច ពុំបានដឹងអំពីឥទ្ធិពលនេះទេ ហើយការត្រួតពិនិត្យលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់កុមារ ក៏ពុំមានដែរនៅក្នុងការអនុវត្តជាក់ស្តែង។ ការព្រួយបារម្ភដ៏ចម្បងរបស់ឪពុកម្តាយ និងអ្នកមានកាតព្វកិច្ចគឺថា កុមារអាចញៀននឹងហ្គេមវីដេអូ ឬងាយប្រឈមទៅនឹងរូបភាពអាសអាភាស។ ឪពុកម្តាយ ឬកុមារមួយចំនួន បានបង្ហាញអំពីការយល់ដឹងអំពីការប្រើប្រាស់បច្ចេកវិទ្យាទាក់ទាញ ដែលមាននៅលើអ៊ីនធើរណេត ដែលប្រើប្រាស់ដោយអ្នកប្រព្រឹត្តល្មើសផ្លូវភេទ និងគ្រោះថ្នាក់ដែល បង្កឡើងដោយការប្រព្រឹត្តបែបនេះ។ ផ្ទុយទៅវិញ គោលគំនិតនៃ "សេវាផ្តល់ជំនួយ" ដែលជាប្រភពអាចឱ្យកុមារទទួលបានព័ត៌មានសម្ងាត់ និងទទួលបានការផ្តល់ប្រឹក្សាដើម្បីដោះស្រាយ បញ្ហារបស់ពួកគេ គឺភាគច្រើនពុំត្រូវបានគេដឹងឡើយ ដែលនេះអាចបញ្ជាក់ថា វិបសាយថ៍ ការផ្ញើសារជាអក្សរ ប្រព័ន្ធផ្សព្វផ្សាយក្នុងសង្គម និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត អាចជាវិធីសាស្ត្រសមស្របជាង ដើម្បីអាចឈាន ទៅរកកុមារជាមួយនឹងព័ត៌មានអំពីការរំលោភបំពានផ្លូវភេទ។ សេវាផ្តល់ជំនួយ អាចមានសក្តានុពល ក្នុងការយកមកប្រើប្រាស់រួមជាមួយប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត ដើម្បីផ្តល់ការ ធ្វើអន្តរាគមន៍ដ៏មាន ប្រសិទ្ធភាពបំផុត។.

ការឆ្លើយតបទៅនឹងការរំលោភបំពាន មានភាពខុសៗគ្នា នៅតាមបណ្តាទីតាំងស្រាវជ្រាវ ផ្សេងៗគ្នា។ ក្នុងករណីជាច្រើន ការឆ្លើយតប ត្រូវពឹងផ្អែកលើការបើកចំហទំនាក់ទំនងរវាងឪពុកម្តាយ និងកុមារ ក៏ដូចជាកម្រិតនៃផ្តោតទៅលើកិត្តិយសគ្រួសារ និងកិត្តិនាមនៅក្នុងគ្រួសារ និងសហគមន៍។ នេះគឺជាការព្រួយបារម្ភដ៏ចម្បងមួយ។ ក្នុងករណីដែលសារៈសំខាន់ខ្លាំងបំផុត ត្រូវផ្តោតទៅលើកិត្តិនាម វដ្តមួយក៏បានចាប់ឡើង ដែលកុមារច្រើនតែពុំសូវរាយការណ៍ពីការរំលោភបំពានឱ្យមនុស្សពេញវ័យបានដឹង ដោយសារតែការគិតថាមានកំហុស និងភាពអាម៉ាស់ ជាលទ្ធផល ឪពុកម្តាយច្រើនតែជ្រើសយកវិធីពុំរាយការណ៍អំពីការរំលោភបំពានឱ្យអាជ្ញាធរបានដឹង ហើយអាជ្ញាធរច្រើនតែបដិសេធអំពីការវត្តមាននៃការរំលោភបំពានផ្លូវភេទលើកុមារ នៅក្នុងសហគមន៍របស់ពួកគេ។ ការរាយការណ៍អំពីដំណើររាំងស្ទះក្នុងការទទួលបានការឆ្លើយតបសមស្របពីអ្នកមានកាតព្វកិច្ច រួមមាន កង្វះធនធាន កង្វះការសម្របសម្រួលរវាងមន្ទីរ និងអង្គភាព កង្វះចំណេះដឹងអំពីច្បាប់ និងនីតិវិធី កង្វះការសហការពីគ្រួសារ ឧបសគ្គដ៏ស្មុគស្មាញផ្អែកនីតិវិធី និងនិន្នាការក្នុងការចាត់ទុកការរំលោភបំពានលើកុមារថាជាបញ្ហាគ្រួសារ ឬរឿងរដ្ឋប្បវេណី។

## ឧបសគ្គ និងឱកាសសម្រាប់ការធ្វើអន្តរាគមន៍



កត្តាសំខាន់ៗមួយចំនួន ត្រូវបានកំណត់ថាបានរួមចំណែកដល់ភាពងាយរងគ្រោះរបស់កុមារពីការរំលោភបំពានផ្លូវភេទ។ ក្នុងចំណោមកត្តាទាំងនេះ ស្ថានភាពគ្រួសារ រួមទាំង ការប្រើប្រាស់គ្រឿងញៀននៅក្នុងគ្រួសារ ការបែកបាក់សម្ព័ន្ធភាពនៅក្នុងគ្រួសារ និងអំពើហិង្សាក្នុងគ្រួសារ គឺជាករណី ដែលកើតមានញឹកញាប់បំផុត។ ការរកឃើញនេះ បង្ហាញឱ្យឃើញសារជាថ្មីនូវតម្រូវការការគាំទ្រ ផ្អែកសង្គម និងហិរញ្ញវត្ថុដែលត្រូវផ្តល់ឱ្យគ្រួសារ និងសហគមន៍ ដូចជាកុមារម្នាក់ៗ។

វត្តមាននៃឧស្សាហកម្មធ្វើដំណើរ និងទេសចរណ៍ នៅក្នុងទីតាំងជិតៗនៅក្នុងស្រុក បានបង្ហាញឱ្យឃើញពីកត្តាគ្រោះថ្នាក់មួយផ្សេងទៀតដែលអាចធ្វើឱ្យមានភាពងាយរងគ្រោះដល់កុមារ។ ជាពិសេស នៅពេលដែលកុមារធ្វើការក្នុងមុខរបរដូចជា អ្នកលក់ដូរតាមផ្លូវ ជាមគ្គុទេសន៍ទេសចរណ៍ ឬធ្វើការក្នុងឧស្សាហកម្មសេវាកម្ម ការដែលកុមារនៅជិតអ្នកធ្វើដំណើរ អាចធ្វើឱ្យពួកគេងាយរងគ្រោះខ្លាំងទៅនឹងភាពទាក់ទាញ និងការកេងប្រវ័ញ្ចផ្លូវភេទ។ ទោះបីជាយ៉ាងនេះក្តី កុមារ និងមនុស្សពេញវ័យនៅក្នុងការសិក្សានេះ ពុំបានផ្តល់គំនិតជាទូទៅថា អ្នកទេសចរ និងអ្នកធ្វើដំណើរគឺជាគ្រោះថ្នាក់ នោះទេ ហើយភាគច្រើន រដ្ឋាភិបាល ពុំបានចាត់ទុកថាបញ្ហានេះគឺជាបញ្ហាអាទិភាពបំផុតទេ ដែលកត្តានេះបញ្ជាក់ថា យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងការគាំទ្រ គឺមានសារៈសំខាន់ណាស់នៅក្នុងវិស័យនេះ។ យុទ្ធនាការបែបនេះ អាចជួយអប់រំអ្នកធ្វើដំណើរ និងអ្នកទេសចរអំពីរបៀបដែលពួកគេអាចជួយបង្កើតឱ្យមានបរិយាកាសទេសចរណ៍ប្រកបដោយសុវត្ថិភាពសម្រាប់កុមារ និងយកចិត្តទុកដាក់គាំទ្រស្ថានភាពគ្រោះថ្នាក់សម្រាប់កុមារក្នុងមូលដ្ឋាន។

ក្រៅពីកុមារដែលរស់នៅជិតតំបន់ទេសចរណ៍ កុមារដែលរស់នៅទីឆ្ងាយ និងទីដាច់ស្រយាល ក៏ងាយនឹងរងគ្រោះផងដែរ ជាពិសេស នៅពេលដែលអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ បានចាកចេញពីទីក្រុងឆ្ពោះទៅកាន់គោលដៅនៃតំបន់ឆ្ងាយដាច់ស្រយាល ដែលការយល់ដឹងអំពី ការរំលោភបំពានផ្លូវភេទមានកម្រិតទាប ហើយអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរ មានការស្ទាក់ស្ទើរក្នុងការចាត់វិធានការ ឬមិនអាចឈានទៅដល់កន្លែងនោះបាន។ បញ្ហានេះបង្ហាញឱ្យឃើញថា កិច្ចខិតខំប្រឹងប្រែងក្នុងការផ្តល់ព័ត៌មានអំពីការរំលោភបំពានផ្លូវភេទកុមារ និងសេវាការពារដែលឆ្លើយតបទៅនឹងការរំលោភបំពានផ្លូវភេទកុមារ គួរតែផ្តល់ឱ្យលើសពីតំបន់ទីក្រុងដែលមានប្រជាជនរស់នៅច្រើន ឬទីកន្លែងសម្រាប់អ្នកទេសចរណ៍ និងដៅចំពោះទីតាំងឆ្ងាយដាច់ស្រយាល ឱ្យបានកាន់តែច្រើន។ ការសិក្សានេះក៏បង្ហាញផងដែរអំពីរបៀបដែលយុទ្ធសាស្ត្រប្រើប្រាស់ដោយអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ មានការផ្លាស់ប្តូរជានិច្ច ដោយហេតុនេះ វិធីសាស្ត្រការពារ និងបង្ការ គួរតែមានលក្ខណៈផ្លាស់ប្តូរទៅតាមនោះដែរ។

បញ្ហាការពារកុមារ ហាក់បីដូចជាមានកំណើនខ្លាំងនៅក្នុងរបៀបវារៈនយោបាយ និងរបៀបវារៈថ្នាក់ជាតិនៅគ្រប់ទីតាំងស្រាវជ្រាវទាំងអស់។ ប៉ុន្តែ ទោះបីជា អ្នកស្រាវជ្រាវបានរកឃើញ ប្រព័ន្ធការពារកុមារដែលបានជ្រើសរើសនៅគ្រប់ទីតាំងស្រាវជ្រាវក៏ដោយ ក៏កម្រិតនៃប្រសិទ្ធភាព របស់រចនាសម្ព័ន្ធ ត្រូវបានរាំងស្ទះដោយបញ្ហាមួយចំនួន ដូចជា កង្វះការបណ្តុះបណ្តាលដល់អាជ្ញាធរ បុគ្គលិកសង្គម និងបុគ្គលិក អង្គការមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធ ការបដិសេធថាពុំមានវត្តមាន នៃការរំលោភបំពាន និងការរំលោភបំពានផ្លូវភេទកុមារ ពីសំណាក់អាជ្ញាធរ ភាពមានកម្រិតនៃសេវាអាចរកបាននៅតាមទីតាំងដាច់ស្រយាលភាគច្រើន និន្នាការចំពោះការដោះស្រាយក្រៅប្រព័ន្ធតុលាការ និងការចាត់ទុកថាការរំលោភបំពានផ្លូវភេទកុមារ ជារឿងរដ្ឋប្បវេណី កង្វល់អំពីបញ្ហាពុករលួយ កង្វះធនធាន និងការសម្របសម្រួលរវាងនាយកដ្ឋាន និងអង្គភាព និងចំណេះដឹងអំពីច្បាប់ និងនីតិវិធី និងការប្រឈមផ្នែកនីតិវិធី ក្នុងការឆ្លើយតបទៅនឹងករណីរំលោភបំពាន ( ឧទា. ចម្ងាយ ការធ្វើដំណើរ និងធនធាន )។ ការប្រឈមទាំងនេះ តម្រូវឱ្យប្រើប្រាស់វិធីសាស្ត្រចម្រុះ និងទូលំទូលាយ ដើម្បីបង្ការ និងឆ្លើយតបឱ្យបានជោគជ័យទៅនឹងការរំលោភបំពានផ្លូវភេទកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទកុមារក្នុងឧស្សាហកម្មធ្វើដំណើរ និងទេសចរណ៍។



# ឯកសារយោង


Action Pour Les Enfants (February 2014), *Investigating Travelling Child Sex Offenders: An analysis of the trends and challenges in the field of child sexual abuse and exploitation in Cambodia.*

Association of Southeast Asian Nations (undated), *ASEAN Tourism Ministers Meeting (M-ATM).*

AusAID (2010), *Project Childhood – Prevention Pillar Project Design Document.*

Baker, S (2004), *Child prostitution and HIV/AIDS in Thailand: Changing realities for Thai and hill-tribe children,* unpublished paper.

Baker, S (2007), *Child Labour and Child Prostitution in Thailand: Changing Realities,* White Lotus.

CDRI and UNFPA (November 2007), *Youth Migration and Urbanisation in Cambodia.*

Chan, I (March 2010), *Addressing Local Demand for Commercial Sex with Children in Cambodia: A Recommended Strategy for ECPAT Cambodia.*

Child Frontiers (2011), *Report on the Commercial Sexual Exploitation of Children in Lao PDR.*

ECPAT Cambodia, NGOCRC, COSECAM, (2007-8), *NGO Joint Statistics Database Report on Trafficking and Rape in Cambodia 2007-2008.*

ECPAT International, (2008), *Combating Child Sex Tourism: Questions and Answers.*

ECPAT International (2006a), *Global Monitoring Report on the Status of Action against Commercial Sexual Exploitation of Children: Cambodia.*

ECPAT International (2006b), *Global Monitoring Report on the Status of Action against Commercial Sexual Exploitation of Children: Thailand, Bangkok.*

ECPAT International (2011), *Global Monitoring: Status Action Against Commercial Sexual Exploitation of Children in Vietnam.*

Ennew J, Gopal, K, Heeran, J and Montgomery, H (1996), *CHILDREN AND PROSTITUTION: How Can We Measure and Monitor The Commercial Sexual Exploitation of Children? Literature Review and Annotated Bibliography,* UNICEF Headquarters, New York, Second Edition.

Gourley, S (2009), *The Middle Way: Bridging the Gap between Cambodian Culture and Children's Rights,* NGO Committee on the Rights of the Child, Phnom Penh.

Grillot, C (2005), *Street Pedophilia in Cambodia – A Survey on Phnom Penh's Suspects and Victims,* Action Pour Les Enfants.

Handicap International/Save The Children (2011), *Out From The Shadows: Sexual Violence Against Children With Disabilities.*

Human Rights Solidarity (1996), *CAMBODIA: Prostitution and Sex Trafficking: A Growing Threat to the Human Rights of Women and Children in Cambodia. Vol. 06 No. 04 NOV 1996.*

Keane, K (2006), *Street-Based Child Sexual Exploitation in Phnom Penh and Sihanoukville: A Profile of Victims,* Action Pour Les Enfants.

MacPherson, A (2011), *The Whole Person, the Whole Family, the Whole Society,* (draft), COSECAM Cambodia.

Maalla M'jid, N., *Report of The Special Rapporteur on the Sale of Children, Child Prostitution and Child Pornography,* Human Rights Council, Twenty-second Session, Agenda Item 3, A/HRC/22/54 (24 December 2012, reissued for technical reasons on 23 January 2013).

MLSW and UNICEF (2009), *Social Welfare System in Lao PDR: An Analysis of Welfare Services for the Prevention and Response to Abuse, Violence, and Exploitation against Children.*

MOLISA and UNICEF Vietnam (2009), *Creating a Protective Environment for Children in Vietnam: An Assessment of Child Protection Laws and Policies, Especially Children in Special Circumstances in Vietnam.*

Montgomery, H (2001), *Modern Babylon? Prostituting Children in Thailand,* Berghahn Books, New York.

Ministry of Tourism of Cambodia (2013), *Tourism Statistics Report.*

Niron, N, Viriya, Y, Gray, L (2001), *Children's Work, Adults' Play: Child Sex Tourism – the Problem in Cambodia,* World Vision.

O'Brian, M, Grillo, M and Barbosa, H (2008), *Sexual Exploitation of Children and Adolescents in Tourism: A Contribution of ECPAT International to the World Congress III against Sexual Exploitation of Children and Adolescents,* ECPAT International.

O'Connell Davidson, J (2004), 'Child Sex Tourism': An Anomalous Form of Movement?', *Journal of Contemporary European Studies,* Vol. 12 (1).

Office of the National Economic and Social Development Board (2009) *Thailand Millennium Development Goals Report 2009*, Bangkok.

Peters, H (2007), *Sex, Sun and Heritage: Tourism Threats and Opportunities in South East Asia,* UNIAP and World Vision.

Putman-Cramer, C (2005), *Child Sex Tourism: Study of The Scope of the Problem and Evaluation of Existing Anti-Child Sex Tourism Initiatives,* COSECAM.

Reimer, JK (2006), *At what price, honour? A qualitative study into domestic trafficking of Vietnamese (girl) children for sexual exploitation,* Chab Dai, Phnom Penh.

Royal Government of Cambodia (August 2008), *Functioning of Commune Committee for Women and Children.* National Committee for the Management of Decentralisation and Deconcentration Reform, Phnom Penh.

Save The Children (February 2009), *Sex Offenders without Borders: An investigation into the sexual abuse and exploitation of children in Thailand, Cambodia and Burma in relation to travel and tourism.*

Steinfatt, T, (2003), *Measuring the Number of Trafficked Women and Children in Cambodia: A Direct Observation Field Study,* USAID.

Suntikul, W, Butler, R and Airey, D (2008), 'A Periodisation of the Development of Vietnam's Tourism Accommodation since the Open Door Policy', *Asia Pacific Journal of Tourism Research,* Vol 13 (1), pp. 67-80.

The Protection Project, Johns Hopkins University (2007), *International Child Sex Tourism: Scope of the Problem and Comparative Case Studies.*

Thomas, F and Mathews, L (2006), *Who Are The Child Sex Tourists in Cambodia?,* Child Wise.

Thomstone, G, Leumwananonthachai, L, and Casey, S (2009), *Social Welfare System in Lao PDR: An Analysis of Welfare Services for the Prevention and Response to Abuse, Violence, and Exploitation against Children.*

Ung, C (2004), *The Sexual Trap,* Cambodian Women Crisis Centre, Phnom Penh.

UNICEF Fact Sheet (undated), *Residential Care in Cambodia.*

UNICEF (2011), *An Analysis of the Commercial Sexual Exploitation of Children in Selected Provinces and Cities of Vietnam.*

UNICEF Bangladesh (2009), *Protection of Children Living on the Streets.*

UNICEF-EAPRO (2011), *With the Best Intentions: A Study of Attitudes Towards Residential Care in Cambodia.*

UNICEF-EAPRO (2012), *Child Maltreatment: Prevalence, Incidence and Consequences in the East Asia and Pacific Region: A Systematic Review of Research.*

UNICEF-EAPRO (2012), *Child Protection in Educational Settings: Findings from Six Countries in East Asia and the Pacific.*

UNICEF Vietnam (2010), *An Analysis of the Situation of Children in Vietnam.*

UNWTO (2013), *Tourism Towards 2030.*

UNWTO (2014), *World Tourism Barometer.*

US Department of State (2011), *Trafficking in Persons Report.*

Vijghen, J (2009), *Report Evaluation, Acting for Women in Distressing Situations (AFESIP), ANESVAD Spain.*

Vijghen, J (2010), *ROM Report on Vietnam,* European Commission.

World Vision International (undated), *Kids understand how other kids hurt: Children and adolescents speak out about sexual exploitation.*

World Travel and Tourism Council (2014), *Cambodia Economic Impact Report.*

World Travel and Tourism Council (2014), *Laos Economic Impact Report.*

World Travel and Tourism Council (2014), *Thailand Economic Impact Report.*

World Travel and Tourism Council (2014), *Vietnam Economic Impact Report.*

Yamauchi, S and Lee, D (June 1999), *Tourism development in the Lao People's Democratic Republic,* Discussion Paper of the United Nations Department of Economic and Social Affairs, No 9, ST/ESA/1999/DP.9.

Yen et al (2012), *Exploratory Research: Trafficking in Boys in Vietnam,* IOM.




# ឧបសម្ព័ន្ធ ១៖ ឧបករណ៍ស្រាវជ្រាវ

ឧបករណ៍ដែលបានយកមកប្រើប្រាស់នៅក្នុងការស្រាវជ្រាវនៅប្រទេសឡាវ គឺជាតំណាងនៃឧបករណ៍ស្រាវជ្រាវដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍ប្រចាំប្រទេសនីមួយៗ និងត្រូវបានបញ្ចូលនៅក្នុងផ្នែកនេះ[១៣៧]។

[១៣៧] សូមបញ្ជាក់ថា មិនមែនសំណួរទាំងអស់ ត្រូវបានយកមកប្រើប្រាស់ក្នុងទម្រង់ដូចគ្នាសម្រាប់ប្រទេសនីមួយៗនោះទេ។

## ១. គោលការណ៍ណែនាំអំពីការពិភាក្សាជាក្រុមសម្រាប់កុមារ

### វគ្គផ្ដើមសេចក្ដី

1. ប្រាប់អ្នកចូលរួមអំពីគោលបំណងរបស់ក្រុម តើនរណាជាមេដឹកនាំក្រុម តើអ្នកចូលរួមម្នាក់ៗមានតួនាទីអ្វីខ្លះ៖ សូមបង្ហាញទស្សនៈ ឬបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក ថាតើមានភាពដូចគ្នា ឬខុសគ្នាពីអ្នកផ្សេងទៀតនៅក្នុងក្រុមយ៉ាងណាខ្លះ ?

2. លេងល្បែងប្រាប់ឈ្មោះ។ អ្នកចូលរួមម្នាក់ៗ ណែនាំឈ្មោះខ្លួនឱ្យអ្នកដទៃបានស្គាល់។ អ្នកផ្សេងទៀតត្រូវប្រាប់ឈ្មោះរបស់ខ្លួន បន្ទាប់មក ត្រូវថាតាមឈ្មោះរបស់អ្នកមុនៗ។

### ប្រធានបទសម្រាប់ការពិភាក្សា

គោលគំនិតនៃការពិភាក្សា គឺត្រូវស្ថិតក្នុងរង្វង់ទស្សនាទានបរិយាកាសសុវត្ថិភាពសម្រាប់កុមារ។ ត្រូវចាប់ផ្ដើមជាមួយទស្សនៈទូទៅអំពីបរិយាកាសសុវត្ថិភាព។ បន្ទាប់មក ត្រូវឱ្យអ្នកចូលរួមស្វែងរកគំនិតដែលពាក់ព័ន្ធនឹងទេសចរណ៍។ សំណួរខាងក្រោមនេះ នឹងត្រូវប្រើប្រាស់ធ្វើជាការណែនាំសម្រាប់ការពិភាក្សាដូចខាងក្រោម៖

១. តើកុមារមានគិតថា នៅផ្ទះ និងនៅក្នុងសហគមន៍របស់ពួកគេ មានសុវត្ថិភាពឬទេ ?

ប្រសិនបើគិតថាមាន តើអ្វីដែលធ្វើឱ្យពួកគេគិតថាមានសុវត្ថិភាព ?

ប្រសិនបើគិតថាគ្មាន តើអ្វីដែលធ្វើឱ្យពួកគេភ័យខ្លាច ?

២. តើកុមារត្រូវធ្វើអ្វីខ្លះ ដើម្បីឱ្យបរិយាកាសរស់នៅរបស់ខ្លួនអាចទទួលបានការការពារច្រើនជាងនេះ ?

៣. តើឪពុកម្ដាយ ឬសហគមន៍របស់កុមារ ត្រូវធ្វើអ្វីខ្លះ ដើម្បីឱ្យបរិយាកាសរស់នៅរបស់ពួកគេអាចទទួលបានការការពារច្រើនជាងនេះ ?

តើកុមារចង់ឱ្យឪពុកម្ដាយ ឬសហគមន៍របស់ខ្លួនធ្វើអ្វីបន្ថែមទៀត ឬប្រាប់ពួកគេយ៉ាងណាខ្លះ ដើម្បីឱ្យពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព ?

៤. តើកុមារយល់យ៉ាងណាចំពោះវិស័យទេសចរណ៍ ?

តើមានចំណុចល្អ ឬអាក្រក់អ្វីខ្លះចំពោះវិស័យទេសចរណ៍ ?

៥. តើកុមារយល់យ៉ាងណាចំពោះបុរស និងស្ត្រីដែលមកពីទីកន្លែង ឬមានវប្បធម៌ផ្សេងទៀត ?

៦. តើកុមារយល់ឃើញយ៉ា ងណាចំពោះកុមារភាព?

៧. តើអ្វីជាការរំលោភបំពានលើកុមារ ?

៨. តើកុមារបានដឹងអំពីអ្វីខ្លះអំពីទំនាក់ទំនងរវាងការរំលោភបំពានផ្លូវភេទកុមារ និងទេសចរណ៍ ?

# ២. គោលការណ៍ណែនាំអំពីការសម្ភាសសម្រាប់កុមារ

## ប្រវត្តិផ្ទាល់ខ្លួន

១. តើប្អូនមានអាយុប៉ុន្មាន? ______________________________

២. ភេទ: ប្រុស ☐ ស្រី ☐

៣. តើប្អូនស្ថិតនៅក្នុងក្រុមជនជាតិដើមភាគតិចណាមួយ? ______________________________

៤. តើប្អូនមានទីកន្លែងកំណើតនៅឯណា? ______________________________

៥. តើប្អូនធ្លាប់បានចូលរៀនដែរឬទេ? ធ្លាប់ ☐ មិនធ្លាប់ ☐

៦. តើប្អូនរៀនបានខ្ពស់បំផុតត្រឹមថ្នាក់ទីប៉ុន្មាន? ______________________________

៧. តើបច្ចុប្បន្នប្អូនកំពុងរស់នៅជាមួយឪពុកម្តាយមែនដែរឬទេ? មែន ☐ មិនមែន ☐

៨. ប្រសិនបើបច្ចុប្បន្នពុំបានរស់នៅជាមួយឪពុកម្តាយទេ តើប្អូនរស់នៅជាមួយនរណា?

______________________________

៩. តើឪពុកម្តាយរបស់ប្អូននៅរស់រានមានជីវិតដែរឬទេ? នៅរស់ ☐ ស្លាប់ ☐

១០. តើឪពុកម្តាយរបស់ប្អូនរស់នៅជាមួយគ្នាដែរឬទេ? នៅ ☐ ទេ ☐

១១. មានបញ្ហាសុខភាពផ្ទាល់ខ្លួន និងពិការភាពដែរឬទេ? ______________________________

១២. តើមានពិការភាពផ្នែកកាយសម្បទា និង/ឬស្មារតីដែរឬទេ?

______________________________

## បទពិសោធន៍ក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង(ICT)

| | ទូរស័ព្ទដៃ | | កំព្យូទ័រ | | អ៊ីនធើរណិត | |
|---|---|---|---|---|---|---|
| ១៣. ធ្លាប់ប្រើប្រាស់ | ធ្លាប់ | មិនធ្លាប់ | ធ្លាប់ | មិនធ្លាប់ | ធ្លាប់ | មិនធ្លាប់ |
| ១៤. ប្រើប្រាស់សប្តាហ៍មុន | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| ១៥. .ប្រើប្រាស់ញឹកញាប់ | | | | | | |

## ការស្វែងយល់អំពីការរំលោភបំពានលើកុមារ និងការការពារ

១៦. តើកុមារភាពជាអ្វី?

នៅពេលណាដែលកុមារម្នាក់ៗក្លាយជាមនុស្សពេញវ័យ?

តើអ្វីជាការអភិវឌ្ឍន៍កុមារ និងការការពារកុមារ?

១៧. តើកុមារទទួលបានការអប់រំអំពីបញ្ហាផ្លូវភេទដោយរបៀបណា?

តើភាគច្រើនបំផុត កុមារទំនងជានិយាយទៅកាន់អ្នកណាអំពីបញ្ហាផ្លូវភេទ និងចំណង់ផ្លូវភេទ?

តើឪពុកម្តាយ និងអ្នកថែទាំ ពិភាក្សាអំពីបញ្ហាផ្លូវភេទ និងចំណង់ផ្លូវភេទជាមួយកុមារដែរឬទេ?

១៨. តើប្អូនមានទស្សនៈយ៉ាងណាអំពីចំណង់ផ្លូវភេទរបស់កុមារា និងកុមារី?

តើនៅអាយុប៉ុន្មានដែលអាចរួមភេទអាចទទួលយកបាន?

តើប្អូនយល់យ៉ាងណាចំពោះការរួមភេទជាមួយភេទតែមួយ?

១៩. តើអ្វីជាការរំលោភបំពានលើកុមារ? តើមានភាពខុសគ្នាទេរវាងកុមារី និងកុមារា?

តើប្អូនមានបានដឹងអំពីកុមារណាម្នាក់ដែលត្រូវបានរំលោភបំពានដែរឬទេ?

២០. តើអ្វីជាការរំលោភបំពានផ្លូវភេទ?

## កត្តាគ្រោះថ្នាក់ និងភាពងាយរងគ្រោះ

២១. តើនរណាដែលងាយរងគ្រោះកាន់តែខ្លាំងដោយសារការរំលោភបំពានលើកុមារ?

តើប្រភេទកុមារមួយចំនួននៅក្នុងគ្រួសារ កាន់តែងាយរងគ្រោះដែរឬទេ?

២២. តើមានគ្រោះថ្នាក់ជាក់លាក់កើតឡើងដោយសារការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទងដែរឬទេ? ដូចជា (អ៊ីនធើរណិត ទូរស័ព្ទដៃ កំព្យូទ័រ)?

តើគ្រួសារបានដឹងអំពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង និងគ្រប់គ្រងលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទងរបស់កុមារបានកម្រិតណា?

២៣. តើអាកប្បកិរិយា និងសារការពារអ្វីដែលឪពុកម្ដាយរបស់ប្អូន បានប្រាស្រ័យទាក់ទងទៅកាន់ប្អូន?

២៤. តើប្អូនមានអារម្មណ៍បែបណាចំពោះបុរស និងស្ត្រីដែលមកពីទីកន្លែង និងមានវប្បធម៌ផ្សេង?

តើប្អូនមានអារម្មណ៍បែបណាចំពោះទេសចរណ៍?

២៥. តើគ្រួសារលើកទឹកចិត្ត ឬមិនលើកទឹកចិត្តឱ្យកុមារនិយាយទៅកាន់មនុស្សប្លែកមុខ?

តើនរណាជាជនប្លែកមុខ?

## ឧបសគ្គ និងឱកាសក្នុងការបង្ការការកេងប្រវ័ញ្ចផ្លូវភេទកុមារ

២៦. តើឪពុកម្ដាយរបស់ប្អូន ត្រូវធ្វើបែបណា ដើម្បីការពារប្អូន និងបងប្អូនរបស់ប្អូនពីគ្រោះថ្នាក់ដែលអាចកើតមាន?

២៧. តើកុមារដែលរងគ្រោះដោយសារការរំលោភបំពាន អំពើហិង្សា ឬការកេងប្រវ័ញ្ច ដឹងថាត្រូវទាក់ទងទៅនរណាដើម្បីឱ្យជួយដែរឬទេ?

តើប្អូនគិតថា ពួកគេនឹងទៅរកអ្នកណា?

តើពួកគេមានសុវត្ថិភាព និងមានទំនុកចិត្តក្នុងការធ្វើដូច្នោះទេ?

២៨. តើប្អូនគិតថា ប្អូនអាចធ្វើឱ្យបរិយាកាសរស់នៅរបស់ប្អូនអាចទទួលបានការការពារច្រើនជាងមុនបានដែរឬទេ?

២៩. ធនធាន យន្តការ និងប្រកសំខាន់ៗនៃព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង (IEC) សម្រាប់កុមារ គ្រួសារ និងសហគមន៍។

៣០. តើជាធម្មតា ប្រជាជនធ្វើយ៉ាងណា នៅពេលដែលកុមារម្នាក់ត្រូវបានរំលោភបំពាន ឬកេងប្រវ័ញ្ចនៅក្នុងសហគមន៍នេះ?

៣១. តើជាធម្មតា ប្រជាជនធ្វើយ៉ាងណា នៅពេលដែលកុមារម្នាក់ត្រូវបានរំលោភបំពាន ឬកេងប្រវ័ញ្ចនៅក្នុងសហគមន៍នេះ?

# ៣. គោលការណ៍ណែនាំអំពីការសម្ភាសសម្រាប់ឪពុកម្តាយ ឬអាណាព្យាបាល ?

## ប្រវត្តិផ្ទាល់ខ្លួន

១. តើប្អូនមានអាយុប៉ុន្មាន ? ______________________

២. ភេទ:     ប្រុស ☐     ស្រី ☐

៣. តើប្អូនស្ថិតនៅក្នុងក្រុមជនជាតិដើមភាគតិចណាមួយ ? ______________________

៤. តើប្អូនមានទីកន្លែងកំណើតនៅឯណា ? ______________________

៥. អ្នកធ្លាប់បានចូលរៀនដែរឬទេ ?     ធ្លាប់ ☐     មិនធ្លាប់ ☐

៦. តើអ្នករៀនបានខ្ពស់បំផុតត្រឹមថ្នាក់ទីប៉ុន្មាន ? ______________________

៧. តើអ្នកមានគ្រួសារហើយឬនៅ ?
បច្ចុប្បន្នមានគ្រួសារ ☐     លែងលះ ☐     មេម៉ាយ/ពោះម៉ាយ ☐     រស់នៅបែកគ្នា ☐

៨. ប្រសិនបើអ្នកមានគ្រួសារ តើអ្នករស់នៅជាមួយប្តីប្រពន្ធរបស់អ្នកដែរឬទេ ?
បាទ/ចាស ☐     ទេ ☐

៩. តើអ្នកមានកូនចំនួនប៉ុន្មាន ? ចំនួនកូន______________________

១០. តើកូនរបស់អ្នករស់នៅជាមួយអ្នកដែរឬទេ ?     បាទ/ចាស ☐     ទេ ☐

១១. តើអ្នកមានមុខរបរអ្វីដែរ ? ______________________

## ការស្វែងយល់អំពីការរំលោភបំពានលើកុមារ និងការការពារ

១២. តើកុមារភាពជាអ្វី ? តើនៅពេលណាដែលកុមារម្នាក់ៗក្លាយជាមនុស្សពេញវ័យ ?

តើអ្វីជាការអភិវឌ្ឍន៍កុមារ និងការការពារកុមារ ?

១២. តើអ្នកមានពិភាក្សាអំពីបញ្ហាផ្លូវភេទ និងចំណង់ផ្លូវភេទជាមួយកូនរបស់អ្នកដែរឬទេ ?

១៤. តើអ្នកមានទស្សនៈយ៉ាងណាចំពោះចំណង់ផ្លូវភេទរបស់កុមារា និងកុមារី ?

តើអ្នកយល់យ៉ាងណាចំពោះការរួមភេទជាមួយភេទតែមួយ ?

១៥. តើនៅអាយុប៉ុន្មានដែលការរួមភេទអាចទទួលយកបាន ?

១៦. តើអ្វីជាការរំលោភបំពានលើកុមារ ? តើមានភាពខុសគ្នាទេរវាងកុមារី និងកុមារា ?

១៧. តើអ្វីជាការរំលោភបំពានផ្លូវភេទ ?

តើពាក្យពេចន៍ និងភាសាអ្វីដែលត្រូវយកមកប្រើប្រាស់ ដើម្បីរៀបរាប់ពីទិដ្ឋភាពនៃបញ្ហាផ្លូវភេទ និងការរំលោភបំពាន ?

១៨. តើអ្វីជាការខាតបង់ និងផលវិបាកនៃការរំលោភបំពានផ្លូវភេទ ?

១៩. តើមិត្តភក្តិ គ្រួសារ និងសហគមន៍ ប្រព្រឹត្តចំពោះកុមារដែលរងការរំលោភបំពាន ឬការធ្វើបាប ឧទា. ជនរងគ្រោះពីការចាប់រំលោភ យ៉ាងដូចម្តេច ?

## កត្តាគ្រោះថ្នាក់ និងភាពងាយរងគ្រោះ

២០. តើអ្វីជាមូលហេតុដែលនាំឱ្យមានបញ្ហាការពារកុមារ ?

២១. តើប្រភេទកុមារមួយចំនួននៅក្នុងគ្រួសារ ងាយរងគ្រោះកាន់តែខ្លាំងដែរឬទេ ហើយដោយសារបញ្ហានេះ ធ្វើឱ្យពួកគេត្រូវទទួលរងនូវការរំលោភបំពាន ការមិនអើពើ ឬការកេងប្រវ័ញ្ច ( ដូចជា កុមារី កុមារពិការ កុមារចំណាកស្រុក។ល។ ) កាន់តែខ្លាំងជាងមុនដែរឬទេ ?

២២. តើកូនរបស់អ្នកបានប្រើប្រាស់ ឬមានលទ្ធភាពទទួលបានបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទងដែរឬទេ ?

តើអាចមានគ្រោះថ្នាក់ជាក់លាក់ណាមួយកើតឡើងដែរឬទេ ? តើអ្នកដឹងពី និងអាចគ្រប់គ្រងលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទងបានកម្រិតណា ?

២៣. តើអាប្បកិរិយា និងសារការពារអ្វីដែលអ្នកប្រាស្រ័យទាក់ទងទៅកាន់កូនរបស់អ្នក ?

២៤. តើគ្រួសារលើកទឹកចិត្ត ឬមិនលើកទឹកចិត្តឱ្យនិយាយទៅកាន់ជនប្លែកមុខ ?

តើនរណាជាជនប្លែកមុខ ?

២៥. តើអ្នកគិតថា កូនរបស់អ្នកនឹងយល់យ៉ាងណាចំពោះបុរស និងស្ត្រីដែលមកពីទីកន្លែង និងមានវប្បធម៌ផ្សេងទៀត ?

២៦. តើអ្នកយល់យ៉ាងណាចំពោះទេសចរណ៍ ?

តើទេសចរណ៍ផ្តល់ផលប៉ះពាល់ដល់ជីវិត និងសហគមន៍របស់អ្នកយ៉ាងដូចម្តេច ?

តើសក្តានុពលនៃទេសចរណ៍មានអ្វីខ្លះ ? តើគ្រោះថ្នាក់មានអ្វីខ្លះ ?

ការយល់ឃើញចំពោះជនបរទេស ទេសចរណ៍ និងឧស្សាហកម្មទេសចរណ៍ កម្រិតនៃការចង់ធ្វើការក្នុងវិស័យទេសចរណ៍/បទពិសោធន៍ធ្វើការនៅក្នុងវិស័យទេសចរណ៍ ចំណេះដឹងអំពីទំនាក់ទំនងរវាងការរំលោភបំពានផ្លូវភេទកុមារ និងវិស័យទេសចរណ៍ ?

## ឧបសគ្គ និងឱកាសក្នុងការបង្ការការកេងប្រវ័ញ្ចផ្លូវភេទកុមារ

២៧. តើអ្នកគិតថា ការអនុវត្តការចិញ្ចឹមបីបាច់ថែរក្សាបែបវិជ្ជមាន/បែបការពារបំផុត នៅក្នុងសហគមន៍របស់អ្នកមានអ្វីខ្លះ ?

២៨. តើអ្នកដឹងទេថា កុមារដែលរងគ្រោះដោយសារការរំលោភបំពាន អំពើហិង្សា ឬការកេងប្រវ័ញ្ច ដឹងថាត្រូវទាក់ទងនរណាដើម្បីឱ្យជួយទេ ហើយតើពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព និងមានទំនុកចិត្តក្នុងការធ្វើដូចនោះទេ ?

២៩. តើសម្លេងរបស់កុមារលើបញ្ហាការពារកុមារនៅក្នុងគ្រួសារ និងសហគមន៍ ត្រូវបានគេយកមកគិតគូរពិចារណាដែរឬទេ ?

៣០. តើកុមារអាចធ្វើឱ្យបរិយាកាសរបស់ពួកគេមានការការពារច្រើនជាងមុន បានយ៉ាងដូចម្តេច ?

៣១. ធនធាន យន្តការ និងប្រកសំខាន់ៗនៃព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង ( IEC ) សម្រាប់កុមារ គ្រួសារ និងសហគមន៍។

៣២. តើមានអ្វីខ្លះដែលអាចធ្វើបាន ដើម្បីបង្ការការរំលោភបំពាន ការកេងប្រវ័ញ្ច និង/ឬការមិនអើពើចំពោះកុមារនៅក្នុងសហគមន៍ ?

៣៣. តើជាធម្មតា ប្រជាជនធ្វើយ៉ាងណា នៅពេលដែលកុមារម្នាក់ត្រូវបានរំលោភបំពាន ឬកេងប្រវ័ញ្ចនៅក្នុងសហគមន៍នេះ ?

៣៤. តើសេវាអ្វី ( ផ្លូវការ និងមិនផ្លូវការ ) ដែលមាននៅក្នុងសហគមន៍ ដើម្បីការពារ និងផ្តល់ការគាំទ្រដល់កុមារដែលប្រឈម ឬធ្លាប់រងការរំលោភបំពាន ការមិនអើពើ ឬការកេងប្រវ័ញ្ច ?

៣៥. តើកុមារ និងក្រុមគ្រួសាររបស់កុមារដែលរងគ្រោះ ឬរងផលប៉ះពាល់ដោយសារការរំលោភបំពាន អំពើហិង្សា និង/ឬការកេងប្រវ័ញ្ច មានលទ្ធភាពទទួលបានសេវាទាំងនេះដែរឬទេ ?

៣៦. តើអ្វីជាទំនាក់ទំនង ( និងគម្លាត ) រវាងផ្នែក/អ្នកចូលរួមក្នុងប្រព័ន្ធផ្លូវការ និងមិនផ្លូវការ ?

តើសមាជិកសហគមន៍មានទស្សនៈបែបណាចំពោះយន្តការការពារកុមារជាផ្លូវការ ?

៣៧. តើឪពុកម្តាយយល់ឃើញយ៉ាងណាចំពោះតួនាទីរបស់គ្រូបង្រៀន និងមានកាតព្វកិច្ចរបស់សហគមមន៍ក្នុងការការពារកូនៗរបស់ពួកគេ ?

៣៨. តើអ្វីដែលអាចធ្វើទៅបានដើម្បីលើកកម្ពស់ការបង្ការ និងការពារប្រឆាំងនឹងអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចនៅក្នុងសហគមន៍ ?

## ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងទិដ្ឋភាពនៃការកេងប្រវ័ញ្ចកុមារ

៣៩. តើមានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុណាមួយទេពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចកុមារ ?

៤០. តើអ្វីដែលអាចធ្វើទៅបាន និងត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីបង្ការការកេងប្រវ័ញ្ចកុមារ ?

# ៤. គោលការណ៍ណែនាំអំពីការសម្ភាសសម្រាប់អ្នកមានកាតព្វកិច្ច

## ប្រវត្តិផ្ទាល់ខ្លួន

១. តើអ្នកមានអាយុប៉ុន្មាន? ______________________________

២. ភេទៈ ប្រុស ☐ ស្រី ☐

៣. សម្ព័ន្ធអង្គការ? ______________________________

៤. មុខតំណែង និង/ឬការទទួលខុសត្រូវ? ______________________________

## ការស្វែងយល់អំពីការរំលោភបំពានលើកុមារ និងការការពារ

៥. តើអ្វីជាឥរិយាបថ និងជំនឿជាទូទៅអំពីកុមារ ការអភិវឌ្ឍន៍កុមារ និងការការពារកុមារ នៅក្នុងសហគមន៍?

តើអ្វីជាកុមារភាព និងនៅពេលណាដែលកុមារម្នាក់ៗក្លាយជាមនុស្សពេញវ័យ?

៦. តើអ្វីជាការរំលោភបំពានលើកុមារ? តើមានភាពខុសគ្នាទេរវាងកុមារី និងកុមារា?

៧. តើនៅអាយុប៉ុន្មានដែលការរួមភេទអាចទទួលយកបាន?

៨. តើអ្នកមានទស្សនៈយ៉ាងណាចំពោះចំណង់ផ្លូវភេទរបស់កុមារា និងកុមារី?

ចំណេះដឹង និងឥរិយាបថចំពោះការរួមភេទជាមួយភេទតែមួយ?

៩. តើអ្វីជាការរំលោភបំពានផ្លូវភេទ?

១០. តើអ្វីជារោគសញ្ញា និងសញ្ញាអំពីការរំលោភបំពានលើកុមារ ហើយតើអ្នកអាចដឹងពីរោគសញ្ញា និងសញ្ញានោះបានដោយរបៀបណា?

១១. តើមិត្តភក្តិ គ្រួសារ និងសហគមន៍ ប្រព្រឹត្តចំពោះកុមារដែលរងការរំលោភបំពាន ឬការធ្វើបាប ឧទា. ជនរងគ្រោះពីការចាប់រំលោភ យ៉ាងដូចម្តេច?

១២. កត្តាគ្រោះថ្នាក់ និងភាពងាយរងគ្រោះ?

១៣. តើអ្វីជាមូលហេតុដែលនាំឱ្យមានបញ្ហាការពារកុមារ?

១៤. តើប្រភេទកុមារមួយចំនួននៅក្នុងគ្រួសារ ងាយរងគ្រោះកាន់តែខ្លាំងដែរឬទេ ហើយដោយសារបញ្ហានេះធ្វើឱ្យពួកគេត្រូវទទួលរងនូវការរំលោភបំពាន ការមិនអើពើ ឬការកេងប្រវ័ញ្ច (ដូចជា កុមារី កុមារពិការ កុមារចំណាកស្រុក។ល។) កាន់តែខ្លាំងជាងមុនដែរឬទេ?

១៥. តើកុមារប្រើប្រាស់អ៊ីនធើរណេត និងបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទងយ៉ាងដូចម្តេច? តើមានគ្រោះថ្នាក់ជាក់លាក់ណាមួយដែលពាក់ព័ន្ធដែរឬទេ?

## ឧបសគ្គ និងឱកាសក្នុងការបង្ការការកេងប្រវ័ញ្ចផ្លូវភេទកុមារ

១៦. តើមានការប្រព្រឹត្តបែបប្រពៃណីប្រកបដោយគ្រោះថ្នាក់ដែរឬទេនៅក្នុងសហគមន៍នេះ? តើអ្វីជាការសាយភាយពីការប្រព្រឹត្តនោះ?

១៧. តើរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើរតួនាទីវិជ្ជមាន អវិជ្ជមាន ឬ អព្យាក្រឹត្យក្នុងការបង្ការការរំលោភបំពាន ការមិនអើពើ និងការកេងប្រវ័ញ្ច?

សូមពន្យល់អំពីតួនាទីរបស់អ្នកទាំងនោះ ហើយតើពួកអនុវត្តរបស់ខ្លួនដោយរបៀបណា?

១៨. តើកុមារដែលរងគ្រោះដោយសារការរំលោភបំពាន អំពើហិង្សា ឬការកេងប្រវ័ញ្ច ដឹងថាត្រូវទាក់ទងនរណាដើម្បីឱ្យជួយទេ ហើយតើពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព និងមានទំនុកចិត្តក្នុងការធ្វើដូចនោះទេ?

ប្រសិនបើដូច្នោះមែន សូមផ្តល់ជាឧទាហរណ៍?

១៩. តើសម្លេងរបស់កុមារលើបញ្ហាការពារកុមារនៅក្នុងគ្រួសារ និងសហគមន៍ ត្រូវបានគេយកមកគិតគូរពិចារណាដែរឬទេ?

## ធនធាន យន្តការ និងច្រកសំខាន់ៗនៃព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង (IEC) សម្រាប់កុមារ គ្រួសារ និងសហគមន៍

២០. តើមានអ្វីខ្លះដែលអាចធ្វើបាន ដើម្បីបង្ការការរំលោភបំពាន ការកេងប្រវ័ញ្ច និង/ឬការមិនអើពើចំពោះកុមារនៅក្នុងសហគមន៍?

២១. តើសេវាអ្វី (ផ្លូវការ និងមិនផ្លូវការ) ដែលមាននៅក្នុងសហគមន៍ ដើម្បីការពារ និងផ្តល់ការគាំទ្រដល់កុមារដែលប្រឈម ឬធ្លាប់រងការរំលោភបំពាន ការមិនអើពើ ឬការកេងប្រវ័ញ្ច?

២២. តើជាធម្មតា ប្រជាជនធ្វើយ៉ាងណា នៅពេលដែលកុមារម្នាក់ត្រូវបានរំលោភបំពាន ឬកេងប្រវ័ញ្ចនៅក្នុងសហគមន៍នេះ? តើអ្វីជាការឆ្លើយតបជាទូទៅចំពោះការការពារ និងការរំលោភបំពានលើកុមារ?

២៣. តើកុមារ និងក្រុមគ្រួសាររបស់កុមារដែលរងគ្រោះ ឬរងផលប៉ះពាល់ដោយសារការរំលោភបំពាន អំពើហិង្សា និង/ឬការកេងប្រវ័ញ្ច មានលទ្ធភាពទទួលបានសេវាទាំងនេះដែរឬទេ?

តើវាមានភាពស្រួល ឬការលំបាកយ៉ាងណាខ្លះក្នុងការទទួលបានសេវាទាំងនោះ?

២៤. តើអ្វីជាទំនាក់ទំនង (និងគម្លាត) រវាងផ្នែក/អ្នកចូលរួមក្នុងប្រព័ន្ធផ្លូវការ និងមិនផ្លូវការ?

តើសមាជិកសហគមន៍មានទស្សនៈបែបណាចំពោះយន្តការការពារកុមារជាផ្លូវការ?

២៥. តើសមាជិកសហគមន៍ពេញចិត្តនឹងការឆ្លើយតបជាទូទៅចំពោះបញ្ហាការពារកុមារ និងសេវាការពារកុមារបច្ចុប្បន្នកម្រិតណា?

២៦. តើអ្នកគិតថា ឪពុកម្តាយ និងអ្នកផ្តល់ការថែទាំចម្បង មានសមត្ថភាពក្នុងការបង្ការករណីនានាមិនឱ្យកើតមានដែរឬទេ?

ប្រសិនបើពុំមានសមត្ថភាពទេ តើមូលហេតុអ្វី?

២៧. តើអ្វីដែលអាចធ្វើទៅបានដើម្បីលើកកម្ពស់ការបង្ការ និងការពារប្រឆាំងនឹងអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចនៅក្នុងសហគមន៍?

## ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងទិដ្ឋភាពនៃការកេងប្រវ័ញ្ចកុមារ

២៨. តើមានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុណាមួយទេពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចកុមារ?

២៩. តើអ្វីដែលអាចធ្វើទៅបាន និងត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីបង្ការការកេងប្រវ័ញ្ចកុមារ?

# ៥. គោលការណ៍ណែនាំអំពីការសម្ភាសសម្រាប់ អ្នករកស៊ីផ្លូវភេទ

## ប្រវត្តិផ្ទាល់ខ្លួន

១. តើអ្នកមានអាយុប៉ុន្មាន? ____________________

២. ភេទ: ប្រុស ☐ ស្រី ☐

៣. តើអ្នកស្ថិតនៅក្នុងក្រុមជនជាតិដើមភាគតិចណាមួយ? ____________________

៤. តើអ្នកមានទីកន្លែងកំណើតនៅឯណា? ____________________

៥. តើអ្នកធ្លាប់បានចូលរៀនដែរឬទេ? ធ្លាប់ ☐ មិនធ្លាប់ ☐

៦. តើអ្នករៀនបានខ្ពស់បំផុតត្រឹមថ្នាក់ទីប៉ុន្មាន? ____________________

## ការងារបច្ចុប្បន្ន

៧. ទីកន្លែងការងារ ឬគ្រឹះស្ថានបច្ចុប្បន្ន លក្ខខណ្ឌការងារ និងលក្ខណៈនៃការងារបច្ចុប្បន្នរបស់អ្នក?

៨. តើនរណាជាភ្ញៀវចម្បងរបស់អ្នក? (ក្នុងស្រុក ឬបរទេស ភេទភ្ញៀវ)។

៩. ប្រវត្តិការងារផ្លូវភេទ ?

១០. តើអ្នកចាប់ផ្តើមការងាររកស៊ីផ្លូវភេទនៅពេលណា និងដោយរបៀបណា ?

១១. តើការរួមភេទលើកដំបូងរបស់អ្នកកើតឡើងដោយសារការបង្ខំ ឬដោយការយល់ព្រម ?

១២. តើមានការបម្លាស់ទី ឬផ្លាស់ប្តូរទីកន្លែងការងារ ឬទីតាំងដែរឬទេចាប់តាំងពីចាប់ផ្តើមការងារផ្លូវភេទមក ?

១៣. តើមានចំណេះដឹង និងការប្រើប្រាស់សេវាដែលអាចរកបានដែរឬទេ ?

១៤. តើបានលឺអំពីសេវាសុខភាព និងសេវាសង្គមប្រភេទណា ?

តើអ្នកធ្លាប់បានប្រើប្រាស់សេវាទាំងនោះដែរឬទេ ?

ប្រសិនបើធ្លាប់ប្រើ តើប្រើសេវាណាមួយ ?

ហេតុអ្វីបានជាអ្នកមិនប្រើសេវាទាំងនោះ ?

១៥. តើអ្នកធ្លាប់ប្រើប្រព័ន្ធទូរស័ព្ទបន្ទាន់ ឬសេវាផ្តល់ជំនួយដែរឬទេ ?

## បណ្តាញសង្គម

១៦. តើនរណាដែលអ្នកតែងតែសុំជំនួយ ឬសុំយោបល់ ? ហេតុអ្វី ?

១៧. តើអ្នករក្សាទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភក្តិរបស់អ្នកដោយរបៀបណា ?

១៨. តើអ្នកមានសេរីភាពកម្រិតណា ក្នុងការចេញក្រៅទីកន្លែងការងារ ?

១៩. ការយល់ឃើញអំពីកុមារភាព និងការការពារកុមារ ?

២០. តើអ្វីជាកុមារភាព អ្វីជាការរំលោភបំពានលើកុមារ ?

តើមានអ្វីខ្លះដែលអាចធ្វើបាន ដើម្បីបង្ការការរំលោភបំពាន ការកេងប្រវ័ញ្ច និង/ឬការមិនអើពើចំពោះកុមារនៅក្នុងសហគមន៍ ?

តើប្រជាជនពេញចិត្តនឹងសកម្មភាពនោះដែរឬទេ ?

ហេតុអ្វីបានជាពេញចិត្ត ឬហេតុអ្វីបានជាមិនពេញចិត្ត ?

២១. បទពិសោធន៍ផ្ទាល់ខ្លួនចំពោះការរំលោភបំពានលើកុមារ ?

២២. តាមបទពិសោធន៍ផ្ទាល់របស់អ្នក តើអ្នកធ្លាប់រងការរំលោភបំពានផ្លូវភេទដែរឬទេ ?

ប្រសិនបើធ្លាប់ តើវាកើតឡើងនៅពេលណា ហើយតើនរណាជាអ្នករំលោភបំពានលើអ្នក ?

២៣. តើអ្នកធ្វើអ្វីនៅពេលដែលអ្នករងការរំលោភបំពាន ?

២៤. តើអ្នកបានសុំជំនួយ ឬសេវាពីនរណាម្នាក់ ឬពីអង្គការណាមួយដែរឬទេ ?

ប្រសិនបើអ្នកសុំ តើអ្នកសុំពីនរណា ?

តើអ្នកបានដឹងពីនរណា ?

តើអ្នកពេញចិត្តកម្រិតណា នៅពេលអ្នកទទួលបានសេវានោះ ?

តើអ្នកនឹងណែនាំមិត្តភក្តិរបស់អ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ឱ្យប្រើសេវានោះដែរឬទេ ?

ប្រសិនបើមិនណែនាំ តើមូលហេតុអ្វី ?

២៥. តើអ្នកធ្លាប់បានឃើញ ឬបានលឺថាកុមារធ្លាប់រងការរំលោភបំពានផ្លូវភេទពីសំណាក់ជនបរទេសដែរឬទេ ?
ប្រសិនបើធ្លាប់ តើពួកគេនោះជានរណា ?

២៦. តើអ្នកគិតថា កុមារងាយរងគ្រោះដោយសារការរំលោភបំពានពីសំណាក់ជនបរទេសដែរឬទេ ?
ប្រសិនបើអ្នកគិតបែបនោះ តើនរណាដែលងាយរងគ្រោះបំផុតពីការរំលោភបំពានលើកុមារ ?

២៧. តាមទស្សនៈរបស់អ្នក តើអ្វីដែលអាចធ្វើបាននៅកម្រិតបុគ្គល គ្រួសារ និងសហគមន៍ ដើម្បីបង្ការការរំលោភបំពានលើកុមារ ?

# ឧបសម្ព័ន្ធ ២៖ ការបែងចែកតាមអ្នកចូលរួម

## ប្រទេសកម្ពុជា

| ក្រុមគោលដៅ | ការសម្ភាស | អ្នកផ្ដល់បទសម្ភាស | | |
|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី |
| ខេត្តសៀមរាប | | | | |
| កុមារដែលចូលរៀន | 2 IIs<br>7 FGIs | 2<br>64 | 2<br>28 | 0<br>36 |
| កុមារដែលធ្វើការកុមារ/តាមផ្លូវ | 3 FGIs | 24 | 10 | 14 |
| គ្រូបង្រៀន | 3 IIs | 3 | 3 | 0 |
| តំណាងអាជ្ញាធរមូលដ្ឋាន | 5 IIs | 5 | 2 | 3 |
| ឪពុកម្ដាយ | 2 IIs | 2 | 0 | 2 |
| អ្នកលក់ដូរតាមផ្លូវ (មានមនុស្សពេញវ័យ) | 1 II | 1 | 0 | 1 |
| បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | 3 IIs<br>2 FGIs | 3<br>8 | 1<br>4 | 2<br>4 |
| ខេត្តមណ្ឌលគិរី | | | | |
| កុមារដែលចូលរៀន | 1 II<br>4 FGIs | 1<br>32 | 1<br>15 | 0<br>17 |
| កុមាររស់នៅក្នុងទីជម្រក | 1 FGI | 9 | 0 | 9 |
| គ្រូបង្រៀន | 3 IIs | 3 | 3 | 0 |
| តំណាងអាជ្ញាធរមូលដ្ឋាន | 4 IIs | 4 | 2 | 2 |
| ឪពុកម្ដាយ | 2 IIs | 2 | 1 | 1 |
| អ្នកលក់ដូរតាមផ្លូវ (មានមនុស្សពេញវ័យ) | 3 IIs | 3 | 1 | 2 |
| បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | 3 IIs | 3 | 3 | 0 |
| **សរុប**<br>អ្នកផ្ដល់បទសម្ភាស ១៦៩ នាក់ | **FGIs: 17**<br>**IIs: 32** | កុមារ ១៣២ នាក់ (ប្រុស ៥៦ ស្រី ៧៦)<br>មនុស្សពេញវ័យ ៣៧ នាក់ (ប្រុស ២០ ស្រី ១៧) | | |

# ប្រទេសថៃ

| ក្រុមគោលដៅ | ការសម្ភាស | អ្នកផ្តល់បទសម្ភាស | | |
|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី |
| ផាតាយ៉ា | | | | |
| កុមារក្នុងអាយុចូលរៀន ១១-១៧ ឆ្នាំ | 5 FGIs* | 41 | 11 | 30 |
| កុមារដែលធ្វើការកុមារ/តាមផ្លូវអាយុ ១៧ ឆ្នាំ | 3 IIs* | 3 | 3 | 0 |
| កុមាររស់នៅក្នុងទីជម្រកអាយុ ១៤ ឆ្នាំ | 2 IIs | 2 | 0 | 2 |
| គ្រូបង្រៀន និង អាជ្ញាធរមូលដ្ឋាន | 6 IIs | 6 | 2 | 4 |
| ឪពុកម្តាយ | 2 IIs<br>1 FGIs | 2<br>3 | 2<br>1 | 0<br>2 |
| សមាជិកសហគមន៍ | 2 IIs<br>1 FGIs | 2<br>3 | 1<br>0 | 1<br>3 |
| បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | 6 IIs | 6 | 1 | 5 |
| ឈៀងម៉ៃ | | | | |
| កុមារក្នុងអាយុចូលរៀន ១១-១៧ ឆ្នាំ | 3 FGIs | 27 | 5 | 22 |
| កុមារដែលធ្វើការកុមារ/តាមផ្លូវអាយុ ១០-១៤ ឆ្នាំ | 3 IIs | 3 | 0 | 3 |
| គ្រូបង្រៀន និង អាជ្ញាធរមូលដ្ឋាន | 11 IIs | 11 | 2 | 9 |
| ឪពុកម្តាយ | 1 IIs | 1 | 0 | 1 |
| សមាជិកសហគមន៍ | 7 IIs | 7 | 4 | 3 |
| **សរុប**<br>អ្នកផ្តល់បទសម្ភាស ១១៧ នាក់ | **FGIs: 10**<br>**IIs: 43** | កុមារ ៧៦ នាក់ (ប្រុស ១៩ ស្រី ៥៧) មនុស្សពេញវ័យ ៤១ នាក់ (ប្រុស ១៣ ស្រី ២៨) | | |

# ប្រទេសឡាវ

| ក្រុមគោលដៅ | ការសម្ភាស | អ្នកផ្តល់បទសម្ភាស | | |
|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី |
| ទីក្រុងវៀងចន្ទ័ | | | | |
| កុមារដែលចូលរៀន | 9 IIs | 9 | 5 | 4 |
| កុមាររៀននៅបឋមសិក្សា | 10 IIs | 10 | 5 | 5 |
| កុមារដែលចូលរៀន (អាយុមិនបានកំណត់) | 1 FGIs | 10 | 5 | 5 |
| យុវវ័យ (អាយុពី ១៥ឆ្នាំ ដល់ ២០ឆ្នាំ) | 1 FGIs | 9 | 5 | 4 |
| កុមារឈប់ចូលរៀន (កម្មករធ្វើការនៅរោងចក្រ ភោជនីយដ្ឋាន កុមារតាមដងផ្លូវ) | 8 IIs | 8 | 2 | 6 |
| ឪពុកម្តាយ ឬអណាព្យាបាល | 15 IIs | 15 | 5 | 10 |
| អ្នកមានភាតព្វកិច្ច | 12 IIs | 12 | 7 | 5 |
| អ្នករកស៊ីផ្លូវភេទ | 3 IIs | 3 | 0 | 3 |
| ទីក្រុង Luang Prabang | | | | |
| កុមាររៀននៅបឋមសិក្សា | 3 IIs | 3 | 1 | 2 |
| កុមាររៀននៅមធ្យមសិក្សា | 1 II | 1 | 0 | 1 |
| កុមារដែលចូលរៀន (អាយុមិនបានកំណត់) | 1 FGIs | 12 | 6 | 6 |
| យុវវ័យ (អាយុពី ១៥ឆ្នាំ ដល់ ២០ឆ្នាំ) | 0 IIs/0 FGI | 0 | 0 | 0 |
| កុមារឈប់ចូលរៀន (កម្មករធ្វើការនៅរោងចក្រ ភោជនីយដ្ឋាន កុមារតាមដងផ្លូវ) | 5 IIs | 5 | 3 | 2 |
| ឪពុកម្តាយ ឬអណាព្យាបាល | 5 IIs | 5 | 3 | 2 |
| អ្នកមានភាតព្វកិច្ច | 4 IIs | 4 | 3 | 1 |
| អ្នករកស៊ីផ្លូវភេទ | 3 IIs | 3 | 0 | 3 |
| **សរុប**<br>អ្នកផ្តល់បទសម្ភាស ១០៩ នាក់ | **FGIs: 3**<br>**IIs: 78** | កុមារ ៦៧ នាក់ (ប្រុស ៣២ ស្រី ៣៥)<br>មនុស្សពេញវ័យ ៤២ នាក់ (ប្រុស ១៨ ស្រី ២៤) | | |

# ប្រទេសវៀតណាម

| ក្រុមគោលដៅ | ការសម្ភាស | អ្នកផ្តល់បទសម្ភាស | | |
|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី |
| កុមាររៀននៅសាលារដ្ឋ អាយុ ១២-១៧ ឆ្នាំ | 8 FGIs | 92 | 33 | 59 |
| កុមាររៀននៅសាលាឯកជន អាយុ ១២-១៧ ឆ្នាំ | 1 FGIs | 9 | 6 | 3 |
| កុមារនៅសាលាជំនាញអាយុ ១២-១៦ ឆ្នាំ | 1 FGIs | 7 | 0 | 7 |
| កុមារកំព្រា និងកមារដែលគេបោះបង់អាយុ ៩-១៦ ឆ្នាំ | 1 FGIs | 8 | 8 | 0 |
| កុមារដែលធ្វើការអាយុ ៩-១៨ ឆ្នាំ | 3 FGIs | 27 | 15 | 12 |
| កុមារដែលជាអ្នកលក់ដូរតាមរដូវកាលអាយុ ៨-១២ ឆ្នាំ | 1 FGIs | 3 | 0 | 3 |
| កុមារពិការអាយុ  ១០-១៦ ឆ្នាំ | 1 FGIs | 9 | មិនបានកំនត់ | មិនបានកំនត់ |
| កុមារដែលរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទអាយុ ១៧ ឆ្នាំ | 1 II | 1 | 0 | 1 |
| អ្នកមើលថែ និងអ្នកជិតខាង | 39 IIs | 39 | មិនបានកំនត់ | មិនបានកំនត់ |
| អ្នកមានកាតាព្វកិច្ច | 24 IIs | 24 | 12 | 12 |
| មន្ត្រី | 29 IIs | 29 | 19 | 10 |
| ម្ចាស់សណ្ឋាគារ | 2 IIs | 2 | 0 | 2 |
| បុរសស្វែងរកក្មេងស្រីដើម្បីរួមភេទ | 7 IIs | 7 | 7 | 0 |
| **សរុប**<br>អ្នកផ្តល់បទសម្ភាស ២៥៧ នាក់ | **FGIs: 16**<br>**IIs: 102** | កុមារ ១៥៦ នាក់<br>( ប្រុស ៦២ ស្រី ៨៥ )<br>មនុស្សពេញវ័យ ១០១<br>នាក់ ( ប្រុស ៣៨ ស្រី ២៤ ) | | |

# សង្ខេបតាមតំបន់

| អ្នកផ្តល់បទសម្ភាស | កុមារ * | កុមារី | កុមារា | មនុស្សពេញវ័យ** | ស្ត្រី | បុរស | FGIs | IIs |
|---|---|---|---|---|---|---|---|---|
| 652 | 431 | 253 | 178 | 221 | 93 | 128 | 46 | 255 |

* ភេទដែលមិនបានកំណត់ ៩នាក់
** ភេទដែលមិនបានកំណត់ ៣៩នាក់



ផ្លូវភេទ ការរំលោភបំពាន និង កុមារភាព បានបង្ហាញពីទិដ្ឋភាពមួយនៃការរកឃើញពីការ សិក្សា ស្រាវជ្រាវដាច់ដោយឡែកៗពីគ្នា ចំនួន៤ ដែលបានធ្វើឡើងនៅសហគមន៍ ដែលងាយរងគ្រោះ នៅក្នុងប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ថៃ និង វៀតណាម ស្តីពីចំណេះដឹង ឥរិយាបថ និង ការប្រព្រឹត្ត ពាក់ពន្ធ័នឹងការរំលោភបំពានផ្លូវភេទលើកុមារ រាប់បញ្ចូលទាំងការធ្វើដំណើរ និង ទេសចរណ៍។

ការស្រាវជ្រាវបានផ្តល់នូវចំណេះដឹងជាទូទៅ អំពីការយល់ដឹងនិងឥរិយាបថរបស់ សហគមន៍ជុំវិញបញ្ហាការរំលោភបំពានផ្លូវភេទលើកុមារ ។ ការសិក្សាស្រាវជ្រាវនេះគឺជា ការរួមចំណែកមួយដើម្បីជាភស្តុតាងដោយផ្អែកលើការ យល់ដឹងកាន់តែប្រសើរឡើងរបស់កុមារដែលងាយរងគ្រោះពីការរំលោភបំពានផ្លូវភេទ និងផ្តល់ជូននូវការ ពង្រឹងនៃការឆ្លើយតបជាច្រើនដែលមានគោលបំណងរក្សាសុវត្ថិកុមារពីគ្រោះថ្នាក់។

**សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍**
ធ្វើសកម្មភាពប្រឆាំងការរំលោភបំពាន

**www.childsafetourism.org**
childsafetourism@wvi.org






Australian Aid

World Vision